# សៀវភៅគោល

# ស្តីពី

# ការឆ្លើយតបនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ តាមប្រព័ន្ធអនឡាញ

## សម្រាប់មន្ត្រីនគរបាល

APLE

End Violence Against Children

unicef for every child

# អារម្ភកថា

បច្ចុប្បន្នការរីកចម្រើនប្រព័ន្ធបច្ចេកវិទ្យាឌីជីថល រួមមាន ការប្រើប្រាស់អ៊ីនធឺណិត និងឧបករណ៍ទំនាក់ទំនងតាមបណ្តាញសង្គម បានជំរុញឱ្យមានការរីកចម្រើននៃការងារនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងសង្គម នៅលើសកលលោក រួមទាំងប្រទេសកម្ពុជាផងដែរ។ ការប្រើប្រាស់អ៊ីនធឺណិត និងបច្ចេកវិទ្យាឌីជីថលក៏ជាបញ្ហាប្រឈម និងបង្កឱ្យមានការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ដែលជាទម្រង់ថ្មីមួយកំពុងកើតឡើង និងរីករាលដាលនៅជុំវិញពិភពលោក ក្នុងនោះប្រទេសកម្ពុជាក៏រងនូវផលប៉ះពាល់ចំពោះបទល្មើសនេះដែរ។

ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ( OCSEA) ដែលកើតឡើង នៅក្នុងទម្រង់ផ្សេងៗគ្នា ដូចជា ការផលិត ការកាន់កាប់ ការចែកចាយ ការផ្សព្វផ្សាយរូបភាព និងសម្ភាររំលោភបំពានផ្លូវភេទកុមារតាមមធ្យោបាយប្រើប្រាស់គេហទំព័រ កម្មវិធីទំនាក់ទំនងសង្គម និងកម្មវិធីហ្គេមសម្រាប់កុមារ ដើម្បីលួងលោមកុមារក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ វាគឺជាបទឧក្រិដ្ឋប្រឆាំងនឹងកុមារ និងជាកង្វល់របស់ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ។

ដើម្បីឆ្លើយតបទៅនឹងកង្វល់ ក៏ដូចជាបញ្ហាប្រឈមនានា អគ្គស្នងការដ្ឋាននគរបាលជាតិ បានសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ (APLE) បង្កើតសៀវភៅគោល ស្តីពីការឆ្លើយតបនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) ក្នុងគោលបំណងបង្កើនសមត្ថភាពយល់ដឹងដល់មន្ត្រីអនុវត្តច្បាប់ ក្នុងការប្រយុទ្ធប្រឆាំងបទល្មើសរំលោភបំពានផ្លូវភេទកុមារដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ។ សៀវភៅគោលនេះ មានមេរៀនជាក់លាក់ដែលអាចផ្តល់ចំណេះដឹង និងបទពិសោធន៍ថ្មីៗជាមូលដ្ឋានសម្រាប់យកទៅបណ្តុះបណ្តាល បង្កើនសមត្ថភាពលើនីតិវិធី បច្ចេកទេសស៊ើបអង្កេត ការស្រាវជ្រាវ និងការប្រមូលភស្តុតាង ស្របតាមការអភិវឌ្ឍន៍ផ្នែកយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជា។

សៀវភៅគោលនេះ បានរៀបចំ ចងក្រងឡើងសម្រាប់ធ្វើការបណ្តុះបណ្តាល ដែលមានវិធីសាស្ត្រងាយស្រួលដល់មន្ត្រីនគរបាលជំនាញក្នុងការដោះស្រាយឱ្យស្របតាមនីតិវិធី ការអនុវត្តបែបកុមារមេត្រី ផ្តល់ភាពងាយស្រួលដល់ការចូលរួមរបស់កុមារ និងគ្រួសារដែលរងផលប៉ះពាល់ពីការរំលោភបំពាន ដោយគិតពីសិទ្ធិ និងឧត្តមប្រយោជន៍កុមារនៅក្នុងបរិយាកាសឌីជីថល៕

ការអភិវឌ្ឍសៀវភៅគោលនេះ មានសារៈសំខាន់ណាស់សម្រាប់រៀបចំវគ្គបណ្តុះបណ្តាលដល់អង្គភាពជំនាញក្នុងការធានាគុណភាព និងប្រសិទ្ធភាព ដើម្បីឆ្លើយតបនឹងការអនុវត្តច្បាប់ និងការជួយសង្គ្រោះជនរងគ្រោះស្របទៅនឹងផែនការសកម្មភាព ដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ( ឆ្នាំ២០២១-២០២៥ ) និងអនុសាសន៍ នៃរបាយការណ៍សិក្សាស្រាវជ្រាវពីការបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា "Disrupting Harm' Cambodia" ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ឆ្នាំ២០២២ ដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

ក្នុងនាមអគ្គស្នងការដ្ឋាននគរបាលជាតិ ខ្ញុំមានកិត្តិយស និងមោទនភាព ដែលបានចូលរួមសម្របសម្រួលក្នុងការរៀបចំសៀវភៅគោលនេះ សម្រាប់ធ្វើការបណ្តុះបណ្តាល និងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ អង្គភាពជំនាញពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជំនាញប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ ក្នុងគោលបំណងទទួលបានចំណេះដឹង និងជំនាញបន្ថែម ដើម្បីឆ្លើយតបនឹងបទល្មើសកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ ជាពិសេស អង្គការសកម្មភាពដើម្បីកុមារ អង្គការយូនីសេហ្វ និងអ្នកពាក់ព័ន្ធទាំងឡាយដែលបានផ្តល់ការគាំទ្រក្នុងការរៀបចំសៀវភៅគោលនេះ។

ថ្ងៃ[illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០២៤

**អគ្គស្នងការនគរបាលជាតិ**

**នាយឧត្តមសេនីយ៍ សរ ថេត**

# សេចក្តីថ្លែងអំណរគុណ

ភាពជឿនលឿននៃបច្ចេកវិទ្យាព័ត៌មានដូចជាអ៊ីនធឺណិតនិងឧបករណ៍ទំនាក់ទំនងឌីជីថលបានជំរុញឱ្យមានការរីកចម្រើននៃការងារនយោបាយសេដ្ឋកិច្ចនិងសង្គមដែលបាននាំប្រទេសកម្ពុជាកាន់តែខិតជិតទៅនឹងប្រទេសក្នុងតំបន់និងពិភពលោក។ការប្រើប្រាស់អ៊ីនធឺណិតនិងបច្ចេកវិទ្យាឌីជីថលបានផ្តល់ឱកាសឱ្យជនល្មើសមានការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA) ដែលជាទម្រង់នៃបទល្មើសថ្មីមួយកំពុងរីករាលដាលនៅជុំវិញពិភពលោក រួមទាំងនៅក្នុងប្រទេសកម្ពុជាផងដែរ។

ផ្អែកលើបរិបទនេះ តម្រូវការនៃការបណ្តុះបណ្តាលគឺជាការងារដ៏ចាំបាច់មួយដែលទទួលបានការគាំទ្រពីស្ថាប័ននគរបាលជាតិកម្ពុជាទាក់ទងនឹងការស៊ើបអង្កេតនិងការស្រាវជ្រាវប្រមូលព័ត៌មានលើប្រធានបទ (OCSEA) ដែលបានបង្ហាញនៅក្នុងរបាយការណ៍បោះពុម្ពផ្សាយក្នុងខែកញ្ញាឆ្នាំ២០២២ ស្តីពីការបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា (Disrupting Harm Cambodia)។ អង្គការសកម្មភាពដើម្បីកុមារ (APLE) បានសហការយ៉ាងជិតស្និទ្ធជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិជាពិសេសតាមរយៈនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនបានធ្វើការប៉ាន់ប្រមាណអំពីតម្រូវការនៃការបណ្តុះបណ្តាលពីមន្ត្រីនគរបាលជំនាញ ដើម្បីលើកកម្ពស់ការកសាងសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាព។

សៀវភៅគោលនេះត្រូវបានបង្កើតឡើងដោយលោក Alastair Hilton ជាទីប្រឹក្សារបស់អង្គការសកម្មភាពដើម្បីកុមារ (APLE) ទទួលបានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រោមបរិបទដ៏ទូលំទូលាយនៃគោលនយោបាយរបស់អង្គភាពឬស្ថាប័នតម្រូវឱ្យមានកិច្ចសហការជាចាំបាច់រវាងភាគីពាក់ព័ន្ធនានានិងមានការគាំទ្រពីក្រុមការងាររបស់អង្គការសកម្មភាពដើម្បីកុមារ (APLE) និងមន្ត្រីជាន់ខ្ពស់ជាថ្នាក់ដឹកនាំនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន។ក្នុងដំណើរការរៀបចំកសាងសៀវភៅនេះយោងតាមរបាយការណ៍វាយតម្លៃតម្រូវការបណ្តុះបណ្តាល ដែលទទួលបានពីការសម្ភាសព័ត៌មានសំខាន់ៗ ជាមួយអ្នកពាក់ព័ន្ធថ្នាក់ជាតិ តំបន់និងអន្តរជាតិនិងស្មារតីនៃអង្គសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីប៉ាន់ប្រមាណតម្រូវការការបណ្តុះបណ្តាល (TNA) និងមានការចូលរួមពីមន្ត្រីជាន់ខ្ពស់ផ្សេងៗទៀតដែលជា តំណាងស្ថាប័ននានាដូចជាស្ថាប័ននគរបាលជាតិកម្ពុជា និងអ្នកចូលរួមជាមួយផ្នែកដំណើរការយុត្តិធម៌ដូចជាតំណាងមកពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន (AHTJPD) នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា (ACD) នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រនិងកោសល្យវិច្ច័យបណ្ឌិត្យសភានគរបាលកម្ពុជា (PAC) ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) និងតំណាងអង្គការជាតិអន្តរជាតិមិនមែនរដ្ឋាភិបាលព្រមទាំងភ្នាក់ងារអនុវត្តច្បាប់អន្តរជាតិមួយចំនួនដែលបានចូលរួមចំណែកក្នុងការបង្ការ ទប់ស្កាត់ និងឆ្លើយតបទៅនឹង អំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទទាំងក្នុងនិងក្រៅប្រព័ន្ធអនឡាញ ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងស្ថាប័នពាក់ព័ន្ធដៃគូអភិវឌ្ឍន៍ជាពិសេសអង្គការសកម្មភាពដើម្បីកុមារ (APLE) និងភាពជាដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ (End Violence Against Children) តាមរយៈអង្គការយូនីសេហ្វប្រចាំប្រទេសកម្ពុជា (UNICEF Cambodia) និងអ្នកពាក់ព័ន្ធទាំងឡាយដែលបានផ្តល់ការគាំទ្របច្ចេកទេស និងថវិកាក្នុងការរៀបចំសៀវភៅគោលនេះឡើង។ **សូមអរគុណ!**

# សេចក្តីណែនាំអំពី ការប្រើប្រាស់សៀវភៅ

សៀវភៅគោលស្តីពីការឆ្លើយតបនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនេះត្រូវបានបង្កើតឡើងបន្ទាប់ពីបានធ្វើការប៉ាន់ប្រមាណលើតម្រូវការនៃការ បណ្តុះបណ្តាល(TNA) ជាមួយនគរបាលជាតិកម្ពុជា។ គោលបំណងរួមនៃសៀវភៅនេះ គឺដើម្បីបង្កើតវគ្គបណ្តុះបណ្តាល ដែលអាចមានដំណើរការ បាន ដើម្បីជួយមន្ត្រីនគរបាលឱ្យយល់អំពីការស៊ើបអង្កេត និងប្រមូលភស្តុតាងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA)។

<u>របាយការណ៍ប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល(TNA)៖</u> បានកំណត់អំពីតម្រូវការក្នុងការអភិវឌ្ឍ «ការរៀនដ៏ចាំបាច់» ទាក់ទងនឹង OCSEA (ដែលជាចំណុចផ្តោតសំខាន់នៃសៀវភៅនេះ)។ របាយការណ៍នេះក៏បានកំណត់តម្រូវការសម្រាប់វគ្គបណ្តុះបណ្តាលបច្ចេកទេសឌីជីថលជាក់លាក់ សម្រាប់មន្ត្រីនគរបាលជំនាញ។ វគ្គបណ្តុះបណ្តាលនេះតម្រូវឱ្យមានដំណើរការខុសប្លែកគ្នាហើយសង្ឃឹមថានឹងត្រូវបានបង្កើតឡើងនាពេលអនាគតដ៏ខ្លីខាងមុខនេះ នៅក្នុងដំណើរការរួមគ្នារវាងនគរបាលជាតិ អង្គការសកម្មភាពដើម្បីកុមារ និងតួអង្គផ្សេងៗទៀតដើម្បីបំពេញបន្ថែមសៀវភៅនេះ។ របាយការណ៍ TNA បង្កើតអនុសាសន៍ជាក់លាក់ ទាក់ទងនឹងខ្លឹមសារ ដែលផ្តល់ការណែនាំដល់វគ្គបណ្តុះបណ្តាលបច្ចេកទេសនេះ។

សៀវភៅនេះផ្តោតលើផ្នែកជាច្រើននៃអ្វីដែលត្រូវបានពិពណ៌នាថាជា«ការរៀនដ៏ចាំបាច់»ដែលត្រូវបានរចនាឡើងដើម្បីបំពេញបន្ថែម (មិនជំនួស) វគ្គបណ្តុះបណ្តាលផ្សេងទៀត ដែលទាក់ទងនឹងដំណើរការនៃការ អនុវត្តបែបកុមារមេត្រី ដែលត្រូវបានបង្កើតឡើង និងផ្តល់ជូនអស់រយៈពេលជាច្រើនឆ្នាំមកហើយនោះទេ តែខ្លឹមសារនៃសៀវភៅនេះ ត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម។



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

**សៀវភៅនេះ** ផ្តល់ការណែនាំសម្រាប់ប្រធានបទនីមួយៗ ហើយមានភ្ជាប់ជាមួយឧបសម្ព័ន្ធ - រួមមានឯកសារទាំងអស់ដែលពាក់ព័ន្ធ សន្លឹកកិច្ចការ និងធនធានពាក់ព័ន្ធផ្សេងទៀតដែលត្រូវការ។

**ឧបសម្ព័ន្ធទាក់ទងនឹងមេរៀននីមួយៗ** នឹងត្រូវបានថតចម្លង និងសម្រាប់ចែកជូនមន្ត្រីនគរបាលដែលចូលរួមវគ្គបណ្តុះបណ្តាលនេះ ក្នុងអំឡុងពេល ចូលរួម ឬក្រោយពេលបញ្ចប់វគ្គនីមួយៗ។

ក៏មានផ្តល់ជូនបន្ថែម «ស្លាយវគ្គបណ្តុះបណ្តាល OCSEA» ផងដែរ ដែលអាចត្រូវបានប្រើប្រាស់ដើម្បីគាំទ្រវគ្គបណ្តុះបណ្តាលនីមួយៗដែលពាក់ព័ន្ធ និងទៅតាមតម្រូវការ។ ពិភពអនឡាញកំពុងផ្លាស់ប្តូរឥតឈប់ឈរ ហើយពេលដែលមាននិន្នាការ ការអភិវឌ្ឍ និងច្បាប់ថ្មីកើតឡើង គ្រូបណ្តុះបណ្តាលនឹងត្រូវធ្វើបច្ចុប្បន្នភាព ហើយត្រូវកែប្រែវិធីសាស្ត្របណ្តុះបណ្តាល ខ្លឹមសារ សន្លឹកកិច្ចការ ស្លាយ និងធនធានផ្សេងៗទៀតដែរ។

មេរៀន ឬប្រធានបទសិក្សានីមួយៗ ត្រូវបានកំណត់ដោយប្រើចំណងជើងដូចខាងក្រោម ហើយកំណត់ចំណាំការពន្យល់ក៏ត្រូវបានផ្តល់ជូននៅខាងក្រោមផងដែរ។ វគ្គទាំងនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ជូនជាព័ត៌មាន ប៉ុន្តែក៏ផ្តល់ឱកាស សម្រាប់ការចូលរួមយ៉ាងសកម្មពីអ្នកចូលរួម និងអ្នកសម្របសម្រួល ដោយពួកគេអាចចែករំលែកបទពិសោធន៍ និងទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេនៅកន្លែងដែលពាក់ព័ន្ធផងដែរ។

**ប្រធានបទសិក្សាដែលមាននៅក្នុងសៀវភៅគោលនេះ មានរួមបញ្ចូលចំណងជើង កំណត់ចំណាំ កំណត់ពន្យល់បន្ថែមរបស់អ្នកសម្របសម្រួលគោលបំណងនៃវគ្គនីមួយៗ មានដូចខាងក្រោម៖**

## លទ្ធផលរំពឹងទុក៖

វគ្គបណ្តុះបណ្តាលខ្លះប្រើពាក្យ «គោលបំណង» និយាយអំពីផ្នែកនេះ ប៉ុន្តែសៀវភៅគោលនេះប្រើពាក្យ «លទ្ធផលរំពឹងទុក» ដើម្បីពិពណ៌នាយ៉ាងច្បាស់អំពីលទ្ធផលដែលរំពឹងទុកពីប្រធានបទ ឬវគ្គនីមួយៗ។

នៅក្នុងស្លាយក៏មានរួមបញ្ចូលការសង្ខេបនៃ«លទ្ធផលរំពឹងទុក»ផងដែរដែលអាចត្រូវបានចែករំលែកនៅដើមដំបូងនៃវគ្គនីមួយៗ។«លទ្ធផលរំពឹងទុក»ត្រូវបានបង្កើតឡើងដោយសារមន្ត្រីនគរបាលដែលបានចូលរួមក្នុងដំណើរការ TNA ដែលបានបង្ហាញថា វាជាតម្រូវការសិក្សារបស់ពួកគេ។ យូរៗទៅមាតិកា និងលទ្ធផលនៃវគ្គបណ្តុះបណ្តាលនេះអាចផ្លាស់ប្តូរ ដូច្នេះលទ្ធផលក៏អាចត្រូវបានកែប្រែផងដែរ។

## កំណត់ចំណាំ៖

មេរៀននីមួយៗមានកំណត់ចំណាំពន្យល់បន្ថែមសម្រាប់អ្នកសម្របសម្រួល ហើយពួកគេគួរតែអានដើម្បីជួយពួកគេក្នុង ការរៀបចំសម្រាប់វគ្គបណ្តុះបណ្តាលនេះ។

កំណត់ចំណាំទាំងនេះ ក៏គួរត្រូវបានប្រើដើម្បីជួយអ្នកសម្របសម្រួល «រៀបចំបរិយាកាស» សម្រាប់ការរៀនសូត្រពេលណែនាំពីវគ្គបណ្តុះបណ្តាលនេះផងដែរ។

កំណត់ចំណាំមួយចំនួនអាចទាក់ទងនឹងវិធីសាស្ត្រជាក់លាក់ដែលត្រូវប្រើឬព័ត៌មានដែលពាក់ព័ន្ធដទៃទៀតដែលអាចជួយពួកគេរៀបចំ និងសម្របសម្រួលវគ្គបណ្តុះបណ្តាលនេះយ៉ាងរលូន។

អ្នកសម្របសម្រួលទទួលបានការលើកទឹកចិត្តឱ្យធ្វើកំណត់ចំណាំបន្ថែមដោយខ្លួនឯង ប្រសិនបើពួកគេចង់ ដើម្បីជួយពួកគេរៀបចំខ្លួនសម្រាប់វគ្គបណ្តុះបណ្តាលនេះ។


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

# ធនធានដែលត្រូវការ៖

ក្នុងករណីពាក់ព័ន្ធផ្នែកនេះ នឹងរំលឹកអ្នកសម្របសម្រួលអំពីសម្ភារៈជាក់លាក់ ដែលចាំបាច់ត្រូវប្រើក្នុងវគ្គនីមួយៗ សម្ភារៈទាំងនេះនឹងរួមបញ្ចូល៖ ប៊ិចពណ៌សម្រាប់គូសចំណាំ និងក្រដាសជាដើម ប៉ុន្តែក៏មានសន្លឹកកិច្ចការ និងធនធានផ្សេងទៀត ដែលអាចរកបាននៅក្នុង «ឧបសម្ព័ន្ធ នីមួយៗ» ផងដែរ។ វគ្គនីមួយៗក៏មានស្លាយ ដែលអាចរកបាននៅក្នុង «ស្លាយវគ្គបណ្តុះបណ្តាល OCSEA»។

## កំណត់ពន្យល់បន្ថែមសម្រាប់ការសម្របសម្រួល៖

ការកំណត់ចំណាំទាំងនេះត្រូវបានផ្តល់ជូនជាទម្រង់នៃកំណត់ចំណាំ «មួយជំហានម្តងៗ» សម្រាប់អ្នកសម្របសម្រួលដើម្បីតាមដាន និងជួយពួកគេក្នុងការសម្របសម្រួលវគ្គនីមួយៗ។ ល្អបំផុតអ្នកសម្របសម្រួលត្រូវអានសៀវភៅគោលនេះ ព្រោះវានឹងជួយពួកគេក្នុងការរៀបចំ និងការគ្រោងគម្រោងសម្រាប់វគ្គនីមួយៗ។

យូរៗទៅ ជាមួយនឹងបទពិសោធន៍កាន់តែច្រើន អ្នកសម្របសម្រួលអាចគិតអំពីរបៀបផ្សេងទៀត ដែលមានភាពសកម្ម មានភាពច្នៃប្រឌិត និងមានប្រសិទ្ធភាព ដើម្បីជួយសម្របសម្រួលដល់វគ្គផ្សេងៗ ហើយថែមទាំងបង្កើតឱកាសសម្រាប់គ្រូបណ្តុះបណ្តាល និងអ្នកចូលរួមចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។អ្នកសម្របសម្រួលក៏ទទួលបានការលើកទឹកចិត្តឱ្យកែប្រែ និងកែលម្អសៀវភៅណែនាំនេះផងដែរ។

## ខ្លឹមសារគន្លឹះ និងសកម្មភាពតស៊ូមតិ

នៅក្នុងដំណើរការ TNA អ្នកចូលរួមមួយចំនួនបានបញ្ចេញមតិថា ជារឿយៗមន្ត្រីនគរបាលប្រហែលជាមិនងាយស្រួល ឬប្រហែលជាមិនមានឱកាសក្នុងការចែករំលែកអ្វីដែលពួកគេបានរៀនជាមួយសហការីរបស់ពួកគេទេ។

ដូច្នេះហើយ នៅចុងបញ្ចប់នៃវគ្គមួយចំនួនផ្នែកនេះ ផ្តល់នូវឧទាហរណ៍យ៉ាងសាមញ្ញមួយចំនួនអំពីរបៀបដែលអ្នកចូលរួមអាចចែករំលែកអ្វីដែលពួកគេបានរៀនដល់សហសេវិក ឬអាចជាមួយកុមារ យុវជន និងគ្រួសារពួកគេ។ «ឈ្នះៗ» សម្រាប់មន្ត្រីនគរបាល កុមារ និងក្រុមគ្រួសារដែលយើងគាំទ្រ។

យើងសង្ឃឹមថា អ្នកយល់ថាការផ្តល់យោបល់ទាំងនេះមានប្រយោជន៍ ហើយអ្នកក៏អាចណែនាំសកម្មភាពគាំទ្រដទៃទៀត ដែលអាចមានប្រយោជន៍។

សូមធ្វើបច្ចុប្បន្នភាព និងកែប្រែមាតិកា ពេលដែលមានចំណេះដឹង ព័ត៌មានការសិក្សា និងច្បាប់ថ្មីលេចឡើង។

# មាតិកា

ទំព័រ

| | |
|---|---|
| មេរៀនទី១ ៖ ការយល់ដឹងពីបច្ចេកវិទ្យា និងពិភពនិមិត្ត របស់កុមារ | ៩ |
| មេរៀនទី២ ៖ របកគំហើញអំពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ | ១៨ |
| មេរៀនទី៣ ៖ ចរិតលក្ខណៈ វិសាលភាព និងផលប៉ះពាល់កុមារ | ២៦ |
| មេរៀនទី៤ ៖ មាត្រាច្បាប់ ពាក់ព័ន្ធនឹងអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ | ៣២ |
| មេរៀនទី៥ ៖ សិទ្ធិកុមារក្នុងពិភពឌីជីថល | ៣៧ |
| មេរៀនទី៦ ៖ គោលការណ៍អនុវត្តនីតិវិធីបែបកុមារមេត្រី | ៤១ |
| មេរៀនទី៧ ៖ ការយល់ដឹងពីជំហានផ្សេងៗ នៃការស៊ើបអង្កេតបទល្មើស | ៤៩ |
| មេរៀនទី៨ ៖ ការកសាងភាពជាដៃគូ និងកិច្ចសហការជាតិ និងអន្តរជាតិ | ៥៦ |
| មេរៀនទី៩ ៖ ការប្រតិបត្តិផ្អែកលើចំណេះដឹង និងជំនាញ | ៦៤ |
| មេរៀនទី១០ ៖ ការដោះស្រាយបញ្ហាប្រឈមទូទៅ | ៦៨ |
| មេរៀនទី១១ ៖ ការលើកកម្ពស់ការរាយការណ៍ និងស្វែងរកជំនួយ | ៧៤ |
| ឧបសម្ព័ន្ធ "ក" ៖ សំនួរចម្លើយ នៃរបកគំហើញការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ | ៨៣ |
| ឧបសម្ព័ន្ធ "ខ" ៖ និយមន័យការរំលោភបំពានផ្លូវភេទលើកុមារ (CSA) និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (CSE) | ៩១ |
| ឧបសម្ព័ន្ធ "ខ១" ៖ ការស្វែងយល់ និងនិយមន័យការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) | ៩៥ |
| ឧបសម្ព័ន្ធ "ខ២" ៖ ករណីសិក្សានៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) | ១០០ |

| | |
|---|---|
| ឧបសម្ព័ន្ធ "គ" ៖ ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងមាត្រាច្បាប់ពាក់ព័ន្ធនៅប្រទេសកម្ពុជា | ១១៨ |
| ឧបសម្ព័ន្ធ "ឃ" ៖ សេចក្ដីសង្ខេប អនុសញ្ញាស្ដីពីសិទ្ធិកុមារ (UNHCR) | ១២៤ |
| ឧបសម្ព័ន្ធ "ឃ១" ៖ សិទ្ធិកុមារក្នុងពិភពឌីជីថល | ១៣០ |
| ឧបសម្ព័ន្ធ "ង" ៖ គោលការណ៍នៃការអនុវត្តបែបកុមារមេត្រី | ១៣៧ |
| ឧបសម្ព័ន្ធ "ច" ៖ ការស៊ើបអង្កេតអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញដែលស្របតាមគោលការណ៍ច្បាប់ | ១៤៦ |
| ឧបសម្ព័ន្ធ "ឆ" ៖ កាតនៃសេចក្ដីថ្លែងការណ៍ (បទពិសោធន៍របស់កុមារ និងគ្រួសារក្នុងការស្វែងរក និងទទួលបានជំនួយពីនគរបាល | ១៥១ |
| ឧបសម្ព័ន្ធ "ឆ១" ៖ ករណីសិក្សា (បទពិសោធន៍វិជ្ជមានរបស់កុមារកម្ពុជាក្នុងការស្វែងរកជំនួយពីនគរបាល | ១៥៦ |
| ឧបសម្ព័ន្ធ "ឆ២" ៖ តម្រូវការរបស់កុមារពីអ្នកអនុវត្តច្បាប់ | ១៥៩ |
| ឧបសម្ព័ន្ធ "ជ" ៖ ករណីសិក្សា (សំនួរសម្រាប់ការងារជាក្រុម) | ១៦០ |
| ឧបសម្ព័ន្ធ "ឈ" ៖ ការដោះស្រាយបញ្ហាប្រឈម និងផលវិបាកទូទៅ | ១៦៦ |

## មេរៀនទី១

# ការយល់ដឹងពីបច្ចេកវិទ្យា និងពិភពនិម្មិត របស់កុមារ



### បច្ចេកវិទ្យា និងពិភពនិម្មិត (Virtual World) របស់កុមារ

## លទ្ធផលរំពឹងទុក៖

អ្នកចូលរួមនឹង៖

- ឆ្លុះបញ្ចាំងពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) របស់ពួកគេផ្ទាល់ ហើយពិចារណាអំពីអត្ថប្រយោជន៍ បញ្ហាប្រឈម និងហានិភ័យ។
- ស្វែងយល់ពីរបៀបដែលកុមារ កំពុងប្រើប្រាស់ប្រព័ន្ធអនឡាញ និងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទនង (ICT) ហើយពិចារណាអំពីអត្ថប្រយោជន៍ និងហានិភ័យដែលអាចកើតឡើងចំពោះពួកគេ។

## ធនធានដែលត្រូវការ៖

ក្តារខៀន ឬក្រដាសផ្ទាំងធំ ប៊ិចពណ៌សម្រាប់គូសចំណាំ ស្កុត ក្រដាសបិទស្ទីគ័រ/បន្ទះក្រដាស (ឧ. ក្រដាស A៤ កាត់ជា ៤ ផ្នែក (អាចជ្រើសរើសបាន) ស្លាយមេរៀន។

## កំណត់ចំណាំ៖

ក្នុងរយៈពេល ២០ឆ្នាំចុងក្រោយនេះ បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) បានដើរតួនាទីកាន់តែច្រើនឡើងក្នុងគ្រប់ទិដ្ឋភាពនៃជីវិតមនុស្សយើងហើយតាមរបៀបជាច្រើនវាបានផ្លាស់ប្រែជីវិតរបស់យើងដូចជាការងារការលំហែ ទំនាក់ទំនង ជីវិតគ្រួសារ អាជីវកម្ម ការធ្វើដំណើរ ការរៀនសូត្រ ការទិញទំនិញ និងសេវាកម្មផ្សេងទៀត ព្រមទាំងការចូលរួមផ្នែកនយោបាយគ្រប់ទិដ្ឋភាពនៃជីវិតរបស់យើងទទួលបានឥទ្ធិពលពីវាបើមិនតាមរបៀបនេះទេក៏តាមរបៀបនោះដែរ។

ជាឧទាហរណ៍ កាលពី ២០ឆ្នាំមុន មិនមែនគ្រប់គ្នាសុទ្ធតែមានទូរស័ព្ទផ្ទាល់ខ្លួនទេ ហើយវាមិនមែនជារឿងចម្លែកទេក្នុងរកឃើញទូរស័ព្ទសាធារណៈតាមផ្លូវ ដែលអ្នកអាចហៅបានចំណាយប្រាក់ ៣០០រៀលក្នុងមួយនាទី។

សព្វថ្ងៃនេះ មនុស្សជាច្រើនគឺជាម្ចាស់ ឬមានលទ្ធភាពអាចប្រើប្រាស់ស្មាតហ្វូនបាន ដែលពួកគេអាចខលជាសំឡេង និងជាវីដេអូ ទៅកាន់នរណាម្នាក់នៅក្នុងផ្នែកណាមួយនៃពិភពលោកនេះ ហើយបង្កើត និងផ្ញើអ៊ីម៉ែល ព្រមទាំងចែករំលែកវីដេអូ និងរូបថត អាចលេងហ្គេម និងមើលភាពយន្ត កម្មវិធីទូរទស្សន៍ និងព្រឹត្តិការណ៍កីឡាផ្សេងៗ ដែលជារឿយៗការទាំងអស់នេះត្រូវបាន «ផ្សាយដោយផ្ទាល់»។ ការអភិវឌ្ឍនៃប្រព័ន្ធអនឡាញ និងឧស្សាហកម្ម បច្ចេកវិទ្យាមានល្បឿនលឿនណាស់ ហើយច្បាប់សង្គម និងច្បាប់សម្រាប់ការប្រើប្រាស់ និងការយល់ដឹងអំពីហានិភ័យតែងតែមានភាពយឺតយ៉ាវ។



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

គោលបំណងរួមនៃមេរៀនដើម្បីលើកទឹកចិត្តឱ្យអ្នកចូលរួម គិតអំពីរបៀបដែលកុមារប្រើប្រាស់បច្ចេកវិទ្យា និងប្រព័ន្ធអនឡាញក្នុងការរស់នៅ ហើយពិចារណាអំពីអត្ថប្រយោជន៍ និងគុណវិបត្តិរបស់វា ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាបន្ថែម។

## កំណត់ពន្យល់បន្ថែមសម្រាប់ការសម្របសម្រួល៖

១. រៀបចំបរិយាកាសនៃវគ្គបណ្តុះបណ្តាលនេះហើយធ្វើការណែនាំអំពីវគ្គនេះដោយប្រើកំណត់ចំណាំខាងលើនិងចែករំលែកពីលទ្ធផលដែលរំពឹងទុកពីវគ្គបណ្តុះបណ្តាល។

២. សូមពន្យល់ដល់ក្រុមអ្នកចូលរួមថា យើងនឹងឆ្លុះបញ្ចាំងអំពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) របស់ពួកគេផ្ទាល់។ យើងនឹងធ្វើដូច្នេះដោយការពិភាក្សាជាដៃគូឬការពិភាក្សាប្រមូលគំនិតក្នុងក្រុមធំជាងនេះ (មួយណាក៏បានឱ្យតែសមរម្យ)។

៣. ក្នុងនាមជាអ្នកសម្របសម្រួលអ្នកគួរផ្តល់យោបល់អំពីភាពស្រដៀងគ្នានិងភាពខុសគ្នាដែលអ្នកសង្កេតឃើញហើយអញ្ជើញក្រុមបញ្ចេញមតិយោបល់របស់ពួកគេទាក់ទងអ្វីដែលពួកគេមើលឃើញ។

៤. ធ្វើការសង្ខេបផ្នែកនៃមេរៀននេះ ដោយចង្អុលបង្ហាញថាមានគុណសម្បត្តិនិងអត្ថប្រយោជន៍ជាច្រើននៃការប្រើប្រាស់បច្ចេកវិទ្យា ហើយថាយើងទាំងអស់គ្នាទទួលបានប្រយោជន៍ពីវាក្នុងនាមជាមនុស្សពេញវ័យស្ទើរតែគ្រប់ទិដ្ឋភាពនៃជីវិតរបស់យើង។ពួកយើងជាច្រើននាក់បានធ្វើកិច្ចការជាច្រើនកាន់តែល្អប្រសើរជាងមុនជាងមុននៅក្នុងពិភពឌីជីថលនេះនេះ។

ទោះជាយ៉ាងណាក៏ដោយ ក៏ចង្អុលបង្ហាញថា ប្រព័ន្ធអនឡាញ និងបច្ចេកវិទ្យាក៏មានសក្តានុពលក្នុងការមានឥទ្ធិពលអវិជ្ជមានលើជីវិតយើង គ្រួសារយើង និងមនុស្សដែលយើងបម្រើផងដែរ។ (អ្នកក៏អាចចែករំលែកស្លាយសង្ខេប ប្រសិនបើអ្នកចង់ចែករំលែកវាជាមួយពួកគេ)។

៥. សូមពន្យល់អ្នកចូលរួមថា ឥឡូវនេះយើងនឹងចំណាយពេលពិចារណា និងសិក្សាអំពីរបៀបដែលកុមារ និងយុវជនកម្ពុជាប្រើប្រាស់អ៊ីនធឺណិត និងបច្ចេកវិទ្យា ហើយថាតើពិភពនិមិត្តមានលក្ខណៈបែបណាសម្រាប់ពួកគេ។

គំនិតរបស់ពួកគេ អាចរួមមាន៖ កុមារប្រើប្រាស់បច្ចេកវិទ្យា និងអ៊ីនធឺណិតសម្រាប់ការកម្សាន្ត (មើលភាពយន្ត និងវីដេអូជាដើម) ដើម្បីបង្កើតមិត្តភក្តិ និងរក្សាទំនាក់ទំនងជាមួយមិត្តភក្តិពួកគេដើម្បីការរៀនសូត្រ ការអប់រំ និងការស្រាវជ្រាវ ដើម្បីណាត់ជួប និងស្វែងរកដៃគូ ដើម្បីចែករំលែករូបភាព និងវីដេអូ និងលេង «ហ្គេម» ដែលកំពុងតែពេញនិយមកាន់តែខ្លាំងឡើងនាពេលបច្ចុប្បន្ននេះ។

៦. បន្ទាប់មកចែករំលែកព័ត៌មានពីស្លាយដែលពាក់ព័ន្ធនឹងស្លាយមេរៀននេះ។ **(ស្លាយលេខ៤)** (ស្លាយនេះរួមបញ្ចូលឧទាហរណ៍នៃនិន្នាការ (ទំនោរ) កម្មវិធី គេហទំព័រ សកម្មភាព សហគមន៍ហ្គេម និងធនធានអប់រំដែលប្រើប្រាស់ដោយកុមារ និងយុវជនកម្ពុជា។) សូមពន្យល់ថា ព័ត៌មាននេះគឺផ្អែកលើព័ត៌មានដែលផ្តល់ដោយអ្នកស្រាវជ្រាវ និងរបាយការណ៍អង្គការសកម្មភាពដើម្បីកុមារ (APLE) យោងតាមអ្វីដែលកុមារប្រាប់ពួកគេ (២០២៣)។

បញ្ជាក់ដែរថា និន្នាការ (ទំនោរ) កម្មវិធី បច្ចេកវិទ្យា និងសកម្មភាពអាចជាទូទៅផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។

៧. បន្តការពិភាក្សាដោយសួរពួកគេអំពីគំនិតរបស់ពួកគេទាក់ទងនឹងអ្វី ដែលពួកគេគិតថាជា«**អត្ថប្រយោជន៍ និងគុណសម្បត្តិ**» ហើយអ្វីជា «**គុណវិបត្តិ និងហានិភ័យ**» សម្រាប់កុមារកម្ពុជា។

នៅដំណាក់កាលនេះ អ្នកគ្រាន់តែសុំគំនិត និងយោបល់របស់ពួកគេ ដែលអាចផ្អែកលើបទពិសោធន៍ជីវិតរបស់ពួកគេផ្ទាល់ (ប្រហែលជាកូនៗរបស់ពួកគេ) ឬអ្វីដែលពួកគេបានឮពីការងាររបស់ពួកគេ និង/ឬការសន្ទនារបស់ពួកគេ។

៨. **ចែករំលែកព័ត៌មានទាក់ទងនឹងការស្រាវជ្រាវអំពីកុមារ និងយុវជនកម្ពុជា និងរបៀបដែលពួកគេប្រើប្រាស់ប្រព័ន្ធអនឡាញ**

បន្ទាប់ពីក្រុមបានចែករំលែកគំនិតរបស់ពួកគេរួចហើយ ពន្យល់ប្រាប់ពួកគេថា យើងនឹងចែករំលែកព័ត៌មានសង្ខេបអំពីការស្រាវជ្រាវទាក់ទងនឹងរបៀបដែលកុមារកម្ពុជាប្រើប្រាស់ប្រព័ន្ធអនឡាញ។ (មានព័ត៌មានដូចគ្នានៅលើស្លាយ៖ ស្លាយទី៤, ៥ និង ៦)។

ព័ត៌មាននេះ គឺផ្អែកលើការស្រាវជ្រាវជាមួយកុមារនៅប្រទេសកម្ពុជា (ការបញ្ឈប់គ្រោះថ្នាក់ ឆ្នាំ២០២១) និងព័ត៌មានបន្ថែមដែលផ្តល់ដោយ APLE ក្នុងឆ្នាំ២០២៣។ (កំណត់ចំណាំចំពោះអ្នកបណ្តុះបណ្តាល ព័ត៌មាននេះអាច និងគួរត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ)។

៩. ចែករំលែកព័ត៌មានបន្ថែមនៅលើ ស្លាយទី៨ «**អត្ថប្រយោជន៍ និងគុណសម្បត្តិ**» និង«**គុណវិបត្តិនិងហានិភ័យ**»សម្រាប់កុមារកម្ពុជា៖ក៏រួមបញ្ចូលព័ត៌មានសំខាន់ៗដែលត្រូវចែករំលែកផងដែរ(មានតំណភ្ជាប់បន្ថែមដែលផ្តល់ជូនក្នុងកំណត់ចំណាំនៅខាងក្រោមស្លាយ)។

១០. បន្ទាប់ពីអ្នកបានចែករំលែកព័ត៌មាននេះរួចហើយ អ្នកអាចសួរសំនួរខាងក្រោមទៅកាន់ក្រុម

- តើព័ត៌មានអ្វីខ្លះដែលធ្វើឱ្យពួកគេភ្ញាក់ផ្អើល?
- តើព័ត៌មានអ្វីខ្លះដែលធ្វើឱ្យពួកគេចាប់អារម្មណ៍?
- តើពួកគេមានមតិយោបល់អ្វី ឬសំនួរអ្វីបន្ថែមទាក់ទងនឹងអ្វីដែលពួកគេបានរៀនដែរឬទេ?

## សកម្មភាព

១. ដោយប្រើក្តារខៀន ឬក្រដាសផ្ទាំងធំ គូសរង្វង់មួយនៅកណ្តាលក្រដាស ហើយសរសេរពាក្យ«អ៊ីនធឺណិត»«បច្ចេកវិទ្យា»និង«ពិភពនិមិត្ត» នៅក្នុងរង្វង់នេះ ហើយផ្នែកខាងឆ្វេងនៃរង្វង់ សូមគូសគំនូសឈរមួយ ដែលមានចំណងជើងថា «**អត្ថប្រយោជន៍ និងគុណសម្បត្តិសម្រាប់ខ្ញុំ**» និងនៅខាងស្តាំដៃ «**ហានិភ័យ និងគុណវិបត្តិសម្រាប់ខ្ញុំ**»។ វាគួរតែមើលទៅស្រដៀងនឹងដ្យាក្រាមខាងក្រោម។ (ការផ្តល់យោបល់មួយចំនួនខាងក្រោមនេះគ្រាន់តែដើម្បីជាការបង្ហាញតែប៉ុណ្ណោះទេ)។

២. សុំឱ្យក្រុមពិភាក្សាគ្នាជាដៃគូ រយៈពេល**១០នាទី** អំពីការប្រើប្រាស់បច្ចេកវិទ្យា វេទិកា កម្មវិធី និងឧបករណ៍ផ្សេងៗរបស់ពួកគេ៖ ពិភាក្សាអំពីគុណសម្បត្តិ និងគុណវិបត្តិ នៃការប្រើប្រាស់របស់ទាំងនេះ។

ពួកគេអាចសរសេរគំនិតរបស់ពួកគេនៅលើក្រដាសកំណត់ចំណាំ(ប្រសិនបើអ្នកមាន)ឬក្រដាសពណ៌។(ឧ.ពណ៌បៃតងសម្រាប់គុណសម្បត្តិហើយពណ៌ខៀវសម្រាប់គុណវិបត្តិ)។

៣. នាំក្រុមតូចនីមួយៗត្រឡប់មកក្រុមធំវិញ រួចស្នើពួកគេឱ្យចែករំលែកគំនិតរបស់ពួកគេ-ជាដំបូងដោយសួរពួកគេអំពីឧបករណ៍និងកម្មវិធីផ្សេងៗដែលពួកគេធ្លាប់បានប្រើប្រាស់ក្នុងជីវិតប្រចាំថ្ងៃពួកគេ។ វាគួរតែងាយស្រួលសម្រាប់ពួកគេក្នុងការចែករំលែក ដោយសារពួកគេប្រើប្រាស់វាជារៀងរាល់ ថ្ងៃ។

៤. សួរក្រុមដោយផ្អែកលើបទពិសោធន៍របស់ពួកគេផ្ទាល់-តើពួកគេដឹងអ្វីខ្លះ **អំពីរបៀបដែលកុមារកម្ពុជាប្រើប្រាស់អ៊ីនធឺណិត** ( ឧ.ឧបករណ៍កម្មវិធី និង វេទិកា ដែលពួកគេប្រើប្រាស់ ) ហើយពួកគេប្រើ**អ៊ីនធឺណិតដើម្បីអ្វី** (ឧ. គោលបំណង និងហេតុផលដែលពួកគេប្រើប្រាស់វា )។អនុញ្ញាតឱ្យពួកគេឆ្លើយតបសិន មុនពេលបន្តទៅមុខទៀត។

## ខ្លឹមសារគន្លឹះ និងសកម្មភាពតស៊ូមតិ

- វាច្បាស់ណាស់ថាទាំងមនុស្សពេញវ័យនិងកុមារពឹងផ្អែកកាន់តែខ្លាំងជាងមុនតាមប្រព័ន្ធអនឡាញនិងបច្ចេកវិទ្យានៅក្នុងគ្រប់ទិដ្ឋភាពនៃជីវិតពួកគេ។ ការរីកចម្រើននៃបច្ចេកវិទ្យា និងការប្រើប្រាស់ទាំងនេះ មានល្បឿនលឿនណាស់រយៈពេលប៉ុន្មានឆ្នាំថ្មីៗកន្លងមកនេះ។
- បច្ចេកវិទ្យាផ្តល់ឱកាសគ្មានទីបញ្ចប់សម្រាប់ការរៀន ការធ្វើការភ្ជាប់ទំនាក់ទំនងសង្គម ការរៀបចំ និងការរៀបចំផែនការ ផ្តល់ភាពសប្បាយ រីករាយ និងការសម្រាកលំហែ មានរបស់ហូប របស់ផឹក ការទិញទំនិញ ការចូលមើលការកម្សាន្តផ្សេងៗ-បញ្ជីគឺគ្មានទីបញ្ចប់ទេ!
- មានគុណសម្បត្តិជាច្រើននៃបច្ចេកវិទ្យា និងអ៊ីនធឺណិត ប៉ុន្តែវាក៏មានគុណវិបត្តិផងដែរ។
- កុមារប្រើប្រាស់ប្រព័ន្ធអនឡាញ កាន់តែច្រើននៅប្រទេសកម្ពុជា ហើយពួកគេក៏ទទួលបានអត្ថប្រយោជន៍ព្រមទាំងប្រឈមនឹងបញ្ហានិងការលំបាកជាច្រើនផងដែរ។
- ប្រសិនបើយើងជួយកុមារ និងយុវជន ដោយអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ OCSEA វាមានប្រយោជន៍សម្រាប់យើងក្នុងការស្វែងយល់អំពីបរិបទដែលកុមារកម្ពុជាប្រើប្រាស់អ៊ីនធឺណិត និង«ពិភពឌីជីថល» ដែលពួកគេកំពុងរស់នៅ។
- យើងដឹងហើយថា ពេលដែលមានរឿងខុសប្រក្រតីកើតឡើង កុមារតែងតែមានអារម្មណ៍ភ័យខ្លាច ច្របូកច្របល់ ហើយពួកគេមិនដឹងថាត្រូវធ្វើអ្វីទេ។ ហើយពួកគេក៏ប្រហែលជាមិនមានអារម្មណ៍ថា ពួកគេអាចទុកចិត្តនគរបាលដើម្បីដោះស្រាយបញ្ហារបស់ពួកគេ។ នគរបាលខ្លះមើលឃើញថា ក្មេង «មិនសហការ» ជាមួយពួកគេទេ ប៉ុន្តែជារឿយៗពួកគេ

គ្រាន់តែមានអារម្មណ៍ភ័យខ្លាច និងច្របូកច្របល់តែប៉ុណ្ណោះ។

- ព័ត៌មាននៅក្នុងមេរៀននេះ អាចមានប្រយោជន៍សម្រាប់យើង ពេលយើងជួបកុមារនិងអាណាព្យាបាលរបស់ពួកគេ។ដូច្នេះយើងមានព័ត៌មានចំណេះដឹងមូលដ្ឋាន អំពីប្រធានបទនេះ។ ការនេះអាចជួយកុមារ និងយុវជន ឱ្យមានអារម្មណ៍ជឿជាក់លើមន្ត្រីនគរបាលថាពួកគេមានចំណេះដឹងនិងការយល់ដឹងសមស្រប...ការនេះអាចជួយឱ្យពួកគេមានភាពជឿជាក់លើយើងក្នុងឋានៈជាមន្ត្រីនគរបាលហើយបន្ទាប់មកមានអារម្មណ៍ជឿជាក់ក្នុងការចែករំលែករឿងរ៉ាវរបស់ពួកគេជាមួយយើង។

ព័ត៌មាននេះ គឺផ្អែកលើការស្រាវជ្រាវជាមួយកុមារនៅប្រទេសកម្ពុជា ( ការបញ្ឈប់គ្រោះថ្នាក់ឆ្នាំ ២០២១ ) និងព័ត៌មានបន្ថែមដែលផ្តល់ដោយ APLE ក្នុងឆ្នាំ២០២៣។ ( កំណត់ចំណាំចំពោះអ្នក បណ្តុះបណ្តាល ព័ត៌មាននេះអាច និងគួរត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ )។

- របាយការណ៍ការបញ្ឈប់គ្រោះថ្នាក់ បានធ្វើការស្ទង់មតិកុមារពីអាយុ ១២ឆ្នាំ ដល់ ១៧ឆ្នាំ (N= ២៤៣៩ ) បង្ហាញ ថា ៨១% នៃកុមារនៅប្រទេសកម្ពុជា គឺជាអ្នកប្រើប្រាស់អ៊ីនធឺណិត។
- ក្នុងចំណោមគំរូបឋមនៃកុមារដែលប្រើអ៊ីនធឺណិតដែលមានអាយុពី ១២ឆ្នាំ ដល់ ១៧ឆ្នាំ ក្នុងប្រទេសកម្ពុជា ចំនួន៩៩២ ស្មើនឹង ៧៧% បានរាយការណ៍ថា កំពុងប្រើប្រព័ន្ធអនឡាញយ៉ាងហោចណាស់ម្តង ក្នុងមួយថ្ងៃ។
- ដូចនៅប្រទេសដទៃទៀតដែរ ស្មាតហ្វូនគឺជាឧបករណ៍ពេញនិយមបំផុតដែលក្មេងអាយុពី ១២ឆ្នាំ ដល់ ១៧ឆ្នាំប្រើដើម្បីប្រើប្រាស់ប្រព័ន្ធអនឡាញ។ ស្ទើរតែទាំងអស់ ៩៩% នៃកុមារដែលបានធ្វើការស្ទង់មតិនៅប្រទេសកម្ពុជា កំពុងប្រើប្រាស់ស្មាតហ្វូនដើម្បីប្រើប្រាស់ប្រព័ន្ធអនឡាញ។ មានតែ ២% ប៉ុណ្ណោះដែលកំពុងប្រើកុំព្យូទ័រខណៈពេលដែលគ្មាននរណាម្នាក់កំពុងប្រើថេបប្លេតឬឧបករណ៍ឌីជីថលផ្សេងទៀតទេ។
- សកម្មភាពអនឡាញដ៏ពេញនិយមបំផុតក្នុងចំណោមកុមារដែលបានធ្វើការស្ទង់មតិនេះគឺសកម្មភាពកម្សាន្ត ពោលគឺការប្រើប្រាស់បណ្តាញសង្គម ៧៩% និងការមើលវីដេអូ ៧៩% ។
- ការពេញនិយមបន្ទាប់គឺការប្រើប្រាស់ការផ្ញើសារភ្លាមៗ៥១%និងការនិយាយទៅកាន់គ្រួសារ មិត្តភក្តិដែលរស់នៅឆ្ងាយ ៥០% ។
- កុមារមានវ័យច្រើនជាងដែលមានអាយុពី ១៤ឆ្នាំ ដល់ ១៧ឆ្នាំ ជាទូទៅចូលរួមក្នុងសកម្មភាពអនឡាញទូលំទូលាយជាងកុមារដែលមានអាយុពី ១២ឆ្នាំ ដល់ ១៣ឆ្នាំ។
- ដូចនៅប្រទេសផ្សេងៗទៀតដែរ ការលេងហ្គេមអនឡាញ គឺជារឿងធម្មតាបំផុតក្នុងចំណោមក្មេងប្រុស ៦៦% ជាងក្មេងស្រី ១៦% ។

- ក្មេងស្រីច្រើនជាងក្មេងប្រុសបានរាយការណ៍ថា ពួកគេប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម និងការផ្ញើសារភ្លាមៗ និងប្រព័ន្ធអនឡាញសម្រាប់ការងារសាលា។
- មានសកម្មភាពមួយចំនួនជាន់គ្នា ឧទាហរណ៍កុមារអាចចូលមើលវីដេអូជាផ្នែកមួយនៃកិច្ចការសាលារបស់ពួកគេ។

### កម្មវិធី និងវេទិកាដែលប្រើច្រើនបំផុត៖ (ស្លាយទី ៧)

- Facebook; Messenger; Telegram
- TikTok
- Instagram
- YouTube
- WhatsApp (ភាគច្រើនជាមនុស្សពេញវ័យ)
- CapCut (កម្មវិធីកាត់តវីដេអូ)
- BIGO Live
- Snapchat
- Discord
- X

### កំណត់ចំណាំបន្ថែមត្រូវបានផ្តល់ជូនដើម្បីជួយអ្នក-អ្នកសម្របសម្រួលពន្យល់ពីគោលបំណងនិងមុខងារនៃកម្មវិធី និង វេទិកានីមួយៗដែលបានប្រើ

**Facebook; Messenger; Telegram៖** ទាំងនេះគឺជាកម្មវិធីទាំងអស់សម្រាប់មនុស្សក្នុងការប្រាស្រ័យទាក់ទងគ្នាតាមរយៈអ្វីដែលគេហៅថា 'ប្រព័ន្ធផ្សព្វផ្សាយសង្គម' Facebook និង Messenger គឺជាផ្នែកមួយនៃវេទិកាដូចគ្នាប្រសិនបើអ្នកមាន Facebook ជាធម្មតាអ្នកមាន Messenger ហើយអ្នកអាចផ្ញើសារជាអក្សរ សារជាសំឡេង និងរូបថត និងវីដេអូ ទៅកាន់អ្នកដទៃ ហើយក៏អាចទទួលការផ្ញើចូលវិញផងដែរ។ អ្នកក៏អាចធ្វើការហៅទូរស័ព្ទ និងហៅជាវីដេអូបានផងដែរ ប្រសិនបើអ្នកភ្ជាប់អ៊ីនធឺណិត។ (**Facebook Messenger** ជាកម្មសិទ្ធិរបស់ជនជាតិអាមេរិក និងមានអ្នកប្រើប្រាស់ប្រចាំខែជាង ៩០០ លាននាក់ នៅ ទូទាំងពិភពលោក។ **Telegram** ត្រូវបានបង្កើតឡើងដោយជនជាតិរុស្ស៊ី និងមានអ្នកប្រើប្រាស់ប្រចាំខែចំនួន ៧០០លាននាក់ នៅទូទាំងពិភពលោក)។

**TikTok៖** គឺជាកម្មវិធីចែករំលែកវីដេអូដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់បង្កើត និងចែករំលែកវីដេអូខ្លីៗ លើប្រធានបទណាមួយ។ វាជាចម្បងផ្អែកលើទូរស័ព្ទ ទោះបីជាអ្នកនៅតែអាចមើលវីដេអូ TikTok ដោយប្រើកម្មវិធីរបស់។ វេទិកាអនុញ្ញាតឱ្យអ្នកប្រើប្រាស់ទទួលបានការច្នៃប្រឌិតជាមួយនឹងខ្លឹមសាររបស់ពួកគេ ដោយប្រើតម្រង ស្ទីគ័រ ការបញ្ចេញសំឡេងបែបផែនសំឡេង និងតន្ត្រីផ្ទៃខាងក្រោយ។ មនុស្សជាង ៧០០ លាននាក់ ប្រើវាជារៀងរាល់ថ្ងៃ។

**Instagram៖** កម្មវិធីចែករំលែករូបថត និងវីដេអូឥតគិតថ្លៃ ដែលមាននៅលើ iPhone និង Android ។ មនុស្សអាចបង្ហោះរូបថត ឬវីដេអូ ហើយចែករំលែកជាមួយអ្នកតាមដានរបស់ពួកគេ ឬជាមួយក្រុមមិត្តភក្តិ

ដែលបានជ្រើសរើស។ ពួកគេក៏អាចផ្ញើសារទៅកាន់អ្នកប្រើប្រាស់ផ្សេងទៀត មើល ផ្តល់មតិ និងចូលចិត្តការបង្ហោះ ដែលចែករំលែកដោយមិត្តរបស់ពួកគេនៅលើ Instagram ផងដែរ។ បុគ្គលដែលមានអាយុចាប់ពី ១៣ឆ្នាំឡើងទៅអាចបង្កើតគណនីមួយដោយចុះឈ្មោះអាសយដ្ឋានអ៊ីម៉ែល និងជ្រើសរើសឈ្មោះអ្នកប្រើប្រាស់។

**YouTube៖** គឺជាគេហទំព័រចែករំលែកវីដេអូឥតគិតថ្លៃ ដែលធ្វើឱ្យវាងាយស្រួលក្នុងការមើលវីដេអូអនឡាញ។ អ្នកអាចបង្កើត និងបង្ហោះវីដេអូផ្ទាល់ខ្លួនរបស់អ្នក ដើម្បីចែករំលែកជាមួយអ្នកដទៃ។ YouTube ត្រូវបានគេបង្កើតឡើងដំបូងក្នុងឆ្នាំ ២០០៥ ពេលនេះ YouTube គឺជាគេហទំព័រដ៏ពេញនិយមបំផុតមួយនៅលើបណ្តាញអនឡាញ ដោយមានអ្នកចូលមើលវីដេអូប្រហែល ៦ពាន់លានម៉ោង ជារៀងរាល់ខែ។

**WhatsApp៖** គឺឥតគិតថ្លៃក្នុងការទាញយកកម្មវិធីផ្ញើសារសម្រាប់ស្មាតហ្វូន។WhatsAppប្រើអ៊ីនធឺណិតដើម្បីផ្ញើសារ រូបភាព អូឌីយ៉ូ ឬវីដេអូ។ សេវានេះគឺស្រដៀងគ្នាទៅនឹងសេវាផ្ញើសារជាអក្សរ ទោះជាយ៉ាងណា ដោយសារតែ WhatsApp ប្រើអ៊ីនធឺណិតដើម្បីផ្ញើសារ ការចំណាយនៃការប្រើប្រាស់ WhatsApp គឺតិចជាងច្រើន។អ្នកក៏អាចប្រើWhatsAppនៅលើកុំព្យូទ័រលើតុរបស់អ្នកផងដែរ។វាពេញនិយមសម្រាប់ក្មេងជំទង់ដោយសារតែលក្ខណៈពិសេសដូចជាការជជែកជាក្រុម សារជាសំឡេង និងការចែករំលែកទីតាំង។ (WhatsApp ត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនតែមួយដែលគ្រប់គ្រង Facebook) ។

**CapCut៖** គឺជាកម្មវិធីប្រើប្រាស់កាត់តរូបភាពវីដេអូ ហើយត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនដូចគ្នាជាមួយ TikTok។

**BIGO Live៖** គឺជាវេទិកាផ្សាយផ្ទាល់ដោយឥតគិតថ្លៃ (គ្រប់គ្រងដោយ Bigo Technology ដែលមានមូលដ្ឋាននៅប្រទេសសិង្ហបុរី) ដែលអនុញ្ញាតឱ្យអ្នកផ្សាយផ្ទាល់ មើលការផ្សាយផ្ទាល់ ហ្គេមបន្តផ្ទាល់ កម្មវិធីផ្សាយផ្ទាល់និងការជជែកជាវីដេអូតាមអ៊ីនធឺណិត។វាត្រូវបានប្រើច្រើនដោយអ្នកលេងហ្គេមហើយកម្មវិធីនេះតម្រូវឱ្យមានអាយុតិចបំផុត ១៦ឆ្នាំ ទើបអាចដើម្បីបង្កើតគណនីបាន។ ទោះជាយ៉ាងណាក៏ដោយ អ្នកប្រើប្រាស់វ័យក្មេងអាចបញ្ឆោតប្រព័ន្ធ AI ដើម្បីចូលបាន។

**Snapchat៖** គឺជាកម្មវិធីផ្ញើសារ និងបណ្តាញសង្គមឥតគិតថ្លៃសម្រាប់ស្មាតហ្វូន។ Snapchat អនុញ្ញាតឱ្យអ្នកផ្ញើសារជាអក្សរ រូបភាព និងវីដេអូខ្លីៗ ទៅកាន់មិត្តភក្តិ និងក្រុមគ្រួសារ។ អ្វីដែលធ្វើឱ្យ Snapchat មានតែមួយគត់ គឺថាសារទាំងនេះភាគច្រើនគឺបណ្តោះអាសន្ន។

**Discord៖** គឺជាកម្មវិធីជជែកជាសំឡេង វីដេអូ និងអត្ថបទ ដែលប្រើដោយមនុស្សរាប់សិបលាននាក់ដែលមានអាយុ ចាប់ពី ១៣ឆ្នាំឡើងទៅ ដើម្បីនិយាយ និងជជែកជាមួយសហគមន៍ និងមិត្តភក្តិរបស់ពួកគេ។

ឥឡូវនេះត្រូវបានគេហៅថាX:Xគឺជាឈ្មោះថ្មីរបស់ក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គមនិងវេទិកាដែលពីមុនត្រូវបានគេស្គាល់ថា **Twitter**។ វាគឺជាសេវាកម្មសម្រាប់មិត្តភក្តិ ក្រុមគ្រួសារ និងអ្នករួមការងារក្នុងការទំនាក់ទំនង និងរក្សាទំនាក់ទំនងតាមរយៈការផ្លាស់ប្តូរសាររហ័ស និងញឹកញាប់។ មនុស្សបង្ហោះសារដែលអាចមានរូបថត វីដេអូ តំណ និងអត្ថបទ សារទាំងនេះត្រូវបានបង្ហោះទៅកាន់ប្រវត្តិរូបរបស់អ្នកដែលបង្ហោះ ពួកវាត្រូវបានផ្ញើដោយស្វ័យប្រវត្តិទៅមនុស្ស ដែលតាមរយៈមនុស្សម្នាក់ ហើយអាចត្រូវបានរកឃើញដោយការស្វែងរកតាមអ៊ីនធឺណិត។



ឧបត្ថម្ភដោយ End Violence Against Children unicef for every child

## កម្មវិធីហ្គេមដែលប្រើច្រើនបំផុតក្នុងប្រទេសកម្ពុជា៖

**Mobile Legends-Bang Bang** គឺជាហ្គេមសង្គ្រាមប្រយុទ្ធតាមអ៊ីនធឺណិតចល័ត ( MOBA ) ដែលអ្នកលេងជាច្រើនអាចចូលលេងរួមគ្នាបាន។

**PUBG Mobile៖** គឺជាហ្គេម **Battle Royale** តាមអ៊ីនធឺណិតមានន័យថា វាជាហ្គេមរស់រានមានជីវិតនៅស្ទួលរបស់វា។ អ្នកលេងត្រូវការរស់រានមានជីវិតបានយូរបំផុត ខណៈពេលដែលការលុបបំបាត់អ្នកលេង ឬក្រុមផ្សេងទៀតដោយប្រើអាវុធ ដែលប្រមូលបានក្នុងអំឡុងពេលហ្គេម។

**Free Fire** ក៏ជាហ្គេម Battle Royale ដែលដាក់អ្នក ឬក្រុមតូចមួយទល់នឹងក្រុមអ្នកលេងធំៗផ្សេងទៀត។ អ្នកលេងម្នាក់ៗអាចទម្លាក់ពីលើឧទ្ធម្ភាគចក្រនៅលើផែនទីដ៏ធំមួយ ដែលអ្នកអាចស្វែងរកលួចអាវុធ ដើម្បីកំចាត់អ្នកលេងផ្សេងទៀត។

**Minecraft** គឺជាហ្គេម **Sandbox** ដែលអនុញ្ញាតឱ្យអ្នកលេងបង្កើតអ្វីៗដែលពួកគេអាចស្រមៃបាន។ វាជាហ្គេមដ៏ល្អសម្រាប់ការច្នៃប្រឌិត និងការដោះស្រាយបញ្ហា ហើយវាអាចលេងទោល ឬជាមួយមិត្តភក្តិ។ Minecraft គឺពេញនិយមសម្រាប់ក្មេងគ្រប់វ័យ ប៉ុន្តែវាពេញនិយមជាពិសេសជាមួយក្មេងៗ។

**Fortnite** គឺជាហ្គេម **Battle Royale** ដែលធ្វើអោយអ្នកលេងប៉ះគ្នាក្នុងការប្រយុទ្ធទៅកាន់បុរសចុងក្រោយដែលឈរ។ វាជាហ្គេមដែលមានល្បឿនលឿន និងគួរឱ្យរំភើប ដែលអាចមានភាពសប្បាយរីករាយជាច្រើនសម្រាប់ក្មេងចាស់ និងក្មេងជំទង់។ ទោះជាយ៉ាងណាក៏ដោយ វាក៏អាចមានអំពើហិង្សាផងដែរ ដូច្នេះហើយវាជារឿងសំខាន់សម្រាប់ឪពុកម្តាយក្នុងការយល់ដឹងអំពីខ្លឹមសារនេះ មុនពេលអនុញ្ញាតឱ្យកូនរបស់ពួកគេលេង។

# មេរៀនទី២

# របកគំហើញអំពីការកេងប្រវ័ញ្ច

## និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ

## លទ្ធផលរំពឹងទុក៖

អ្នកចូលរួមនឹង៖

- ឆ្លុះបញ្ចាំងចំណេះដឹងដែលមានស្រាប់អំពី OCSEA និងសិក្សាព័ត៌មានថ្មីៗដោយផ្អែកលើការស្រាវជ្រាវក្នុងប្រទេសកម្ពុជា
- ឆ្លុះបញ្ចាំងឥរិយាបថ និងជំនឿដែលមានស្រាប់
- ផ្សាភ្ជាប់ទៅនឹងចំណេះដឹងដែលមានស្រាប់អំពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ
- ការយល់ដឹងបន្ថែមពី អំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ

## កំណត់ចំណាំ៖

នៅក្នុងមេរៀនទី១ អ្នកចូលរួមបានឆ្លុះបញ្ចាំងអំពីការប្រើប្រាស់បច្ចេកវិទ្យាផ្ទាល់ខ្លួន ហើយចាប់ផ្ដើមស្វែងយល់អំពីពិភពនិមិត្តរបស់កុមារកម្ពុជា។ យើងបានរៀនថា វាមានសារៈសំខាន់ក្នុងការស្វែងយល់អំពីរបៀប ដែលកុមារប្រើប្រាស់ និងមានទំនាក់ទំនងជាមួយបច្ចេកវិទ្យាក្នុងជីវិតប្រចាំថ្ងៃ មុនពេលពួកគេប្រឈម ឬជួបប្រទះបទឧក្រិដ្ឋតាមប្រព័ន្ធអនឡាញ ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។ នៅក្នុងមេរៀននេះ យើងនឹងផ្ដោតលើអ្វីដែលត្រូវបានគេស្គាល់ថាជា «ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ»។ យើងចាប់ផ្ដើមដោយការសួរពួកគេ និងប្រមូលយកគំនិតពួកគេទាក់ទងនឹងអ្វីដែលពួកគេបានដឹងរួចហើយអំពី OCSEA ហើយធ្វើការស្វែងយល់អំពីឥរិយាបថ និងជំនឿមួយចំនួនរបស់ពួកគេ។

វាជាការសំខាន់ដែលយើងត្រូវធ្វើដូច្នេះ ព្រោះថាយើងមិនគួរធ្វើការសន្មតអំពីចំណេះដឹងដែលមានស្រាប់ទេ (ព្រោះថាយើងអាចធ្វើឱ្យអ្នកចូលរួមបាត់បង់ឱកាសសិក្សាអ្វីដែលសំខាន់)។ វាក៏មានប្រយោជន៍ក្នុងការផ្ដល់ឱកាសឱ្យអ្នកចូលរួមបានចូលរួមជាមួយយើង ជាជាងគ្រាន់តែប្រាប់ពួកគេអំពីអ្វីដែលយើងគិតថាពួកគេត្រូវតែដឹង។

មេរៀននេះអ្នកសម្របសម្រួលក៏អាចធ្វើការកត់សម្គាល់គំនិតដែលមានប្រយោជន៍ ចំណុចខ្លាំង ខ្សោយ ឬសូម្បីតែជំនឿ និងឥរិយាបថដែលបង្គ្រោះថ្នាក់ដែលអ្នកចូលរួមខ្លះអាចមាន មេរៀននេះមានសារៈសំខាន់យើងអាចបង្កើនភាពខ្លាំង និងដោះស្រាយជាមួយឥរិយាបទដែលបង្គ្រោះថ្នាក់នៅក្នុងការរៀននេះ)។ មេរៀននេះក៏បង្ហាញពីតម្រូវការរបស់អ្នកចូលរួម ដើម្បីឱ្យអ្នកសម្របសម្រួល អាចធ្វើការរៀបចំ វគ្គបណ្ដុះបណ្ដាលបន្តបន្ទាប់ឱ្យបានកាន់តែល្អប្រសើរ។


ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

មេរៀននេះក៏មានការធ្វើតេស្តដ៏សាមញ្ញមួយ ដែលអ្នកចូលរួមអាចផ្តល់ចម្លើយ «**ពិត**» ឬ «**មិនពិត**» (ជាអនាមិក ឬ មិនសរសេរឈ្មោះ) ទៅកាន់សំណួរ និងប្រធានបទមួយចំនួនទាក់ទងនឹង OCSEA នៅប្រទេសកម្ពុជា។ ដូច្នេះ ការធ្វើតេស្ត មានគោលបំណងចំនួនបី៖ (ក) វាជារបៀបដ៏រីករាយមួយ ដែលឱ្យអ្នកចូលរួមអាចចូលរួមក្នុងការរៀនអំពីការពិតសំខាន់ៗទាក់ទងនឹងOCSEA។ (ខ) វាអាចផ្តល់ឱកាសឱ្យអ្នកសម្របសម្រួលបានយល់ដឹងអំពីចំណេះដឹងដែលមានស្រាប់ និងតម្រូវការសិក្សាជាក់លាក់របស់អ្នកចូលរួម។ (គ) ប្រសិនបើប្រើវានៅខាងដើម និងចុងបញ្ចប់នៃវគ្គសិក្សា វាអាចប្រើជាការធ្វើតេស្តមុន និងក្រោយវគ្គបណ្តុះបណ្តាលបាន។

**ចំណាំ៖** បញ្ហា និងការពិត ដែលមាននៅក្នុងកម្រងសំណួរតេស្តនេះ គឺផ្អែកលើភស្តុតាងពីការស្រាវជ្រាវបញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា និងការអនុវត្តនៅក្នុងបរិបទប្រទេសកម្ពុជា ដែលបានសរសេរក្នុងខែមេសា ឆ្នាំ២០២៣។ ដូច្នេះខណៈដែលវាផ្តល់នូវរូបភាពត្រឹមត្រូវនៃបរិបទនៅពេលនេះ វាអាច និងគួរតែត្រូវបានកែប្រែជាប្រចាំ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរធម្មជាតិនៃពិភពនិមិត្តដែលយើងកំពុងរស់នៅ និងលក្ខណៈជាក់លាក់នៃ OCSEA។

## ធនធានដែលត្រូវការ៖

ឧបសម្ព័ន្ធ "ក" (ទំព័រ ៨៣) និងស្លាយ (ពីស្លាយ ៩)

### កំណត់ពន្យល់បន្ថែមសម្រាប់ការសម្របសម្រួល៖

- ធ្វើឱ្យប្រាកដថាអ្នកសម្របសម្រួលបានអានឧបសម្ព័ន្ធ «ក» **សន្លឹកកិច្ចការភ្ជាប់ជាមួយចម្លើយ** និងការពន្យល់បន្ថែម មុនពេលសម្របសម្រួលមេរៀននេះហើយពន្យល់ ចម្លើយពិតប្រាកដដែលមានក្នុងស្លាយមេរៀន។
- ស្វាគមន៍ក្រុម ចែករំលែកលទ្ធផលនៃការរំពឹងទុករបស់វគ្គបណ្តុះបណ្តាលដោយប្រើកំណត់ចំណាំនៅខាងលើ និងស្លាយ។ សូមពន្យល់ប្រាប់ពួកគេថា យើងនឹងប្រើប្រាស់សកម្មភាព និងធនធានផ្សេងៗ ដើម្បីសម្រេចបានលទ្ធផលទាំងនេះ។
- ចាប់ផ្តើមដោយសុំឱ្យក្រុមពិភាក្សា និងចែករំលែកគំនិតរបស់ពួកគេអំពីអ្វីដែលពួកគេបានដឹង ឬឮអំពី ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (ជាភាសាអង់គ្លេស យើងប្រើអក្សរកាត់ «OCSEA» ប៉ុន្តែសម្រាប់ភាសាខ្មែរ យើងប្រហែលមិនអាចប្រើអក្សរកាត់បានទេ)។

  អ្នកអាចធ្វើដូច្នេះបាន ដោយសុំពួកគេឱ្យពិភាក្សាគ្នាជាគូរយៈពេលពីរបីនាទី ហើយបន្ទាប់មកសុំពួកគេឱ្យចែករំលែកក្នុងក្រុម។ ការស្នើសុំពួកគេ


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

ឱ្យពិភាក្សាគ្នាជាគូអនុញ្ញាតឱ្យគ្រប់គ្នាមានឱកាសក្នុងការចែករំលែកគំនិតយោបល់របស់ពួកគេ។

គោលគំនិតនៃលំហាត់នេះ គឺដើម្បីប្រមូល (ឬទាញយក) គំនិតរបស់ពួកគេ។ នៅដំណាក់កាលនេះ វាមិនសំខាន់ក្នុងការផ្តល់មតិយោបល់ក្បោះក្បាយច្រើនពេកអំពីគំនិតដែលពួកគេចែករំលែក ឬនិយាយថាគំនិតរបស់ពួកគេ«ពិត»ឬ«មិនពិត»ព្រោះថានេះមិនមែនជាគោលបំណងនៃលំហាត់នេះទេ។

**ចំណុចពិភាក្សាសំខាន់ៗ ដើម្បីក្រុមធ្វើការឆ្លុះបញ្ចាំង មានដូចជា៖**

- តើ OCSEA មានន័យយ៉ាងដូចម្តេច?
- តើវាពាក់ព័ន្ធនឹងឥរិយាបថ ឬទង្វើអ្វីខ្លះ?
- តើវាកើតឡើងដោយរបៀបណា?
- តើអ្នកណាជាជនរងគ្រោះ ហើយអ្នកណាជាជនល្មើស?

- បន្ទាប់ពីពួកគេបានចំណាយពេលពីរបីនាទីដើម្បីពិភាក្សាហើយសុំពួកគេឱ្យចែករំលែកនៅក្នុងក្រុម។អ្នកអាចសរសេរគំនិតរបស់ពួកគេនៅលើក្រដាសផ្ទាំងធំ ឬក្តារខៀន ដូច្នេះមនុស្សទាំងអស់នៅក្នុងក្រុមអាចមើល ឃើញបាន។ វាអាស្រ័យលើចំណេះដឹង និងបទពិសោធន៍ ដែលមានស្រាប់របស់ក្រុម អ្នកអាចទទួលបានការឆ្លើយតបមួយចំនួន ដែលមានប្រយោជន៍ និង/ឬត្រឹមត្រូវ ហើយការឆ្លើយតបផ្សេងទៀតមិនសូវត្រឹមត្រូវប៉ុន្មានទេ។នៅដំណាក់កាលនេះវាមិនសូវសំខាន់ក្នុងការកែតម្រូវការឆ្លើយតបដែលមិនត្រឹមត្រូវទេព្រោះថាព័ត៌មានដែលត្រឹមត្រូវនឹងត្រូវផ្តល់ជូននៅក្នុងវគ្គបន្ទាប់។(ទុករយៈពេលច្រើននាទីសម្រាប់ការចែករំលែកនៅក្នុងក្រុមធំ)

- អនុញ្ញាតឱ្យក្រុមពិភាក្សាដោយសង្ខេបអំពីព័ត៌មានដែលពួកគេចែករំលែកប្រសិនបើពួកគេចង់ធ្វើដូច្នេះ។

  ពន្យល់ប្រាប់ពួកគេថាអ្នកនឹងមិនបញ្ចេញមតិលម្អិតនៅដំណាក់កាលនេះទេ ប្រសិនបើព័ត៌មានដែលពួកគេចែករំលែកវាត្រឹមត្រូវ និងជាការពិតហើយ ព្រោះយើងនឹងបន្តតាមដានព័ត៌មានទាំងនេះនៅវគ្គបន្ទាប់ទៀត។

  គោលបំណងនៃវគ្គនេះ គឺដើម្បីស្វែងយល់ និងកសាងអ្វីដែលក្រុមបានដឹងរួចហើយ។ ទុកក្រដាសផ្ទាំងធំនេះនៅលើជញ្ជាំងដូច្នេះអ្នកអាចត្រលប់ទៅមើលវាវិញ នៅពេលក្រោយប្រសិនបើអ្នកត្រូវការ។

- ពន្យល់ប្រាប់ក្រុមថា ឥឡូវនេះ អ្នកនឹងចែកសន្លឹកកម្រងសំនួរ ការធ្វើ

តេស្តទៅកាន់មនុស្សម្នាក់ៗនៅក្នុងក្រុម។វាគឺជាកម្រងសំណួរដែលពួកគេត្រូវឆ្លើយ «ពិត» ឬ «មិនពិត» អំពីប្រធានបទដែលពាក់ព័ន្ធនឹង OCSEA ដែលមាន ១៤សំនួរ។

- អ្នកចូលរួមម្នាក់ៗ ត្រូវឆ្លើយសំនួរទាំងនេះដោយខ្លួនឯង ដោយសម្ងាត់ ដោយមិនពិភាក្សា ឬមើលចម្លើយរបស់អ្នកដទៃឡើយ។

ទុកពេលប្រហែល ៧-១០នាទី ដើម្បីឱ្យមនុស្សគ្រប់គ្នានៅក្នុងក្រុមបំពេញសន្លឹកកម្រងសំនួរនេះ ដោយមិនដាក់ឈ្មោះ ហើយបន្ទាប់មកបត់វាជា ពីរ ហើយដាក់វានៅក្នុងប្រអប់មួយដែលផ្តល់ឱ្យពួកគេ។

ពេលពួកគេបានបំពេញវារួចរាល់ហើយក្នុងនាមជាអ្នកសម្របសម្រួលសូមសាប់សន្លឹកកម្រងសំនួរទាំងនេះ ហើយចែកវាទៅឱ្យមនុស្សនៅក្នុងក្រុមវិញ ដោយឱ្យមនុស្សម្នាក់ៗមានសន្លឹកកម្រងសំនួរណា ដែលមិនមែនជារបស់ពួកគេ។

- នៅលើផ្ទាំងក្រដាសធំ ឬក្តារខៀន សូមបង្កើតតារាងយ៉ាងសាមញ្ញមួយស្រដៀងគ្នានឹងតារាងខាងក្រោម។ សម្រាប់សំណួរនីមួយៗ សុំក្រុមឱ្យលើកដៃឡើង (ឧ. រាប់ចំនួនអ្នកដែលឆ្លើយថា «ពិត» និងចំនួនអ្នកដែលឆ្លើយថា «មិនពិត») ហើយសរសេរចំនួនសរុបទៅតាមជួរដែលពាក់ព័ន្ធ។

នេះជាឧទាហរណ៍នៃតារាងដែលអ្នកអាចគូរបាន៖

| លេខសំណួរ | ចំនួនអ្នកឆ្លើយ ថា «ពិត» | ចំនួនអ្នកឆ្លើយ ថា «មិនពិត» |
|---|---|---|
| ១ | ១១ | ១២ |
| ២ | ៥ | ១៨ |
| ៣ | ២២ | ១ |
| ៤ | ១៤ | ១៣ |

តាមរយៈការបំពេញតារាងសម្រាប់សំនួរទាំងអស់នេះ អ្នកអាចបង្ហាញ ពីភាពខុសគ្នា នៃការឆ្លើយតបរបស់មនុស្សម្នាក់ៗនៅក្នុងក្រុម ហើយដោយសារ ការបំពេញសន្លឹកកម្រងសំនួរនេះធ្វើឡើង ដោយមិនបានដាក់ឈ្មោះ ដូច្នេះគ្មានអ្នកចូលរួមណាម្នាក់នឹងមានអារម្មណ៍ខ្មាស់អៀនដោយសារចម្លើយមិនត្រឹមត្រូវរបស់ពួកគេទេ។ការពិនិត្យមើលចម្លើយរួមគ្នានេះគួរតែចំណាយពេលតែប៉ុន្មាននាទីតែប៉ុណ្ណោះ។

អ្នកអាចផ្តល់មតិយោបល់លើចម្លើយនីមួយៗ ដែលបង្ហាញពីភាពខុសគ្នា

នៃអ្នកអាចផ្តល់មតិយោបល់លើចម្លើយនីមួយៗ ដែលបង្ហាញពីភាពខុសគ្នានៃចម្លើយរបស់ពួកគេចំពោះសំនួរតែមួយដូចគ្នា។

- ពេលអ្នកបានបំពេញតារាងរួចរាល់ហើយ អ្នកអាចពិនិត្យមើលចម្លើយដែលត្រឹមត្រូវទាំងអស់ ដោយអានតាមចម្លើយនីមួយៗនៅលើសន្លឹកកិច្ចការដែលបានផ្តល់ឱ្យនិង/ឬប្រើស្លាយដែលមានព័ត៌មានត្រឹមត្រូវ(**ស្លាយទី ១០-២៣**)។ ស្លាយដែលបានរៀបចំរួចហើយ គ្រាន់តែប្រាប់ពីការពិតនៃចំណងជើង មិនប្រាប់ព័ត៌មានលម្អិតទេ (អ្នកអាចប្រើឯកសារចែកជូនដើម្បីពន្យល់ព័ត៌មានលម្អិត ប្រសិនបើអ្នកចង់ធ្វើដូច្នេះ)។

**ការធ្វើបែបនេះនឹងចំណាយពេលយ៉ាងហោចណាស់ ៣០នាទី**

អនុញ្ញាតឱ្យក្រុមផ្តល់មតិយោបល់ លើការឆ្លើយតបត្រឹមត្រូវនីមួយៗ ប្រសិនបើពួកគេចង់ធ្វើដូច្នេះ។ ពួកគេអាចនឹងភ្ញាក់ផ្អើលចំពោះព័ត៌មានមួយចំនួន?

ពន្យល់ប្រាប់ពួកគេថា ព័ត៌មាននេះនឹងត្រូវផ្តល់ជូននៅក្នុងឯកសារចែកជូន ហើយអាចនឹងមានប្រយោជន៍ ក្នុងការចែករំលែកឯកសារនេះ ជាមួយសហសេវិកនៅក្នុងការិយាល័យរបស់ពួកគេនិង/ឬនៅក្នុងការសន្ទនាជាមួយកុមារ និងយុវជន និងអាណាព្យាបាល ពេលពួកគេស្វែងរកការគាំទ្រដើម្បីដាក់ពាក្យបណ្តឹងទៅកាន់នគរបាល។

អ្នកក៏អាចសុំឱ្យក្រុមផ្តល់យោបល់ អំពីអត្ថប្រយោជន៍បន្ថែម នៃការមានព័ត៌មានត្រឹមត្រូវអំពី OCSEA នៅប្រទេសកម្ពុជាផងដែរ។

- ចែកសន្លឹកសំនួរចម្លើយទៅកាន់ក្រុម ហើយសុំពួកគេឱ្យរក្សាវាទុកដោយសុវត្ថិភាពសម្រាប់ជាឯកសារយោងរបស់ពួកគេ។

- ពន្យល់ពួកគេថាវគ្គនេះនឹងបញ្ចប់ក្នុងពេលឆាប់ៗនេះប៉ុន្តែសូមសួរក្រុមសិនថាតើពួកគេមានសំណួរអ្វីបន្ថែមទៀតទាក់ទងនឹង OCSEA ដែរឬទេ? បើមានសរសេរវានៅលើផ្ទាំងក្រដាសធំ។ អ្នកក៏អាចផ្តល់យោបល់អំពីភាពស្រដៀងគ្នា និងភាពខុសគ្នារវាងគំនិតរបស់ពួកគេ ដែលប្រមូលបានពីពេលមុន និងព័ត៌មានពិតផងដែរ។

ការសម្របសម្រួលសំនួរក៏អាចផ្តល់ឱ្យអ្នកនូវគំនិតបន្ថែមអំពីតម្រូវការសិក្សារបស់ក្រុម សូមប្រាកដថាអ្នកឆ្លើយតបទៅកាន់ពួកគេ ហើយបញ្ចូល វាទៅក្នុងវគ្គបណ្តុះបណ្តាលនៅពេលក្រោយ។

- បិទវគ្គនិងសម្រាករយៈពេលខ្លី។ពេលអ្នករៀបចំសម្រាប់វគ្គបន្ទាប់ដែលនឹងផ្តោតលើការចែករំលែកព័ត៌មានត្រឹមត្រូវ និងករណីសិក្សាអំពី OCSEA នៅប្រទេសកម្ពុជា។


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

## សកម្មភាព

### តើ OCSEA មានន័យយ៉ាងដូចម្តេច ?

សាកសួរទៅក្រុមទាំងមូលដើម្បីឱ្យពួកគេមានយោបល់ OCSEA ? អញ្ជើញអ្នកស្ម័គ្រចិត្តឱ្យចែករំលែកនូវអ្វីដែលពួកគេបានដឹងឬបានឮនិងអាចទៅជាកន្លែងដែលពួកគេបានរៀន ឬ បានឮ អំពីរឿងនេះ។ ពន្យល់ថាមេរៀនបន្ទាប់នឹងស៊ីជម្រៅបន្ថែមទៀតអំពី និងកំណត់ OCSEA។

### តើវាពាក់ព័ន្ធនឹងអាកប្បកិរិយា ឬសកម្មភាពអ្វីខ្លះ ?

សួរក្រុមថាតើពួកគេដឹងអ្វីខ្លះអំពីទង្វើ ឬអាកប្បកិរិយា ដែលអាចពាក់ព័ន្ធនឹង OCSEA ហើយទទួលយកការឆ្លើយតប និងយោបល់របស់ពួកគេមួយចំនួន។

(នេះអាចផ្អែកលើសិក្ខាសាលាឬព្រឹត្តិការណ៍សិក្សាផ្សេងទៀតដែលពួកគេបានចូលរួមនិយាយជាមួយសហសេវិកអំពីករណី ការអានឯកសារ និង/ឬធ្វើការលើករណី។ សុំឱ្យពួកគេចែករំលែកបទពិសោធន៍របស់ពួកគេអំពីអ្វីដែលពួកគេដឹងនិងកន្លែងដែលពួកគេបានឮអំពីវា)។ពន្យល់ថាមេរៀនបន្ទាប់នឹងស៊ីជម្រៅបន្ថែមទៀត អំពីការកំណត់ និងចែករំលែកឧទាហរណ៍ជាក់ស្តែង នៃអំពើឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនៅក្នុង OCSEA។

### តើវាកើតឡើងដោយរបៀបណា ?

ដូចទៅនឹងសំណួរខាងលើដែរ សួរអ្វីដែលពួកគេដឹងអំពីរបៀបដែល OCSEA អាចកើតឡើង។ គោលបំណងនៃការសន្ទនា គឺដើម្បីទាញយកគំនិតពីក្រុមលើចំណេះដឹងការងារ និងបទពិសោធន៍ប្រតិបត្តិការ និងការរៀនសូត្រដែលមានស្រាប់របស់ពួកគេ។ មនុស្សមួយចំនួននៅក្នុងក្រុមអាចមានបទពិសោធន៍ច្រើនជាងអ្នកផ្សេងទៀត ប៉ុន្តែព្យាយាមលើកទឹកចិត្តឱ្យមានការឆ្លើយតបជាច្រើន។ ពន្យល់ថាមេរៀនបន្ទាប់នឹងចូលកាន់តែស៊ីជម្រៅអំពីរបៀបដែល OCSEA កើតឡើងដោយផ្អែកលើករណីជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា។

### តើអ្នកណាជាជនរងគ្រោះ ហើយអ្នកណាជាជនល្មើស ?

ដូចទៅនឹងសំណួរខាងលើសួរថាតើពួកគេដឹងអ្វីខ្លះអំពីជនរងគ្រោះនៃ OCSEA អាចជានរណា ហើយពួកគេគិតថាជនល្មើសអាចជានរណា។

ឧទាហរណ៍៖ តាមគំនិតរបស់ពួកគេ តើជនរងគ្រោះភាគច្រើនជាស្ត្រី ? តើជនរងគ្រោះមានអាយុប៉ុន្មាន ? តើជនល្មើសទំនងជាមនុស្សចម្លែក ឬស្គាល់បុគ្គលនោះ ? តើជនល្មើសទំនងជាជនជាតិខ្មែរ ឬបរទេស ?

គោលបំណងនៃការសន្ទនា គឺដើម្បីទាញយកគំនិតពីក្រុមលើចំណេះដឹងការងារ និងបទពិសោធន៍ប្រតិបត្តិការ និងការរៀនសូត្រដែលមានស្រាប់របស់ពួក

គេ។ មនុស្សមួយចំនួននៅក្នុងក្រុមអាចមានបទពិសោធន៍ច្រើនជាងអ្នកផ្សេងទៀត ប៉ុន្តែព្យាយាមលើកទឹកចិត្តឱ្យមានការឆ្លើយតបជាច្រើន។

ពន្យល់ថាមេរៀនបន្ទាប់នឹងស៊ីជម្រៅបន្ថែមទៀត អំពីរបៀបដែលជនរងគ្រោះ និងជនល្មើសនៃ OCSEA នៅក្នុងមេរៀនបន្ទាប់ ហើយនេះនឹងផ្តែកលើករណីជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា។

### ហានិភ័យ និងភាពងាយរងគ្រោះ ?

ពន្យល់ក្រុមថា វាអាចមានប្រយោជន៍ក្នុងការដឹងអំពីកត្តាហានិភ័យ និងភាពងាយរងគ្រោះទាក់ទងនឹងកុមារទៅនឹង OCSEA ដើម្បីការពារពួកគេ។ សួរថាតើក្រុមណាខ្លះ ដែលគេគិតថាងាយរងគ្រោះបំផុតពី OCSEA នៅកម្ពុជា ? តើពួកគេដឹងអ្វីខ្លះអំពីប្រភេទនៃហានិភ័យ ដែលមនុស្សប្រឈមមុខនៅពេលពួកគេប្រើប្រាស់អ៊ីនធឺណិត ? (នេះអាចផ្អែកលើចំណេះដឹង និងបទពិសោធន៍ ដែលមានស្រាប់របស់ពួកគេអំពីករណី ដែលបានធ្វើការ ឬការសិក្សាពីមុន)។

នៅចំណុចនេះក្នុងវគ្គបណ្តុះបណ្តាលវាមិនមានសារៈសំខាន់ខ្លាំងទេប្រសិនបើពួកគេនិយាយត្រូវឬខុសអំពីរឿងនេះដោយសារមេរៀននេះត្រូវបានរៀបចំឡើងដើម្បីឱ្យអ្នកចូលរួមនិយាយអំពីគំនិត និងចំណេះដឹងដែលមានស្រាប់របស់ពួកគេ។ ពន្យល់ថាមេរៀនបន្ទាប់នឹងផ្តល់ព័ត៌មានលម្អិតបន្ថែមអំពីហានិភ័យ និងភាពងាយរងគ្រោះ។

### ខ្លឹមសារគន្លឹះ និងសកម្មភាពតស៊ូមតិ

- ការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាបង្ហាញថា កុមារដែលប្រើអ៊ីនធឺណិតមាន ១១% ដែលមានអាយុពីចន្លោះពី ១២ឆ្នាំ ដល់ ១៧ឆ្នាំ ត្រូវបានជួបប្រទះនូវការកេងប្រវ័ញ្ចផ្លូវភេទនិងការរំលោភបំពានតាមអនឡាញនៅក្នុងឆ្នាំមុន។ បើគិតជាចំនួនប្រជាជន មានន័យថាមានកុមារ ១៦០,០០០នាក់អាចនឹងរងផលប៉ះពាល់។
- ជនល្មើសជាច្រើនគឺជាមនុស្សដែលកុមារស្គាល់ រួមទាំងគ្រួសារផងដែរ។ ការនេះ គឺជាឧបសគ្គចំពោះការរាយការណ៍។
- ជនរងគ្រោះមានទាំងក្មេងប្រុស និងក្មេងស្រី។
- តាមរយៈការស្ទង់មតិពីគ្រួសារ ក្នុងចំណោមក្មេងអាយុពី ១២ឆ្នាំ ដល់ ១៧ឆ្នាំ ដែលប្រើអ៊ីនធឺណិត ក្មេងប្រុសត្រូវបានគេរាយការណ៍ច្រើនជាងក្មេងស្រីបានរងគ្រោះទទួលរងនូវអំពើកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ គ្រប់ទម្រង់ដែលបានស៊ើបអង្កេត។
- ផលប៉ះពាល់ជាច្រើនគឺដូចគ្នាទៅនឹងផលប៉ះពាល់ ដែលកើតចេញពីការ

រំលោភបំពានលើបុគ្គលដែរ។

- OCSEA ជាច្រើនក៏មានការពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារក្រៅប្រព័ន្ធអនឡាញផងដែរ។
- នេះក៏អាចរាប់បញ្ចូលទាំងការធ្លាក់ទឹកចិត្ត ការធ្វើបាបខ្លួនឯង ការថប់បារម្ភ រោគសញ្ញា ដែលទាក់ទងនឹងជំងឺស្ត្រេសក្រោយការប៉ះទង្គិចផ្លូវចិត្ត និងការពិបាកក្នុងការជឿជាក់លើអ្នកដទៃ។
- វាមិនងាយស្រួលទេ ក្នុងការរាយការណ៍ អំពីទម្រង់អំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញទៅកាន់នរណាម្នាក់។
- មានឧបសគ្គជាច្រើនក្នុងការរាយការណ៍រួមទាំងកង្វះចំណេះដឹងអំពីរបៀបរាយការណ៍ និងរាយការណ៍ពីណាទៅណា កង្វះទំនុកចិត្ត និងមិនដឹងថាអ្នកណាមានសុវត្ថិភាពក្នុងការប្រាប់ ឬរាយការណ៍ទេ។
- នៅពេលដែលកុមារជួបមន្ត្រីនគរបាលសម្រាប់ការសម្ភាស វាមានសារៈសំខាន់ខ្លាំងណាស់ប្រសិនបើនគរបាលសម្ភាសន៍ជាបុរសឬស្ត្រីហើយត្រូវប្រាកដថាបរិស្ថានមានសុវត្ថិភាពសម្រាប់ពួកគេការផ្តល់ឱ្យពួកគេនូវជម្រើស ធ្វើឱ្យពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព ហើយនឹងជួយឱ្យពួកគេមានទំនុក ចិត្តកាន់តែច្រើន ដើម្បីអាចនិយាយ និងធ្វើសេចក្តីថ្លែងការណ៍បាន។

មេរៀនទី៣

# ចរិតលក្ខណៈ វិសាលភាព និងផលប៉ះពាល់កុមារ

## លទ្ធផលរំពឹងទុក៖

អ្នកចូលរួមនឹង៖

- កំណត់បានយ៉ាងច្បាស់លាស់នូវសកម្មភាពដែលត្រូវបានចាត់ទុកថាជា OCSEA។
- ស្វែងយល់ពីទំនាក់ទំនងរវាងការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានលើកុមារតាមប្រព័ន្ធអនឡាញ (OCSEA) និងក្រៅប្រព័ន្ធអនឡាញ (CSEA)។
- ចាប់ផ្តើមស្វែងយល់អំពីហានិភ័យ ភាពងាយរងគ្រោះ និងមូលហេតុដែល OCSEA កើតឡើង។

## កំណត់ចំណាំ៖

នៅក្នុងពីរមេរៀនដំបូងអ្នកចូលរួមបានឆ្លុះបញ្ចាំងពីការប្រើប្រាស់អ៊ីនធឺណិតផ្ទាល់ខ្លួនរបស់ពួកគេបានទទួលការណែនាំឱ្យចូលទៅកាន់ពិភពឌីជីថលដែលកុមារនិងយុវជនកំពុងប្រើប្រាស់និងស្វែងយល់អំពីគំនិតផ្ទាល់ខ្លួនរបស់ពួកគេអំពីអ្វីដែលពួកគេបានដឹងអំពី OCSEA។ ការនេះផ្តល់នូវមូលដ្ឋានគ្រឹះនៃចំណេះដឹង ដែលអ្នកចូលរួមអាចស្វែងយល់បន្ថែមបាន។

នៅក្នុងការវាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាល (TNA) អ្នកចូលរួមមានសំណួរជាច្រើនអំពី OCSEA។ ពួកគេចង់ដឹងបន្ថែមទៀតថា អ្វីទៅជា OCSEA? តើវាមានលក្ខណៈយ៉ាងដូចម្តេច? របៀបដែលគេប្រព្រឹត្ត? អ្នកណាជាអ្នកប្រព្រឹត្ត? អ្នកណាជាជនរងគ្រោះ? តើមានផលប៉ះពាល់អ្វីខ្លះដល់កុមារ និងគ្រួសារ? ពីរបីមេរៀនបន្ទាប់ទៀតនឹងឆ្លើយតបដោយផ្ទាល់ទៅនឹងចម្លើយនៃសំណួរទាំងនេះ។

ដូច្នេះវគ្គនេះ ចាប់ផ្តើមដោយផ្តោតការយកចិត្តទុកដាក់លើបញ្ហា OCSEA ដើម្បីឱ្យអ្នកចូលរួមអាចមើលឃើញដំណើររឿង និងបទពិសោធន៍ [ពិត] របស់មនុស្សពេញវ័យ កុមារ និងអាណាព្យាបាល។ យើងធ្វើដូច្នេះដោយចែករំលែកអំពីនិយមន័យទូទៅ និងការពិពណ៌នាអំពីទង្វើ និងឥរិយាបថ ដែលទាក់ទងនឹង OCSEA (ផ្អែកលើរបាយការណ៍បញ្ជប់គ្រោះថ្នាក់នៅប្រទេសកម្ពុជា) ហើយនៅមេរៀនបន្ទាប់ទៀត យើងនឹងចែករំលែកករណីសិក្សាដោយផ្អែកលើសាច់រឿងពិតរបស់កុមារក្នុងនៅប្រទេសកម្ពុជា។

ករណីសិក្សានឹងជួយអ្នកចូលរួមឱ្យយល់ពីរបៀប OCSEA បានកើតឡើង បច្ចេកវិទ្យា និងកម្មវិធីអ្វីខ្លះ ដែលគេប្រើប្រាស់ ហើយក៏ជួយអ្នកសិក្សាឱ្យយល់ពីបញ្ហាមួយចំនួនទាក់ទងនឹងភាពងាយរងគ្រោះ ហានិភ័យ និងរបៀបដែលវាប៉ះពាល់ដល់កុមារនិងយុវជនផងដែរ។(បញ្ហាទាក់ទងនឹងហានិភ័យភាពងាយរងគ្រោះនិងផលប៉ះពាល់

នៃ OCSEA ក៏នឹងត្រូវបញ្ជាក់បន្ថែមនៅក្នុងវគ្គផ្សេងទៀតផងដែរ)។ ករណីសិក្សាត្រូវបានរៀបចំឡើងដោយមានមុខងារច្រើនយ៉ាង ហើយនៅវគ្គក្រោយៗទៀត គេនឹងប្រើវាដើម្បីគាំទ្រដល់ការរៀនសូត្រក្នុងការឆ្លើយតប និងការគាំទ្រកុមារតាមនីតិវិធីដែលមានស្រាប់ ហើយក៏បញ្ជាក់អំពីការអនុវត្តបែបកុមារមេត្រីផងដែរ។

នៅក្នុងសិក្ខាសាលា TNA ដែលមានការចូលរួមដោយមន្ត្រីនគរបាល AHTJP និង ACD មានអ្នកចូលរួមជាច្រើននាក់ បានស្នើសុំការបំភ្លឺបន្ថែមអំពីរបៀបដែលការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ (CSEA) ទាក់ ទងនឹង OCSEA ព្រមទាំងភាពខុសគ្នា និងភាពស្រដៀងគ្នារវាង OCSEA និង CSEA។ ដូច្នេះវគ្គនេះនឹងរួមបញ្ចូលព័ត៌មានដែលឆ្លើយតបទៅនឹងសំណើទាំងនេះ។

## ធនធានដែលត្រូវការ៖

ឧបសម្ព័ន្ធ "ខ" (ទំព័រ ៩១) "ខ១" (ទំព័រ ៩៥) និង "ខ២" (ទំព័រ ១០០) និងស្លាយ (ពីស្លាយ ២៤)

### កំណត់ពន្យល់បន្ថែមសម្រាប់ការសម្របសម្រួល៖

១. កំណត់ចំណាំពិសេសសម្រាប់អ្នកសម្របសម្រួល៖ ត្រូវប្រាកដថាអ្នកបានអានផែនការមេរៀន ឯកសារចែកជូន និងករណីសិក្សាទាំងអស់ឱ្យបានលម្អិតជាផ្នែកនៃការរៀបចំរបស់អ្នកសម្រាប់មេរៀននេះ។វានឹងផ្តល់ឱ្យអ្នកនូវព័ត៌មានដែលពាក់ព័ន្ធ ដើម្បីជួយអ្នកចូលរួមក្នុងការសិក្សាប្រកបដោយប្រសិទ្ធភាពនិងសម្រាប់អ្នកក្នុងការឆ្លើយតបទៅនឹងសំនួរដែលពួកគេអាចសួរបាន។

២. ស្វាគមន៍ក្រុម និងចែករំលែកអំពីលទ្ធផលនៃការរំពឹងទុកចេញពីវគ្គនេះ ដោយប្រើកំណត់ចំណាំនៅខាងលើ និងស្លាយ។ សូមពន្យល់ប្រាប់ពួកគេថា យើងនឹងប្រើប្រាស់សកម្មភាព និងធនធានផ្សេងៗ ដើម្បីទទួលបានលទ្ធផលនៃការរំពឹងទុកនេះ។

៣. រំលឹកក្រុមថា កាលពីវគ្គមុនពួកគេត្រូវបានស្នើសុំឱ្យធ្វើការឆ្លុះបញ្ចាំង អំពីគំនិតរបស់ពួកគេទាក់ទងនឹង OCSEA និងពិពណ៌នាអំពីអត្ថន័យរបស់ OCSEAមានឥរិយាបថឬសកម្មភាពអ្វីខ្លះដែលជាប់ពាក់ព័ន្ធរបៀបដែលវាកើតឡើង ហើយអ្នកណាជាជនរងគ្រោះ និងជនល្មើស។

សូមពន្យល់ប្រាប់ពួកគេថា គំនិតជាច្រើនរបស់ពួកគេមានប្រយោជន៍ខ្លាំងណាស់ ហើយឥឡូវនេះយើងនឹងស្វែងយល់បន្ថែមអំពី OCSEA ដោយផ្អែកលើការស្រាវជ្រាវក្នុងប្រទេសកម្ពុជា។

៤. ពន្យល់ប្រាប់ពួកគេថា ជាដំបូងអ្នកនឹងរំលឹកក្រុមអំពីនិយមន័យនៃពាក្យ



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

«ការរំលោភបំពានផ្លូវភេទកុមារ CSA » និង «ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ CSE »។

៥. ឥឡូវនេះ សូមពន្យល់ប្រាប់ក្រុមថា អ្នកនឹងចែករំលែកការពិពណ៌នាអំពីអ្វីដែលត្រូវបានគេចាត់ទុកថាជា OCSEA ដោយប្រើស្លាយដែលបានផ្តល់ឱ្យដែលជាព័ត៌មានដូចគ្នាដែលមាននៅលើ**ឧបសម្ព័ន្ធឧទាហរណ៍របស់ OCSEA**។

ដោយប្រើស្លាយ សូមនិយាយអំពីសកម្មភាព និងឥរិយាបថរបស់ OCSEA នីមួយៗ ដោយពន្យល់យ៉ាងច្បាស់ពីអត្ថន័យរបស់វា ដោយប្រើកំណត់ចំណាំដែលមាននៅលើសន្លឹកធនធាន។ អ្នកក៏អាចប្រើឧទាហរណ៍ពីការងាររបស់អ្នក ដើម្បីជួយពន្យល់ពីសាច់រឿងជាក់លាក់ណាមួយផងដែរ។

ទុកពេលច្រើនសម្រាប់ការចែករំលែកនិងការពន្យល់ដោយអនុញ្ញាតឱ្យក្រុមសួរសំនួរ និងបញ្ជាក់អត្ថន័យនៃទង្វើ និងឥរិយាបថនីមួយៗ។

៦. ស្វាគមន៍ក្រុមត្រឡប់មកវិញហើយពន្យល់ប្រាប់ពួកគេថាដើម្បីស្វែងយល់បន្ថែមអំពី OCSEA និងប្រភេទនៃសកម្មភាព និងឥរិយាបថដែលពាក់ព័ន្ធនឹងវា អ្នកនឹងចែករំលែក**ឧបសម្ព័ន្ធ ៦៣ ជាករណីសិក្សា**ជាបន្តបន្ទាប់ដែលផ្អែកលើករណីពិត និងព្រឹត្តិការណ៍ពិតក្នុងប្រទេសកម្ពុជា។

អាស្រ័យលើទំហំក្រុម សូមបំបែកក្រុមធំទៅជាក្រុមតូចៗដែលមានអ្នកចូលរួមចំនួន ៣, ៤ ឬ ៥នាក់។

៧. ពន្យល់ប្រាប់ក្រុមថាភារកិច្ចរបស់ពួកគេ គឺត្រូវអង្គុយជាមួយគ្នា ហើយពិភាក្សាករណីសិក្សានីមួយៗ ហើយរៀបចំបទបង្ហាញដល់ក្រុមដទៃទៀត ដូច្នេះពួកគេអាចចែករំលែកការពិតសំខាន់ៗនៃករណីនីមួយៗ។

ទុកពេលច្រើនដើម្បីឱ្យពួកគេអាន សង្ខេប និងរៀបចំបទបង្ហាញរបស់ពួកគេ។ ការធ្វើបែបនេះអាចត្រូវការពេលពី ៣០-៤៥ នាទី។

ពន្យល់ប្រាប់ពួកគេថា ពួកគេអាចប្រើផ្ទាំងក្រដាស ហើយអាចបង្កើតផ្ទាំងរូបភាពផងដែរ ប្រសិនបើពួកគេចង់ធ្វើដូច្នេះ ហើយវាជួយដល់ការពន្យល់ករណីសិក្សានេះដល់ក្រុមដទៃទៀត។

**នៅក្នុងបទបង្ហាញខ្លីរបស់ពួកគេសូមពន្យល់ប្រាប់ពួកគេថាពួកគេត្រូវបានស្នើសុំឱ្យធ្វើដូចខាងក្រោម៖**

៨. ពណ៌នាអំពីតួអង្គសំខាន់ៗ និងសាច់រឿងចម្បងក្នុងករណីសិក្សា

៩. គូសបញ្ជាក់ថា ករណីនេះកើតឡើង **តាមប្រព័ន្ធអនឡាញ/ក្រៅប្រព័ន្ធអនឡាញ** ប្រសិនបើមាន។

១០. ចែករំលែកព័ត៌មានបន្ថែមអំពីរបៀបដែលព្រឹត្តិការណ៍នេះបានប៉ះពាល់ដល់កុមារ និងគ្រួសារ (ប្រសិនបើព័ត៌មាននេះមាននៅក្នុងករណីសិក្សា)។

១១. បញ្ចេញមតិយោបល់អំពីបញ្ហាណាមួយដែលគួរឱ្យចាប់អារម្មណ៍ ឬ ថ្មីសម្រាប់ពួកគេ។

១២. បញ្ចេញមតិយោបល់អំពីបញ្ហាណាមួយ ដែលធ្វើឱ្យមានការភ័ន្តច្រឡំ ឬពិបាកសម្រាប់ពួកគេក្នុងនាមពួកគេជាមន្ត្រីនគរបាល។

១៣. អនុញ្ញាតឱ្យក្រុមដទៃទៀត សួរសំនួរបន្ថែម (ពន្យល់ប្រាប់អ្នកចូលរួមទាំងអស់ថា ពេលក្រុមផ្សេងទៀតកំពុងធ្វើបទបង្ហាញ ពួកគេក៏នឹងត្រូវបានស្នើសុំឱ្យយកចិត្តទុកដាក់ និងសួរសំនួរដែលពាក់ព័ន្ធផងដែរ)។

១៤. ពេលដែល ក្រុមទាំងអស់មានឱកាសចែករំលែកបទបង្ហាញរបស់ពួកគេ ហើយពួកគេនឹងបានដឹងពីករណី និងសាច់រឿងជាច្រើនដែលទាក់ទងនឹង OCSEA ហើយទទួលបានគំនិតកាន់តែច្រើនថែមទៀតអំពីបញ្ហា និងការលំបាកដែលជនរងគ្រោះកំពុងប្រឈម។

ក្រុមអាចមានសំណួរបន្ថែមទៀតអំពី OCSEA ដែលអ្នកអាចកត់ត្រាវាទុកក្នុងផ្ទាំងក្រដាសធំ ឬក្ដារខៀន ដើម្បីដោះស្រាយវានៅពេលក្រោយ។

១៥. ចែកសៀវភៅជាមួយករណីសិក្សាទាំងអស់ដល់ក្រុម ហើយពន្យល់ប្រាប់ពួកគេថា សៀវភៅ និងករណីសិក្សាទាំងនេះ គឺដើម្បីឱ្យពួកគេប្រើប្រាស់ជាឯកសារយោងបន្ថែម ព្រោះយើងនឹងប្រើប្រាស់វានៅក្នុងវគ្គបន្ទាប់ ដើម្បីពិចារណាបញ្ហាផ្លូវច្បាប់ ការឆ្លើយតបរបស់នគរបាល និងការអនុវត្តបែបកុមារមេត្រី។

ស្នើទៅកាន់ក្រុមថា វានឹងមានប្រយោជន៍សម្រាប់ពួកគេក្នុងការដែលពួកគេអានករណីសិក្សាទាំងអស់ជាមុនសម្រាប់វគ្គបន្ទាប់ទៀត ប្រសិនបើពួកគេអាចធ្វើទៅបាន។

## សកម្មភាព

១. សួរក្រុមថាតើពួកគេអាចចងចាំពីការបណ្ដុះបណ្ដាលជាមូលដ្ឋានរបស់ពួកគេ តើនិយមន័យនៃការរំលោភបំពានផ្លូវភេទលើកុមារ CSA គឺជាអ្វី និងសកម្មភាពអ្វីខ្លះដែលត្រូវបានគេចាត់ទុកថាជាCSA។ទទួលយកការឆ្លើយតបមួយចំនួនពីក្រុម។ នៅពេលដែលអ្នកពេញចិត្តនឹងការឆ្លើយតប របស់ពួកគេ សូមសួរក្រុមថាតើសកម្មភាព ឬអាកប្បកិរិយាបែបណាខ្លះដែលត្រូវបានចាត់ទុកថាជាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ CSE។ នេះប្រហែលជាពិបាកបន្តិចសម្រាប់ពួកគេក្នុងការពន្យល់ឬបញ្ចេញមតិប៉ុន្តែសូមទទួលយកការឆ្លើយតបមួយចំនួនពីក្រុម។


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

២. បង្ហាញស្លាយដែលមាននិយមន័យនៃពាក្យ CSA និង CSE ទៅកាន់ក្រុមជាការរំលឹកឡើងវិញ សូមប្រាកដថាក្រុមទទួលបានការយល់ដឹងច្បាស់លាស់។ អ្នកក៏អាចចែករំលែកច្បាប់ចម្លងនៃ**ឧបសម្ព័ន្ធ ខ១** ដើម្បីឱ្យពួកគេរក្សាទុកសម្រាប់ជាឯកសារយោងបន្ថែម។ បញ្ជាក់ប្រាប់ក្រុមថា និយមន័យដែលបានចែករំលែកនៅទីនេះពិពណ៌នាអំពីសកម្មភាពនិងឥរិយាបថជាច្រើន ប៉ុន្តែប្រហែលជាមិនដូចគ្នាទាំងស្រុងទៅនឹងការពិពណ៌នានៅក្នុងច្បាប់ប្រទេសកម្ពុជាទេ។ សកម្មភាពផ្លូវច្បាប់នឹងត្រូវចែករំលែក និងបញ្ជាក់នៅក្នុងវគ្គបន្ទាប់ទៀត។

៣. ចែកករណីសិក្សាផ្សេងៗដល់ក្រុមនីមួយៗ៖ ត្រូវប្រាកដថាគំរូផ្សេងគ្នានៃឥរិយាបថ និងទង្វើគ្រប់ប្រភេទត្រូវបានចែកដល់ពួកគេ។ ឧទាហរណ៍៖

**ក្រុម ១៖** ករណីសិក្សាចំនួនពីរ (ក) ជាប់ទាក់ទងនឹងការមាន CSAM, (ខ) ការលួងលោមតាមប្រព័ន្ធអនឡាញក្នុងគោលបំណងទាក់ទងនឹងផ្លូវភេទ

**ក្រុម ២៖** ករណីសិក្សាចំនួនពីរ (**គ និង ឃ**)ការចែករំលែក CSAM (គ)ការផ្សាយបន្តផ្ទាល់

**ក្រុម ៣៖** ករណីសិក្សាចំនួនពីរ (**ច**)ការបៀតបៀនផ្លូវភេទ (**ង**)ការចែករំលែកខ្លឹមសារផ្លូវភេទដែលបង្កើតដោយខ្លួនឯង

៤. អញ្ជើញតំណាងក្រុមនីមួយៗដើម្បីផ្តល់បទបង្ហាញដល់ក្រុមដទៃបន្ទាប់ពីការងារក្រុមរបស់ពួកគេបានបញ្ចប់

៥. ស្នើទៅក្រុមថា វានឹងមានប្រយោជន៍សម្រាប់ពួកគេក្នុងការអានករណីសិក្សាទាំងអស់ជាមុននៃវគ្គបន្ទាប់ ប្រសិនបើអាចធ្វើទៅបាន

## ខ្លឹមសារគន្លឹះ និងសកម្មភាពតស៊ូមតិ



- OCSEA អាចកើតឡើងយ៉ាងពេញលេញ (ឬទាំងស្រុង) តាមអ៊ីនធឺណិត (មិនមានទំនាក់ទំនងរាងកាយ ឬការជួបក្រៅបណ្តាញរវាងជនល្មើស និងជនរងគ្រោះ)
- ប៉ុន្តែវាក៏អាចជាការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ ដែលកើតឡើងក្រៅប្រព័ន្ធអនឡាញ-ប៉ុន្តែត្រូវបានសម្របសម្រួលដោយបច្ចេកវិទ្យាឌីជីថល។(ឧ.ការលួងលោមតាមប្រព័ន្ធអ៊ីនធឺណិត-បន្ទាប់មកបំពាននៅក្រៅប្រព័ន្ធអនឡាញ)
- ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ដែលត្រូវបានប្រព្រឹត្តក្រៅប្រព័ន្ធអនឡាញ ក៏អាចទៅជាក្នុងប្រព័ន្ធអនឡាញដែរ នៅពេលដែលរូបភាព ឬវីដេអូ នៃការរំលោភបំពានត្រូវបានចែករំលែកតាមប្រព័ន្ធអនឡាញ។

- ការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាយើងខណៈពេលដែលករណីទាំងអស់នៃ OCSEA រួមបញ្ចូលធាតុផ្សំ ការកេងប្រវ័ញ្ច និងការរំលោភបំពាន អាចកើតឡើងតាមអនឡាញហើយជារឿយៗកើតឡើងនៅចំណុចជាច្រើននៅជាប់គ្នារវាងអនឡាញ និងក្រៅអនឡាញ។
- ដូច្នេះ មានន័យថា ការរំលោភបំពាន និងការកេងប្រវ័ញ្ចណាមួយអាចផ្លាស់ប្តូរពីអនឡាញ និងក្រៅអនឡាញ នៅចំណុចផ្សេងៗគ្នាតាមពេលវេលា។

ក្នុងនាមជាមន្ត្រីនគរបាលដែលកំពុងស៊ើបអង្កេត និងគាំទ្រកុមារ ដែលរងផលប៉ះពាល់ដោយ OCSEA ដូច្នេះ អ្នកនឹងត្រូវស្វែងយល់ពីរបៀបដែលការរំលោភបំពាននិងការកេងប្រវ័ញ្ចបានកើតឡើងដោយពិចារណាថាតើធាតុផ្សំណាមួយកើតឡើងក្នុង ឬក្រៅប្រព័ន្ធអនឡាញ។

# មេរៀនទី៤

# មាត្រាច្បាប់ ពាក់ព័ន្ធនឹងអំពើកេងប្រវ័ញ្ច

## និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ

## លទ្ធផលរំពឹងទុក៖

អ្នកចូលរួមនឹង៖

- ស្វែងយល់ពីលិខិតតូបករណ៍ជាតិអន្តរជាតិដែលទាក់ទងនឹងអំពើកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទ ប្រទេសកម្ពុជាពេលបច្ចុប្បន្នទាក់ទងនឹង OCSEA
- ស្វែងយល់អំពីការផ្លាស់ប្តូរក្នុងសេចក្តីព្រាងច្បាប់ (ច្បាប់ស្តីអំពីការការពារកុមារ និងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន)
- ស្វែងយល់អំពីការឆ្លើយតបសមស្រប ពេលដែលសកម្មភាពរបស់ OCSEA ខុសច្បាប់ និងមិនខុសច្បាប់ ប៉ុន្តែមានគ្រោះថ្នាក់

## កំណត់ចំណាំ៖

អ្នកចូលរួមនឹងយល់កាន់តែច្បាស់អំពីប្រភេទនៃសកម្មភាព និងឥរិយាបថ ដែលត្រូវបានចាត់ ទុកថាជា OCSEA និងបានរៀនពីពាក្យបច្ចេកទេសមួយចំនួន ដែលត្រូវបានប្រើដើម្បីពិពណ៌នា។

ក្រុមពិភាក្សាក៏គួរតែមានការយល់ដឹងកាន់តែច្បាស់អំពីទំនាក់ទំនងរវាងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ ហើយថាក្នុងនាមជាមន្ត្រីនគរបាល ត្រូវតែដឹងអំពី អំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទទាំងក្នុង និងក្រៅប្រព័ន្ធអនឡាញដែលបានប្រព្រឹត្តលើកុមារ។

ករណីសិក្សាដែលផ្អែកលើរឿងរ៉ាវ និងបទពិសោធន៍ជាក់ស្តែងរបស់កុមារ និងយុវជនកម្ពុជា ផ្តល់ឱ្យពួកគេនូវការយល់ដឹងកាន់តែច្បាស់ អំពីប្រភេទនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្ត របៀបដែលគេប្រើបច្ចេកវិទ្យា ដើម្បីប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ ភាពចម្រុះនៃជនល្មើស និងលក្ខណៈខុសប្លែកគ្នានៃកុមាររងគ្រោះ។ ករណីសិក្សាក៏បានផ្តល់នូវការយល់ដឹងខ្លះៗអំពីផលប៉ះពាល់នៃបទឧក្រិដ្ឋទាំងនេះ ការលំបាកដែលកុមារមានក្នុងការរាយការណ៍ និងបញ្ហាប្រឈមរបស់មន្ត្រីនគរបាលក្នុងការជួយជនរងគ្រោះទទួលបានយុត្តិធម៌។

មានសារៈសំខាន់សម្រាប់មន្ត្រីនគរបាល ដែលមានទំនួលខុសត្រូវក្នុងការបម្រើដល់សាធារណជន ក្នុងការស៊ើបអង្កេតប្រមូលព័ត៌មាន និងភស្តុតាង ដើម្បីគាំទ្រដល់ការផ្តន្ទាទោសជនល្មើស។ ពួកគេចាំបាច់ត្រូវមានចំណេះដឹង និងការយល់ដឹងច្បាស់អំពីច្បាប់ពាក់ព័ន្ធនឹងបទល្មើស OCSEA។ វាមានសារៈសំខាន់ដូចគ្នាក្នុងការដែលត្រូវស្វែងយល់អំពីគម្លាតនៅក្នុងច្បាប់នាពេលបច្ចុប្បន្ន (ដោយសារតែបច្ចេកវិទ្យា និងច្បាប់ទាក់ទង នឹងបទឧក្រិដ្ឋតាមប្រព័ន្ធអនឡាញកំពុងព្យាយាមតាមឱ្យទាន់បទឧក្រិដ្ឋដែលជនល្មើសប្រព្រឹត្ត)ដើម្បីដឹងថាពួកគេត្រូវធ្វើការបន្តដោយរបៀបណា ហើយត្រូវចាត់វិធានការសកម្មភាពអ្វីខ្លះ បើយោងតាមច្បាប់។


ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

ចាំបាច់ផងដែរ ដែលមន្ត្រីនគរបាលត្រូវយល់ដឹងអំពីច្បាប់ ដូច្នេះពួកគេអាចពន្យល់បានយ៉ាងច្បាស់ទៅកាន់កុមារ យុវជន និងអាណាព្យាបាល ដែលរងផលប៉ះពាល់ដោយ OCSEA ថាសិទ្ធិរបស់ពួកគេមានអ្វីខ្លះ។

ក្នុងនាមជាអ្នកសម្របសម្រួល អ្នកត្រូវយល់ច្បាស់អំពីច្បាប់ដែលអ្នកនឹងចែករំលែក ដូច្នេះអ្នកត្រូវទុកពេលវេលាឱ្យបានច្រើនសម្រាប់ការធ្វើផែនការ និងការរៀបចំក្នុងការសម្របសម្រួលសម្រាប់វគ្គនេះ។

## ធនធានដែលត្រូវការ៖

ឧបសម្ព័ន្ធ "គ" (ទំព័រ ១១៨) និងស្លាយ (**ពីស្លាយ ៤៤**)

### កំណត់ពន្យល់បន្ថែមសម្រាប់ការសម្របសម្រួល៖

១. ស្វាគមន៍ក្រុម និងចែករំលែកអំពីលទ្ធផល នៃការរំពឹងទុកចេញពីវគ្គនេះ ដោយប្រើកំណត់ចំណាំនៅខាងលើ និងស្លាយ។ សូមពន្យល់ប្រាប់ពួកគេថា យើងនឹងប្រើប្រាស់សកម្មភាព និងធនធានផ្សេងៗ ដើម្បីទទួលបានលទ្ធផលនៃការរំពឹងទុកនេះ។

២. រំលឹកក្រុមអំពីឥរិយាបថ និងសកម្មភាពចម្បងៗ ដែលត្រូវបានចាត់ទុកថាជា OCSEA (កាលពីវគ្គមុន) ហើយពន្យល់ប្រាប់ពួកគេថា ភារកិច្ចនៅក្នុងផ្នែកទីមួយនៃវគ្គនេះ គឺត្រូវកំណត់ឱ្យច្បាស់ថា តើច្បាប់ប្រទេសកម្ពុជាមួយណាដែលពាក់ព័ន្ធនឹងសកម្មភាព ឬបទឧក្រិដ្ឋនីមួយៗ ហើយធ្វើការកត់សម្គាល់អំពីគម្លាតផ្លូវច្បាប់មួយចំនួនដែលអាចកើតមាន។

៣. វាមិនទំនងទេ ដែលអ្នកចូលរួមនឹងដឹងរួចហើយថាទង្វើ ឬឥរិយាបថបែបណាខ្លះត្រូវបានចែងដោយច្បាប់ជាក់លាក់ណាមួយ ដូច្នេះសូមពន្យល់ប្រាប់ពួកគេថា ផ្នែកនៃវគ្គនេះនឹងចែករំលែកអំពីច្បាប់ដែលពាក់ព័ន្ធ ដោយប្រើស្លាយ និង/ឬសន្លឹកធនធានច្បាប់ដែលពាក់ព័ន្ធ។

ពួកគេនឹងអាចរក្សាឯកសារធនធានទុក ដើម្បីប្រើជាឯកសារយោង ព្រោះវាពណ៌នាអំពីច្បាប់ពាក់ព័ន្ធទាំងអស់យ៉ាងលម្អិត។ ពន្យល់ប្រាប់ពួកគេថា យើងនឹងប្រើសន្លឹកធនធាននៅក្នុងវគ្គក្រោយៗទៀតពេលដែលយើងអនុវត្តច្បាប់នៅក្នុងករណីសិក្សា។

៤. ការប្រើប្រាស់ផ្ទាំងស្លាយ និងស្លាយដែលពាក់ព័ន្ធ៖ (ក)ទង្វើ ឬឥរិយាបថនីមួយៗ (ខ)ច្បាប់ពាក់ព័ន្ធបានចែងអ្វីខ្លះ និង(គ)គម្លាតដែនកំណត់ ឬវិធានការពិសេសណាមួយដែលទាក់ទងនឹងច្បាប់។

អ្នកក៏អាចផ្តល់យោបល់ (ក្នុងករណីដែលពាក់ព័ន្ធ) លើបញ្ហាជាក់លាក់ណាមួយដែលទាក់ទងនឹងតួនាទីរបស់មន្ត្រីនគរបាលផងដែរ។ ស្លាយនឹងរួមបញ្ចូលតារាងដែលមើលទៅស្រដៀងនឹងសន្លឹកធនធាន (សូមមើលខាង ក្រោម)។

៥. បន្ទាប់មកពន្យល់ប្រាប់ក្រុមថា ច្បាប់ជាតិដែលអ្នកទើបបានចែករំលែកជាមួយពួកគេចែងអំពីតួនាទីរបស់មន្ត្រីនគរបាលក្នុងការការពារកុមារប្រឆាំងនឹងបទឧក្រិដ្ឋ OCSEA ហើយចែងអំពីប្រភេទ បទឧក្រិដ្ឋណាខ្លះដែលមន្ត្រីនគរបាលអាចធ្វើការស៊ើបអង្កេត និងកាត់ទោសជនល្មើសបាន។ **កំណត់សម្គាល់ពិសេស៖** លើសពីនេះក៏មានផែនការ និងក្របខ័ណ្ឌថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិដែលពាក់ព័ន្ធនឹងOCSEAផងដែរដែលមានទាក់ទងនឹងភាគីដែលពាក់ព័ន្ធជាច្រើនទៀត។ ប្រអប់ខាងក្រោមនេះសង្ខេបក្របខ័ណ្ឌទាំងនេះ ហើយអ្នកក៏អាចមើលវានៅលើផ្ទាំងស្លាយផងដែរ ប្រសិនបើចាំបាច់។

៦. នៅថ្នាក់តំបន់ ផែនការសកម្មភាពក្នុងតំបន់អាស៊ាន ដើម្បីការពារកុមារទាំងអស់ពីការកេងប្រវ័ញ្ច និងការរំលោភបំពានតាមប្រព័ន្ធអនឡាញរៀបរាប់លម្អិតយ៉ាងច្បាស់អំពីតួនាទីរបស់អ្នកពាក់ព័ន្ធទាំងអស់រួមទាំងមន្ត្រីនគរបាល និងក្របខ័ណ្ឌការពារកុមារតាមប្រព័ន្ធអនឡាញរបស់ ITU/ASEAN ផងដែរ។

៧. នៅកម្រិតថ្នាក់ជាតិ ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ និងផែនការអនុវត្តយុទ្ធសាស្ត្រការការពារ កុមារកម្ពុជាឆ្នាំ២០២២-២០២៦(កំពុងព្រាង)មានឯកសារយោងលើតួនាទីនៃការអនុវត្តច្បាប់។

៨. លើសពីនេះ សេចក្តីព្រាង**ច្បាប់ស្តីពីការការពារកុមារ** ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទនិងសេចក្តីព្រាង**ច្បាប់ប្រឆាំងបទល្មើសបច្ចេកវិទ្យា** រួមជាមួយនឹងក្រមព្រហ្មទណ្ឌនៃព្រះរាជា ណាចក្រកម្ពុជាបានផ្តល់នូវឧបករណ៍នីតិប្បញ្ញត្តិជាតិសំខាន់ៗជាច្រើន។

ពេលដែលសេចក្តីព្រាងច្បាប់ទទួលបានសច្ចាប័ន និងដាក់ឱ្យមានដំណើរការ ឯកសារបណ្តុះបណ្តាល នឹងត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំង

អំពីការអភិវឌ្ឍទាំងនេះ។

៩. មុនពេលបិទវគ្គនេះ ផ្តល់ឱកាសឱ្យអ្នកចូលរួមសួរសំណួរ និងស្វែងរកភាពច្បាស់លាស់អំពីច្បាប់ដែលពាក់ព័ន្ធហើយពន្យល់ប្រាប់ពួកគេថាពួកគេនឹងមានឱកាសពង្រឹងការសិក្សារបស់ពួកគេទាក់ទងនឹងច្បាប់ ពេលយើងអនុវត្តន៍ការសិក្សារបស់ពួកគេនៅក្នុងករណីសិក្សានៅវគ្គក្រោយៗទៀត។

១០. ពន្យល់ប្រាប់ពួកគេថា មុនពេលយើងរៀនអំពីការអនុវត្តអ្វីដែលយើងបានរៀននៅក្នុងវគ្គបន្ទាប់ យើងនឹងផ្តោតលើការសិក្សាអំពី**សិទ្ធិកុមារក្នុងពិភពឌីជីថល** និងការរំលឹកអំពីគោលការណ៍សំខាន់ៗ នៃ**គោលការណ៍ណែនាំការអនុវត្តដោយផ្តោតលើកុមារ**សម្រាប់ការគាំទ្រកុមារដែលរងផលប៉ះពាល់ដោយបទឧក្រិដ្ឋផ្លូវភេទ។

## សកម្មភាព

បែងចែកជាក្រុមពិភាក្សាលើមាត្រាច្បាប់ពាក់ព័ន្ធទៅនឹងអំពើខាងក្រោម៖

- ការល្បួងលោមកុមារតាមប្រព័ន្ធអនឡាញ
- ការផលិតការកាន់កាប់ឬការចែកចាយរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ ( CSAM )
- ការផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ
- ការចែករំលែកខ្លឹមសារពាក់ព័ន្ធនឹងផ្លូវភេទ ឬរូបភាពអាសអាភាសរបស់ពួកគេ ដែលបង្កើតដោយខ្លួនឯងពាក់ព័ន្ធនឹងកុមារ។
- ការគំរាមកំហែងខាងផ្លូវភេទលើកុមារ
- ការបៀតបៀនផ្លូវភេទលើកុមារ

### ការប៉ះពាល់ ឬការបៀតបៀនផ្លូវភេទលើកុមារ
### មាត្រាច្បាប់ពាក់ព័ន្ធ OCSEA

| មាត្រាច្បាប់ពាក់ព័ន្ធ (ច្បាប់នៅកម្ពុជា) | ការពន្យល់បន្ថែម (ចន្លោះខ្វះខាត, ដែនកំណត់.....) |
| --- | --- |
| | |

- បទបង្ហាញតាមក្រុមបន្ទាប់ពីកិច្ចពិភាក្សា


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

## ខ្លឹមសារគន្លឹះ និងសកម្មភាពតស៊ូមតិ

- ផ្នែកពាក់ព័ន្ធបំផុតនៃច្បាប់កម្ពុជាស្តីពីការកេងប្រវ័ញ្ចផ្លូវភេទជាទូទៅដែលរួមបញ្ចូលឧក្រិដ្ឋកម្ម OCSEA គឺច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ លើសពីនេះមានក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏បានកំណត់បទល្មើសមួយចំនួនទាក់ទងនឹង OCSEA ផងដែរ។

- ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងការរំលោភបំពានតាមប្រព័ន្ធអនឡាញ និងផែនការអនុវត្តយុទ្ធសាស្ត្រការពារកុមារកម្ពុជាឆ្នាំ២០២២-២០២៦ (កំពុងព្រាង)ក៏មានឯកសារយោងទៅលើតួនាទីរបស់មន្ត្រីអនុវត្តច្បាប់ផងដែរ។ លើសពីនេះសេចក្តីព្រាងច្បាប់ស្តីពីការការពារកុមារច្បាប់ស្តីពីការបង្ក្រាបអំពើ ជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងសេចក្តីព្រាងច្បាប់ស្តីពីប្រឆាំងបទល្មើសបច្ចេកវិទ្យារួមជាមួយនឹងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់នូវឧបករណ៍នីតិប្បញ្ញត្តិជាតិសំខាន់ៗ។

- នៅថ្នាក់តំបន់ ផែនការសកម្មភាពក្នុងតំបន់អាស៊ាន ដើម្បីការពារកុមារទាំងអស់ពីការកេងប្រវ័ញ្ចនិងការរំលោភបំពានតាមប្រព័ន្ធអនឡាញរៀបរាប់លម្អិតយ៉ាងច្បាស់អំពីតួនាទីរបស់អ្នកពាក់ព័ន្ធទាំងអស់ រួមទាំងមន្ត្រីនគរបាល និងក្របខ័ណ្ឌការពារកុមារតាមប្រព័ន្ធអនឡាញរបស់ ITU/ASEAN ផងដែរ។

- នៅកម្រិតថ្នាក់ជាតិ ផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ និងផែនការអនុវត្តយុទ្ធសាស្ត្រការការពារកុមារកម្ពុជាឆ្នាំ២០២២-២០២៦ (កំពុងព្រាង) មានឯកសារយោងលើតួនាទី នៃការអនុវត្តច្បាប់។

## មេរៀនទី៥

# សិទ្ធិកុមារក្នុងពិភពឌីជីថល

## លទ្ធផលរំពឹងទុក៖

អ្នកចូលរួមនឹង៖

- ស្វែងយល់អំពីគោលការណ៍សំខាន់ៗ នៃសិទ្ធិកុមារ។
- យល់ដឹងបន្ថែមស្តីពីសិទ្ធិកុមារដែលត្រូវបានអនុវត្តនៅក្នុងពិភពឌីជីថល។
- ស្វែងយល់ពីរបៀបដែលមន្ត្រីនគរបាលគួរអនុវត្តផ្អែកសិទ្ធិកុមារ របៀបដែលមន្ត្រីនគរបាលអាចនឹងគួរតែអនុវត្តន៍ផ្អែកលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

## កំណត់ចំណាំ៖

បន្ទាប់ពីបានសិក្សាអំពីច្បាប់ជាតិទាក់ទងនឹងបទឧក្រិដ្ឋ OCSEA អ្នកចូលរួមក៏ត្រូវរំលឹកអំពីសិទ្ធិកុមារ និងស្វែងយល់អំពីរបៀប ដែលពួកគេអនុវត្តន៍វានៅក្នុងពិភពឌីជីថលផងដែរ។

កុមារ សំដៅលើបុគ្គលដែលមានអាយុក្រោម ១៨ឆ្នាំ មានសិទ្ធិទទួលបានបានការការពារពិសេស ដែលត្រូវបានព្រមព្រៀងក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ។ ខណៈពេលដែលសិទ្ធិមនុស្ស និងអនុសញ្ញាគ្រប់គ្រង និងការការពារត្រូវអនុវត្តន៍ស្មើៗគ្នាចំពោះកុមារ និងមនុស្សពេញវ័យ កុមារនៅគ្រប់ទីកន្លែងមានសិទ្ធិពិសេស ដោយសារភាពងាយរងគ្រោះ និងស្ថានភាពដែលកុមារប្រឈម ស្របតាមអាយុ និងសមត្ថភាពដែលកំពុងអភិវឌ្ឍន៍។

ដោយសារប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ CRC ដែលកំណត់ថា មានសិទ្ធិចំនួន៣២ ដែលកុមារទាំងអស់ត្រូវមាន ហើយទទួលបានការធានាថាពួកគេនឹងទទួលបានសិទ្ធិទាំងនេះ។

មន្ត្រីនគរបាល ក៏ត្រូវយល់ដឹងអំពី CRC ដែរ និងភាពពាក់ព័ន្ធនៃសិទ្ធិទាំងនេះទៅនឹងការ ងាររបស់ពួកគេផងដែរ។ ដូច្នេះវគ្គនេះនឹងរំលឹកអ្នកចូលរួមអំពីអនុសញ្ញាស្តីអំពីសិទ្ធិកុមារ CRC និងផ្តល់យោបល់អំពីរបៀបដែលសិទ្ធិទាំងនេះត្រូវបានអនុវត្តនៅក្នុងពិភពឌីជីថលផងដែរ។ វាជាការសំខាន់ដែលថា បន្ថែមពីលើច្បាប់ជាតិ មន្ត្រីនគរបាលត្រូវដឹង និងធ្វើតាមគោលការណ៍ និងមាត្រានៃច្បាប់នេះផងដែរ។

សូមកត់សម្គាល់ផងដែរថាមេរៀននេះ អាចមិនសូវមានសកម្មភាពចូលរួមរបស់អ្នកចូលរួមប៉ុន្មានទេ ព្រោះថា វាជាវគ្គដែលចែករំលែកព័ត៌មានសំខាន់ៗ ប៉ុន្តែវាជាផ្នែកមួយដ៏សំខាន់នៃការរៀនសូត្រ។ សកម្មភាពដែលមានក្នុងវគ្គនេះ នឹងរំលឹកអ្នកចូលរួមអំពីទំនាក់ទំនងនៃព័ត៌មានអំពីច្បាប់ទាំងនេះនៅក្នុងការអនុវត្តជាក់ស្តែង។

## ធនធានដែលត្រូវការ៖

**ឧបសម្ព័ន្ធ "ឃ" (ទំព័រ ១២៤) និង "ឃ១" (ទំព័រ ១៣០) និងស្លាយ (ចាប់ពីស្លាយ ៥៤)**



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

## កំណត់ពន្យល់បន្ថែមសម្រាប់ការសម្របសម្រួល៖

១. សូមស្វាគមន៍ក្រុម ហើយពន្យល់ប្រាប់ពួកគេថា យើងនឹងសិក្សាអំពីសិទ្ធិរបស់កុមារ និងរបៀបដែលអនុវត្តន៍វានៅក្នុងពិភពឌីជីថល។

២. ពន្យល់ប្រាប់ក្រុមថាអ្នកនឹងណែនាំពួកគេអំពីសិទ្ធិសំខាន់ៗមួយចំនួនរបស់កុមារ យោងទៅតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ CRC ជាអនុសញ្ញាអង្គការសហប្រជាជាតិ ដែលត្រូវបានចុះហត្ថលេខា និងផ្តល់សច្ចាប័នដោយរាជរដ្ឋាភិបាលកម្ពុជា (UNCRC)។

**ការនេះមានន័យថា ភាគីពាក់ព័ន្ធទាំងអស់ក្នុងប្រទេស ដែលបានចុះហត្ថលេខាលើអនុសញ្ញានេះ ត្រូវមានកាតព្វកិច្ចចាត់វិធានការអ្វីក៏ ដោយ ដែលពួកគេអាចធ្វើបាន ដើម្បីការពារ លើកកម្ពស់ និងគាំទ្រសិទ្ធិរបស់កុមារ។ ភាគីទាំងនេះរាប់បញ្ចូលទាំងមន្ត្រីនគរបាល និងអ្នកពាក់ព័ន្ធដទៃទៀតនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។**

៣. ប្រើស្លាយដែលបានផ្តល់ជូន ដើម្បីចែករំលែកព័ត៌មានសំខាន់ៗទាក់ទងនឹង UNCRC (ព័ត៌មាននេះក៏ត្រូវបានរួមបញ្ចូលផងដែរ នៅក្នុងឧបសម្ព័ន្ធដែលអ្នកនឹងចែករំលែកជាមួយអ្នកចូលរួមបន្ទាប់ពីវគ្គនេះ)។ធ្វើបទបង្ហាញអំពីផ្នែកនីមួយៗនៃសន្លឹកកិច្ចការ/ស្លាយ ដោយពន្យល់ប្រាប់អំពីចំណុចនីមួយៗយ៉ាងច្បាស់ដល់អ្នកចូលរួម។ (អ្នកអាចសុំឱ្យអ្នកចូលរួមជួយដោយការអានផ្នែកខ្លះនៃសន្លឹកកិច្ចការនេះ)។

៤. ពេលដែលក្រុម/ដៃគូបានធ្វើកំណត់ចំណាំលើមាត្រានីមួយៗរួចរាល់ហើយ អ្នកអាចអញ្ជើញពួកគេឱ្យចែករំលែកគំនិតរបស់ពួកគេនៅក្នុងក្រុមធំដោយបង្ហាញពីចំណុចសំខាន់ៗនិងឥរិយាបថដែលមន្ត្រីនគរបាលដែលមានទំនួលខុសត្រូវ និងសីលធម៌ ត្រូវអនុវត្តន៍តាម។

អ្នកចូលរួមផ្សេងទៀតក៏អាចបន្ថែមគំនិតមានប្រយោជន៍ផ្សេងទៀតនិង/ឬសុំការបំភ្លឺបន្ថែមប្រសិនបើចាំបាច់។

៥. ក្នុងនាមជាអ្នកសម្របសម្រួល អ្នកប្រហែលជាត្រូវរៀបចំការណែនាំដ៏មានប្រយោជន៍មួយចំនួន ដោយផ្អែកលើចំណេះដឹងរបស់អ្នក អំពីរបៀបដែលមន្ត្រីនគរបាលធ្វើប្រតិបត្តិការនិងការយល់ដឹងរបស់អ្នកអំពីសិទ្ធិនិងគោលការណ៍នៃការអនុវត្តតាមបែបកុមារមេត្រី (សូមមើលវគ្គបន្ទាប់)។

ដើម្បីជួយអ្នកយើងបានរៀបចំកំណត់ចំណាំបន្ថែមទៀតសម្រាប់អ្នកសម្របសម្រួល ដើម្បីជួយអ្នកណែនាំអ្នកអំពីដំណើរការ និងផ្តល់ជូនគំនិតមានប្រយោជន៍មួយចំនួន ប្រសិនបើអ្នកចូលរួមពិបាករកចម្លើយ។

៦. ទុកពេលវេលាឱ្យអ្នកចូលរួមសួរសំនួរ អំពីទិដ្ឋភាពណាមួយ នៃសិទ្ធិកុមារ


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

នៅក្នុងពិភពឌីជីថល។

៧. ពន្យល់ប្រាប់ក្រុមថា មន្ត្រីនគរបាលត្រូវគិតអំពីផលប៉ះពាល់នៃសិទ្ធិកុមារទាំងអស់លើគ្រប់ទិដ្ឋភាពនៃការងាររបស់ពួកគេនិងរបៀបដែលពួកគេអាចរួមបញ្ចូលការការពារសិទ្ធិកុមារទៅក្នុងសកម្មភាពការងារប្រចាំថ្ងៃរបស់ពួកគេ។

## សកម្មភាព

១. សួរទៅកាន់ក្រុមថា តើពួកគេធ្លាប់បានឮអំពី «សិទ្ធិកុមារ» ពីមុនមកទេ? ហើយថា តើពួកគេមានចំណេះដឹងអំពីច្បាប់ពាក់ព័ន្ធដែលបង្ហាញអំពីសិទ្ធិរបស់កុមារដែរឬទេ? ឬថា តើសិទ្ធិកុមារមូលដ្ឋានមានអ្វីខ្លះ? ទុកពេលវេលាពីរទៅបីនាទី ដើម្បីឱ្យក្រុមចែករំលែកគំនិតរបស់ពួកគេ។ អ្នកអាចសរសេរគំនិតរបស់ពួកគេនៅលើផ្ទាំងក្រដាសធំ ឬក្តារខៀនក៏បានប្រសិនបើអ្នកចង់។

២. បន្ទាប់មកអ្នកក៏អាចចែក**សន្លឹកកិច្ចការសិទ្ធិកុមារនៅក្នុងពិភពឌីជីថល**ហើយសុំឱ្យអ្នកចូលរួមធ្វើការជាក្រុមតូចៗ ឬជាដៃគូ។

សុំឱ្យពួកគេអានតាមសន្លឹកកិច្ចការនោះហើយបន្ថែមកំណត់ចំណាំទៅក្នុងប្រអប់ដែលពាក់ព័ន្ធ ដែលមាននៅក្នុងអត្ថបទនោះ។ (ឧទាហរណ៍៖ **ក្រុមទី១** ធ្វើលើមាត្រា២ និង៣, **ក្រុមទី២** ធ្វើលើមាត្រា១២ និង១៣, **ក្រុមទី៣** ធ្វើការលើមាត្រា១៦ និង១៩ ហើយក្រុមបន្តបន្ទាប់ទៀតធ្វើការលើមាត្រាដទៃរហូតទាល់តែអស់មាត្រាសំខាន់ៗ ដែលមានទាំងប៉ុន្មាន។

ឧទាហរណ៍៖ យោងតាម**មាត្រា១២**(សិទ្ធិឯកជនភាព) ក្រុមអាចធ្វើកំណត់ចំណាំបន្ថែមអំពីផលប៉ះពាល់នៃមាត្រានេះសម្រាប់មន្ត្រីនគរបាលនៅក្នុង ប្រអប់អត្ថបទនៅលើសន្លឹកកិច្ចការនេះ។

**ឧទាហរណ៍មួយដូចខាងក្រោម៖**

ឧទាហរណ៍៖ យោងតាម**មាត្រា១២** (សិទ្ធិឯកជនភាព)

**ដើម្បីរក្សាសិទ្ធិរបស់កុមារ ការនេះមានន័យថាក្នុងនាមយើងជាមន្ត្រីនគរបាល៖**

- ក្នុងនាមជាមន្ត្រីនគរបាល យើងត្រូវតែប្រាកដថា ការសម្ភាសធ្វើឡើងជាលក្ខណៈឯកជន និងរក្សាការសម្ងាត់មិនមែនធ្វើឡើងនៅក្នុងការិយាល័យដែលបើកចំហនោះទេ។
- កុមារដែលត្រូវបានរាប់បញ្ចូលនៅក្នុងការស៊ើបអង្កេតតាមរបៀបមួយដែលការពារអត្តសញ្ញាណរបស់ពួកគេពីសាធារណជន។ (ឧ. នៅពេលដែល


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

ហៅពួកគេឱ្យធ្វើសេចក្ដីថ្លែង សូមធ្វើដូច្នេះតាមរបៀបមួយដែលនឹងមិនជូនដំណឹងដល់អ្នកជិតខាងទាំងមូល ដែលអាចធ្វើឱ្យមានការប៉ះទង្គិចចិត្តយ៉ាងខ្លាំងនោះទេ)។

- ព័ត៌មាន និងភស្តុតាងមិនគួរណាត្រូវបានចែករំលែកដោយមន្ត្រីនគរបាលទៅកាន់មនុស្សផ្សេងទៀត ដែលមិនចាំបាច់ត្រូវដឹងទេ។
- ភស្តុតាងទាំងអស់គួរតែរក្សាសុវត្ថិភាព និងរក្សាការសម្ងាត់ជានិច្ច។ សេចក្ដីថ្លែង និងភស្តុតាងរូបវន្ត គួរតែត្រូវបានរក្សាទុកដោយសុវត្ថិភាពនៅក្នុងទូដែលចាក់សោជានិច្ច។
- **ភស្តុតាងឌីជីថល៖** មន្ត្រីនគរបាលមិនគួរទាញយកភស្តុតាងឌីជីថលចូលទៅក្នុងទូរស័ព្ទ និងឧបករណ៍ផ្ទាល់ខ្លួនរបស់ពួកគេឡើយ ហើយមិនគួរចែករំលែកភស្តុតាងឌីជីថល(រូបថត រូបភាព ឬវីដេអូ) ជាមួយមិត្តភក្ដិ ឬក្រុមសង្គម ដោយប្រើវេទិកាឯកជន ដូចជា៖ Messenger, Telegram ឬ WhatsApp ទេ។

## ខ្លឹមសារគន្លឹះ និងសកម្មភាពតស៊ូមតិ

បញ្ចប់មេរៀនដោយប្រើចំណុចសង្ខេបដូចខាងក្រោម៖

- ក្នុងនាមយើងជាមន្ត្រីនគរបាល យើងមានតួនាទីយ៉ាងសំខាន់ក្នុងការការពារ និងលើកកំពស់សិទ្ធិរបស់កុមារ នៅក្នុងគ្រប់ផ្នែកនៃការងាររបស់យើង។
- កុមារនិងយុវជនដែលទទួលរងការរំលោភបំពាននិងការកេងប្រវ័ញ្ចគឺជាការរំលោភសិទ្ធិរបស់ពួកគេ ហើយពិបាកនឹងជឿទុកចិត្តលើបុគ្គលណាម្នាក់ រួមទាំងមន្ត្រីនគរបាលផងដែរ។
- ប្រសិនបើយើងយកវិធីសាស្ត្រដោយផ្អែកលើសិទ្ធិការគោរពនិងការលើកកម្ពស់សិទ្ធិរបស់ពួកគេការធ្វើបែបនេះអាចជួយយើងកសាងទំនុកចិត្តជាមួយកុមាររងគ្រោះ សាក្សី និងក្រុមគ្រួសាររបស់ពួកគេបាន។
- ប្រសិនបើយើងបង្កើនទំនុកចិត្តពួកគេកាន់តែខ្លាំងជាងមុន នោះកុមាររងគ្រោះនឹងមានអារម្មណ៍ថាមានសុវត្ថិភាពជាងមុន។ ការនេះនឹងនាំឱ្យមានកិច្ចសហការ និងកិច្ចសហការកាន់តែប្រសើរឡើង ហើយសេចក្ដីថ្លែងការណ៍ និងភស្តុតាងដែលពួកគេផ្ដល់ឱ្យនឹង កាន់តែប្រសើរជាងមុន។
- ការទទួលបានភស្តុតាងកាន់តែប្រសើរជាងមុន ក៏ជួយសម្រួលដល់ការស៊ើបអង្កេតឱ្យកាន់តែមានប្រសិទ្ធភាព។

## មេរៀនទី៦

# គោលការណ៍អនុវត្តនីតិវិធីបែបកុមារមេត្រី

## លទ្ធផលរំពឹងទុក៖

អ្នកចូលរួមនឹង៖

- យល់ដឹងអំពី (ឬត្រូវបានរំឭកអំពី) នៃការអនុវត្តបែបកុមារមេត្រី នៅពេលសម្ភាសន៍ និងគាំទ្រកុមារអំពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ
- យល់ដឹងអំពីផលប៉ះពាល់កុមារពីអំពើកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ
- យល់ដឹងពីអត្ថប្រយោជន៍នៃការអនុវត្តបែបកុមារមេត្រី

## កំណត់ចំណាំ៖

អ្នកចូលរួមបានសិក្សារួចហើយ អំពីការអនុវត្តបែបកុមារមេត្រី នៅក្នុងវគ្គបណ្តុះបណ្តាលកាលពីពេលមុន ហើយបានដឹងគេអាចទទួលបានអត្ថប្រយោជន៍ពីការរំលឹកឡើងវិញ។ អ្នកចូលរួមខ្លះ ប្រហែល ជាមិនធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលនេះពីមុនហើយការអនុវត្តបែបកុមារមេត្រីជាមេរៀនថ្មីសម្រាប់មន្ត្រីនគរបាល។

គោលការណ៍ការអនុវត្តកុមារមេត្រីមានទំនាក់ទំនង មានយ៉ាងជិតស្និទ្ធទៅនឹងសិទ្ធិកុមារ ដែលបានបង្រៀននៅក្នុងវគ្គមុន ហើយនឹងជួយពង្រឹងការសិក្សា។ មានសារៈសំខាន់ណាស់សម្រាប់មន្ត្រីនគរបាល ដែលធ្វើការជាមួយកុមាររងគ្រោះ កុមារដែលងាយរងគ្រោះ និងកុមារជាសាក្សី ដើម្បីយល់ពីគោលការណ៍ជាមូលដ្ឋាននៃការ អនុវត្តបែបកុមារមេត្រី និងយល់ពីរបៀបអនុវត្តគោលការណ៍ទាំងនេះឱ្យមានប្រសិទ្ធភាពក្នុងការងារប្រចាំថ្ងៃពួកគេ។

មានភស្តុតាងដែលបានមកពីការស្រាវជ្រាវ ដែលផ្តល់ដោយកុមារអំពីបទពិសោធន៍របស់ពួកគេជាមួយមន្ត្រីនគរបាល (រួមទាំងការស្រាវជ្រាវបញ្ឈប់គ្រោះថ្នាក់កុមារ) ត្រូវបានលាយបញ្ចូលគ្នា។ កុមារខ្លះមានបទពិសោធន៍ល្អជាមួយមន្ត្រីនគរបាលនៅពេលរាយការណ៍អំពីបទឧក្រិដ្ឋផ្លូវភេទ ប៉ុន្តែក៏មានកុមារដែលជួបបញ្ហាប្រឈម ផងដែរ។

កុមារខ្លះជួបបទពិសោធន៍ការអនុវត្តដែលមិនស្របតាមស្តង់ដារបានកំណត់ទុក។ មានកុមារខ្លះជួបបទពិសោធន៍នៃការរើសអើងកង្វះការរក្សាការសម្ងាត់និងភាពឯកជនត្រូវបានគេសម្ភាសន៍ក្នុងបរិយាកាសដែលពិបាកសម្រាប់ពួកគេឬពេលដែលមន្ត្រីនគរបាលប្រើប្រាស់ភាសានិងពាក្យបច្ចេកទេសដែលកុមារមិនយល់។កុមារនិងឪពុកម្តាយមួយចំនួនបានបញ្ចេញមតិថាពួកគេមិនទទួលបានឥរិយាបទនៃការប្រយ័ត្នប្រយែងអំពីភាពរសើបឬសេចក្តីសប្បុរសពីមន្ត្រីនគរបាលទេ ដែលវាបង្កភាពតក់ស្លុត និងរំដើបរំជួលដល់កុមារ។


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

គោលបំណងនៃមេរៀននេះ គឺមេរៀននេះមិនមានគោលបំណង ធ្វើការបណ្ដុះបណ្ដាល ឡើងវិញនូវប្រធានបទពីមុនៗទេឬដើម្បីជំនួសវគ្គបណ្ដុះបណ្ដាលដែលនគរបាលត្រូវផ្ដោតដែលទាក់ទងនឹងការអនុវត្តបែបកុមារមេត្រីទេ។ វគ្គនេះត្រូវបានរៀបចំឡើងដើម្បីណែនាំមន្ត្រីនគរបាលអំពីគោលការណ៍ និងការណែនាំសំខាន់ៗ (និងដើម្បីរំឭកអ្នកដែលបានទទួលការបណ្ដុះបណ្ដាលនេះរួចហើយ) ហើយអ្វីដែលសំខាន់នោះ គឺសង្កត់ធ្ងន់ទៅលើការរំពឹងទុកនៃការណែនាំ ដែលអ្នកចូលរួមទាំងអស់ត្រូវដឹង ដែលទាក់ទងនឹងរបៀបដែលពួកគេគួរអនុវត្តន៍។

អ្នកប្រហែលជាចង់សួរអ្នកចូលរួមមុនពេលចាប់ផ្ដើមមេរៀន (ឬក្នុងអំឡុងពេលនៃមេរៀនបណ្ដុះបណ្ដាលនេះក៏បាន) ថាតើមានអ្នកណាម្នាក់ក្នុងចំណោមពួកគេបានចូលរួមវគ្គបណ្ដុះបណ្ដាលផ្ដោតលើប្រធានបទនេះកាលពីមុនដែរឬទេ។ ប្រសិនបើមានច្រើន ពេលដែលអ្នកជួយសម្របសម្រួលការងារជាក្រុម វាអាចមានប្រយោជន៍ក្នុងការដាក់ពួកគេឱ្យធ្វើការជាក្រុមជាមួយអ្នកផ្សេងទៀត ដើម្បីជួយគាំទ្រដល់ដំណើរការនៃការសិក្សា។

ការដែលមន្ត្រីនគរបាលត្រូវស្វែងយល់អំពីគម្លាតនៅក្នុងច្បាប់នាពេលបច្ចុប្បន្ន (ដោយសារតែបច្ចេកវិទ្យានិងច្បាប់ទាក់ទងនឹងបទល្មើសតាមប្រព័ន្ធអនឡាញកំពុងព្យាយាមតាមឱ្យទាន់បទឧក្រិដ្ឋដែលជនល្មើសប្រព្រឹត្ត) ដើម្បីដឹងថាពួកគេត្រូវធ្វើការបន្តដោយរបៀបណា ហើយត្រូវចាត់វិធានការសកម្មភាពអ្វីខ្លះ បើយោងតាមច្បាប់។ វាក៏ជាការចាំបាច់ផងដែរ ដែលមន្ត្រីនគរបាលត្រូវយល់ដឹងអំពីច្បាប់ ដូច្នេះពួកគេអាចពន្យល់បានយ៉ាងច្បាស់ទៅកាន់កុមារ យុវជន និងអាណាព្យាបាលដែលរងផលប៉ះពាល់ដោយ OCSEA ថាសិទ្ធិរបស់ពួកគេមានអ្វីខ្លះ។

## ធនធានដែលត្រូវការ៖

**ឧបសម្ព័ន្ធ "ង" (ទំព័រ ១៣៧) និងស្លាយ (ពីស្លាយ ៧២)**

### កំណត់ពន្យល់បន្ថែមសម្រាប់ការសម្របសម្រួល៖

១. ណែនាំវគ្គនេះដោយប្រើកំណត់ចំណាំខាងលើ។ពន្យល់ប្រាប់ក្រុមថាយើងនឹងរៀនអំពីការអនុវត្តបែបកុមារមេត្រីដោយប្រើធនធានជាច្រើន។

អ្នកអាចចែករំលែកនិយមន័យដ៏សាមញ្ញមួយនៃ «ការអនុវត្តបែបកុមារមេត្រី» ដោយប្រើស្លាយ (ស្លាយទី៧៣)៖

> *គោលគំនិតនៃ «ការអនុវត្តបែបកុមារមេត្រី» សម្រាប់មន្ត្រីនគរបាល មានន័យថាជាការអនុវត្តដែលធានាថា ពេលដែលកុមារមកទាក់ទងជាមួយមន្ត្រីនគរបាល និងប្រព័ន្ធយុត្តិធម៌ ពួកគេនឹងទទួលបានការប្រព្រឹត្តតាមរបៀបមួយដែលត្រឹមត្រូវ សមរម្យ និងមិនបង្កគ្រោះថ្នាក់ដល់ពួកគេទេ។*

ពន្យល់ប្រាប់ពួកគេថា ការនេះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលមានកាតព្វកិច្ចធ្វើសកម្មភាពតាមរបៀបមួយ ដែលលើកកម្ពស់ផលប្រយោជន៍ដ៏ល្អបំផុតសម្រាប់កុមារ ក្នុងគ្រប់ជំហាន ទាំងអស់នៃទំនាក់ទំនងរបស់យើង និងការធ្វើការជាមួយពួកគេ។ ការធ្វើបែបនេះមិនមែនជាជម្រើសទេ តែវាជាតម្រូវការ។

អ្នកក៏អាចសួរក្រុមផងដែរថា តើពួកគេគិតថា ការអនុវត្តបែបកុមារមេត្រីអាចមាន**អត្ថប្រយោជន៍អ្វីខ្លះដល់កុមារ?**

ពួកគេប្រហែលជាមិនទាន់ប្រាកដក្នុងចិត្តក្នុងដំណាក់កាលនេះនៅឡើយទេ ប៉ុន្តែយើងនឹងពិនិត្យមើលសំណួរនេះឡើងវិញនៅចុងបញ្ចប់នៃវគ្គនេះ។

២. អ្នកចូលរួមមួយចំនួនបានចូលរួមវគ្គបណ្តុះបណ្តាល អំពីការអនុវត្តបែបកុមារមេត្រីកាលពីពេលមុនរួចហើយ ប៉ុន្តែសម្រាប់អ្នកខ្លះ វាអាចជាប្រធានបទថ្មីស្រឡាងសម្រាប់ពួកគេ។ (អ្នកអាចសួរពួកគេថា តើមាននរណាម្នាក់នៅក្នុងក្រុមធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាល អំពីប្រធានបទនេះកាលពីមុនទេ?)។

ពន្យល់ប្រាប់ក្រុមថា វគ្គនេះគឺជាការរំលឹកឡើងវិញសម្រាប់អ្នកខ្លះ ហើយអាចជាប្រធានបទថ្មីសម្រាប់អ្នកផ្សេងទៀត។ ទោះជាយ៉ាងណាក៏ដោយ វាតែងតែមានសារៈសំខាន់សម្រាប់យើងក្នុងការរំលឹកឡើងវិញអំពីការអនុវត្តបែបកុមារមេត្រី ពេលធ្វើការជាមួយកុមារដែលរងផលប៉ះពាល់ដោយ សារការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ។

៣. សូមពន្យល់ប្រាប់ពួកគេថា ការអនុវត្តបែបកុមារមេត្រីមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសិទ្ធិកុមារ ដែលយើងបានរៀននៅក្នុងវគ្គមុន។ ការអនុវត្តបែបកុមារមេត្រី បានលេចជារូបរាងឡើង ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ ដើម្បីជួយមន្ត្រីនគរបាលជុំវិញពិភពលោក ប្រព្រឹត្តចំពោះកុមារប្រកបដោយភាពស្មើគ្នា និងភាពសមរម្យ ពេលធ្វើការជាមួយកុមារ ហើយមានសារៈសំខាន់ ជាពិសេសពេលធ្វើការជាមួយកុមារទាក់ទងនឹងបទល្មើសផ្លូវភេទ។

៤. **ដោយប្រើស្លាយ** សូមពន្យល់ប្រាប់ពួកគេថា អ្នកនឹងណែនាំក្រុមអំពីគោលការណ៍សំខាន់ៗ ឬតម្រូវការមួយចំនួននៃការអនុវត្តបែបកុមារមេត្រី។ គោលការណ៍ៈ តម្រូវការសំខាន់ៗ ទាំងនេះរួមមាន៖

## គោលការណ៍ទូទៅ៖

- ការប្រើនីតិវិធីការអនុវត្តបែបកុមារមេត្រី-វិធីសាស្ត្រដោយផ្តោតលើកុមារជាសំខាន់

- ធ្វើការក្នុងភាពជាដៃគូដើម្បីធានាបាននូវវិធីសាស្ត្រពហុវិស័យប្រកបដោយប្រសិទ្ធភាព
- មានវិធីសាស្ត្រដោយគិតអំពីយេនឌ័រ
- ការសម្ភាស ៖ ផ្តល់អាទិភាពដល់សុខុមាលភាព និងប្រយោជន៍ដ៏ល្អបំផុតសម្រាប់កុមារ

**តម្រូវការចាំបាច់៖**

- ការបង្កើតបរិយាកាសបែបកុមារមេត្រី
- មានវត្តមានរបស់អ្នកគាំទ្រ
- មានវត្តមានមន្ត្រីសង្គមកិច្ច
- កុមារដែលមានពិការភាព
- យេនឌ័ររបស់មន្ត្រីនគរបាលដែលធ្វើបទសម្ភាស
- មិនឱ្យកុមារទំនាក់ទំនងជាមួយនឹងជនសង្ស័យ
- កែសម្រួលការប្រើប្រាស់ភាសាស្របទៅតាមអាយុ និងកម្រិតនៃការអភិវឌ្ឍរបស់កុមារ

៥. មានវិធីសាស្ត្រពីរយ៉ាងដែលអ្នកសម្របសម្រួលអាចបង្រៀនប្រធានបទនេះ វាអាស្រ័យលើទំហំនៃក្រុម ពេលវេលាដែលមាន និងចំណាប់ចំណូលចិត្តរបស់អ្នកសម្របសម្រួល។

វិធីសាស្ត្រមួយគឺមានការចូលរួម (ពីអ្នកចូលរួមដោយការធ្វើការជាក្រុមតូចៗ)៖ សូមមើលចំណុច (ក) ខាងក្រោម។ វិធីសាស្ត្រមួយទៀតគឺជាវិធីសាស្ត្រ «រចនាបទនៃការបង្រៀន» ជាការបង្រៀនតាមប្រពៃណីដោយប្រើស្លាយ៖ សូមមើលចំណុច (ខ) ខាងក្រោម។ មានការពណ៌នាអំពីវិធីសាស្ត្រទាំងពីរនេះ។

អ្នកអាចសម្រេចចិត្តថា តើវិធីសាស្ត្រមួយណាដែលអ្នកនឹងប្រើ មុនពេលអ្នកសម្របសម្រួលវគ្គនេះ។

៦. មានឧទាហរណ៍ខាងក្រោមដែលបង្ហាញថាកិច្ចការដែលបានបញ្ចប់រួចរាល់ហើយ មើលទៅអាចមានលក្ខណៈយ៉ាងដូចម្តេច៖ **ស្លាយ ៧៨-៧៩**

**បង្កើតបរិយាកាសបែបកុមារមេត្រី៖**

- ការសម្ភាសជាមួយកុមារគួរតែធ្វើឡើងក្នុងកន្លែងឯកជនប្រកបដោយផាសុកភាព ដែលមិនមានការរំខាន (ឧទាហរណ៍៖ សំឡេងទូរស័ព្ទ មនុស្សដើរចេញចូល) និងមានសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្តសម្រាប់កុមារ និងសមាជិកគ្រួសារ។

- ការសម្ភាសជាមួយកុមាររងគ្រោះនិងកុមារជាសាក្សីមិនគួរណាធ្វើឡើងនៅក្នុងការិយាល័យដ៏មមាញឹកដែលមានមនុស្សអាចមើលឃើញកុមារនិងស្តាប់ឮអ្វីដែលពួកគេនិយាយនោះទេ។
- ប្រដាប់ប្រដាក្មេងលេងនិងហ្គេមអាចមានប្រយោជន៍ពេលកុមារកំពុងរង់ចាំមុនពេលសម្ភាសន៍ ប៉ុន្តែគួរតែត្រូវបានយកទុកដាក់ក្នុងពេលសម្ភាសន៍ ដើម្បីកុំឱ្យមានការរំខានដល់កុមារ។
- ប្រសិនបើមិនមានកន្លែងបែបកុមារមេត្រីនៅក្នុងប៉ុស្តិ៍នគរបាលសម្រាប់កុមារទេ សូមស្នើសុំប្រើប្រាស់កន្លែងដែលមានសុវត្ថិភាពសម្រាប់កុមាររបស់ភាគីដែលពាក់ព័ន្ធផ្សេងទៀត (ដូចជាកន្លែងបុគ្គលិកសង្គមកិច្ចឬអង្គការមិនមែនរដ្ឋាភិបាល)។
- មន្ត្រីនគរបាលគួរជៀសវាងពាក់ឯកសណ្ឋានពេញលេញជានគរបាលព្រោះជារឿយៗវាអាចធ្វើឱ្យកុមារមានអារម្មណ៍ភ័យខ្លាច (គួរស្លៀកសំលៀកបំពាក់ស៊ីវិល)។
- មន្ត្រីនគរបាលគួរតែអង្គុយក្បែរកុមារ ជាជាងអង្គុយនៅចំមុខកុមារដើម្បីជៀសវាងការប្រឈមមុខដាក់គាត់។

**អ្វីដែលគួរឱ្យចាប់អារម្មណ៍ និង/ឬថ្មី៖ (ស្លាយ ៨០-៨១)**

- *យើងពិបាកស្វែងរកកន្លែងឯកជន ប៉ុន្តែឥឡូវនេះយើងយល់ថាវាអាចធ្វើឱ្យមនុស្សមានអារម្មណ៍សុវត្ថិភាព*
- *ការយល់ដឹងថាកន្លែងបែបកុមារមេត្រី អាចជួយឱ្យកុមារមានអារម្មណ៍ធូរស្រាលជាងមុន*
- *មិនបានដឹងថា ឯកសណ្ឋានអាចជាការរារាំងដល់កុមារទេ*
- *ប្រើកន្លែងនៅការិយាល័យអង្គការមិនមែនរដ្ឋាភិបាលប្រសិនបើយើងមិនមានកន្លែងដែលមានសុវត្ថិភាពសម្រាប់កុមារ។ វាអាចមិនសូវស្រួលសម្រាប់យើង ប៉ុន្តែមានប្រយោជន៍សម្រាប់កុមារ។*

**អត្ថប្រយោជន៍សម្រាប់កុមារ៖**

- *ប្រសិនបើពួកគេមានអារម្មណ៍ថា មានសុវត្ថិភាពជាងនេះ តើពួកគេអាចចែករំលែកបានច្រើនជាងនេះដែរឬទេ?*

**ដើម្បីធានាថាមានការអនុវត្តតាមគោលការណ៍នៃការមានសុវត្ថិភាពសម្រាប់កុមារ ក្នុងនាមយើងជាមន្ត្រីនគរបាលយើងគួរ៖**

- *យើងអាចស្នើសុំធនធានសម្រាប់បន្ទប់កុមារមេត្រី នៅការិយាល័យរបស់យើង ប្រសិនបើមិនមានទេ យើងអាចធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីប្រើប្រាស់កន្លែងឯកជនប្រសិនបើពួកគេមាន ដូចជានៅ A21 ក្នុងខេត្តសៀមរាប។*

៧. អនុញ្ញាតឱ្យក្រុមមានពេលវេលាគ្រប់គ្រាន់ ដើម្បីពិភាក្សា និងបង្កើតគំនិត ហើយសរសេរនៅលើផ្ទាំងក្រដាសធំ។ តាមក្បួនខ្នាតទូទៅ អនុញ្ញាតយ៉ាងហោចរយៈពេល **២០នាទី** ក្នុងមួយប្រធានបទសម្រាប់ក្រុមនីមួយៗ។

ដូច្នេះប្រសិនបើក្រុមពិភាក្សា **២ ប្រធានបទ = ៤០ នាទី ៣ ប្រធានបទ = ៦០ នាទី។**

៨. ពេលបានបញ្ចប់រួចរាល់ហើយ សូមអនុញ្ញាតឱ្យក្រុមបង្ហាញគំនិតរបស់ពួកគេទៅកាន់ក្រុមដទៃទៀត។ ក្នុងនាមជាអ្នកសម្របសម្រួល អ្នកអាចផ្តល់យោបល់លើគំនិតដែលមានប្រយោជន៍ និងធ្វើកំណត់ចំណាំអំពីអ្វីដែលអាចទាមទារឱ្យមានសកម្មភាពបន្ថែមទៀត ដែលចាំបាច់ត្រូវបញ្ចូលទៅក្នុងកិច្ចពិភាក្សា សកម្មភាព ឬរបាយការណ៍។

៩. នៅចុងបញ្ចប់នៃវគ្គ សុំឱ្យក្រុមផ្តល់មតិយោបល់ជាទូទៅអំពី «អត្ថប្រយោជន៍នៃការការអនុវត្តបែបកុមារមេត្រី»។

## សកម្មភាព

១. សួរក្រុមថាតើពួកគេធ្លាប់បានឮអំពី «ការអនុវត្តបែបកុមារមេត្រី» កាលពីមុនទេ (ជួនកាលគេហៅវាថា «ការអនុវត្តដោយផ្តោតលើកុមារ» «ការផ្តោតលើកុមារជាសំខាន់» ឬពាក្យស្រដៀងគ្នាផ្សេងទៀត)។

សួរពួកគេថាតើ «ការអនុវត្តបែបកុមារមេត្រី» មានន័យយ៉ាងដូចម្តេច។ ស្តាប់ការឆ្លើយតបរបស់ពួកគេហើយសរសេរគំនិតរបស់ពួកគេនៅលើ ផ្ទាំងក្រដាសធំ ឬក្តារខៀន ប្រសិនបើអ្នកចង់ធ្វើដូច្នេះ ដើម្បីឱ្យមនុស្សដទៃទៀតក្នុងក្រុមអាចមើលឃើញ។

២. **ការធ្វើការជាក្រុមតូចៗ - វិធីសាស្ត្រចូលរួម៖**

បែងចែកក្រុមធំជាក្រុមតូចៗ (ប្រហែលមានគ្នាពី ៤-៦នាក់) ហើយចែក**ប្រធានបទ**កុមារមេត្រី (ខុសៗគ្នា) ដែលអ្នកបានរៀបចំរួចហើយ ហើយក៏ចែកទំព័រ ឬផ្នែកនៃសន្លឹកកិច្ចការទាក់ទងនឹងប្រធានបទមានសុវត្ថិភាពសម្រាប់កុមារទៅកាន់ក្រុមនីមួយៗផងដែរ។

បន្ទាប់មក អ្នកអាចសុំឱ្យក្រុមតូចៗទាំងនោះ ធ្វើការលើប្រធានបទផ្សេងៗគ្នា ដែលអ្នកបានផ្តល់ជូនពួកគេ ដោយឱ្យពួកគេធ្វើកំណត់ចំណាំអំពីអ្វីដែលមន្ត្រីនគរបាលគួរតែធ្វើនៅក្នុងការបំពេញការងាររបស់ពួកគេ។

បន្ទាប់ពីបានធ្វើចប់រួចរាល់ហើយ ពួកគេអាចចែករំលែកគំនិតរបស់ពួកគេនៅក្នុងបទបង្ហាញនៅក្នុងក្រុមធំ។


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

ក្រុមនីមួយៗអាចធ្វើបទបង្ហាញដោយសង្ខេបអំពីប្រធានបទមានសុវត្ថិភាពសម្រាប់កុមារ និងចែករំលែកគំនិតយោបល់របស់ពួកគេជាមួយក្រុមដទៃ។

យើងសូមធ្វើការណែនាំឱ្យក្រុមទាំងអស់ធ្វើការលើប្រធានបទ «វិធីសាស្ត្រដោយគិតអំពីភាពរសើបចំពោះយេនឌ័រ» ព្រមទាំងប្រធានបទយ៉ាងហោចណាស់ពីរផ្សេងទៀត។

ឧទាហរណ៍៖ ក្រុម (ក) ធ្វើលើ៖

ការប្រើប្រាស់នីតិវិធីការអនុវត្តបែបកុមារមេត្រី - វិធីសាស្ត្រដោយផ្តោតលើកុមារជាសំខាន់

ផ្តល់អាទិភាពដល់សុខុមាលភាព និងប្រយោជន៍ដ៏ល្អបំផុតសម្រាប់កុមារ៖

វិធីសាស្ត្រដោយគិតអំពីភាពរសើបចំពោះយេនឌ័រ៖

ក្រុម (ខ) ធ្វើលើ៖

ធ្វើការក្នុងភាពជាដៃគូដើម្បីធានាបាននូវវិធីសាស្ត្រពហុវិស័យប្រកបដោយប្រសិទ្ធភាពបង្កើតបរិយាកាសដែលមានសុវត្ថិភាពសម្រាប់កុមារ៖

វិធីសាស្ត្រដោយគិតអំពីភាពរសើបចំពោះយេនឌ័រ៖

ក្រុម (គ) ធ្វើលើ៖

កែសម្រួលការប្រើភាសាស្របទៅតាមអាយុ និងកម្រិតនៃការអភិវឌ្ឍរបស់កុមារ៖

វិធីសាស្ត្រដោយគិតអំពីភាពរសើបចំពោះយេនឌ័រ៖

កុមារដែលមានពិការភាព៖

ក្រុមអាចមានប្រធានបទបី ឬច្រើនដើម្បីពិភាក្សា អាស្រ័យលើពេលវេលាដែលមាន។ ល្អបំផុត ប្រធានបទទាំងអស់ត្រូវបានចែករំលែកស្មើគ្នាក្នុងចំណោមក្រុមអ្នកចូលរួមទាំងអស់។

៣. ក្រុមនីមួយៗគួរតែទទួលបានផ្ទាំងក្រដាសធំ និងប៊ិចពណ៌គូសចំណាំ ហើយត្រូវការការណែនាំយ៉ាងច្បាស់លាស់។ ពួកគេនឹងត្រូវបានរំពឹងថាត្រូវធ្វើការជាក្រុមជាមួយគ្នាយ៉ាងសកម្ម ដោយបំពេញកិច្ចការមួយចំនួនដូចខាងក្រោម៖ (**ស្លាយ ៧៧ ក៏បង្ហាញពីជំហានទាំងបួនដើម្បីបំពេញកិច្ចការនេះផងដែរ**)

ក.អានកំណត់ចំណាំសម្រាប់ប្រធានបទនីមួយៗដែលមាននៅលើសន្លឹកកិច្ចការ

ខ.ធ្វើការឆ្លុះបញ្ចាំងនិងពិភាក្សាអំពីកំណត់ចំណាំ៖កត់សម្គាល់អ្វីដែល **គួរឱ្យចាប់អារម្មណ៍ និង/ឬថ្មីសម្រាប់ពួកគេ**។ (ពួកគេក៏អាចកត់សម្គាល់សំណួរជាក់លាក់ណាមួយ ដែលពួកគេមានទាក់ទងនឹងប្រធានបទនេះផងដែរ ប្រសិនបើពួកគេត្រូវការបញ្ជាក់បន្ថែម)

គ.គូសចំណាំអ្វីៗដែលពួកគេគិតថា មាន**អត្ថប្រយោជន៍**ទាក់ទងនឹងគោលការណ៍ និងការណែនាំអំពីប្រធានបទនេះ

ឃ.កត់សម្គាល់ **អ្វីខ្លះដែលអ្នកត្រូវធ្វើដើម្បីអនុវត្តន៍តាមតម្រូវការទាំងនេះ?**

## ខ្លឹមសារគន្លឹះ និងសកម្មភាពតស៊ូមតិ

- ក្នុងនាមជាមន្ត្រីនគរបាលមានតួនាទីយ៉ាងសំខាន់ក្នុងការការពារនិងលើកកម្ពស់សិទ្ធិរបស់កុមារនៅក្នុងគ្រប់ផ្នែក នៃការងាររបស់យើង។
- ការនេះក៏មានន័យថា ត្រូវធ្វើតាមការអនុវត្តបែបកុមារមេត្រី។
- ការទទួលបានភស្តុតាងកាន់តែល្អប្រសើរជាងមុន ជួយសម្រួលដល់ការស៊ើបអង្កេតកាន់តែមានប្រសិទ្ធភាព និងអាចបង្កើនលទ្ធភាព នៃដំណើរការកាន់តែរលូន និងលទ្ធផលជោគជ័យផងដែរ។
- កុមារ និងយុវជនដែលមានអាយុខុសគ្នា និងដំណាក់កាលនៃការអភិវឌ្ឍខុសគ្នាដែលទទួលរងការរំលោភបំពាន និងការកេងប្រវ័ញ្ចពិបាកនឹងជឿទុកចិត្តលើបុគ្គលណាម្នាក់ រួមទាំងមន្ត្រីនគរបាលផងដែរ។
- ប្រសិនបើយើងប្រើវិធីសាស្ត្រកុមារមេត្រីដោយគោរពនិងការលើកកម្ពស់សិទ្ធិរបស់ពួកគេ ការធ្វើបែបនេះអាចជួយយើងកសាងទំនុកចិត្តជាមួយកុមាររងគ្រោះ សាក្សី និងក្រុមគ្រួសាររបស់ពួកគេ។
- ប្រសិនបើយើងបង្កើនទំនុកចិត្តពួកគេកាន់តែខ្លាំងជាងមុន នោះកុមាររងគ្រោះនឹងមានអារម្មណ៍ថាមានសុវត្ថិភាពជាងមុន។ការនេះនឹងនាំឱ្យមានកិច្ចសហការ និងកិច្ចសហប្រតិបត្តិការកាន់តែប្រសើរឡើង ហើយសេចក្តីថ្លែងការណ៍និងភស្តុតាងដែលពួកគេផ្តល់ឱ្យនឹងទំនងជាកាន់តែល្អប្រសើរ

## មេរៀនទី៧

# នីតិវិធីនៃការស៊ើបអង្កេត

## លទ្ធផលរំពឹងទុក៖

អ្នកចូលរួមនឹង៖

- ការយល់ដឹងពីដំហានផ្សេងៗ នៃការស៊ើបអង្កេតបទល្មើស
- ការយល់ដឹងពីបទល្មើស ធាតុផ្សំនៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ ក្នុង និងក្រៅប្រព័ន្ធអនឡាញ

## ធនធានដែលត្រូវការ៖

ឧបសម្ព័ន្ធ "ច" (ទំព័រ ១៤៦) ស្លាយ (ពីស្លាយ ៨២) ក្រដាសផ្ទាំងធំដែលមានដំណាក់កាលនីមួយៗ នៃការស៊ើបអង្កេតសរសេរនៅផ្នែកខាងលើ។

## កំណត់ចំណាំ៖

មន្ត្រីនគរបាលនឹងបានសិក្សាអំពីដំហាន និងកិច្ចការនៃការស៊ើបអង្កេតមុនៗ នៅក្នុងការបណ្ដុះបណ្ដាល (ជាមូលដ្ឋាន) របស់ខ្លួន ដូច្នេះអ្នកចូលរួមគួរតែដឹងអំពីប្រធានបទនេះ។

ទោះយ៉ាងណាស់ ដូចដែល TNA បានបង្ហាញ ជាញឹកញាប់មានការភ័ន្តច្រឡំមួយចំនួនអំពីបទឧក្រិដ្ឋក្រៅប្រព័ន្ធអនឡាញ និងតាមប្រព័ន្ធអនឡាញ របៀបដែល OCSEA ទាក់ទងគ្នាទៅវិញទៅមក ហើយការនេះចាំបាច់ត្រូវមានការបញ្ជាក់ឱ្យបានច្បាស់ទាក់ទងនឹងដំណើរការស៊ើបអង្កេត និងតួនាទីរបស់មន្ត្រីនគរបាលនៅក្នុងដំណើរការងារនោះ។

ដូច្នេះ វគ្គបណ្ដុះបណ្ដាលនេះត្រូវបានរៀបចំឡើង ដើម្បីរំលឹកអំពីដំហាន និងកិច្ចការសំខាន់ៗ នៃការស៊ើបអង្កេត និងផ្ដល់ឱកាសសម្រាប់អ្នកចូលរួម ដើម្បីឆ្លុះបញ្ចាំងពីកិច្ចការបន្ថែមណាមួយ ដែលអាចត្រូវការនៅពេលស៊ើបអង្កេតបទឧក្រិដ្ឋ OCSEA ។

យើងបានដឹងហើយថា បទឧក្រិដ្ឋ OCSEA ជារឿយៗអាចពាក់ព័ន្ធនឹងធាតុផ្សំនៃបទឧក្រិដ្ឋទាំងក្រៅប្រព័ន្ធអនឡាញ និងតាមប្រព័ន្ធអនឡាញ ហើយអ្នកចូលរួមគួរចងចាំអំពីករណីនេះ។

ឥឡូវនេះ ដោយអ្នកចូលរួមក៏បានសិក្សាអំពីសិទ្ធិកុមារ និងធាតុផ្សំសំខាន់ៗនៃការអនុវត្តស្ដីពីកុមារមេត្រី ក៏មានប្រយោជន៍ផងដែរក្នុងការរំលឹកពួកគេអំពីរបៀបដែលពួកគេអាចបញ្ចូលមេរៀនទាំងនោះទៅក្នុងដំណាក់កាលនីមួយៗនៃការស៊ើបអង្កេត។


ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

## កំណត់ពន្យល់បន្ថែមសម្រាប់ការសម្របសម្រួល៖

១. សូមស្វាគមន៍ក្រុម និងចែករំលែកលទ្ធផល ដែលបានគ្រោងទុកនៃវគ្គបណ្តុះបណ្តាល ដោយប្រើកំណត់សម្គាល់ និងតាមស្លាយខាងលើ។ សូមពន្យល់ថាយើងនឹងប្រើប្រាស់សកម្មភាពនិងធនធានផ្សេងៗដើម្បីសម្រេចបានលទ្ធផលទាំងនោះ។

២. **ប្រើស្លាយ**ដើម្បីបង្ហាញដោយសង្ខេបអំពីដំណាក់កាលនៃការស៊ើបអង្កេត។

សូមពន្យល់ថា ដំណាក់កាលនៃការស៊ើបអង្កេតទាំងនេះ អាចមានភាពខុសប្លែកគ្នាបន្តិចបន្តួចទៅនឹងគំនិតដែលពួកគេបានលើកឡើង ប៉ុន្តែទាំងនេះគឺជាដំណាក់កាលដែលយើងនឹងប្រើប្រាស់នៅក្នុងការបណ្តុះបណ្តាលផ្សេងទៀត ដើម្បីជួយយើងឱ្យកាន់តែយល់ច្បាស់ពីតួនាទីរបស់មន្ត្រីនគរបាល និងសកម្មភាពដែលយើងគួរធ្វើតាមដំណាក់កាលនីមួយៗក្នុងនាមជាមន្ត្រីនគរបាល។ ដំណាក់កាលនីមួយៗត្រូវបានសង្ខេបនៅក្នុងប្រអប់ខាងក្រោម៖

១.ទទួលពាក្យបណ្តឹង
២.ដំណាក់កាលស៊ើបអង្កេតបឋម
៣.ដំណាក់កាលសួរចម្លើយ/ប្រមូលភស្តុតាង
៤.សរសេររបាយការណ៍សំយោគ និងដាក់របាយការណ៍ទៅតុលាការ និងធ្វើរបាយការណ៍
៥.ដំណាក់កាលព្រះរាជអាជ្ញា
៦.ដំណាក់កាលចៅក្រមស៊ើបសួរ
៧.ការជំនុំជម្រះក្តី

៣. ពន្យល់អ្នកចូលរួមថា យើងនឹងធ្វើការជាក្រុមតូចដើម្បីពិភាក្សា និង**កំណត់កិច្ចការជាក់លាក់**នៅក្នុងការស៊ើបអង្កេតដែលមន្ត្រីនគរបាលទទួលខុសត្រូវទាក់ទងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ។ ពន្យល់ថា មានភាពខុសប្លែកគ្នាបន្តិចបន្តួចនៅក្នុងវគ្គនេះ យើងនឹងផ្តោតលើ OCSEA ទាក់ទងនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។

រំលឹកអ្នកចូលរួមថា នៅក្នុងបទឧក្រិដ្ឋ OCSEA ជាច្រើន (មិនមែនទាំងអស់) អាចត្រូវបានប្រព្រឹត្តទាំង**តាមប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ**។ដូច្នេះនៅពេលគិតអំពីកិច្ចការនេះពួកគេត្រូវចងចាំអំពីចំណុចនេះ ហើយពិចារណាពីរបៀបដែលករណីនេះអាចមានឥទ្ធិពលលើតួនាទី និងកិច្ចការដែលពួកគេធ្វើ។


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

៤. បំបែកអ្នកចូលរួមទៅជា ៧ក្រុមតូច (អាស្រ័យលើចំនួនអ្នកចូលរួមដោយក្នុងមួយក្រុមអាចមានចំនួន ៥, ៦ ឬ ៧នាក់)។ ដាក់ក្រុមនីមួយៗនៅតាមក្រដាសផ្ទាំងធំ និងពន្យល់ទៅកាន់ក្រុមថា ពួកគេត្រូវធ្វើការជាក្រុមយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព។

នៅពេលសកម្មភាពចាប់ផ្តើម ពួកគេនឹងមានពេលត្រឹមតែ **៣នាទី**ប៉ុណ្ណោះ ដើម្បីពិភាក្សាយ៉ាងឆាប់រហ័សអំពីតួនាទី និងភារកិច្ចរបស់មន្ត្រីនគរបាលចំពោះកិច្ចការនីមួយៗ ហើយសរសេរគំនិតរបស់ពួកគេនៅលើក្រដាសផ្ទាំងធំ (សូមមើលឧទាហរណ៍ខាងក្រោម)។ ពន្យល់អ្នកចូលរួមថា នៅពេលចាប់ផ្តើមសកម្មភាពពួកគេគួរតែសរសេរអំពីគំនិតរបស់ខ្លួនឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន នៅលើក្រដាសផ្ទាំងធំតាមពេលវេលាដែលពួកគេមាន។

នៅពេលអ្នកផ្តុំកញ្ចែឬចុចកណ្តឹងក្រុមត្រូវប្តូរទីតាំងភ្លាមៗទៅកាន់ក្រដាសផ្ទាំងធំបន្ទាប់ មកបន្តរហូតដល់ក្រុមទាំងអស់បានបញ្ចប់កិច្ចការនៅលើក្រដាសផ្ទាំងធំនីមួយៗ។

ពន្យល់អ្នកចូលរួមថា ពួកគេមិនត្រូវចម្លងមតិយោបល់ពីក្រុមផ្សេងទៀតឡើយ ប៉ុន្តែត្រូវបន្ថែមកិច្ចការថ្មី ដោយផ្អែកលើគំនិតរបស់ពួកគេ។

៥. បន្ទាប់មក ឆ្លៀតពេលដើរជុំវិញក្រដាសផ្ទាំងធំនីមួយៗជាមួយក្រុមធំ ដើម្បីមើលគំនិតរបស់ពួកគេ។

ប្រហែលជាមិនចាំបាច់ផ្តល់មតិយោបល់ច្រើនលើខ្លឹមសារនៅពេលនេះទេ លុះត្រាតែមានតម្រូវការក្នុងការបញ្ជាក់ខ្លឹមសារជាក់លាក់ សួរសំនួរ និង/ឬធ្វើការកត់សម្គាល់ដែលចាំបាច់ដើម្បីពង្រឹងការរៀនសូត្រ។

រំលឹកក្រុមថាបទឧក្រិដ្ឋOCSEAអាចត្រូវបានប្រព្រឹត្ត**តាមប្រព័ន្ធអនឡាញទាំងស្រុង** ហើយកិច្ចការសម្រាប់មន្ត្រីនគរបាលអាចប្រែប្រួល យោងទៅតាមករណីនីមួយៗ។ក្នុងករណីដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្ត**ក្រៅប្រព័ន្ធអនឡាញនិងតាមប្រព័ន្ធអនឡាញ**អាចមានកិច្ចការស្រដៀងគ្នា(ចំណាយពេលប្រហែល ៣០នាទី សម្រាប់ការពន្យល់ពីចំណុចនេះ)។

នៅពេលដែលអ្នកបានបញ្ចប់កិច្ចការនេះ សូមថ្លែងអំណរគុណដល់អ្នកចូលរួមសម្រាប់គំនិតរបស់ពួកគេ ហើយសម្រាករយៈពេលខ្លី។

៦. នៅពេលអ្នកត្រលប់ចូលវិញ សូមប្រើស្លាយដែលអ្នកបានរៀបចំ ដើម្បីចែករំលែកគំនិតទាក់ទងនឹងកិច្ចការសម្រាប់ដំណាក់កាលនីមួយៗ។ ស្លាយផ្សេងទៀតក៏នឹងត្រូវធ្វើដូចគ្នា ប៉ុន្តែអាចមានកិច្ចការបន្ថែមដែលត្រូវបញ្ជាក់។


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

៧. នៅពេលអ្នកបង្ហាញស្លាយនីមួយៗ សូមរំលឹកក្រុមអំពីមេរៀន ដែលយើងបានរៀនរួចហើយ ទាក់ទងនឹងការលើកកម្ពស់**សិទ្ធិកុមារ** និងធានា**ការអនុវត្តនីតិវិធីបែបកុមារមេត្រី។** អ្នកក៏អាចឱ្យអ្នកចូលរួមបញ្ចេញមតិអំពីរបៀបធ្វើកិច្ចការទាំងនោះនៅលើស្លាយនីមួយៗ។ (ការនេះនឹងពង្រឹងការរៀនសូត្ររបស់ពួកគេ ហើយរំលឹកពួកគេថា សិទ្ធិកុមារ និងការអនុវត្តបែបកុមារមេត្រី គឺជាលក្ខខណ្ឌតម្រូវចាំបាច់ក្នុងតួនាទីជាមន្ត្រីនគរបាល)។

៨. នៅពេលដែលអ្នកបានបញ្ចប់ការបង្ហាញស្លាយសូមចែកឧបសម្ព័ន្ធ"ច" ការស៊ើបអង្កេតអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារដែលស្របតាមគោលការណ៍ច្បាប់។ ទៅឱ្យអ្នកចូលរួម និងប្រាប់ឱ្យពួកគេរក្សាទុកសម្រាប់ជាឯកសារយោងបន្ថែម។

## សកម្មភាព

១. សួរអ្នកចូលរួមថា តើពួកគេអាចបញ្ចេញមតិអំពី **ជំហាន (ឬដំណាក់កាល) ផ្សេងៗ** នៃការស៊ើបអង្កេត តាំងពីពេលចាប់ផ្តើមរហូតដល់ចប់បានដែរឬទេ?

ទុកពេលវេលាខ្លះសម្រាប់ការចែករំលែក ហើយប្រសិនបើចាំបាច់សរសេរគំនិតមួយចំនួនរបស់ពួកគេនៅលើក្រដាសផ្ទាំងធំ/ក្តារខៀន ដោយសង្ឃឹមថា ពួកគេនឹងចងចាំព័ត៌មានសំខាន់ៗនេះ ពីការបណ្តុះបណ្តាលមូលដ្ឋានរបស់ពួកគេ។

២. អាស្រ័យលើចំនួនអ្នកចូលរួមសូមបំបែកពួកគេទៅជាក្រុមតូចៗហើយផ្តល់ឱ្យពួកគេនូវច្បាប់ចម្លងនៃឧបសម្ព័ន្ធ"ច" **ការស៊ើបអង្កេតអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ ដែលស្របតាមគោលការណ៍ច្បាប់។**

សូមពន្យល់ថា ពួកគេអាចប្រើសន្លឹកកិច្ចការនេះ ជាការរំលឹកអំពីជំហានសំខាន់ៗ និងបញ្ចូលប្រអប់អត្ថបទ (ទទេ) សម្រាប់ពួកគេដើម្បីសរសេរពីគំនិតរបស់ពួកគេ ប្រសិនបើពួកគេចង់ធ្វើដូច្នេះ។

សូមដាក់ក្រដាសផ្ទាំងធំទទេចំនួន៧នៅជុំវិញបន្ទប់(នៅលើជញ្ជាំងឬនៅលើតុ)ដោយសរសេរដំណាក់កាលស៊ើបអង្កេតនីមួយៗនៅផ្នែកខាងលើ។ ដូច្នេះ អ្នកគួរមានក្រដាសផ្ទាំងធំ (ទទេ) សម្រាប់ដំណាក់កាលនីមួយៗ។

| ទទួលពាក្យបណ្តឹង | ដំណាក់កាលស៊ើបអង្កេតបឋម | ដំណាក់កាលសួរចម្លើយ/ប្រមូលភស្តុតាង | សរសេរ និងធ្វើរបាយការណ៍សំយោគ | ដំណាក់កាលព្រះរាជអាជ្ញា | ដំណាក់កាលចៅក្រមស៊ើបសួរ | ការជំនុំជម្រះក្តី |
|---|---|---|---|---|---|---|
| | | | | | | |


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

៣. បំបែកអ្នកចូលរួមទៅជា៧ក្រុមតូចៗ(អាស្រ័យលើចំនួនអ្នកចូលរួមដោយក្នុងមួយក្រុមអាចមានចំនួន ៥, ៦ ឬ ៧នាក់)។ ដាក់ក្រុមនីមួយៗនៅតាមក្រដាសផ្ទាំងធំ និងពន្យល់ទៅកាន់ក្រុមថា ពួកគេត្រូវធ្វើការជាក្រុមយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព។

៤. ចាប់ផ្ដើមធ្វើកិច្ចការហើយត្រូវប្រាកដថាអ្នកឱ្យក្រុមនីមួយៗផ្លាស់ប្ដូរទីតាំងបន្ទាប់ពីរយៈពេល **៣នាទី** រហូតដល់ក្រុមទាំងអស់បានបញ្ចប់កិច្ចការ។ លំហាត់នេះនឹងសាកល្បងសមត្ថភាពរបស់ពួកគេក្នុងការធ្វើការងារជាក្រុមយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព ចំណេះដឹងអំពីកិច្ចការរបស់ពួកគេក្នុងដំណាក់កាលនីមួយៗនៃការស៊ើបអង្កេត ហើយក៏នឹងមានភាពរីករាយផងដែរ។ការធ្វើការយ៉ាងឆាប់រហ័សនឹងបង្កើនសមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយបញ្ហា។

## ខ្លឹមសារគន្លឹះ និងសកម្មភាពតស៊ូមតិ



### ភារកិច្ចសម្រាប់នគរបាលក្នុងដំណាក់កាលទទួលបណ្ដឹង៖

- ជួបជាមួយអ្នកដាក់ពាក្យបណ្ដឹងនិងអាណាព្យាបាល/គ្រួសារ (ឬបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដំបូង ឬមនុស្សផ្សេងទៀត)
- ទទួលយកសេចក្ដីរាយការណ៍ដំបូងពីដើមបណ្ដឹង កុមាររងគ្រោះ និងសាក្សី ឬអ្នករាយការណ៍ព័ត៌មាន
- ប្រសិនបើករណីទាំងនេះជា «បទល្មើសជាក់ស្ដែង» នគរបាលអាចចាប់ខ្លួនជនសង្ស័យភ្លាមៗ ប៉ុន្តែប្រសិនបើមិនមែនជាបទល្មើសជាក់ស្ដែងទេ នគរបាលនឹងស្នើសុំការស៊ើបអង្កេតស្រាវជ្រាវ ទៅព្រះរាជអាជ្ញា ព្រះរាជអាជ្ញា...។ល។

**សូមចាំថា ត្រូវអនុវត្តភារកិច្ចទាំងនេះ ដោយយោងតាមការណែនាំអំពីការអនុវត្តបែបកុមារមេត្រី។ សូមមើល ឯកសារស្ដីអំពីសិទ្ធិកុមារក្នុងឧបសម្ព័ន្ធ"យ" ជាឯកសារយោង។**

### ភារកិច្ចរបស់នគរបាលក្នុងដំណាក់កាលស៊ើបអង្កេតបឋម៖

- រៀបចំលិខិត ព័ត៌មានសង្ខេបអង្គហេតុ ដើម្បីស្នើសុំទៅថ្នាក់ដឹកនាំរបស់ខ្លួន និងព្រះរាជអាជ្ញា ដើម្បីធ្វើការស៊ើបអង្កេតបឋម។
- ការកំណត់អត្តសញ្ញាណជនរងគ្រោះ (ការសម្ភាសជនរងគ្រោះ និងការសម្ភាសសាក្សី យោងតាមការណែនាំស្ដីអំពីការអនុវត្តបែបកុមារមេត្រី)។
- ការពិនិត្យសុខភាព (ប្រសិនបើចាំបាច់-ករណីខ្លះប្រហែលជាមិនចាំបាច់ទេ ហើយបទល្មើស OCSEA ខ្លះក៏មិនចាំបាច់ដែរ)។

- ការប្រមូលភស្តុតាងរូបវន្តដំបូង (ប្រសិនបើពាក់ព័ន្ធ - ប្រហែលជាមិនចាំបាច់ទេក្នុងករណីដែលកើតឡើងតាមប្រព័ន្ធអនឡាញទាំងស្រុង)។
- ការប្រមូលលើកដំបូងនៃការរឹបអូស និងការរក្សាទុកប្រកបដោយសុវត្ថិភាពឬការរក្សាទុកភស្តុតាងឌីជីថល/ឧបករណ៍ (ការធ្វើបែបនេះតម្រូវឱ្យមានការបណ្តុះបណ្តាលអ្នកឯកទេសបច្ចេកទេសឬឌីជីថលបន្ថែមទៀត-មិនទាន់ធ្វើចប់សព្វគ្រប់នៅឡើយទេ)។
- ការកំណត់អត្តសញ្ញាណជនសង្ស័យ (ឈ្មោះ ភេទ ថ្ងៃ ខែ ឆ្នាំកំណើត សញ្ជាតិ មុខរបរ អាសយដ្ឋាន...។ល។)
- ប្រសិនបើ និងពេលប្រមូលបានភស្តុតាងគ្រប់គ្រាន់

**សូមចាំថា ត្រូវអនុវត្តភារកិច្ចទាំងនេះ ដោយយោងតាមការណែនាំអំពីការអនុវត្តបែបកុមារមេត្រី។ សូមមើល ឯកសារស្តីអំពីសិទ្ធិកុមារក្នុងឧបសម្ព័ន្ធ"យ" ជាឯកសារយោង។**

**ដំណាក់កាលស្តាប់ចម្លើយ/ប្រមូលភស្តុតាង៖**

**ភារកិច្ចនគរបាល៖** (សូមកត់ចំណាំ៖ ការបណ្តុះបណ្តាលជាក់លាក់ និង ការផ្តោតទៅលើការកំណត់អត្តសញ្ញាណ ការរឹបអូស ការរក្សាទុកឧបករណ៍ឌីជីថល និងភស្តុតាងត្រូវបានគ្រោងទុករួចហើយ ទោះបីមិនទាន់បានកើតឡើងនៅឡើយក៏ដោយ)។

- ការស្តាប់ចម្លើយជនសង្ស័យដោយផ្អែកលើបទល្មើសព្រហ្មទណ្ឌធ្វើឱ្យស្របតាមនីតិវិធីច្បាប់។
- កំណត់រកកន្លែងកើតហេតុ (ក្នុងករណី OCSEA ខ្លះ៖ «កន្លែងកើតហេតុ» អាចមានទាំងនៅលើប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ)។
- ការស្វែងរកកន្លែងកើតហេតុឌីជីថលលើកដំបូង (មានតែក្នុងករណីតាមប្រព័ន្ធអនឡាញតែប៉ុណ្ណោះ អាចជាឧបករណ៍អេឡិកត្រូនិក និងឌីជីថល កម្មវិធីអនឡាញ បណ្តាញសង្គម កម្មវិធីក្លោដ ឧបករណ៍ផ្ទុកឯកសារ គណនីអ៊ីម៉ែលជាដើម។ ដូច្នេះអាចទាមទារការបណ្តុះបណ្តាល និងជំនាញបន្ថែម រួមទាំងកិច្ចសហប្រតិបត្តិការជាមួយអង្គភាពជំនាញពាក់ព័ន្ធផងដែរ។)។
- រាយការណ៍ទៅថ្នាក់ដឹកនាំ ព្រះរាជអាជ្ញា ដើម្បីសុំគោលការណ៍ការចង្អុលបង្ហាញ ឬដឹកនាំបន្ថែម ។

សូមចាំថា ត្រូវអនុវត្តន៍ភារកិច្ចទាំងនេះ ដោយយោងតាមការណែនាំអំពីការអនុវត្តបែបកុមារមេត្រី។ សូមមើល ឯកសារស្តីអំពីសិទ្ធិកុមារក្នុងឧបសម្ព័ន្ធ "ឃ" ជាឯកសារយោង។

**ការសរសេរបាយការណ៍សំយោគ៖**

- សរសេរបាយការណ៍សំណុំរឿង និងរៀបចំកញ្ចប់ភស្តុតាងតាមនីតិវិធីច្បាប់ ដើម្បីបញ្ជូនទៅថ្នាក់ដឹកនាំពិនិត្យ មុនសម្រេចបញ្ជូនទៅតុលាការ។
- ភ្ជាប់ឯកសារគាំទ្រទាំងអស់ (ពាក្យបណ្តឹងរបស់ដើមបណ្តឹង សេចក្តីថ្លែងការណ៍របស់ជនរងគ្រោះ សាក្សី និងជនសង្ស័យ កំណត់ហេតុឃាត់ខ្លួន......។ល។)
- វិញ្ញាបនប័ត្រវេជ្ជសាស្ត្រ (គោលសល្យវិច្ឆ័យ ប្រសិនបើមាន)
- ភស្តុតាងគាំទ្រផ្សេងទៀត-ភស្តុតាងឌីជីថល(ត្រូវទាមទារមានការបណ្តុះបណ្តាលបន្ថែមស្តីអំពីរបៀបកំណត់អត្តសញ្ញាណ ការរក្សាទុកប្រកបដោយសុវត្ថិភាព និងការរក្សាទុកភស្តុតាងឌីជីថល)។

## មេរៀនទី៨

# ការកសាងភាពជាដៃគូ និងកិច្ចសហការជាតិ និងអន្តរជាតិ

## លទ្ធផលរំពឹងទុក៖

អ្នកចូលរួមនឹង៖

- ស្វែងយល់ការស្វែងរកជំនួយ និងការសហការជាមួយមន្ត្រីនគរបាលទាក់ទងនឹង OCSEA។
- ស្វែងយល់ពីតម្រូវការរបស់កុមារ និងអ្នកផ្សេងទៀតដើម្បីជួយដល់ពួកគេ។
- ស្វែងយល់អំពី "ការអនុវត្តល្អ" និងរបៀបដែលវាអាចនាំទៅរកលទ្ធផលជោគជ័យ។

## កំណត់ចំណាំ៖

មកដល់ពេលនេះនៅក្នុងវគ្គបណ្តុះបណ្តាល អ្នកចូលរួមត្រៀមខ្លួន ដើម្បីអនុវត្តន៍នូវអ្វីដែលពួកគេបានរៀនចំពោះករណីសិក្សា ហើយធ្វើការរួមគ្នាអំពីរបៀបឆ្លើយតបយ៉ាងសមស្របទៅនឹងតម្រូវការរបស់កុមារ យុវជន និង គ្រួសារដែលរងគ្រោះដោយ OCSEA។

អ្នកចូលរួមបានដឹងពីរបៀបដែលកុមារប្រើប្រាស់អ៊ីនធឺណិត ប្រភេទបទឧក្រិដ្ឋ OCSEA ច្បាប់ពាក់ព័ន្ធជាធរមាន និងរបៀបដែលបទល្មើស មានផលប៉ះពាល់ដល់កុមារ និងគ្រួសារ។

យើងក៏បានដឹងផងដែរអំពីជាតុផ្សំសំខាន់ៗនៃសិទ្ធិកុមារ (ក្នុង និងក្រៅប្រព័ន្ធអនឡាញ) ជាតុផ្សំនៃការអនុវត្តបែបកុមារមេត្រី សារៈសំខាន់ និងអត្ថប្រយោជន៍នៃការអនុវត្តតាមនីតិវិធីទាំងនោះ។

ទោះយ៉ាងណា មុនពេលយើងអនុវត្តមេរៀនដែលយើងបានរៀនចំពោះករណីសិក្សា មានវគ្គសិក្សាដ៏សំខាន់មួយផ្សេងទៀត។ មេរៀនមានសារៈសំខាន់ ព្រោះវាផ្តោតលើការយកចិត្តទុកដាក់របស់យើងលើបទពិសោធន៍ច្បាប់របស់កុមារដែលរងគ្រោះដោយ OCSEA និងទទួលបានការអនុវត្តនីតិវិធី និង ច្បាប់។

បទពិសោធន៍របស់ពួកគេអាចបង្រៀនយើងអំពីអ្វីមាន និងមិនមានប្រយោជន៍ ហើយក៏អាចជួយយើងឱ្យយល់បន្ថែមអំពីអ្វីដែលមន្ត្រីនគរបាលគួរធ្វើ និងអ្វីដែលមិនគួរធ្វើ។

មេរៀនចែករំលែកសារ និងចំណេះដឹងសំខាន់ៗ ដែលនឹងជួយអ្នកចូលរួមកំណត់សកម្មភាព និងវិធីសាស្ត្រដែលមានប្រយោជន៍ ដែលពួកគេអាចអនុវត្តក្នុងករណីសិក្សា និងក្នុងជីវិតជាក់ស្តែង។

មេរៀននេះក៏នឹងចែករំលែកពីករណីសិក្សាផងដែរ ដោយផ្អែកលើបទពិសោធន៍របស់ជនរងគ្រោះម្នាក់នៅក្នុងករណីជាក់ស្តែង (ពីរបាយការណ៍បញ្ឈប់គ្រោះថ្នាក់នៅប្រទេសកម្ពុជា)។ មេរៀននេះបង្ហាញយ៉ាងច្បាស់ពីតថភាពនៃ


ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

"ការអនុវត្តល្អៗ"។

# ធនធានដែលត្រូវការ៖

ឧបសម្ព័ន្ធ "ធ" (ទំព័រ ១៥១) "ធ១" (ទំព័រ ១៥៦) និង "ធ២" (ទំព័រ ១៥៩) និងស្លាយ (ពីស្លាយ ៩៤)

## កំណត់ពន្យល់បន្ថែមសម្រាប់ការសម្របសម្រួល៖

១. សូមស្វាគមន៍ក្រុម និងចែករំលែកលទ្ធផលដែលបានគ្រោងទុកពីវគ្គនេះ ដោយប្រើកំណត់សម្គាល់ និងស្លាយខាងលើ។ ពន្យល់ថាយើងនឹងប្រើប្រាស់សកម្មភាព និងធនធាន ដើម្បីសម្រេចបានលទ្ធផលទាំងនោះ។

២. ពន្យល់ថា មន្ត្រីនគរបាលកំពុងបង្កើនការរំពឹងទុកក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់កុមារប្រកបដោយប្រសិទ្ធភាព និងវិជ្ជាជីវៈ។ នេះមានន័យថាមន្ត្រីនគរបាលត្រូវបានរំពឹងថានឹងឆ្លើយតបទៅនឹងតម្រូវការរបស់កុមារស្របតាមការណែនាំអំពីកុមារមេត្រី និងដោយការគោរពសិទ្ធិកុមារគ្រប់ពេលវេលា។

៣. បញ្ជាក់ដល់ក្រុមថា ការធ្វើកិច្ចការទាំងនេះមិនមែនជាជម្រើសទេ វាជាការរំពឹងទុកអំពីតួនាទីរបស់ពួកគេក្នុងនាមជាមន្ត្រីនគរបាល។

**សង្ឃឹមថាអ្នកចូលរួមនឹងចងចាំ ប្រសិនបើអ្នកចូលរួមមិនចងចាំទេ សូមរំលឹកពួកគេថា៖**

*កុមារ និងយុវជនដែលមានអាយុ និងដំណាក់កាលលូតលាស់ខុសគ្នា ដែលត្រូវបានកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទពិបាកនឹងជឿទុកចិត្តលើនរណាម្នាក់រួមទាំងមន្ត្រីនគរបាលផងដែរ។ ប្រសិនបើយើងអនុវត្តន៍វិធីសាស្ត្រកុមារមេត្រី ហើយគោរព និងលើកកម្ពស់សិទ្ធិរបស់ពួកគេផងដែរ៖*

*នេះអាចជួយយើងកសាងទំនុកចិត្តជាមួយកុមាររងគ្រោះសាក្សីនិងក្រុមគ្រួសាររបស់ពួកគេ។ ប្រសិនបើយើងទទួលបានការជឿជាក់កាន់តែខ្លាំង កុមាររងគ្រោះនឹងមាន*


ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

*អារម្មណ៍ថា កាន់តែមានសុវត្ថិភាព។ នោះនឹងនាំឱ្យមានកិច្ចសហការកាន់តែប្រសើរឡើង ហើយការផ្តល់របាយការណ៍ និងភស្តុតាងក៏កាន់តែប្រសើរផងដែរ។ ភស្តុតាងកាន់តែប្រសើរនាំឱ្យមានការស៊ើបអង្កេតកាន់តែមានប្រសិទ្ធភាពខ្ពស់ មានភាពលឿន និងទទួលបានជោគជ័យ។*

៤. ពន្យល់ថា យើងមានសំណាងដែលនៅឆ្នាំ២០២២ ការស្រាវជ្រាវត្រូវបានចេញផ្សាយនៅក្នុងប្រទេសកម្ពុជាដែលផ្តោតលើ OCSEA ហើយផ្នែកខ្លះនៃការស្រាវជ្រាវរួមមានការសម្ភាសជាមួយមន្ត្រីអនុវត្តច្បាប់ និងកុមារ និងគ្រួសារដែលរងផលគ្រោះដោយ OCSEA។

ការស្រាវជ្រាវនេះបង្ហាញយ៉ាងច្បាស់ អំពីបទពិសោធន៍របស់កុមារក្នុងអំឡុងពេល និងបន្ទាប់ពី OCSEA និងបទពិសោធន៍របស់ពួកគេជាមួយនឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ចាប់ពីការរាយការណ៍ ឬការលាតត្រដាងព័ត៌មានរហូតដល់លទ្ធផលចុងក្រោយនៃករណី។

ការនេះមានប្រយោជន៍ណាស់ ដោយសារវាជួយយើងឱ្យដឹងពីអ្វីដែលជា **ការអនុវត្តល្អ និងមានប្រយោជន៍**ទាក់ទងនឹងការធ្វើការជាមួយកុមារ ដូច្នេះយើងអាចកសាងសមត្ថភាពរបស់យើង ធ្វើអ្វីដែលមានប្រយោជន៍កាន់តែច្រើន និងកែលម្អអ្វីដែលយើងធ្វើ។

យើងក៏អាចដឹងថា **អ្វីជាការអនុវត្តមិនល្អ និងមិនមានប្រយោជន៍**នៅពេលធ្វើការជាមួយកុមារដែលរងផលប៉ះពាល់ដោយការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ ហើយរៀនចៀសវាងការធ្វើរឿងទាំងនោះ។

៥. ពន្យល់ថាអ្នកនឹងបំបែកក្រុមធំទៅជាក្រុមតូចៗ (ឬជាគូអាស្រ័យលើចំនួនអ្នកចូលរួម)។ បន្ទាប់មកចែកកាតមួយចំនួន ដែលមានរបាយការណ៍ពីកុមារ អំពីបទពិសោធន៍របស់ពួកគេ ក្នុងការជួបជាមួយមន្ត្រីនគរបាល។ **ប្រើកាតឆ្លើយតបដែលមានប្រយោជន៍** ជាមុនសិន។ មានកាតចំនួន ១២ (អ្នកអាចបង្កើតកាតបន្ថែមប្រសិនបើអ្នកមានបំណងបង្កើត) ដូច្នេះអ្នកអាចបង្កើតក្រុម និងផ្តល់ឱ្យក្រុមនីមួយៗនូវកាតចំនួន ២, ៣ ឬ ៤សន្លឹក។

៦. ពេលដែលអ្នកបានបញ្ចប់កិច្ចការនេះ សូមអរគុណដល់ក្រុមហើយសង្ខេបចំណុចសិក្សាដែលមានប្រយោជន៍បំផុតមួយចំនួន។

៧. បន្ទាប់មកពន្យល់ថា យើងក៏មានកាតមួយចំនួនទៀតដើម្បីចែកដល់ក្រុម ប៉ុន្តែពេលនេះ របាយការណ៍ និងសារតើមកពីកុមារ និងឪពុកម្តាយ ដោយគូសបញ្ជាក់ពីបទពិសោធន៍ដែលមិនសូវមានប្រយោជន៍ដែលពួកគេមាន។ អ្នកចូលរួមមួយចំនួនប្រហែលជាមិនចូលចិត្តគំនិតនេះទេ ឬប្រហែលជាមានការជំទាស់បន្តិចបន្តួច នេះគឺជាការរំពឹងទុក។

ក្នុងនាមជាអ្នកសម្របសម្រួល កិច្ចការរបស់អ្នកគឺដើម្បីជួយពួកគេកុំឱ្យដោះសារចំពោះស្ថានភាពដែលមិនមានប្រយោជន៍ទាំងនោះ ហើយគូសបញ្ជាក់ពីដំណោះស្រាយវិជ្ជមាន ការឆ្លើយតបដោយសមស្របបែបកុមារមេត្រី និងអត្ថប្រយោជន៍ពីការអនុវត្តតាមដំណោះស្រាយ និងការឆ្លើយតបទាំងនោះសម្រាប់កុមារ និងការស៊ើបអង្កេត។

៨. នៅពេលដែលអ្នកបានបញ្ចប់កិច្ចការនេះសូមអរគុណដល់ក្រុមហើយសង្ខេបចំណុចសិក្សាដែលមានប្រយោជន៍បំផុតមួយចំនួនពីការពិភាក្សា។ (**មើលស្លាយទី ៩៤ ផងដែរ ប្រសិនបើអ្នកចង់ចែករំលែក**)

សូមរំលឹកក្រុមថា៖

- ជារឿយៗ កុមាររក្រៀមក្រំ និងតក់ស្លុតយ៉ាងខ្លាំង ដោយសារបទពិសោធន៍នៃការទទួលរងការកេងប្រវ័ញ្ច និងរំលោភបំពាន។
- ជារឿយៗ ពួកគេមានការភ័យខ្លាចយ៉ាងខ្លាំង ក្នុងការប្រាប់ពីរឿងរ៉ាវរបស់ពួកគេ ហើយកុមារជាច្រើនរាយការណ៍ថា មានអារម្មណ៍ភ័យខ្លាច នឹងការគំរាមកំហែងពីមន្ត្រីនគរបាល និងការរំពឹងទុកដែលពួកគេត្រូវប្រាប់ពីបទពិសោធន៍ដែលគួរឱ្យខ្មាស់អៀនរបស់ពួកគេ។
- ដូចនេះ រាល់សកម្មភាព ឬឥរិយាបថរបស់មន្ត្រីនគរបាលចំពោះកុមារអាចធ្វើឱ្យមានភាពខុសគ្នាយ៉ាងសំខាន់ចំពោះលទ្ធផលនៃករណី ប៉ុន្តែមានសារៈសំខាន់ខ្លាំងណាស់ចំពោះសុខភាពនិងសុខុមាលភាពរបស់កុមារគ្រប់រូប។
- វាជាកាតព្វកិច្ចរបស់អ្នកក្នុងនាមជាមន្ត្រីនគរបាលដែលត្រូវប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីលើកកម្ពស់សិទ្ធិរបស់ពួកគេ និងអនុវត្តន៍តាមបែបកុមារមេត្រីគ្រប់ពេលវេលា។ វាមិនមែនជាជម្រើសទេ គឺចាំបាច់ត្រូវធ្វើបែបនេះ។

៩. សម្រាករយៈពេលខ្លី ដើម្បីឱ្យក្រុមត្រៀមខ្លួនសម្រាប់ផ្នែកចុងក្រោយនៃវគ្គ។

១០. បន្ទាប់ពីសម្រាក សូមពន្យល់ថា អ្នកនឹងចែករំលែកករណីសិក្សាពីជីវិតពិតដែលមាននៅក្នុងរបាយការណ៍បញ្ឈប់គ្រោះថ្នាក់នៅប្រទេសកម្ពុជា (ឆ្នាំ ២០២២)។ ករណីសិក្សានេះផ្អែកលើបទពិសោធន៍របស់កុមារីជាជនជាតិខ្មែរម្នាក់ ដែលជាជនរងគ្រោះពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

កុមារី និងឪពុករបស់នាងជាទូទៅមានបទពិសោធន៍ល្អជាមួយនគរបាល និងមនុស្សផ្សេងទៀតនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ ពួកគេចង់ចែករំលែកបទពិសោធន៍របស់ពួកគេ ដើម្បីឱ្យយើងទាំងអស់គ្នាបានរៀនរំលែក

បទពិសោធន៍របស់ពួកគេ ដើម្បីឱ្យយើងទាំងអស់គ្នាបានរៀនពីបទពិសោធន៍ទាំងនោះ...។

ករណីនេះនឹងជួយអ្នកចូលរួមក្នុងការកំណត់**ការឆ្លើយតបជាវិជ្ជមាន និងមានប្រយោជន៍**របស់មន្ត្រីនគរបាលនិង**បង្ហាញពីអ្វីដែលជា"ការអនុវត្តល្អ" នៅក្នុងជីវិតជាក់ស្តែង**។

វាបង្ហាញពីរបៀបដែលការលើកកម្ពស់សិទ្ធិកុមារ និងការអនុវត្តតាមការអនុវត្តកុមារមេត្រីអាចផ្តល់អត្ថប្រយោជន៍ដល់មនុស្សគ្រប់គ្នាដែលពាក់ព័ន្ធ និងនាំឱ្យទទួលបានលទ្ធផលជោគជ័យ។

១១. ក្នុងនាមជាអ្នកសម្របសម្រួល អ្នកមានជម្រើសចំនួន ៣ អំពីរបៀបដែលអ្នកចែករំលែកករណីសិក្សានេះ។

**ក៖** អ្នកអាចចែកច្បាប់ចម្លងនៃករណីសិក្សានីមួយៗ ឱ្យអ្នកចូលរួមអានដោយស្ងៀមស្ងាត់ដោយខ្លួនឯងហើយបន្ទាប់មកប្រមូលពួកគេឱ្យមកជុំគ្នា ដើម្បីពិភាក្សា និងឆ្លើយសំនួរ៖

> *"តើអ្វីជាចំណុចសំខាន់ក្នុងករណីសិក្សានេះដែលអ្នកអាចនិងគួរអនុវត្តក្នុងការងាររបស់អ្នក?"*
>
> *"តើអ្នកអាចលើកឧទាហរណ៍ពីការងារផ្ទាល់ខ្លួនរបស់អ្នកដែលអ្នកបានធ្វើរឿងដែលមានប្រយោជន៍ និងវិជ្ជមានស្រដៀងគ្នានេះ ដើម្បីជួយដល់កុមារដែលរងផលប៉ះពាល់ដោយការរំលោភបំពាន ឬការកេងប្រវ័ញ្ចដែរឬទេ?"*

**ខ៖**អ្នកអាចបំបែកក្រុមធំទៅជាក្រុមតូចៗចែកចាយករណីសិក្សាហើយឱ្យពួកគេអានជាមួយគ្នាក្នុងក្រុមតូច និងឆ្លើយសំណួរខាងលើ បន្ទាប់មកឱ្យអ្នកចូលរួមចូលទៅក្រុមធំវិញសម្រាប់ការចែករំលែក និងការពិភាក្សាកាន់តែទូលំទូលាយ។

**គ៖**អ្នកអាចចែករំលែកករណីសិក្សាដោយប្រើស្លាយ(**ស្លាយទី៩៥-១០៤**) ដោយចែករំលែកចំណុចនីមួយៗនៅលើស្លាយនីមួយៗ ម្តងមួយៗ។ នៅពេលបញ្ចប់ សូមលើកទឹកចិត្តឱ្យមានការពិភាក្សាលើសកម្មភាពវិជ្ជមានរបស់នគរបាល ហើយថែមទាំងឆ្លើយសំណួរខាងលើ (**ស្លាយទី ១០៤**)។

ប្រសិនបើអ្នកត្រូវត្រឡប់ទៅមើលស្លាយនីមួយៗ(**ពីស្លាយទី៩៦-១០៤**) ដើម្បីឆ្លើយសំនួរ "តើអ្វីជាចំណុចសំខាន់ក្នុងករណីសិក្សានេះ ដែលអ្នកអាចនិងគួរអនុវត្តក្នុងការងាររបស់អ្នក?" សូមធ្វើដូច្នេះចុះ។

បង្ហាញស្លាយនៅលើអេក្រង់ (**ស្លាយទី ១០៥**)។

១២. អ្នកអាចសុំយោបល់ពីពួកគេអំពីរបៀប ដែលគំនិតទាំងនេះអាចយកទៅអនុវត្តបាននៅក្នុងការងារប្រចាំថ្ងៃរបស់នគរបាលជាមួយកុមារនិងយុវជនដែលរងផលប៉ះពាល់ដោយការកេងប្រវ័ញ្ច ឬការរំលោភបំពានផ្លូវភេទ។

**ឧទាហរណ៍៖** ប្រសិនបើកុមារនិយាយថាពួកគេត្រូវការឱ្យមានអ្នកយល់ចិត្តពួកគេ-សួរក្រុមពីអ្វីដែលពួកគេអាចធ្វើ និង/ឬនិយាយ ដើម្បីបង្ហាញការយល់ចិត្តចំពោះកុមារ។

**ឧទាហរណ៍ផ្សេងទៀត៖** ប្រសិនបើកុមារនិយាយថា ពួកគេត្រូវការមនុស្សដើម្បីលើកទឹកចិត្តពួកគេ សួរក្រុមនូវអ្វីដែលពួកគេអាចនិយាយ ឬធ្វើដើម្បីលើកទឹកចិត្តកុមារតាមរបៀបដែលមានប្រយោជន៍។

បន្តពិភាក្សាអំពីគំនិតផ្សេងទៀតដែលកុមារបានលើកឡើង ហើយស្វែងរកឧទាហរណ៍អំពីរបៀបដែលមន្ត្រីនគរបាលអាចបំពេញតម្រូវការទាំងនេះ។

***សង្ខេបនិងចែករំលែកដោយប្រើចំណុចខាងក្រោមដែលត្រូវបានដាក់បញ្ចូលផងដែរនៅក្នុងឯកសារចែក៖ អ្នកអាចនិយាយថា៖***

*"ប្រសិនបើ យើងប្តេជ្ញាចិត្តយ៉ាងពិតប្រាកដក្នុងការលើកកម្ពស់សិទ្ធិកុមារ ហើយឆ្លើយតបតាម របៀបកុមារមេត្រី យើងអាចចាប់ផ្តើមដោយសិក្សាពាក្យ និងគំនិតរបស់ពួកគេ ហើយគិតអំពីរបៀបដែលយើងអាចអនុវត្តន៍វានៅក្នុងការងារប្រចាំថ្ងៃរបស់យើង។ ប្រសិនបើយើងអាចបញ្ចូលគំនិតទាំងនេះនិងធ្វើឱ្យទៅជាការអនុវត្តប្រចាំថ្ងៃនោះនឹងមានអត្ថប្រយោជន៍ជាច្រើន*

- កុមារនឹងមានអារម្មណ៍ថាមានសុវត្ថិភាព និងជឿជាក់លើអ្នកកាន់តែច្រើន ហើយមានទំនុកចិត្តកាន់តែច្រើន និងអាចសហការកាន់តែជិតស្និទ្ធជាមួយអ្នក។
- វានឹងធ្វើឱ្យដំណើរការកាន់តែលឿន និងបង្កើនលទ្ធភាពនៃលទ្ធផលជោគជ័យសម្រាប់អ្នកក្នុងនាមជាមន្ត្រីនគរបាលនិងសម្រាប់កុមារដែលជាជនរងគ្រោះ។
- របៀបដែលអ្នក និងមនុស្សផ្សេងទៀតប្រព្រឹត្តចំពោះពួកគេ ក៏អាចជះឥទ្ធិពលវិជ្ជមានផងដែរលើរបៀបដែលពួកគេបានធូរស្បើយពីអ្វីដែលពួកគេជួបប្រទះ។
- ការធ្វើតាមការណែនាំទាំងនេះគឺ "ឈ្នះ-ឈ្នះ" សម្រាប់គ្រប់គ្នា!។

១៣. ចែកឯកសារដល់អ្នកចូលរួមឱ្យទុក និងបិទវគ្គ ហើយអរគុណអ្នកចូលរួមសម្រាប់ការងារ និងការប្តេជ្ញាចិត្តរបស់ពួកគេចំពោះបញ្ហាទាំងនេះ។

ពន្យល់ថា នៅក្នុងវគ្គបន្ទាប់ យើងនឹងចែករំលែកចំណេះដឹងរួមគ្នា ដើម្បីពិនិត្យមើលឱ្យកាន់តែស៊ីជម្រៅចំពោះករណីសិក្សាហើយពិចារណាពីរបៀបដែលយើងអាចអនុវត្តវាទៅនឹងសេណារីយ៉ូករណីជាក់ស្តែង។

## សកម្មភាព

១. សួរក្រុមថាតើពួកគេអាចចងចាំពីវគ្គដែលទាក់ទងនឹងការលើកកម្ពស់សិទ្ធិកុមារ និងការអនុវត្តកុមារមេត្រីដែរឬទេ? និងតើកុមារនឹងទទួលបានអត្ថប្រយោជន៍អ្វីខ្លះពីសកម្មភាពទាំងនោះ?

២. ពន្យល់ថា កិច្ចការរបស់ពួកគេគឺត្រូវអានកាតក្នុងក្រុម រួចពិភាក្សា និងពិចារ ណា៖(ស្លាយទី ៩២)

៣. តើអ្វីជាទង្វើ ឬឥរិយាបថសំខាន់ៗនៅក្នុងរបាយការណ៍នីមួយៗ?

៤. តើអ្វីជាលទ្ធផលនៃឥរិយាបថ ឬទង្វើនោះ ហើយតើវានឹងផ្តល់អត្ថប្រយោជន៍ដល់កុមារយ៉ាងដូចម្តេច?

៥. តើឥរិយាបថ ឬទង្វើនោះនឹង (ឬអាច)ផ្តល់អត្ថប្រយោជន៍ដល់កុមារ និងធ្វើឱ្យដំណើរការនៃករណីនេះប្រសើរឡើងយ៉ាងដូចម្តេច?

៦. តើវាទាក់ទងនឹងការអនុវត្តកុមារមេត្រី និង/ឬ ការលើកកម្ពស់សិទ្ធិកុមារយ៉ាងដូចម្តេច?

**៧. ផ្តល់ពេលវេលាឱ្យក្រុមប្រហែល ១០ នាទីដើម្បីពិភាក្សាអំពីរបាយការណ៍ទាំងនោះ៖**

- ឱ្យគ្រប់គ្នាចូលមកកាន់ក្រុមវិញហើយសុំឱ្យពួកគេអានរបាយការណ៍មួយចំនួន និងសង្ខេបចម្លើយរបស់ពួកគេ។ ក៏គួរចងចាំផងដែរក្នុងការ **គូសបញ្ជាក់ពីការអនុវត្តបែបកុមារមេត្រី និងរបៀបដែលសិទ្ធិកុមារត្រូវបានលើកកម្ពស់។**
- ចែកចាយកាតមួយចំនួនដូចដែលអ្នកបានធ្វើពីមុនមកប៉ុន្តែលើកនេះគឺចែក **កាតឆ្លើយតបដែលមិនមានប្រយោជន៍។**
- ពន្យល់ថា កិច្ចការរបស់ពួកគេ គឺត្រូវអានរបាយការណ៍នៅលើកាតក្នុងក្រុមម្តងមួយៗ ហើយបន្ទាប់មកពិភាក្សា និងពិចារណាសំនួរខាងក្រោម៖ **(ស្លាយទី៩៣)**

- តើអ្វីជាបញ្ហាចម្បង ការលំបាក ឬឥរិយាបថ ឬស្ថានភាពដែលមិនមានប្រយោជន៍នៅក្នុងរបាយការណ៍នីមួយៗ?
- តើចំណុចទាំងនោះប៉ះពាល់ដល់កុមារយ៉ាងដូចម្តេច? (ឬតើវាទំនងជាប៉ះពាល់ដល់កុមារយ៉ាងដូចម្តេច?)
- តើអ្នកគិត ឬមានអារម្មណ៍យ៉ាងណាចំពោះអ្វីដែលកុមារពណ៌នា?
- តើអ្វីដែលកុមារពិពណ៌នាអាចប៉ះពាល់ដល់លទ្ធផលនៃដំណើរការនេះដោយរបៀបណា?

នៅពេលគិតអំពីការអនុវត្តកុមារមេត្រី និងការលើកកម្ពស់សិទ្ធិកុមារ តើអ្នកមានដំណោះ ស្រាយបែបណា ដើម្បីធ្វើឱ្យស្ថានភាពកាន់តែប្រសើរឡើង? តើមានដំណោះស្រាយផ្សេងពីនេះដែរឬទេ?

ផ្តល់ពេលវេលាឱ្យក្រុមប្រហែល ១៥នាទី ទៅ ២០នាទី ដើម្បីពិភាក្សាអំពីរបាយការណ៍។

## ៨. ជាសកម្មភាពជួយមន្ត្រីនគរបាលក្នុងការចែករំលែកនិងផ្សព្វផ្សាយចំណេះដឹងរបស់ពួកគេ

បោះពុម្ពរូបភាព (**ស្លាយទី១០៥**) លើក្រដាស A៣ ហើយចែកអ្នកចូលរួមម្នាក់មួយសន្លឹកនៅចុងបញ្ចប់នៃវគ្គ។

សុំមន្ត្រីនគរបាលដែលមានវត្តមាន ឱ្យយករូបភាពនោះត្រឡប់ទៅកន្លែងធ្វើការវិញ ហើយចំណាយពេល ១៥នាទី នៅការិយាល័យរបស់ពួកគេដើម្បីចែក រំលែកគំនិតសំខាន់ៗ ទាំងនេះជាមួយសហការីរបស់ពួកគេ។

បន្ទាប់មក ស្នើសុំឱ្យពួកគេបិទក្រដាសផ្ទាំងធំនៅកន្លែងដែលងាយមើលឃើញនៅលើជញ្ជាំងក្នុងការិយាល័យរបស់ពួកគេ ដើម្បីឱ្យពួកគេ និងសហការីរបស់ពួកគេអាចចងចាំពីអ្វី ដែលកុមារត្រូវការគ្រប់ពេលវេលា។

នេះក៏នឹងរំលឹកពួកគេអំពីសារៈសំខាន់ នៃការលើកកម្ពស់សិទ្ធិកុមារ និងតាមការអនុវត្តបែបកុមារមេត្រី។

## ខ្លឹមសារគន្លឹះ និងសកម្មភាពតស៊ូមតិ



- កុមារនឹងមានអារម្មណ៍មានសុវត្ថិភាព និងទុកចិត្តអ្នកកាន់តែច្រើន ហើយមានអារម្មណ៍ជឿជាក់ជាងមុននិងអាចសហការកាន់តែជិតស្និទ្ធជាមួយអ្នក
- វានឹងធ្វើឱ្យដំណើរការកាន់តែរលូន និងបង្កើនលទ្ធភាពនៃលទ្ធផលជោគជ័យសម្រាប់អ្នកក្នុងនាមជាមន្ត្រីនគរបាល។
- របៀបដែលអ្នក និងមនុស្សផ្សេងទៀតប្រព្រឹត្តក៏អាចមានឥទ្ធិពលវិជ្ជមានយ៉ាងខ្លាំងទៅលើរបៀបដែលពួកគេព្យាបាលពីបទពិសោធន៍របស់ពួកគេ។
- ការធ្វើតាមការណែនាំទាំងនេះគឺជា 'ឈ្នះ-ឈ្នះ' សម្រាប់អ្នករាល់គ្នា!

# មេរៀនទី៩

# ការប្រតិបត្តិផ្អែកលើចំណេះដឹង និងជំនាញ

## លទ្ធផលរំពឹងទុក៖

អ្នកចូលរួមនឹងធ្វើការជាក្រុម ដោយប្រើករណីសិក្សា និងអនុវត្តន៍អ្វីដែលពួកគេបានរៀនពីវគ្គទាំងអស់ដើម្បី៖

- ឆ្លុះបញ្ចាំងរបៀបនៃការអនុវត្តល្អៗ និងរៀបចំផែនការស៊ើបអង្កេតករណី OCSEA ។
- កំណត់ជំហាន នីតិវិធីអនុវត្តន៍ស្របតាមផែនការ
- ពិចារណា និងវិភាគលើភាពងាយរងគ្រោះ ក្ដីកង្វល់ និងបញ្ហាជាក់លាក់ក្នុងករណីសិក្សានីមួយៗ។

## កំណត់ចំណាំ៖

ការរៀនសូត្រ និងចំណេះដឹងដែលទទួលបានមកទល់ពេលនេះក្នុងវគ្គបណ្ដុះបណ្ដាល បានធ្វើឱ្យអ្នកចូលរួមត្រៀមខ្លួនរួចជាស្រេចសម្រាប់ការស៊ើបអង្កេតករណី OCSEA ដោយពិចារណា និងរៀបចំផែនការច្បាស់លាស់ ហើយផ្អែកលើមូលដ្ឋានគ្រឹះនៃសិទ្ធិកុមារ និងការអនុវត្តបែបកុមារមេត្រី។ អ្នកនឹងកត់សម្គាល់ថា សិទ្ធិកុមារ និងការអនុវត្តបែបកុមារមេត្រី ត្រូវបានលើកឡើងពេញមួយវគ្គបណ្ដុះបណ្ដាល ដូច្នេះអ្នកចូលរួមគួរតែស៊ាំនឹងលក្ខខណ្ឌតម្រូវនេះ។

ឥឡូវនេះដល់ពេលសម្រាប់អ្នកចូលរួម ដើម្បីអនុវត្តចំណេះដឹងរបស់ពួកគេចំពោះករណីសិក្សា ដែលផ្អែកលើករណីជាក់ស្ដែងពីការស្រាវជ្រាវ និងការអនុវត្ត។ ករណីសិក្សាមានភាពប្រាកដនិយមតាមដែលអាចធ្វើបាន ព្រោះវាផ្អែកលើព្រឹត្តិការណ៍ និងបទឧក្រិដ្ឋជាក់ស្ដែង។ ករណីសិក្សាទាំងនេះឆ្លុះបញ្ចាំងពីតថភាពនៃ OCSEA នៅប្រទេសកម្ពុជាសព្វថ្ងៃ។ ករណីសិក្សាផ្ដល់ព័ត៌មានច្បាស់លាស់ និងតម្រុយសំខាន់ៗមួយចំនួនទាក់ទងនឹងបញ្ហាសំខាន់ៗ សម្រាប់អ្នកចូលរួមពិចារណា។

ដូច្នេះ កំណត់សម្គាល់បន្ថែមសម្រាប់អ្នកសម្របសម្រួល ក៏ត្រូវបានរៀបចំសម្រាប់អ្នកសម្របសម្រួលផងដែរ។ កំណត់ សម្គាល់ទាំងនេះអាចជួយអ្នកនៅពេលសង្កេតមើលការធ្វើបទបង្ហាញរបស់ពួកគេ ហើយត្រូវប្រាកដថាអ្នកចូលរួមបានឆ្លើយតបយ៉ាងសមស្របចំពោះកិច្ចការ និងមិនខកខានចំណុចសំខាន់ៗណាមួយឡើយ។

លើសពីនេះ ច្បាប់ចម្លងនៃករណីសិក្សាមានជាមួយនឹងកំណត់សម្គាល់បន្ថែម និងការប្រើប្រាស់ពណ៌ផ្សេងៗ ដើម្បីបញ្ជាក់ពីបញ្ហាជាក់លាក់ដែលគួរត្រូវបានជ្រើសរើសដោយអ្នកចូលរួម។

ការសម្របសម្រួលនៃវគ្គនេះគឺងាយស្រួលយល់ដោយអ្នកនឹងតម្រូវឱ្យពួកគេប្រើប្រាស់ចំណេះដឹងបទពិសោធន៍ និងជំនាញដែលមានស្រាប់របស់ពួកគេ ចំណេះដឹងបន្ថែមពីវគ្គបណ្ដុះបណ្ដាលនេះ ហើយធ្វើការជាក្រុម ឬក្រុមតូចៗ ដើម្បីអនុវត្តន៍ចំណេះដឹងទាំងនោះ។


ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

ដើម្បីអនុវត្តន៍ចំណេះដឹងទាំងនោះ។

សន្លឹកកិច្ចការមានសំណួរដើម្បីជួយក្រុមឱ្យធ្វើតាមកិច្ចការ ត្រូវបានរៀបចំឡើងដើម្បីងាយស្រួលធ្វើតាម និងអនុវត្តន៍ "មួយជំហានម្តងៗ" និងបំផុសគំនិតរបស់ពួកគេ។

ពួកគេអាចប្រើប្រាស់ឯកសារផ្សេងទៀត ដែលអ្នកបានផ្តល់ឱ្យពួកគេ (ឧទាហរណ៍៖ OCSEA និងច្បាប់របស់ប្រទេសកម្ពុជា សិទ្ធិកុមារ ។ល។) ជាឯកសារយោង ដូច្នេះវាគឺជាអ្វីដែលគេហៅថាជាការងារជាក្រុម។

**ចំណាំ៖** វគ្គនេះត្រូវបានបង្កើតឡើងសម្រាប់អ្នកចូលរួមក្នុងការធ្វើការជាក្រុមទោះបីជាវាអាចត្រូវបានកែសម្រួលសម្រាប់ពួកគេឱ្យធ្វើការជាគូ ឬក្នុងករណីខ្លះ ជាបុគ្គល ប្រសិនបើចាំបាច់។

ក៏មានជម្រើសផងដែរក្នុងការឱ្យអ្នកចូលរួមដើរតួដើម្បីបង្ហាញចំណេះដឹង និងជំនាញរបស់ពួកគេដែលពួកគេបានសម្ភាសន៍កុមាររងគ្រោះ និងដែលបានពិពណ៌នានៅក្នុងករណីសិក្សា។

## ធនធានដែលត្រូវការ៖

ឧបសម្ព័ន្ធ "ខ២" (ទំព័រ ១០០) (ក្រុមនីមួយៗអាចជ្រើសរើសករណីសិក្សា OCSEA លម្អិតមួយ ឬករណីសិក្សាពីរដែលមិនសូវលម្អិត) និងឧបសម្ព័ន្ធ "ជ" (ទំព័រ ១៦០) (សំណួរអំពីករណីសិក្សាសម្រាប់ការងារជាក្រុម) ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត និងស្លាយ។

### កំណត់ពន្យល់បន្ថែមសម្រាប់ការសម្របសម្រួល៖

១. ស្វាគមន៍ក្រុមនិងចែករំលែកលទ្ធផលដែលបានគ្រោងទុកនៃវគ្គនេះដោយប្រើកំណត់សម្គាល់ និងស្លាយខាងលើ។ ពន្យល់ថា យើងនឹងប្រើប្រាស់សកម្មភាព និងធនធានផ្សេងៗ ដើម្បីសម្រេចបានលទ្ធផលទាំងនោះ។

២. ពន្យល់ថា យើងនឹងប្រើប្រាស់បទពិសោធន៍ និងចំណេះដឹងដែលមានស្រាប់ របស់ក្រុមទាំងអស់ជាមួយនឹងចំណេះដឹងថ្មីរបស់ពួកគេអំពី OCSEA និងអនុវត្តន៍ចំណេះដឹងទាំងនោះចំពោះករណីសិក្សា។

រំលឹកក្រុមថា ករណីសិក្សាគឺផ្អែកលើករណីជាក់ស្តែងពីការស្រាវជ្រាវ និងការអនុវត្ត។ ករណីសិក្សាមានភាពប្រាកដនិយមតាមដែលអាចធ្វើបាន


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

ព្រោះវាផ្អែកលើព្រឹត្តិការណ៍ និងបទល្មើសជាក់ស្តែង។ ករណីសិក្សាទាំងនោះឆ្លុះបញ្ចាំងពីតថភាពនៃ OCSEA នៅកម្ពុជាសព្វថ្ងៃ។

៣. ពន្យល់ថា អ្នកនឹងផ្តល់ឱ្យក្រុមនីមួយៗនូវករណីសិក្សាមួយ (ពួកគេគួរតែដឹងពីករណីសិក្សានៅពេលឥឡូវនេះ ប្រសិនបើពួកគេបានអានករណីសិក្សានោះ)។ អ្នកក៏នឹងផ្តល់ឱ្យក្រុមនីមួយៗនូវច្បាប់ចម្លងនៃសំនួរ ដើម្បីណែនាំពួកគេឱ្យធ្វើកិច្ចការ។

៤. ពន្យល់ថាសមាជិកក្រុមម្នាក់ៗនឹងចូលរួមយ៉ាងសកម្មក្នុងការធ្វើបទបង្ហាញ (ឧទាហរណ៍៖ កុំប្រចាំមនុស្សតែម្នាក់ ឬពីរនាក់ឱ្យធ្វើការងារនេះ)។ នេះជាការងារជាក្រុម

៥. កិច្ចការគឺងាយស្រួលយល់ ហើយក្រុមត្រូវអនុវត្តតាមជំហាន ដែលបានបង្ហាញនៅក្នុងសន្លឹកកិច្ចការ។ ទោះយ៉ាងណា សូមប្រើស្លាយដែលពាក់ព័ន្ធដើម្បីបង្ហាញដល់ក្រុមនូវជំហាននីមួយៗនិងសំណួរអំពីកិច្ចការប្រសិនបើអ្នកគិតថា ការធ្វើដូចនេះអាចជួយពួកគេ។

៦. បែងចែកក្រុមទៅជាក្រុមតូចៗដោយក្នុងមួយក្រុមមាន ៥នាក់ ហើយសុំឱ្យពួកគេចាប់ផ្តើមធ្វើការជាមួយគ្នា។

ក្នុងនាមជាអ្នកសម្របសម្រួលគឺធានាថា ក្រុមបន្តធ្វើកិច្ចការទៅតាមពេលវេលាកំណត់។ លើសពីនេះ អ្នកអាចផ្តល់ការលើកទឹកចិត្ត និងឆ្លើយសំណួរដើម្បីបញ្ជាក់ពីកិច្ចការ។ អ្នកក៏អាចរំលឹកពួកគេអំពីបញ្ហាសំខាន់ៗ ដើម្បីបញ្ចូលក្នុងបទបង្ហាញរបស់ពួកគេ ប្រសិនបើមានភាពស្រពេចស្រពិល។

សូមរំលឹកពួកគេថា ការលើកកម្ពស់សិទ្ធិកុមារ និងការអនុវត្តកុមារមេត្រីគឺជាលក្ខខណ្ឌតម្រូវចាំបាច់នៃការងាររបស់ពួកគេ ប្រសិនបើចាំបាច់។ កុំភ្លេចប្រើ កំណត់សម្គាល់បន្ថែមសម្រាប់អ្នកសម្របសម្រួល ប្រសិនបើអ្នកត្រូវ ការធ្វើដូច្នេះ។

៧. បន្ទាប់ពីក្រុមបានបញ្ចប់កិច្ចការរបស់ពួកគេ សូមសម្រាករយៈពេលខ្លី។

៨. បន្ទាប់មកសុំឱ្យក្រុមនីមួយៗធ្វើបទបង្ហាញនៃចម្លើយរបស់ពួកគេនៅលើក្រដាសផ្ទាំងធំ។

ពួកគេគួរពណ៌នាសង្ខេបអំពីករណី និងឆ្លើយសំនួរទាំងអស់ដែលមាននៅក្នុងសន្លឹកកិច្ចការ។

អ្នកចូលរួមផ្សេងទៀតអាចត្រូវបានលើកទឹកចិត្តឱ្យសួរសំនួរឬផ្តល់មតិត្រលប់ជាវិជ្ជមាន បន្ទាប់ពីការធ្វើបទបង្ហាញបានបញ្ចប់។

៩. ក្នុងនាមជាអ្នកសម្របសម្រួល ប្រសិនបើអ្នកសម្គាល់ឃើញអ្វីមួយនៅក្នុងបទបង្ហាញដែលមិនត្រឹមត្រូវ ឬចម្លើយដែលមានលក្ខណៈវិជ្ជមាន និងការប្រើប្រាស់ចំណេះដឹងដែលបានរៀនបានយ៉ាងល្អ សូមកត់ចំណាំទុក។ ដូចគ្នានេះដែរ ប្រសិនបើចំណុចសិក្សាសំខាន់ៗ ដែលមិនត្រូវបានលើកឡើងនៅក្នុងបទបង្ហាញ សូមប្រើចំណេះដឹងផ្ទាល់ខ្លួនរបស់អ្នក និងកំណត់សម្គាល់បន្ថែមសម្រាប់អ្នកសម្របសម្រួលដើម្បីបញ្ជាក់ចំណុចទាំងនោះ។

១០. នៅពេលដែលក្រុមទាំងអស់បានបញ្ចប់ការធ្វើបទបង្ហាញរបស់ពួកគេ សូមសង្ខេបចំណុចសិក្សាសំខាន់ៗ។

១១. ប្រសិនបើអ្នកចង់ធ្វើដូច្នេះ ហើយអ្នកមានពេល អ្នកក៏អាចសួរក្រុម ឬស្វែងរកអ្នកស្ម័គ្រចិត្តដើម្បីដើរតួក្នុងការសម្តែងដើម្បីបង្ហាញពីការអនុវត្តវិជ្ជមាន និងការប្រើប្រាស់ការអនុវត្តកុមារមេត្រី។

## សកម្មភាព

ពន្យល់ថា លំហាត់នេះគឺជាការងារជាក្រុម ដោយមានការចូលរួមពីសមាជិកម្នាក់ៗក្នុងក្រុម។

- ពួកគេនឹងមានពេល ២០នាទី ដើម្បីអានករណីសិក្សារួមគ្នា និងសំណួរណែនាំ
- បន្ទាប់មកពួកគេនឹងមានពេល ៤៥នាទី បន្ថែមទៀត ដើម្បីឆ្លើយសំនួរនីមួយៗ និងកត់ត្រាចំណុចសំខាន់ៗ នៅលើក្រដាសផ្ទាំងធំសម្រាប់សំនួរនីមួយៗ
- បន្ទាប់មក ពេលក្រុមមកជុំគ្នា ក្រុមនីមួយៗនឹងមានពេលបន្ថែម ១៥ ទៅ ២០នាទី ដើម្បីសង្ខេបចម្លើយរបស់ពួកគេ និងធ្វើបទបង្ហាញដល់ក្រុមធំ។ (ដូច្នេះ ៥ ក្រុមនឹងមានពេលបន្ថែម ៥៧-១០០នាទី)

## ខ្លឹមសារគន្លឹះ និងសកម្មភាពតស៊ូមតិ

- ឆ្លុះបញ្ចាំងពីការអនុវត្តល្អ និងរៀបចំផែនការស៊ើបអង្កេតករណី OCSEA
- កំណត់ជំហាននីតិវិធី និងការអនុវត្តសមស្របសម្រាប់ការអនុវត្តលើផែនការរបស់ពួកគេ។
- ពិចារណា និងវិភាគលើភាពងាយរងគ្រោះ កង្វល់ និងបញ្ហាប្រឈមដែលអាចកើតមានក្នុងសំណុំរឿង។
- គូសបញ្ជាក់អំពីរបៀបប្រើប្រាស់នីតិវិធីដែលមានលក្ខណៈកុមារមេត្រី និងគោរពសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ ក្នុងដំណើរការស៊ើបអង្កេត។
- ចែករំលែកនូវការអនុវត្តល្អៗ ក្នុងការឆ្លើយតបទៅនឹង OCSEA។

## មេរៀនទី១០

# ការដោះស្រាយបញ្ហាប្រឈមទូទៅ

## លទ្ធផលរំពឹងទុក៖

អ្នកចូលរួមនឹង៖

- កំណត់ពីបញ្ហាប្រឈមរបស់មន្ត្រីនគរបាលដែលធ្វើការជាមួយកុមារដែលរងផលប៉ះពាល់ដោយ OCSEA
- កំណត់ពីការឆ្លើយតបជាវិជ្ជមានចំពោះបញ្ហាប្រឈមយោងតាមគោលការណ៍ណែនាំអំពីការអនុវត្តបែបកុមារមេត្រី

## កំណត់ចំណាំ៖

ការស្រាវជ្រាវដែលទាក់ទងនឹងបទពិសោធន៍របស់កុមារក្នុងការទទួលបានយុត្តិធម៌ កំណត់អំពីការលំបាក និងបញ្ហាប្រឈមនៅក្នុងដំណើរការផ្លូវច្បាប់ ចាប់ពីការរាយការណ៍ដំណាក់កាលដំបូងរហូតដល់ដំណាក់កាលតុលាការ។

កុមារនិងអាណាព្យាបាលខ្លះមិនសហការជាមួយនគរបាលនិងមនុស្សដែលមានអំណាចដោយងាយស្រួលឡើយ។ ពួកគេប្រហែលជាមិនសូវយល់ច្បាស់ពីសិទ្ធិឬអំពីដំណើរការផ្លូវច្បាប់។មួយវិញទៀតផលប៉ះពាល់ពីការការកេងប្រវ័ញ្ច និងរំលោភបំពាន អាចធ្វើឱ្យប៉ះទង្គិចផ្លូវចិត្ត ហើយពួកគេក៏អាចមានអារម្មណ៍អាម៉ាស់ផងដែរ។ (ករណីសិក្សា ក៏បង្ហាញពីបញ្ហាជាច្រើន ដែលកុមារជួបប្រទះ)។

**បញ្ហាទាំងអស់ដែលបានពិពណ៌នាខាងលើ និងបញ្ហាជាច្រើនទៀត បង្កើតឱ្យមានរនាំងរាំងដំណើរការមិនមានភាពរលូន និងសុវត្ថិភាព។**

នៅពេល TNA ត្រូវបានអនុវត្តជាមួយមន្ត្រីនគរបាល ពួកគេក៏បានកំណត់បញ្ហាប្រឈមមួយចំនួន ដែលពួកគេជួបប្រទះក្នុងតួនាទីរបស់ពួកគេក្នុងការស៊ើបអង្កេតនិងផ្តន្ទាទោសបទបទល្មើសនៃការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទទាំងក្នុង និងក្រៅប្រព័ន្ធអនឡាញ។

ការលំបាកទាក់ទងនឹងប្រធានបទផ្សេងៗគ្នាជាច្រើន រួមទាំងការលំបាកក្នុងការជួបដោយផ្ទាល់ជាមួយកុមារ និងអាណាព្យាបាលរបស់ពួកគេ ព្រមទាំងបញ្ហាទាក់ទងនឹងបច្ចេកវិទ្យាផងដែរ។

មន្ត្រីនគរបាលក៏បានលើកឡើងផងដែរថា ជារឿយៗដំណើរការស៊ើបអង្កេតមិនងាយស្រួលនោះទេ ហើយកុមារពិបាកក្នុងការសហការ។

ប៉ុន្តែនៅពេលដែលយើងពិនិត្យឱ្យកាន់តែជិតដល់នូវព័ត៌មានលម្អិតនៃករណីទាំងនេះជាញឹកញាប់យើងអាចឃើញថាអ្វីដែលមន្ត្រីអាចចាត់ទុកថាជា "ការមិនសហការ" គឺជាញឹកញាប់កុមារ និងគ្រួសារកំពុងប្រឈមនឹងបញ្ហាជាក់ស្តែង



ឧបត្ថម្ភដោយ End Violence Against Children unicef for every child

ដែលធ្វើឱ្យពួកគេពិបាកយល់ និងពិបាកដោះស្រាយ ជាមួយនឹងអ្វីដែលបានកើតឡើងចំពោះ ពួកគេ។

មានពេលខ្លះ គម្លាតរវាងទស្សនៈរបស់ជនរងគ្រោះ និងមន្ត្រីនគរបាល និងការខ្វះការយល់ដឹងរវាងកុមារដែលទទួលបានយុត្តិធម៌ និងអ្នកដែលមានភារកិច្ចជួយពួកគេ។

លំហាត់នេះត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាប្រឈមទូទៅដែលកុមារនិងនគរបាលជួបប្រទះដោយស្វែងរកដំណោះស្រាយសាមញ្ញ។ **បញ្ហាទាំងអស់ គឺផ្ដោតលើស្ថានភាព និងករណីជាក់ស្ដែង។**

កំណត់សម្គាល់ខាងក្រោមណែនាំអំពីវិធីមួយចំនួន ដើម្បីជួយសម្រួលដល់វគ្គសិក្សានេះ ដែលអាចត្រូវបានធ្វើនៅក្នុងក្រុមធំ ឬក្រុមតូច ប៉ុន្តែក៏ស្វែងរកវិធីច្នៃប្រឌិតផ្សេងទៀត ដើម្បីសម្រេចបាននូវកិច្ចការនេះ ក៏ត្រូវអនុវត្តផងដែរ។

## ធនធានដែលត្រូវការ៖

ឧបសម្ព័ន្ធ "ឈ" (ទំព័រ ១៦៦) និងស្លាយមេរៀន

### កំណត់ពន្យល់បន្ថែមសម្រាប់ការសម្របសម្រួល៖

១. សូមស្វាគមន៍ក្រុម និងចែករំលែកលទ្ធផលដែលបានគ្រោងទុកនៃមេរៀនសិក្សានេះ ដោយប្រើកំណត់សម្គាល់ និងស្លាយខាងលើ។ ពន្យល់ថាយើងនឹងប្រើប្រាស់សកម្មភាពនិងធនធានផ្សេងៗដើម្បីសម្រេចបានលទ្ធផល។

២. ពន្យល់ថា នៅក្នុងដំណើរការ TNA ដែលជះឥទ្ធិពលលើការបង្កើតវគ្គបណ្ដុះបណ្ដាលនេះ មន្ត្រីនគរបាលបានកំណត់ពីការលំបាក និងបញ្ហាប្រឈមមួយចំនួនក្នុងការងាររបស់ពួកគេជាមួយកុមារដែលរងផលប៉ះពាល់ដោយការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ។ ត្រូវប្រាកដថា អ្នកពន្យល់ពីចំណុចនៅក្នុងកំណត់សម្គាល់ (ខាងលើ) អំពីភាពខុសគ្នានៃទស្សនៈនិង "ភាពខ្វះចន្លោះ" ក្នុងការស្វែងយល់ពីកុមារ ដែលរងផលប៉ះពាល់ដោយការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទដែលបានឡើង។

៣. **បញ្ហាប្រឈមមួយចំនួនដែលមន្ត្រីនគរបាលបានចែករំលែក រួមមាន៖**

- បញ្ហាប្រឈមក្នុងការជួបដោយផ្ទាល់ជាមួយកុមារនិងអាណាព្យាបាលរបស់ពួកគេ

- ពួកគេអាចមានអារម្មណ៍ថា កុមារមិនសហការ
- ពួកគេអាចមានបញ្ហាប្រឈមក្នុងការយល់ដឹងអំពីបច្ចេកវិទ្យា
- ពួកគេប្រហែលជាចង់ស្វែងរកដំណោះស្រាយរហ័សចំពោះបញ្ហា (ប៉ុន្តែប្រហែលជាមិនមានដំណោះស្រាយរហ័ស និងងាយស្រួលទេ)

៤. **ប៉ុន្តែ នៅពេលដែលយើងស្តាប់កុមារ និងក្រុមគ្រួសាររបស់ពួកគេអំពីទស្សនៈរបស់ពួកគេ យើងដឹងថា៖**

- ពួកគេមិនងាយសហការជាមួយនគរបាលឡើយ
- ជារឿយៗ ពួកគេមិនយល់ពីច្បាប់ ដំណើរការច្បាប់ ឬយល់ពីអត្ថប្រយោជន៍នៃច្បាប់ឡើយ
- ពួកគេអាចមានការភ័យខ្លាច និង/ឬ មិនទុកចិត្តនគរបាល
- ពួកគេអាចមានការថប់បារម្ភ និង/ឬ មានអារម្មណ៍អៀនខ្មាស់និងអាម៉ាស់យ៉ាងខ្លាំង
- ពួកគេអាចឈឺចាប់ តក់ស្លុត និងច្របូកច្របល់
- ពួកគេអាចស្គាល់ជនល្មើស ហើយភ័យខ្លាចចំពោះការតបត
- ពួកគេអាចបន្ទោសខ្លួនឯងចំពោះអ្វីដែលបានកើតឡើង ឬត្រូវបានស្តីបន្ទោស
- ពួកគេអាចមានពិការភាព ហើយពិបាកយល់ ឬពិបាកទំនាក់ទំនង

៥. ពន្យល់ទៅកាន់ក្រុមថា បញ្ហាទាំងនេះ និងបញ្ហាជាច្រើនទៀត រារាំងដំណើរការមិនមានភាពរលូន និងសុវត្ថិភាព។ នៅពេលដែលយើងពិនិត្យមើលឱ្យបានជិតដល់ចំពោះព័ត៌មានលម្អិតនៃករណីទាំងនេះជាញឹកញាប់យើងអាចមើលឃើញថា កុមារមិនសហការ ប៉ុន្តែត្រូវប្រឈមមុខនឹងបញ្ហាជាក់ស្តែងដែលធ្វើឱ្យពិបាកក្នុងការដំណើរការ។

**មានពេលខ្លះ គម្លាតរវាងទស្សនៈរបស់ជនរងគ្រោះ និងនគរបាល និងការខ្វះការយល់ដឹងរវាងកុមារដែលទទួលបានយុត្តិធម៌ និងអ្នកដែលមានភារកិច្ចជួយពួកគេ។**

៦. លំហាត់នេះត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាប្រឈម បញ្ហាទូទៅ ដែលកុមារ និងនគរបាលជួបប្រទះ និងស្វែងរកដំណោះស្រាយ។

**លំហាត់នេះក៏ត្រូវបានរៀបចំឡើងដើម្បីស្វែងរកវិធីដើម្បីបំពេញ "ភាពខ្វះចន្លោះ" រវាងអ្វីដែលមន្ត្រីនគរបាលមើលឃើញ និងរបៀបដែលកុមាររងគ្រោះមានអារម្មណ៍ និងបទពិសោធន៍ នៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។**

ពន្យល់ថា ឧទាហរណ៍ទាំងអស់នៃបញ្ហាដែលអ្នកនឹងចែករំលែកគឺផ្អែកលើស្ថានភាព និងករណីជាក់ស្តែង។

៧. លំហាត់នេះអាចធ្វើជាក្រុមធំ ក្រុមតូច ឬជាគូ។ កំណត់សម្គាល់ខាងក្រោមនឹងពន្យល់សង្ខេបអំពីវិធីសាស្ត្រផ្សេងៗ ប៉ុន្តែអ្នកក៏អាចបង្កើតវិធីសាស្ត្រសម្របសម្រួលផ្ទាល់ខ្លួនផងដែរ។ មុននឹងចាប់ផ្តើម សូមរំលឹកក្រុមទាំងមូលឱ្យចងចាំពីនីតិវិធីកុមារមេត្រី និងការលើកកម្ពស់សិទ្ធិកុមារ គឺជាផ្នែកសំខាន់នៃការងាររបស់ពួកគេ ហើយចំណុចទាំងអស់នេះគួរត្រូវបានដាក់បញ្ចូលនៅក្នុងការឆ្លើយតបទាំងអស់។

៨. **ឧទាហរណ៍អំពីករណីដោយប្រើស្លាយ៖** មុនពេលអ្នកសម្របសម្រួលឱ្យធ្វើលំហាត់ ប្រសិនបើអ្នកត្រូវការបង្ហាញកិច្ចការ អ្នកអាចធ្វើដូច្នេះបានដោយប្រើឧទាហរណ៍ខាងក្រោម។

### ឧទាហរណ៍អំពីបញ្ហាប្រឈមដែលកុមារបានចែករំលែក

កុមារនិយាយថា ពួកគេមិនចង់រាយការណ៍ដោយសារខ្លាចជនល្មើស និង/ឬជនល្មើសជាបុគ្គលដែលគេស្គាល់។ ពួកគេព្រួយបារម្ភអំពីអ្វីដែលនឹងកើតឡើង។

- *តើមានបញ្ហាចម្បងអ្វីខ្លះសម្រាប់អ្នកដើម្បីពិចារណា?*
- *តើអ្នកគួរធ្វើអ្វី និងគួរនិយាយដូចម្តេច?*

អ្នកចូលរួមគួរតែអាចកំណត់ពីបញ្ហាសំខាន់ៗមួយចំនួន និងអាចស្វែងរកដំណោះស្រាយមានប្រយោជន៍មួយចំនួនដើម្បីយកឈ្នះបញ្ហាទាំងនោះ។

ឧទាហរណ៍ បញ្ហាសំខាន់ៗមួយចំនួនដែលត្រូវពិចារណា គឺកំណត់អត្តសញ្ញាណជនល្មើស ហើយប្រសិនបើគាត់មានសិទ្ធិចូលទៅកាន់កុមារទាំងតាមប្រព័ន្ធអនឡាញ ឬក្រៅប្រព័ន្ធអនឡាញ ដែលធ្វើឱ្យកុមារផ្សេងទៀតអាចមានហានិភ័យហើយជនល្មើសអាចបង្កគ្រោះថ្នាក់ដល់កុមារ ប្រសិនបើពួកគេរាយការណ៍។ តម្រូវការដើម្បីអនុវត្តន៍ការវាយតម្លៃសុវត្ថិភាព និងហានិភ័យអាស្រ័យលើព័ត៌មានលម្អិតនៃករណី។

មន្ត្រីនគរបាលត្រូវបង្ហាញឱ្យច្បាស់ថា ពួកគេយល់ពីបញ្ហា និងធានាចំពោះកុមារថា ពួកគេនឹងព្យាយាមឱ្យអស់ពីលទ្ធភាព ហើយធ្វើការជាមួយដៃគូអង្គការមិនមែនរដ្ឋាភិបាល ដើម្បីរក្សាសុវត្ថិភាពរបស់កុមារ។ ពួកគេអាចពន្យល់ (ជាភាសាដែលកុមារយល់) ពីរបៀបដែលប្រព័ន្ធច្បាប់អាច

ដំណើរការដើម្បីរក្សាសុវត្ថិភាពកុមារ។ លើកទឹកចិត្តកុមារឱ្យសួរសំនួរ។ ប្រសិនបើកុមារត្រូវការកន្លែងមានសុវត្ថិភាព សូមចូលរួមជាមួយពួកគេក្នុងការស្វែងរកដំណោះស្រាយនេះ (ឧទាហរណ៍៖ សមាជិកគ្រួសារដែលមានសុវត្ថិភាព)។

៩. នៅពេលអ្នកធ្វើកិច្ចការរួចរាល់ ឱ្យអ្នកចូលរួមចូលមកក្នុងក្រុមដើម្បីសង្ខេបមេរៀនសំខាន់ៗ ដែលបានរៀន។ អរគុណអ្នកចូលរួមសម្រាប់ការចូលរួមរបស់ពួកគេ និងបិទបញ្ចប់វគ្គបណ្តុះបណ្តាល។

### សកម្មភាព



**១. ដើម្បីសម្របសម្រួលដល់ការធ្វើលំហាត់ប្រាណជាក្រុមធំ៖**

ស្នើសុំអ្នកស្ម័គ្រចិត្តក្នុងការជ្រើសរើសកាតពីកញ្ចប់ កាតបញ្ហាប្រឈម និងការលំបាកទូទៅ។

ពួកគេអាចអានកាតនោះឱ្យក្រុមទាំងមូលស្តាប់ ដោយស្វែងរកចម្លើយពីក្រុមអំពីវិធីឆ្លើយតបទៅនឹងស្ថានភាព និងដោះស្រាយបញ្ហា ដោយយោងតាមការណែនាំអំពីកុមារ និងត្រូវប្រាកដថា ពួកគេលើកកម្ពស់សិទ្ធិកុមារ។

ប្រសិនបើអ្នកកត់សម្គាល់ពីភាពខ្វះចន្លោះសំខាន់ៗនៅក្នុងចម្លើយ និងការឆ្លើយតប អ្នកអាចពន្យល់ពីអ្វីដែលត្រូវធ្វើបន្ថែមទៀតនៅក្នុងសេណារីយ៉ូនីមួយៗ។

ត្រូវប្រាកដថា អ្នកចូលរួមមិនដោះសារចំពោះសេណារីយ៉ូទាំងនោះ (ឧទាហរណ៍៖ ដោយសារតែពួកគេផ្តោតលើតម្រូវការរបស់មន្ត្រីនគរបាល មិនមែនកុមារ)។

ក៏ត្រូវប្រាកដផងដែរថា មនុស្សមិននិយាយលេងសើច និងបញ្ចេញមតិមិនសមរម្យអំពីទិដ្ឋភាពណាមួយនៃសេណារីយ៉ូ (ឧទាហរណ៍ ក្រុមមនុស្ស LGBTQI ការរំលោភបំពានលើកុមារា ឬបញ្ហាយេនឌ័រផ្សេងទៀត ឬកុមារមានពិការភាពជាដើម)។ ត្រូវប្រាកដថា អ្នកប្រើកាតដែលទាក់ទងនឹងប្រភេទផ្សេងៗគ្នាទាំងអស់ (ឧទាហរណ៍៖ ទាក់ទងនឹងកុមារ បរិស្ថាន/ដំណើរការច្បាប់ ការគ្រប់គ្រងករណី។ល។) (ក្នុងករណីមួយចំនួនអ្នកក៏អាចសុំឱ្យអ្នកស្ម័គ្រចិត្តដំបូងជ្រើសរើសអ្នកចូលរួមម្នាក់ទៀត ដើម្បីសម្តែងក្នុងឈុតឆាកខ្លីមួយដោយបង្ហាញពីអ្វីដែលត្រូវធ្វើ និងនិយាយ)។

**២. ដើម្បីសម្របសម្រួលការធ្វើលំហាត់ជាក្រុមតូចៗ ឬជាគូ៖**

បំបែកក្រុមធំទៅជាក្រុមតូច ឬជាគូ។

ចែកកាតពីរបីសន្លឹកទៅឱ្យក្រុម ឬដៃគូនីមួយៗពីកញ្ចប់ **កាតបញ្ហាប្រឈមនិងការលំបាកទូទៅ**។ ត្រូវប្រាកដថា អ្នកប្រើកាតដែលទាក់ទងនឹងប្រភេទ

ផ្សេងៗទាំងអស់ ឧទាហរណ៍៖ ទាក់ទងនឹងកុមារ បរិស្ថាន/ដំណើរការច្បាប់ ការគ្រប់គ្រងករណី។

សុំឱ្យពួកគេធ្វើការរួមគ្នាដើម្បីពិភាក្សាអំពីកាតនីមួយៗ ស្វែងរកដំណោះស្រាយ។ ទុកពេល ១៥ឬ២០នាទី ដើម្បីពិភាក្សា និងស្រកដំណោះស្រាយ។

បន្ទាប់មកឱ្យអ្នកចូលរួមចូលមកក្នុងក្រុមវិញ ដើម្បីចែករំលែក និងពិភាក្សាអំពីដំណោះស្រាយមួយចំនួនរបស់ពួកគេ ចំពោះបញ្ហាដែលពួកគេបានពិភាក្សា។

អ្នកក៏អាចសុំឱ្យក្រុមតូចជ្រើសរើសកាតមួយចំនួន ហើយសម្តែងក្នុងឈុតឆាកខ្លីមួយ ដូច្នេះពួកគេអាចអនុវត្តអ្វីដែលត្រូវនិយាយ និងរបៀបឆ្លើយតបយ៉ាងសមស្រប។

## ខ្លឹមសារគន្លឹះ និងសកម្មភាពតស៊ូមតិ

- កុមារមិនចង់ផ្តល់សក្ខីកម្មទេ ដោយសារតែខ្លាចជនល្មើស ឬជនល្មើសគឺជាមនុស្សដែលពួកគេស្គាល់។
- នគរបាលត្រូវមានសមត្ថភាពដោះស្រាយបញ្ហាចំពោះកុមារនិងក្រុមគ្រួសារក្នុងពេលជាមួយគ្នា។
- នគរបាលគួរតែមានសមត្ថភាព ក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងបទល្មើសឧក្រិដ្ឋជាក់លាក់ ដែលពាក់ព័ន្ធនឹងបទល្មើសបច្ចេកវិទ្យា។

## មេរៀនទី១១

# ការយល់ដឹងបន្ថែមពីវិធានសុវត្ថិភាពនៅតាមប្រព័ន្ធអនឡាញ

## និងការលើកកម្ពស់ការរាយការណ៍ និងស្វែងរកជំនួយ

## លទ្ធផលរំពឹងទុក៖

បន្ទាប់ពីសិក្សាមេរៀននេះចប់ អ្នកអាច៖

- ស្វែងយល់អំពីការដោះស្រាយបញ្ហាប្រឈម ការលំបាក និងភាពលំបាកនៅក្នុងករណី (OCSEA) ភាពលំបាកទាក់ទងនឹងកុមារ ឬគ្រួសារ
- ស្វែងយល់ពីសារៈសំខាន់នៃការរាយការណ៍ យល់ដឹងពីយន្តការរាយការណ៍ និងឆ្លើយតប

## កំណត់ចំណាំ៖

ក្នុងនាមជាមន្ត្រីនគរបាល អ្នកផ្តល់សេវាពាក់ព័ន្ធឆ្លើយតបនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA) ត្រូវមានចំណេះដឹង និងជំនាញមូលដ្ឋានផងដែរ ជាពិសេសជានាសុវត្ថិភាពនៅតាមប្រព័ន្ធអនឡាញ និងការលើកកម្ពស់ការរាយការណ៍ និងស្វែងរកជំនួយផ្សេងៗ។ អ្នកមិនត្រឹមតែជួយផ្តល់បទអន្តរាគមន៍ឆ្លើយតបចំពោះបទល្មើសនោះទេប៉ុន្តែត្រូវជួយចូលរួមផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងនិងទប់ស្កាត់ការប្រឈមមុខ នឹងហានិភ័យរបស់កុមារ និងយុវជនផងដែរ។

នៅក្នុងមេរៀននេះអ្នកនឹងស្វែងយល់បន្ថែមពីការដោះស្រាយបញ្ហាប្រឈម ការលំបាក និងភាពលំបាកនៅក្នុងករណី (OCSEA)ភាពលំបាកទាក់ទងនឹងកុមារ ឬគ្រួសារ និងស្វែងយល់ដឹងពីសារៈសំខាន់វិធានការសុវត្ថិភាព និងការរាយការណ៍របស់ប្រជាពលរដ្ឋ។ លើសពីនេះទៀត អ្នករៀនអំពីរបៀបចូលប្រើ APLE Chatbot និងចូលប្រើ APLE Chatbot តាមទូរស័ព្ទដៃស្មាតហ្វូន ដែលស្វែងរកចម្លើយនៃបញ្ហាចម្ងល់របស់អ្នកជាច្រើនផងដែរ។



ឧបត្ថម្ភដោយ End Violence Against Children, unicef for every child

# ខ្លឹមសារមេរៀន

## ស្វែងយល់ដឹងពីសារៈសំខាន់វិធានការសុវត្ថិភាព និងការរាយការណ៍របស់ប្រជាពលរដ្ឋ

ក្នុងនាមជាមន្ត្រីនគរបាលត្រូវចាំបាច់យល់ដឹងពីវិធានសុវត្ថិភាពនៃការប្រើប្រាស់បច្ចេកវិទ្យាផងដែរ។ អ្នកអាចជួយពន្យល់ដល់ក្រុមគ្រួសារកុមារ និងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យមានការយល់ដឹងពីការប្រើប្រាស់ឧបករណ៍ និងប្រព័ន្ធបច្ចេកវិទ្យា អ៊ីនធឺណិត និងអនឡាញមានសុវត្ថិភាព ជាពិសេសបណ្តាញព័ត៌មាន សង្គម។

## ១. វិធានសុវត្ថិភាពលើអ៊ីនធឺណិត[1]

អ្នកប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ចាំបាច់ត្រូវយល់ដឹងពីវិធានសុវត្ថិភាព នៅពេលតភ្ជាប់បណ្តាញ អ៊ីនធឺណិត ក្នុងការសិក្សាស្រាវជ្រាវ ការអប់រំ ការធ្វើទំនាក់ទំនង ការកម្សាន្ត ការធ្វើពាណិជ្ជកម្ម ។ល។ វិធានសុវត្ថិភាពមួយចំនួនអ្នកប្រើប្រាស់ត្រូវដឹងរួមមាន៖ការកំណត់ឯកជនភាពសុវត្ថិភាពនៃការស្វែងរក ព័ត៌មាន ការរាំងខ្ទប់បុគ្គលណាម្នាក់ វិធីសាស្ត្រការពារខ្លួនពីការលួងលោម និងរបៀបប្រាស្រ័យទាក់ទង ប្រកបដោយសុវត្ថិភាពលើប្រព័ន្ធអនឡាញ។

## ២. ការកំណត់ឯកជនភាព



ឯកជនភាព និងសុវត្ថិភាពតាមអនឡាញមានសារៈសំខាន់ដូចគ្នា។ កម្មវិធីអនឡាញភាគច្រើនផ្តល់ មធ្យោបាយឱ្យយើងអាចកំណត់ឯកជនភាពដើម្បីគ្រប់គ្រងព័ត៌មានដែលយើងកំពុងប្រើប្រាស់ និងចែករំលែក។

អ្នកអាចកំណត់ឯកជនភាពនៅលើកម្មវិធីអនឡាញ ឬគេហទំព័រ ដោយរកមើល និងជ្រើសរើសយក ពាក្យដូចជា "គណនីរបស់ខ្ញុំ (My Account)"ឬ"ការកំណត់(Settings)"។ ពាក្យទាំងពីរនេះ ជាកន្លែងដែលអ្នកនឹងធ្វើការកំណត់ឯកជនភាពតាមការសម្រេចចិត្តដូចជា៖

- ព័ត៌មានដែលអ្នកចង់ឱ្យគេមើលឃើញនៅលើទំព័រ (Page) ឬប្រវត្តិរូប (Profile) របស់អ្នក
- អ្នកអាចចែករំលែកឱ្យអ្នកផ្សេងទៀតមើលឃើញការបង្ហោះរូបថតវីដេអូឬមាតិកាផ្សេងៗក្រោយពីបានធ្វើការកំណត់ឯកជនភាពលើគណនីរួចរាល់ហើយអ្នកត្រូវធ្វើបច្ចុប្បន្នភាពលើការកំណត់ទាំងនេះឱ្យបានទៀងទាត់។
- ក្រៅពីការកំណត់ខាងលើ អ្នកក៏ត្រូវគិតថា នរណាគួរទទួលយក ធ្វើជាមិត្ត (Friend) ឬអ្នកតាមដាន (Follower) នៅលើអនឡាញ។ ជម្រើសដែលមានសុវត្ថិភាពបំផុតគឺមានតែមិត្តភក្តិ និងក្រុមគ្រួសារ ដែលអ្នកបានស្គាល់ដោយផ្ទាល់។ ប្រសិនបើអ្នកអនុញ្ញាតឱ្យអ្នកដទៃ មើលឃើញព័ត៌មានដែលអ្នកបង្ហោះចែករំលែកនោះ អាចនឹងត្រូវបានមើលឃើញដោយអ្នកមិនធ្លាប់ជួប ឬស្គាល់។ ចូរនិយាយជាមួយ មនុស្សពេញវ័យដែលអ្នកទុកចិត្ត ដើម្បីស្វែងរកអ្វីដែលធ្វើឱ្យអ្នកមានសុវត្ថិភាពបំផុត។

[1] ដកស្រង់ចេញពីសៀវភៅណែនាំបង្រៀនអំពីសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញកម្រិតបឋមសិក្សាបឋមភូមិ


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

# ៣. ការកំណត់សុវត្ថិភាពនៃការស្វែងរកតាមអនឡាញ

- អ៊ីនធឺណិតគឺជាកន្លែងមួយដែលផ្ទុកព័ត៌មានល្អៗយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលអ្នកអាចស្វែងរកបាន។ កម្មវិធីស្វែងរកតាមអ៊ីនធឺណិត ឬគេហៅថា ម៉ាស៊ីនស្វែងរក (Search Engine) ជួយយើងប្រមូល និងបង្រួមចំនួនព័ត៌មានដែលមកពីប្រភពផ្សេងៗគ្នា ជុំវិញពិភពលោក។ វាជាឧបករណ៍ដែលមនុស្សប្រើ ដើម្បីស្វែងរកព័ត៌មានលើប្រធានបទគ្រប់ប្រភេទ។

- អ្នកប្រហែលជាដឹងរួចហើយថា ដើម្បីប្រើឧបករណ៍នេះ អ្នកត្រូវវាយសំណួរ ឬពាក្យគន្លឹះទៅក្នុងរបារ ឬប្រអប់ទទេនៅលើម៉ាស៊ីនស្វែងរក ឬនៅក្នុងកម្មវិធីរុករក (Browser) របស់អ្នក (កន្លែងដែលអ្នក វាយអាសយដ្ឋានគេហទំព័រ) ដើម្បីទទួលបានព័ត៌មានអំពីប្រធានបទដែលអ្នកចង់ដឹងបន្ថែម។ បន្ទាប់មក អ្នកចុច Return ឬ Search key ហើយម៉ាស៊ីនស្វែងរកនឹងធ្វើដំណើរការរបស់វា។ ប៉ុន្តែអ្វីដែលសំខាន់ អ្នកត្រូវដឹងថា ម៉ាស៊ីនស្វែងរកណាមួយដែលជួយអ្នកស្វែងរកព័ត៌មានប្រកបដោយសុវត្ថិភាព និងអាចទុកចិត្តបាន។

- **ប្រមាញ់អ្នករុករកតាមអ៊ីនធឺណិត៖** ចូរអ្នកស្វែងរកព័ត៌មានជាក់លាក់តាមរយៈវេទិកាអនឡាញផ្សេងៗគ្នា ដោយប្រើប្រាស់តារាង ភារកិច្ច ឬសំណួរដែលចែកជូន។ បន្ទាប់មក ចូរពន្យល់ប្រាប់អំពីសារៈសំខាន់នៃការផ្ទៀងផ្ទាត់ព័ត៌មាន ការកំណត់ប្រភពដែលអាចទុកចិត្តបាន និងការប្រុងប្រយ័ត្នរបស់អ្នកក្នុងការចែករំលែកព័ត៌មានផ្ទាល់ខ្លួន។

- កម្មវិធីស្វែងរកមួយចំនួនបានបំពាក់មុខងារបន្ថែមដើម្បីជួយដល់ការស្វែងរកប្រកបដោយសុវត្ថិភាព។ជម្រើសនៃការស្វែងរកមួយដែលមានសុវត្ថិភាព គឺការប្រើមុខងារ Safe Search ដែលម៉ាស៊ីនស្វែងរក មួយចំនួនបានបំពាក់មកជាមួយ ដូចជា Google Chrome Firefox Safari ជាដើម។ Safe Search អាចជួយដកមាតិកាមិនសមរម្យចេញ ជាពិសេសមាតិកាដែលមានលក្ខណៈហិង្សា អាសអាភាស អាក្រាត ។ល។ ហើយវាបង្ហាញតែមាតិកាដែលល្អ សមស្របនឹងអាយុ និងមានប្រយោជន៍។

ដើម្បីធ្វើការកំណត់លើសុវត្ថិភាព និងសន្តិសុខនៅលើម៉ាស៊ីនស្វែងរក ឬកម្មវិធីរុករកតាមអ៊ីនធឺណិត អ្នកត្រូវអនុវត្តវិធីដូចខាងក្រោម៖

- **នៅលើកម្មវិធី ហ្គូហ្គលក្រូម (Google Chrome)៖** នៅរបារខាងលើ សូមចុចលើសញ្ញា ( ) ចុច លើ "ការកំណត់" (Settings) បន្ទាប់មកទៀតចុចលើពាក្យឯកជនភាព និងសន្តិសុខ (Privacy and Security)។ បន្ទាប់មក ចុចលើពាក្យ សន្តិសុខ (Security) និងចុចយកពាក្យ ការពារ ប្រកបដោយស្តង់ដារ (Standard Protection)

- **នៅលើកម្មវិធីហ្វៃអឺហ្វក (Firefox)៖** នៅរបារខាងលើសូមចុចលើសញ្ញា (...) បន្ទាប់មកទៀតចុច លើសញ្ញាផ្ទាំងឯកជនថ្មី (NewPrivateWindow) បន្ទាប់មកចុចលើពាក្យជម្រើស (Options) និង បន្ទាប់មកទៀតចុចលើពាក្យ ឯកជនភាព (Privacy)។

» **នៅលើកម្មវិធីសាហ្វារី (Safari)៖**

១. ចុចលើ ពាក្យ ហ្វាល់ (File) បន្ទាប់មកចុចលើពាក្យ ផ្ទាំង ឯកជនថ្មី (New Private Window)

២. ចុចលើពាក្យ កុំតាមដាន (Do Not Track) បន្ទាប់មក ចុចលើពាក្យ ចំណូលចិត្ត (Preferences)និងជ្រើសរើសពាក្យ ឯកជនភាព (Privacy Tab)។

ការរុករកប្រកបដោយសុវត្ថិភាពមានន័យថាការប្រើប្រាស់អ៊ីនធឺណិតតាមរបៀបដែលអាចការពារអ្នកពីគ្រោះថ្នាក់ដែលអាចកើតមាន។ អ្នកគួរតែអនុវត្តវិធីដូចខាងក្រោម ដើម្បីធ្វើការរុករកប្រកបដោយ សុវត្ថិភាពនៅលើអ៊ីនធឺណិត៖

» **ប្រើតែគេហទំព័រណាដែលអាចទុកចិត្តបាន៖** វាដូចជាការដែលអ្នកទៅកន្លែងដែលអ្នកដឹងថាមានសុវត្ថិភាពដូច្នេះដែរ។បើអ្នកជាកុមារអ្នកគួរចូលទៅប្រើគេហទំព័រដែលបង្កើតឡើងសម្រាប់កុមារឬដែលត្រូវបានណែនាំដោយមនុស្សពេញវ័យ ដែលអ្នកជឿទុកចិត្ត ដូចជា ឪពុកម្តាយ គ្រូបង្រៀន ឬបណ្ណារក្សជាដើម។

» **រក្សាព័ត៌មានផ្ទាល់ខ្លួនជាឯកជនភាព៖** វាដូចជាការមិនប្រាប់មនុស្សប្លែកមុខអំពីព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកនៅក្នុងជីវិតពិតដែរ។ អ្នកមិនត្រូវចែករំលែកព័ត៌មានផ្ទាល់ខ្លួន ដូចជា ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ ឬឈ្មោះសាលារៀនតាមអ៊ីនធឺណិតទេ ព្រោះវាជួយការពារឯកជនភាពរបស់អ្នក និងរក្សាសុវត្ថិភាពអ្នក។

» **ប្រុងប្រយ័ត្នលើតំណភ្ជាប់ (URL) និងការផ្សាយពាណិជ្ជកម្មតំណភ្ជាប់** គឺដូចជាច្រកទ្វារទៅកាន់កន្លែងផ្សេងទៀតនៅលើអ៊ីនធឺណិត។ សូមប្រយ័ត្នចំពោះការចុចលើតំណភ្ជាប់ ឬការផ្សាយពាណិជ្ជកម្ម

## ៤. ការរាំងខ្ទប់នរណាម្នាក់លើអនឡាញ (Block)

» **ណែនាំកុមារត្រូវយល់ដឹងពីរបៀបរាំងខ្ទប់ (Block) នរណាម្នាក់ ឬគណនី**ណាមួយដែលប៉ុនប៉ងលួងលោម ឬធ្វើការគំរាមកំហែងខ្លួន។ កម្មវិធីអនឡាញភាគច្រើនមានមុខងារទប់ស្កាត់ការពារទំនាក់ទំនងជាមួយនរណាម្នាក់ឬគណនីណាមួយដែលយើងមិនចង់មានទំនាក់ទំនងជាមួយ។ អ្នកត្រូវរាយការណ៍ពីការគំរាមកំហែងជូនសមត្ថកិច្ចដើម្បីមានចំណាត់ការសមស្របទៅនឹងជនល្មើស។




» **ការរាំងខ្ទប់នរណាម្នាក់នៅលើអ៊ីនធឺណិត** គឺជាមធ្យោបាយដ៏មានប្រយោជន៍មួយ ដើម្បីការពារ ពួកគេពីការទាក់ទងអ្នក ឬមើលឃើញមាតិការបស់អ្នក។អ្នកគួរអនុវត្តជំហានងាយៗដូចខាង ក្រោម ដើម្បីរាំងខ្ទប់ នរណាម្នាក់នៅលើអ៊ីនធឺណិត។



© UNICEF Cambodia/2022/Bunsak But

# ឧបសម្ព័ន្ធ



## សៀវភៅគោលស្តីពី
## “ការឆ្លើយតបនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ”

— *សម្រាប់មន្ត្រីនគរបាល*



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

ឧបត្ថម្ភដោយ

# ឧបសម្ព័ន្ធ “ក”៖

## របកគំហើញការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA)

— *សំនួរចម្លើយ*

# ទស្សនៈ ឬជំនឿមួយចំនួនពាក់ព័ន្ធនឹងអំពើកេងប្រវ័ញ្ច និងរំលោភបំពាន ផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ( OCSEA)

| សំនួរ | ចម្លើយ និងការពន្យល់បន្ថែម |
|---|---|
| ១. ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) នៅកម្ពុជាគឺកម្រកើតមានណាស់ និងមិនមានផលប៉ះពាល់ដល់កុមារ និងយុវជនច្រើនទេ។ | **មិនពិត៖** ការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាបង្ហាញថា កុមារដែលប្រើអ៊ីនធឺណិតមាន **11%** ដែលមានអាយុពីចន្លោះពី ១២-១៧ឆ្នាំ ត្រូវបានជួបប្រទះនូវការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញបើគិតជាចំនួនប្រជាជនមានន័យថាមានកុមារ**160,000**នាក់អាចនឹងរងផលប៉ះពាល់។<br>**ការពិតមួយចំនួនអំពីបទពិសោធន៍របស់កុមារ៖**<br>» នេះរាប់បញ្ចូលទាំងកុមារដែលត្រូវបានblackmailed ( គម្រាមកំហែងផ្លូវភេទ ) ក្នុងការចូលរួមក្នុងសកម្មភាពផ្លូវភេទ<br>» កុមារដែលមានរូបភាពផ្លូវភេទរបស់ខ្លួន ត្រូវបានចែកចាយដោយគ្មានការអនុញ្ញាតពីកុមារ។<br>» ឬកុមារដែលត្រូវបានបង្ខិតបង្ខំឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទតាមរយៈការសន្យាឱ្យប្រាក់ ឬឱ្យជាអំណោយ។<br>» លើសពីនេះ 9% នៃកុមារដែលប្រើអ៊ីនធឺណិតក្នុងប្រទេសកម្ពុជា បានរាយការណ៍ថាពួកគេបានចែកចាយរូបភាព ឬវីដេអូអាក្រាតដោយខ្លួនឯងតាមអនឡាញ។<br>» នៅក្នុងគំរូស្ទង់មតិតាមគ្រួសារ និងកុមារចំនួន 161នាក់ ( 16% ) ត្រូវបានផ្ញើរូបភាពអាក្រាតដែលមិនចង់បានក្នុងឆ្នាំកន្លងទៅ។ |

២. ចន្លោះឆ្នាំ២០១៧ និងឆ្នាំ២០១៩ចំនួនបាយការណ៍ដែលសង្ស័យថា OCSEA បានរាយការណ៍ទៅមជ្ឈមណ្ឌលជាតិទទួលបន្ទុកកុមារបាត់ខ្លួន និងកុមារត្រូវបានគេកេងប្រវ័ញ្ច (CyberTips) ទាក់ទងនឹងប្រទេសកម្ពុជាបានកើនឡើង ៥០% ។

**មិនពិត៖** តួលេខជាក់ស្តែង គឺកើនឡើង ២៦១% ចន្លោះឆ្នាំ២០១៧ និង២០១៩។ នេះបង្ហាញថា ជាបញ្ហាធ្ងន់ធ្ងរ។

៣. ជនល្មើសឬជនសង្ស័យនៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) ភាគច្រើនជាជន មិនស្គាល់អត្តសញ្ញាណរបស់ជនរងគ្រោះ និងជាជនបរទេសមិនមែនជាជនជាតិខ្មែរ។

**មិនពិត៖ យោងតាមការស្រាវជ្រាវ៖**
ជនល្មើស OCSEA ភាគច្រើនគឺជាមនុស្សដែលស្គាល់កុមាររួចហើយ។ ជារឿយៗបុគ្គលទាំងនេះគឺជាសមាជិកគ្រួសារ មិត្តភក្តិពេញវ័យ មិត្តភក្តិ ឬដៃគូស្នេហា។ មនុស្សដែលមិនធ្លាប់ស្គាល់កុមារត្រូវទទួលខុសត្រូវចំពោះបទល្មើសដែលទាក់ទងនឹង OCSEA ប្រហែល ២៥%។

៤. មិនងាយស្រួលសម្រាប់កុមារក្នុងការលាតត្រដាងនៅពេលដែលការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) កើតឡើង។

**ពិត៖**

- ជនរងគ្រោះតែងតែមានអារម្មណ៍អាម៉ាស់ ពេលជួបប្រទះនឹងការស្តីបន្ទោសពីភាពរងគ្រោះ ឬបន្ទោសខ្លួនឯងចំពោះអ្វីដែលបានកើតឡើង។
- ជនល្មើសជាច្រើនគឺជាមនុស្សដែលកុមារស្គាល់ រួមទាំងគ្រួសារផងដែរ។ ការនេះគឺជាឧបសគ្គចំពោះការរាយការណ៍។
- ជនរងគ្រោះ អាចមានអារម្មណ៍ខ្មាស់អៀនក្នុងការនិយាយអំពីបញ្ហាផ្លូវភេទ។ ការប្រាប់នរណាម្នាក់អំពីរឿងនេះ គឺពិបាកណាស់។
- ដូច្នេះមន្ត្រីនគរបាល ត្រូវមានជំនាញច្រើន មានចិត្តសណ្តោសមេត្តា និងការយល់ចិត្ត និងប្រព្រឹត្តចំពោះកុមារ និងអាណាព្យាបាលដោយយកចិត្តទុកដាក់ និងដោយការគោរពនៅពេលសម្ភាសន៍ពួកគេ។

| | | |
|---|---|---|
| ៥. នៅកម្ពុជាការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ភាគច្រើនប៉ះពាល់ដល់តែក្មេងស្រី និងយុវនារីតែប៉ុណ្ណោះ។ | **មិនពិត៖** | » នៅកម្ពុជាជនរងគ្រោះមានទាំងក្មេងប្រុស និងក្មេងស្រី។<br>» តាមរយៈការស្ទង់មតិពីគ្រួសារ ក្នុងចំណោមក្មេងអាយុ ១២-១៧ឆ្នាំ ដែលប្រើអ៊ីនធឺណិត ក្មេងប្រុសត្រូវបានគេរាយការណ៍ច្រើនជាងក្មេងស្រីថា បានទទួលរងគ្រោះពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) គ្រប់ទម្រង់ដែលបានស៊ើបអង្កេត។ |
| ៦. ក្មេងប្រុសងាយស្រួលក្នុងការរាយការណ៍ជាងក្មេងស្រី ព្រោះពួកគេមានអារម្មណ៍មិនសូវខ្មាស់អៀន និងមិនចាំបាច់ខ្វល់ខ្វាយពីកេរ្តិ៍ឈ្មោះដូចក្មេងស្រីនោះទេ។ | **មិនពិត៖** | » ក្មេងប្រុសប្រាប់យើងថា ពួកគេក៏មានភាពអាម៉ាស់ខ្លាំងផងដែរ ហើយថែមទាំងមានការប៉ះទង្គិចដោយការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ទាំងក្នុងប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ។<br>» ជាញឹកញយស្ថានភាពរបស់ពួកគេកាន់តែអាក្រក់ទៅៗ ដោយមានអ្នកគិតថា ការរំលោភបំពានលើក្មេងប្រុសមិនសូវធ្ងន់ធ្ងរ។<br>» មិនថាជនរងគ្រោះមានអត្តសញ្ញាណបែបណាទេ យើងត្រូវតែយកចិត្តទុកដាក់លើស្ថានភាពរបស់ពួកគេជានិច្ច។ |
| ៧. ផលប៉ះពាល់នៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) អាចធ្ងន់ធ្ងរ ប៉ុន្តែមិនធ្ងន់ធ្ងរដូចការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទក្រៅប្រព័ន្ធអនឡាញ (CSEA) ដូច្នេះងាយស្រួលក្នុងការរាយការណ៍ និងសង្គ្រោះ។ | **មិនពិត៖** | » ជនរងគ្រោះតែងតែបន្ទោសខ្លួនឯងចំពោះអ្វីដែលបានកើតឡើង។<br>» នេះអាចកាន់តែអាក្រក់ទៅៗដោយការភ័យខ្លាចនៃការលាតត្រដាងរូបភាពផ្លូវភេទអាចត្រូវបានចែករំលែក និងបន្តនៅលើអ៊ីនធឺណិតរយៈពេលយូរ។<br>» ការភ័យខ្លាចនេះអាចមានរយៈពេលយូរ។<br>» ផលប៉ះពាល់ជាច្រើនដូចគ្នាទៅនឹងផលប៉ះពាល់ដែលកើតចេញពីការរំលោភបំពានលើបុគ្គលផ្ទាល់ដែរ។<br>» OCSEA ជាច្រើនក៏ពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទក្រៅប្រព័ន្ធអនឡាញ។ |

- នេះក៏អាចរាប់បញ្ចូលទាំងការធ្លាក់ទឹកចិត្ត ការធ្វើបាបខ្លួនឯង ការថប់បារម្ភ ពេគសញ្ញាដែលទាក់ទងនឹងជំងឺស្ត្រេសក្រោយការប៉ះទង្គិចផ្លូវចិត្ត និងការពិបាកក្នុងការជឿជាក់លើអ្នកដទៃ។

៨. នៅពេល OCSEA កើតឡើង យុវជន និងកុមារតែងតែដឹងអំពីរបៀប និងកន្លែងត្រូវរាយការណ៍ ជាធម្មតាទាក់ទងទៅកាន់អាជ្ញាធរពាក់ព័ន្ធដូចជា នគរបាលឬអង្គការមិនមែនរដ្ឋាភិបាល។ នេះមិនមែនជាការលំបាកសម្រាប់ពួកគេទេ។

**មិនពិត៖**

- មិនងាយស្រួលក្នុងការរាយការណ៍អំពីការកេងប្រវ័ញ្ច ឬរំលោភបំពានផ្លូវភេទទៅកាន់នរណាម្នាក់។
- មានឧបសគ្គជាច្រើនក្នុងការរាយការណ៍ រួមទាំងកង្វះចំណេះដឹងអំពីរបៀបរាយការណ៍ និងរាយការណ៍ពីណាទៅណា កង្វះទំនុកចិត្ត និងមិនដឹងថាអ្នកណាមានសុវត្ថិភាពក្នុងការប្រាប់ ឬរាយការណ៍។
- ក្នុងចំណោមកុមារដែលជួបរងអំពើការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ (OCSEA) មានត្រឹមតែ ២,៥% បានទាក់ទងទៅបុគ្គលិកសង្គម 3% បានទាក់ទងទៅបណ្តាញជំនួយ និង ២,៩% បានទាក់ទងនគរបាល។
- កុមារដែលទទួលរងឧក្រិដ្ឋកម្ម OCSEA ប្រសិនបើពួកគេជ្រើសរើសលាតត្រដាង ពួកគេទំនងជាប្រាប់មនុស្សនៅក្នុងបណ្តាញទំនាក់ទំនងបុគ្គលរបស់ពួកគេ ជាពិសេសមិត្តភក្តិ (៤០%) បងប្អូនបង្កើត (២៤%) និងម្នាក់ក្នុងចំណោមប្រាំនាក់ (២៥%) ដែលប្រាប់អាណាព្យាបាល។
- ទាក់ទងនឹងការពិត គឺថាប្រហែលមួយក្នុងចំណោមបី (៣៤%) កុមារដែលបានទទួលរងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ មិនបានប្រាប់អ្នកណាម្នាក់ទាល់តែសោះ ហើយមិនមានភាពខុសគ្នាតាមអាយុ ឬរវាងក្មេងប្រុស និងក្មេងស្រីនោះទេ។

៩. នៅពេលកុមារចូលប្រើប្រព័ន្ធអនឡាញ និងយល់ព្រមទាក់ទងឬបង្កើតមិត្តភក្តិជាមួយនរណាម្នាក់ដែលប្រព្រឹត្តអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ

**មិនពិត៖**

- កុមារមិនមានជម្រើសទេ ក្រៅពីការចូលប្រព័ន្ធអនឡាញ
- ប្រសិនបើមានអ្វីខុស កុមារជាច្រើនក៏ជឿលើគំនិតនេះ ហើយបន្ទោសខ្លួនឯង។

(OCSEA) នៅពេលក្រោយមកកុមារនោះ គួរតែទទួលខុសត្រូវខ្លះហើយស្តីបន្ទោសចំពោះអ្វីដែលបានកើតឡើង។ តាមរបៀបខ្លះយើងអាចនិយាយបានថាពួកគេ «ឱ្យដៃ»។

- ជនល្មើសក៏មានជំនាញខ្ពស់ក្នុងការលួងលោមជនរងគ្រោះ និងធ្វើឱ្យពួកគេមានអារម្មណ៍ថា ត្រូវទទួលការស្តីបន្ទោសនោះ។
- វាមិនមែនជាកំហុសរបស់កុមារទេ នៅពេលដែលពួកគេត្រូវបានគេកេងប្រវ័ញ្ច ឬរំលោភបំពានទាំងក្នុង ឬក្រៅប្រព័ន្ធអនឡាញនោះ។
- យើងត្រូវប្រាស្រ័យទាក់ទងយ៉ាងច្បាស់ជាមួយកុមារថា ពួកគេមិនត្រូវបន្ទោសខ្លួនឯងឡើយ។

១០. មនុស្សពេញវ័យ និងកុមារភាគច្រើន មិនមានការយល់ដឹងច្រើនអំពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) ទេ នេះធ្វើឱ្យពួកគេងាយចាញ់ការបោកបញ្ឆោតក្នុងការកេងប្រវ័ញ្ច និងរំលោភបំពាន។

**ពិត៖**

- ល្បឿននៃការអភិវឌ្ឍបច្ចេកវិទ្យា និងពិភពឌីជីថលមានល្បឿនលឿន
- ប៉ុន្តែការយល់ដឹងអំពីគ្រោះថ្នាក់ និងហានិភ័យនៃពិភពឌីជីថលនៅយឺតយ៉ាវ
- មនុស្សជាច្រើនមិនដឹងអំពីគ្រោះថ្នាក់រហូតដល់មានរឿងអាក្រក់កើតឡើង
- ជនល្មើសកសាងទំនុកចិត្ត និងបោកបញ្ឆោតមនុស្សផងដែរ។
- ដូច្នេះនៅពេលដែលមានរឿងអាក្រក់កើតឡើង ជនរងគ្រោះតែងតែតក់ស្លុត ភ័យខ្លាច និងប៉ះទង្គិច ហើយបន្ទោសខ្លួនឯង។
- ដូច្នេះនៅពេលដែលពួកគេរាយការណ៍ វានឹងជួយពួកគេ ប្រសិនបើអ្នកអាចផ្តល់ព័ត៌មានត្រឹមត្រូវអំពី OCSEA ថាតើវាកើតឡើងយ៉ាងដូចម្តេច ហើយពន្យល់ពួកគេមិនត្រូវបន្ទោសខ្លួនឯងនោះទេ។

១១. ការបៀតបៀនផ្លូវភេទតាមប្រព័ន្ធអនឡាញ កម្រកើតមានណាស់ ព្រោះជារឿងដែលកើតឡើងក្រៅប្រព័ន្ធអនឡាញច្រើនជាង ហើយមិនធ្ងន់ធ្ងរទេ។

**មិនពិត៖ យោងតាមការស្ទង់មតិតាមគ្រួសារនៅកម្ពុជា៖**

- ស្ទើរតែ១៦%នៃកុមារដែលប្រើអ៊ីនធឺណិតនៅក្នុងប្រទេសកម្ពុជាបានជួបប្រទះការបៀតបៀន។
- នេះរាប់បញ្ចូលទាំងការចំអន់លេងសើច ប្រវត្តិកុមារ ឬកត់សម្គាល់អំពីរាងកាយរូបរាង ឬសកម្មភាពផ្លូវភេទរបស់កុមារ។

- ក្មេងប្រុស និងក្មេងស្រីត្រូវ គឺជាកម្មវត្ថុបានទទួលរងនូវមតិយោបល់ទាំងនេះ
- កុមារតូចៗដែលមានអាយុពី ១២-១៥ ឆ្នាំ (១៧%) ជួបប្រទះការបៀតបៀន បើធៀបនឹង ១៣% នៃក្មេងអាយុពី ១៦-១៧ ឆ្នាំ
- កុមារភាគច្រើនបានទទួលផលអវិជ្ជមាន ហើយជាទូទៅមានអារម្មណ៍អាម៉ាស់ធុញថប់ ឬខឹង នឹងការប្រព្រឹត្តនេះ។

១២. រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) ជាធម្មតាប៉ះពាល់ដល់កុមារវ័យជំទង់។

**មិនពិត៖**

- ទិន្នន័យ Hotline ប្រាប់យើងថា រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) កំពុងប៉ះពាល់ដល់កុមារគ្រប់វ័យ
- រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) ពាក់ព័ន្ធនឹងកុមារទើបចេះដើរមាន ២៣% នៃរបាយការណ៍ទាំងអស់ក្នុងរយៈពេលបីឆ្នាំ។
- ភាគច្រើននៃរបាយការណ៍ទាំងនេះទាក់ទងនឹងក្មេងប្រុស (៨៨%) បន្ទាប់មកមានទាំងសម្ភារៈដែលពាក់ព័ន្ធនឹងក្មេងប្រុសនិងក្មេងស្រី (៦%) និងសម្រាប់តែក្មេងស្រី (៦%)។

១៣. ពេលកុមារទៅជួបនគរបាលដើម្បីសម្ភាសន៍ វាមិនសំខាន់ទេ ប្រសិនបើមន្ត្រីសម្ភាសជាប្រុស ឬស្រីនោះ។

**មិនពិត៖ ការស្រាវជ្រាវ និងបទពិសោធន៍ប្រាប់យើងថា៖**

- កុមារជាច្រើនអាចមានការភ័យខ្លាច នៅពេលទំនាក់ទំនងជាមួយមន្ត្រីនគរបាល។ ការនិយាយអំពីរឿងផ្លូវភេទ ការកេងប្រវ័ញ្ច និងរំលោភបំពាន គឺពិបាកខ្លាំងណាស់សម្រាប់កុមារទាំងអស់។
- កុមារចូលចិត្តមានជម្រើស នៃភេទរបស់មន្ត្រីនៅពេលពួកគេត្រូវបានសម្ភាសន៍។
- ការផ្តល់ជម្រើសឱ្យពួកគេ ធ្វើឱ្យពួកគេមានអារម្មណ៍ថា មានសុវត្ថិភាពជាងមុន ហើយនឹងជួយឱ្យពួកគេមានទំនុកចិត្តកាន់តែច្រើនក្នុងការនិយាយ និងធ្វើសេចក្តីថ្លែងការណ៍។

- គោលការណ៍ជាមូលដ្ឋានមួយនៃការអនុវត្តកុមារមេត្រី គឺដើម្បីជានានូវដំណើរការ និង បរិយាកាសសុវត្ថិភាពសម្រាប់ការសម្ភាស ហើយការផ្តល់ជម្រើសអាចជួយសម្រេចបាន។
- ក្នុងនាមជាមន្ត្រីនគរបាលអ្នកគួរតែធ្វើអ្វីគ្រប់យ៉ាង ដែលអ្នកអាចធ្វើបានដើម្បីផ្តល់ជម្រើស។

១៤. ប្រសិនបើកុមារឬយុវវ័យជួបប្រទះរឿងអាក្រក់នៅក្នុងប្រព័ន្ធអនឡាញ ពួកគេត្រូវទទួលខុសត្រូវ ព្រោះ ពួកគេជាផ្នែកមួយដែលត្រូវស្តីបន្ទោស ចំពោះអ្វីដែលបានកើតឡើង។

**ខុស៖**

- កុមារ និងយុវជន មិនមានជម្រើសអ្វីក្រៅពីរស់នៅជាផ្នែកមួយនៃជីវិតរបស់ពួកគេតាមប្រព័ន្ធអនឡាញ។
- នៅពេលដែលពួកគេជួបប្រទះការកេងប្រវ័ញ្ច ឬរំលោភបំពានគ្រប់ប្រភេទ ពួកគេមិនគួរត្រូវបានស្តីបន្ទោសឡើយ។
- ជនរងគ្រោះមិនទទួលខុសត្រូវចំពោះអ្វីដែលកើតឡើងនោះទេ នោះគឺជាការទទួលខុសត្រូវរបស់ជនល្មើសតែប៉ុណ្ណោះ។
- យើងមិនគួរប្រាប់ជនរងគ្រោះថា ពួកគេត្រូវបន្ទោសខ្លួនឯងទេ។



© UNICEF Cambodia/2022/Bunsak But

# ឧបសម្ព័ន្ធ “ខ”៖

## និយមន័យ

# ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទកុមារ


ឧបត្ថម្ភដោយ

# និយមន័យនៃការរំលោភបំពានផ្លូវភេទលើកុមារ (CSA)៖

និយមន័យទាំងនេះ គឺផ្អែកលើពាក្យដែលបានប្រើនៅក្នុងសៀវភៅណែនាំស្តីពីយុទ្ធសាស្ត្រឆ្លើយតបបែបកុមារមេត្រីចំពោះកុមាររងគ្រោះ ដែលផលិតដោយអង្គការសកម្មភាពដើម្បីកុមារ (APLE) ក្នុងឆ្នាំ២០១៩ និយមន័យត្រូវបានកែសម្រួល និងធ្វើបច្ចុប្បន្នភាពបន្តិចបន្តួចលើចំណុចដែលសមស្រប។ (ចំណាំ៖ សកម្មភាព និងនិយមន័យដែលបានផ្តល់ខាងក្រោមអាចមិនត្រូវបានគ្របដណ្តប់ដោយច្បាប់កម្ពុជានៅពេលនេះទេ...ប៉ុន្តែវានឹងត្រូវបានលើកឡើងនៅក្នុងមេរៀនសិក្សានាពេលខាងមុខ)។

## អង្គការសុខភាពពិភពលោក (WHO) កំណត់ការរំលោភបំពានផ្លូវភេទលើកុមារថា ៖

"ការចូលរួមរបស់កុមារក្នុងសកម្មភាពផ្លូវភេទដែលគាត់មិនយល់ដឹងបានពេញលេញមិនអាចផ្តល់ការយល់ព្រមជាមុន ឬដែលកុមារមិនទាន់មានការអភិវឌ្ឍផ្នែកបញ្ញាគ្រប់គ្រាន់ និងមិនអាចផ្តល់ការយល់ព្រម ឬដែលបំពានច្បាប់ ឬបម្រាមសង្គម។ ការរំលោភបំពានផ្លូវភេទលើកុមារ ត្រូវបានបង្ហាញដោយសកម្មភាព រវាងកុមារ និងមនុស្សពេញវ័យ ឬកុមារផ្សេងទៀត ដែលតាមអាយុ ឬការអភិវឌ្ឍ ស្ថិតក្នុងទំនាក់ទំនងនៃទំនួលខុសត្រូវ ការជឿទុកចិត្ត ឬអំណាច សកម្មភាព ដែលមានបំណងបំពេញចំណង់ផ្លូវភេទ ឬបំពេញតម្រូវការរបស់បុគ្គលផ្សេងទៀត។"

**" វាជារឿងសំខាន់ក្នុងការកត់សម្គាល់ថា កុមារមិនអាចយល់ព្រមចំពោះការរំលោភបំពានបានទេ។"**

**The Disrupting Harm Research បន្ថែមថា:**

"ការរំលោភបំពានផ្លូវភេទលើកុមារសំដៅលើសកម្មភាពផ្លូវភេទផ្សេងៗដែលប្រព្រឹត្តចំពោះកុមារ (មនុស្ស ដែលមានអាយុក្រោម ១៨ឆ្នាំ) ដោយមិនគិតពីថា តើកុមារដឹង ឬអត់ ថាអ្វីដែលកំពុងកើតឡើងចំពោះពួកគេគឺមិនធម្មតា ឬអាចទទួលយកបាននោះទេ។ វាអាចត្រូវបានប្រព្រឹត្តដោយមនុស្សពេញវ័យ ឬមិត្តភក្តិ ហើយជាធម្មតាពាក់ព័ន្ធនឹងបុគ្គល ឬក្រុមដែលទាញយកអត្ថប្រយោជន៍ពីអតុល្យភាពនៃអំណាច។ វាអាចប្រព្រឹត្តទៅដោយគ្មានកម្លាំងច្បាស់លាស់ ដោយជនល្មើសតែងតែប្រើអំណាច ឧបាយកល ឬការបោកប្រាស់។"

## សកម្មភាពនៃការរំលោភបំពានផ្លូវភេទ ដោយផ្ទាល់ និងមិនផ្ទាល់

1. APLE Cambodia, សៀវភៅណែនាំបណ្តុះបណ្តាល៖ យុទ្ធសាស្ត្រឆ្លើយតបបែបកុមារមេត្រីជាមួយកុមាររងគ្រោះនៅក្នុងករណីនៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ ,ភ្នំពេញ, ឆ្នាំ២០១៩។
2. អង្គការសុខភាពពិភពលោក (១៩៩៩), ការផ្លាស់ប្តូរសង្គម និងសុខភាពផ្លូវចិត្ត អំពើហិង្សា និងការការពាររបួស។ (ត្រូវបានដកស្រង់ផងដែរនៅក្នុង គោលការណ៍ណែនាំពាក្យភាសាលុចសំបួរ)



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

## សកម្មភាពរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

- ការស្ទាបអង្អែលកុមារដោយចេតនាផ្លូវភេទដោយមិនសមរម្យ (ដូចជាការលូកដៃស្ទាបអង្អែល ថើប ឬប្រើមាត់លើរាងកាយរបស់កុមារ ជាពិសេសតំបន់ប្រដាប់បន្តពូជ ឬអ្វីដែលចាត់ទុកថាជា "ផ្នែកឯកជន")។
- ការប៉ះពាល់កុមារក្នុងវិធីដែលជំរុញឱ្យពួកគេមានអារម្មណ៍ផ្លូវភេទនិង/ឬសម្រេចកាមលើកុមារ(វាមិនតម្រូវឱ្យកុមារទទួលបានការឈានដល់ចំណុចកំពូល ឬការបញ្ចេញទឹកកាមដែលត្រូវបានចាត់ទុកថាសម្រេចកាមដោយខ្លួនឯងនោះទេ)។
- ការឱ្យកុមារប៉ះពាល់ផ្នែកឯកជនរបស់អ្នកដទៃ សម្រេចកាមអោយអ្នកដទៃ ឬឱ្យកុមារធ្វើអំពើផ្លូវភេទលើបុគ្គលផ្សេងទៀត។
- ការដាក់បញ្ចូលក្នុងផ្លូវភេទកុមារ (ការបញ្ចូលវត្ថុចូលទៅក្នុងទ្វារមាស ឬរន្ធគូថរបស់កុមារ ឬការបញ្ចូលឧបករណ៍ផ្លូវភេទទៅក្នុងមាត់កុមារ)។
- ការរំលោភសេពសន្ថវៈកុមារ (ការរួមភេទតាមទ្វារមាស ការរួមភេទតាមរន្ធគូថ និងការរួមភេទតាមមាត់)។
- ការប្រើកុមារជាវត្ថុអាសអាភាស (ឧទាហរណ៍ ការថតរូប និងវីដេអូនៃសកម្មភាពផ្លូវភេទជាមួយកុមារ)។
- ការបង្ខំ បញ្ចុះបញ្ចូល ឬបង្ខិតបង្ខំកុមារឱ្យប្រព្រឹត្តអំពើផ្លូវភេទជាមួយកុមារដទៃទៀត។
- ការបង្ខំ បញ្ចុះបញ្ចូល ឬបង្ខិតបង្ខំកុមារឱ្យប្រព្រឹត្តអំពើផ្លូវភេទជាមួយសត្វ។

## សកម្មភាពនៃការរំលោភបំពានផ្លូវភេទ ដោយមិនផ្ទាល់

- សកម្មភាពផ្លូវភេទ (សម្រេចកាមដោយខ្លួនឯង ឬសកម្មភាពផ្លូវភេទផ្សេងទៀតជាមួយមនុស្សម្នាក់ទៀត) នៅចំពោះមុខកុមារ។
- ការដាក់តាំងបង្ហាញរូបភាព និងសម្ភារៈអាសអាភាស នៅទីសាធារណៈ។
- ការបញ្ចុះបញ្ចូលកុមារឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទ។
- ការបង្ហាញរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (ភាពយន្ត គំនូរជីវចល រូបថត គំនូរ ឬគំនូរឌីជីថល) ដែលពណ៌នាអំពីសកម្មភាពផ្លូវភេទរបស់កុមារ ឬមនុស្សពេញវ័យផ្សេងទៀត។
- ការមើល ឬទាញយករូបភាពផ្លូវភេទរបស់កុមារដើម្បីរក្សាទុក និងចែកចាយ។
- ការចូលរួមរបស់កុមារក្នុងការសន្ទនាបែបផ្លូវភេទ មិនសមរម្យ ដែលអាចជាផ្នែកមួយនៃអំពើល្បួងលោមកុមារក្នុងគោលបំណងផ្លូវភេទ។

# និយមន័យនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ (CSE)៖

និយមន័យនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារអាចពិបាកយល់បន្តិច ទោះជាយ៉ាងណាក៏ដោយ វាអាចពាក់ព័ន្ធនឹងសកម្មភាពរំលោភបំពានដូចគ្នាជាច្រើនដែលបានពិពណ៌នាខាងលើ។ ហើយវាមានទំនាក់ទំនងជាមួយគ្នារវាងការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទ ។

ទោះជាយ៉ាងណាក៏ដោយ អ្វីដែលបែងចែកនិយមន័យគោលនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារពីទម្រង់ផ្សេងទៀតការរំលោភបំពានផ្លូវភេទលើកុមារ គឺជាផ្តោតសំខាន់ទៅលើ ការដោះដូរ ដែលមាននៅក្នុងការកេងប្រវ័ញ្ច។ ការដោះដូរនេះអាចកើតឡើងក្នុងទម្រង់ផ្សេងៗ ( ឧទាហរណ៍ លុយ ទីជម្រក ទំនិញសម្ភារៈ ឬអ្វីដែលមើលមិនឃើញ ដូចជាការការពារ ការយកចិត្តទុកដាក់ ការស្រលាញ់ ឬទំនាក់ទំនង ) ឬសូម្បីតែការសន្យា។

**ការរំលោភបំពានផ្លូវភេទលើកុមារ ក៏ក្លាយជាការកេងប្រវ័ញ្ចផងដែរ នៅពេលដែលកុមារ ឬភាគីទីបីទទួលបានអត្ថប្រយោជន៍តាមរយៈប្រាក់ចំណេញ។**

ពិធីសារបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ( មាត្រា ២ ) បានកំណត់ទម្រង់បីនៃការកេងប្រវ័ញ្ចផ្លូវភេទ៖

១. ការលក់កុមារ កំណត់ថាជាសកម្មភាព ឬប្រតិបត្តិការណាមួយ ដែលកុមារត្រូវបានផ្ទេរដោយបុគ្គល ឬក្រុមមនុស្សណាមួយទៅឱ្យអ្នកផ្សេង ដើម្បីប្រាក់កម្រៃ ឬអ្វីផ្សេងទៀតណាមួយ។

២. ពេស្យាចារកុមារ[3] ការប្រើប្រាស់កុមារក្នុងសកម្មភាពផ្លូវភេទ ដើម្បីប្រាក់កម្រៃ ឬទម្រង់ផ្សេងៗនៃអ្វីមួយ។

៣. រូបភាពនិងសម្ភារៈអាសអាភាសរបស់កុមារតំណាងណាមួយ ទោះជាដោយមធ្យោបាយណាក៏ដោយ នៃកុមារដែលចូលរួមក្នុងសកម្មភាពផ្លូវភេទជាក់ស្តែង ឬក្លែងបន្លំ ឬតំណាងណាមួយនៃផ្នែកផ្លូវភេទរបស់កុមារសម្រាប់គោលបំណងផ្លូវភេទជាចម្បង។

3. ឥឡូវនេះត្រូវបានគេសំដៅជាទូទៅថាជាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុង/សម្រាប់ពេស្យាចារ ( គោលការណ៍ណែនាំសម្រាប់ការការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ )

# ឧបសម្ព័ន្ធ “ខ១”៖

# ការស្វែងយល់ និងនិយមន័យនៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA)


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

# ការស្វែងយល់ និងនិយមន័យការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA)

ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) អាចនឹងពិបាកយល់។ អ្នកចូលរួមក្នុងការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីនគរបាលជំនាញ (TNA) បានសម្តែងការភ័ន្តច្រឡំមួយ ចំនួនអំពីOCSEAនិងទំនាក់ទំនងទៅរបស់វានឹងអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារនៅក្រៅប្រព័ន្ធអនឡាញ(CSA) និង (CSE) ក៏ដូចជាភាពស្រដៀងគ្នា និងភាពខុសគ្នា។ សន្លឹកកិច្ចការនេះ និងពន្យល់បន្ថែម ដូចខាងក្រោម។ សន្លឹកកិច្ចការនេះ នឹងផ្តល់ការយល់ដឹងបន្ថែម។

- OCSEAសំដៅលើស្ថានភាពនៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ ដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថល អ៊ីនធឺណិត និងការប្រាស្រ័យទាក់ទងគ្នានៅចំណុចណាមួយ ក្នុងអំឡុងពេលប្រព្រឹត្តអំពើកេងប្រវ័ញ្ច ឬរំលោភបំពានផ្លូវភេទ។
- OCSEA ក៏អាចកើតឡើងតាមរយៈអន្តរកម្មលើប្រព័ន្ធអនឡាញ និងដោយផ្ទាល់រវាងជនល្មើស និងកុមារ។
- ប្រហែលជាការពិពណ៌នាឬបែងចែកថាការកេងប្រវ័ញ្ចនិងរំលោភបំពានផ្លូវភេទកុមារ«តាមប្រព័ន្ធអនឡាញ» ឬ «ក្រៅប្រព័ន្ធអនឡាញ» ទាំងស្រុង មិនបានជួយយើងឱ្យយល់ បង្ការ ឬឆ្លើយតបទៅនឹងបញ្ហាទេ។

## ដូច្នេះ៖

- ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) អាចកើតឡើងយ៉ាងពេញលេញ [ឬទាំងស្រុង] តាមប្រព័ន្ធអនឡាញ (មិនមានទំនាក់ទំនងរាងកាយ ឬការជួបក្រៅប្រព័ន្ធអនឡាញរវាងជនល្មើស និងជនរងគ្រោះ)។
- ប៉ុន្តែវាក៏អាចជាការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ដែលកើតឡើងក្រៅប្រព័ន្ធអនឡាញ ដោយត្រូវបានសម្របសម្រួលដោយបច្ចេកវិទ្យាឌីជីថលអនឡាញ។ (ឧទា. ការលួងលោមតាមប្រព័ន្ធអនឡាញបន្ទាប់មករំលោភបំពានក្រៅប្រព័ន្ធអនឡាញ)។
- ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទដែលត្រូវបានប្រព្រឹត្តក្រៅប្រព័ន្ធអនឡាញ ហើយបន្ទាប់មកផ្លាស់ទីទៅក្នុងប្រព័ន្ធអនឡាញតាមរយៈការចែកចាយរូបភាព ឬវីដេអូនៃការរំលោភបំពាន។
- ការស្រាវជ្រាវនៅក្នុងប្រទេសកម្ពុជាបានបង្ហាញថា ខណៈពេលដែលករណីOCSEAទាំងអស់រួមបញ្ចូលធាតុនៅតាមប្រព័ន្ធអនឡាញ ជារឿយៗវាកើតឡើងនៅចំណុចជាច្រើននៅប្រសប់គ្នារវាងប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ។


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

នៅពេលដែលមន្ត្រីនគរបាលកំពុងស៊ើបអង្កេត និងផ្តល់ការគាំទ្រដល់កុមាររងគ្រោះ ដោយអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទ ដូច្នេះអ្នកនឹងស្វែងយល់ពីរបៀបដែលបានកើតឡើង ដោយពិចារណាថា តើផ្នែកណានៃបទល្មើស គឺជាធាតុផ្សំក្រៅប្រព័ន្ធអនឡាញ និងតាមប្រព័ន្ធអនឡាញ។

# តើការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) មានចរិតលក្ខណៈបែបណា?

ទម្រង់ និងឥរិយាបថខាងក្រោម នឹងពិពណ៌នាយ៉ាងខ្លីអំពីអ្វីដែលត្រូវបានចាត់ទុកថា ជាការកេងប្រវ័ញ្ច និងជាការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) បើយោងទៅតាមរបាយការណ៍បញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា (Distrupting Harm) និងផ្អែកលើការណែនាំវាក្យសព្ទលុចសំបួរ (Luxembourg Terminology Guidelines)។

សូមចំណាំថាចំពោះនិយមន័យផ្លូវច្បាប់ បើយោងតាមច្បាប់កម្ពុជា អាចមានភាពខុសគ្នាបន្តិចបន្តួច ហើយនៅពេលអភិវឌ្ឍន៍សន្លឹកកិច្ចការងារនេះ ប្រហែលជាមិនត្រូវបានចាត់ទុកថាជាបទល្មើសនោះទេ។ និយមន័យ និងការពិចារណាផ្នែកច្បាប់នឹងត្រូវបានពិភាក្សានៅក្នុងវគ្គផ្សេងទៀត។

## ការផលិត ការកាន់កាប់ ឬការចែកចាយសម្ភាររំលោភបំពានផ្លូវភេទកុមារ (CSAM)៖

- រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) សំដៅរូបថត វីដេអូ សម្លេង ឬការថតផ្សេងទៀត ឬមាតិកាតំណាងផ្សេងទៀតនៃការរំលោភបំពានផ្លូវភេទកុមារពិត ឬបង្កើតដោយឌីជីថល ឬផ្នែកកេរភេទរបស់កុមារសម្រាប់គោលបំណងផ្លូវភេទជាចម្បង។

- CSAM ត្រូវបានគេប្រើជំនួសអោយពាក្យ «រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ» (Child Pornography)។ ពាក្យ «រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ» ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយកាលពីអតីតកាលដើម្បីពណ៌នាអំពីសម្ភារៈបែបនេះប៉ុន្តែឥឡូវនេះត្រូវបានគេទទួលស្គាល់ថា អាចធ្វើឱ្យមានភាពធម្មតា និងមិនឆ្លុះបញ្ចាំងពីភាពធ្ងន់ធ្ងរនៃការរំលោភបំពានដែលពាក់ព័ន្ធ។

- ដើម្បីដោះស្រាយបញ្ហានេះ មានការផ្លាស់ប្តូរវាក្យសព្ទពី «រូបភាព និងសម្ភារៈអាសអាភាសកុមារ» ទៅជា «រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ( CSAM)» ដើម្បីបញ្ជាក់អំពីបទល្មើស និងគ្រោះថ្នាក់ដែលកើតមានលើកុមារ។ គោលបំណងគឺផ្តោតលើលក្ខណៈរំលោភបំពាននៃសម្ភារៈទាំងនេះ ជាជាងចាត់ទុក ថាជាទម្រង់រូបភាពអាសអាភាស ដែលបង្កប់ន័យបរិបទយល់ព្រម ឬភាពស្របច្បាប់សម្រាប់មនុស្សពេញវ័យ។

- ទោះជាយ៉ាងណា ត្រូវបានកំណត់និយមន័យខុសៗគ្នានៅក្នុងក្របខណ្ឌច្បាប់នៃប្រទេសនីមួយៗ។

## ការផ្សាយផ្ទាល់អំពីការរំលោភបំពានផ្លូវភេទលើកុមារ៖

- សំដៅលើការអូសទាញ ឬបង្ខំកុមារឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទតែម្នាក់ឯង ឬជាមួយមនុស្សផ្សេងទៀត ដែលសកម្មភាពនោះត្រូវបានផ្សាយផ្ទាល់ក្នុងពេលជាក់ស្តែង ដោយមានអ្នកទស្សនាពីចម្ងាយក្នុងពេលតែមួយតាមរយៈឧបករណ៍ ឬកម្មវិធីអនឡាញណាមួយរួមបញ្ចូលទាំងកម្មវិធីជជែកកំសាន្ត និងកម្មវិធីសន្និសីទវីដេអូ។

- អ្នកទស្សនា ជាទូទៅជាមនុស្សដែលស្នើសុំឬបញ្ជាឱ្យធ្វើសកម្មភាពរំលោភបំពានផ្លូវភេទលើកុមារ ឬប្រាប់ឱ្យសំដែងទង្វើផ្លូវភេទផ្សេងៗតាមតែគេចង់បាន។

- អ្នកមើលអាចនឹងត្រូវបង់ប្រាក់សម្រាប់ការទស្សនា ជនល្មើសអាចចូលមើលតាមរយៈអ្នកសម្របសម្រួល ឬអន្តរការីនៃការរៀបចំសកម្មភាពនោះ។ អន្តរការី អាចជាសាច់ញាតិរបស់កុមារ ឬអ្នករស់នៅក្នុងសហគមន៍តែមួយជាមួយកុមារ។

## ការល្បួងលោមតាមប្រព័ន្ធអនឡាញសម្រាប់គោលបំណងផ្លូវភេទ៖

- សំដៅដល់ដំណើរការបង្កើត ឬកសាងទំនាក់ទំនងជាមួយកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញ ឬបច្ចេកវិទ្យាឌីជីថលក្នុងចេតនាកេងប្រវ័ញ្ចឬរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញឬនៅក្រៅប្រព័ន្ធអនឡាញ។

- ទោះបីជាយ៉ាងណាក៏ដោយ វាបានក្លាយជាវិធីសាស្ត្រធម្មតា និងកាន់តែទូលំទូលាយសម្រាប់ជនល្មើសក្នុងការបង្កើតទំនាក់ទំនង ទំនុកចិត្ត ដើម្បីឈានដល់ការរំលោភបំពានផ្លូវភេទលើកុមារ។ ជាឧទាហរណ៍ កុមារត្រូវបានល្បួងលោម និងបញ្ចុះបញ្ចូលឱ្យថត ឬផលិតរូបភាពអាក្រាត ឬពាក់កណ្តាលអាក្រាតដោយខ្លួនឯង និងចែកចាយរូបភាព-សម្ភារៈទាំងនោះតាមរយៈបច្ចេកវិទ្យាឌីជីថល ដោយមិនចាំបាច់មានការជួប ឬរំលោភបំពានដោយផ្ទាល់។

- ការស្រាវជ្រាវ និងរបាយការណ៍ពីកុមារ និងយុវជន ក៏កំណត់នូវសកម្មភាពបន្ថែមដែលអាចត្រូវបានចាត់ទុកថាជាការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) គឺអាស្រ័យលើកាលៈទេសៈជាក់លាក់។

## ការគំរាមកំហែងផ្លូវភេទលើកុមារ៖

- ជួនកាលគេហៅថា «Sextortion» គឺសំដៅលើការប្រើប្រាស់រូបភាពអាក្រាតដែលទទួលបានពីកុមារ ឬរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទ (CSAM) (អាចជារូបភាពដែលបង្កើតឡើងដោយខ្លួនឯង) ដើម្បីគំរាមកំហែង ឬបង្ខិតបង្ខំកុមារឲ្យបំពេញចំណង់ផ្លូវភេទ ឬផ្តល់នូវអត្ថប្រយោជន៍ផ្សេងៗ ដូចជាប្រាក់។ (ឧ. ការគំរាមបង្ហោះ ឬចែកចាយរូបភាពអាក្រាតលើបណ្តាញសង្គម)

- ដើមឡើយរូបភាព-សម្ភារៈទាំងនេះអាចត្រូវបានចែករំលែកដោយស្ម័គ្រចិត្តពីកុមារ ប៉ុន្តែក្រោយមកត្រូវបានប្រើប្រាស់ដើម្បីគំរាមកំហែងពួកគេ។

- ក្នុងករណីកើតឡើងលើកុមារ ជារឿយៗកុមារត្រូវបានបង្ខំឱ្យបន្តថត ឬបង្កើតរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទបន្ថែម


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

## ការបៀតបៀនផ្លូវភេទកុមារ និងការបង្ហាញមាតិកាអាសអាភាសដល់កុមារ

- ទាំងពីរនេះអាចចាត់ទុកបានថាជាអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) ឬឥរិយាបថដែលអាចនាំឱ្យមាន OCSEA នៅក្នុងករណីមួយចំនួន។

- ជាឧទាហរណ៍ ជនល្មើសអាចបង្ហាញកុមារដោយចេតនាចំពោះខ្លឹមសារផ្លូវភេទ ដែលជាផ្នែកនៃយុទ្ធសាស្ត្រនៃកលល្បិចលួងលោម ដែលត្រូវបានរចនាឡើងដើម្បីបន្សាំពួកគេនឹងសកម្មភាពផ្លូវភេទ។

- យ៉ាងណាមិញ ជារឿងសំខាន់ក្នុងការទទួលស្គាល់ថា មានភាពខុសគ្នារវាងការមើលដោយស្ម័គ្រចិត្ត នៃខ្លឹមសារផ្លូវភេទដោយកុមារ និងការមើលដែលត្រូវបានបង្ខំ ឬបង្ខិតបង្ខំ។

- ការមើលដោយស្ម័គ្រចិត្តនៃខ្លឹមសារផ្លូវភេទ មិនត្រូវបានរួមបញ្ចូលក្នុងនិយមន័យនៃអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ(OCSEA)ដែលប្រើក្នុងរបាយការណ៍បញ្ញប់គ្រោះថ្នាក់នោះទេ។

- អាស្រ័យលើអាយុរបស់កុមារ និងខ្លឹមសារផ្លូវភេទ ( ឧ. វីដេអូ ) អាចមិនត្រូវបានចាត់ទុកថាជាបទល្មើស ប៉ុន្តែអាចបង្កគ្រោះថ្នាក់ដល់កុមារទាក់ទងនឹងការអភិវឌ្ឍន៍របស់ពួកគេនិងការយល់ដឹងអំពីការយល់ព្រមលើទំនាក់ទំនងផ្លូវភេទ។ ( ឧ. ក្មេងអាយុមួយឆ្នាំមើលវីដេអូហិង្សា និង/ឬផ្លូវភេទ )។

## ការចែករំលែករូបភាព-សម្ភារៈផ្លូវភេទដែលបង្កើតដោយខ្លួនឯងរបស់កុមារ៖

- កន្លែងដែលយុវជនពីរនាក់(ឧ.ដៃគូអាយុ ១៧ឆ្នាំ ក្នុងទំនាក់ទំនង) យល់ព្រមក្នុងការចែករំលែករូបភាពផ្ទាល់ខ្លួន វាប្រហែលជាមិនត្រូវបានចាត់ទុកថាជាការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) ទេ។

- ទោះបីជាយ៉ាងណាក៏ដោយ វាអាចនាំទៅដល់ ឬជាផ្នែកមួយនៃ OCSEA ប្រសិនបើវាត្រូវបានបញ្ជូនបន្តដោយគ្មានការអនុញ្ញាតពីអ្នកពាក់ព័ន្ធម្នាក់ ឬទាំងពីរ ឬប្រសិនបើវាត្រូវបានទទួលតាមរយៈការបោកប្រាស់ ឬការបង្ខិតបង្ខំតាមគ្រប់មធ្យោបាយ ។

# ឧបសម្ព័ន្ធ “១២”៖

## ករណីសិក្សា
## ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA)

# ករណីសិក្សា៖ ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ

ករណីសិក្សាខាងក្រោម ត្រូវបានបង្កើតឡើងជាពិសេសសម្រាប់ការបណ្ដុះបណ្ដាល អំពីការឈ្វេងយល់អំពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA)។ ករណីសិក្សាទាំងនេះផ្អែកលើករណី ជីវិតពិត និងមានព័ត៌មានលម្អិតបន្ថែមទៀតសម្រាប់គោលបំណងសិក្សា។ ករណីសិក្សាទាំងនេះ អាចត្រូវបានរក្សាទុកជាឯកសារទាំងមូល និងចែករំលែកដល់អ្នកចូលរួមបន្ទាប់ពីមេរៀនទី៣។

ករណីសិក្សាទាំងនេះនឹងត្រូវបានប្រើនៅក្នុង **វគ្គទី៣៖ «OCSEA ក្នុងប្រទេសកម្ពុជា-តើវាមានលក្ខណៈបែបណា ?»** ដើម្បីណែនាំពីបទល្មើស និងសកម្មភាពដែលបានប្រព្រឹត្តលើកុមារ។ វានឹងជួយអ្នកចូលរួមយល់អំពីប្រភេទនៃសកម្មភាព អាកប្បកិរិយា និងបទឧក្រិដ្ឋ ដែលកុមារ និងយុវជនកំពុងប្រឈម។

(ក្រោយមកករណីសិក្សាទាំងនេះក៏នឹងត្រូវបានប្រើនៅក្នុងវគ្គទី៥៖ «OCSEA និងច្បាប់ជាតិ» និងវគ្គទី១០៖ «ការឆ្លើយតបទៅនឹង OCSEA» ប៉ុន្តែនឹងមានសំណួរជាក់លាក់បន្ថែមទៀត ដើម្បីឱ្យអ្នកចូលរួមឆ្លើយតប។ (សំនួរនឹង ត្រូវបានផ្ដល់ជូនដាច់ដោយឡែកពីគ្នា។)

ករណីសិក្សាទាំងនេះ ត្រូវបានបង្ហាញក្រោមចំណងជើងជាក់លាក់ដែលទាក់ទងនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) ដែលមាននៅក្នុងរបាយការណ៍បញ្ឈប់គ្រោះថ្នាក់នៅកម្ពុជា (២០២២)។

## ការផលិត ការកាន់កាប់ ឬការចែកចាយ រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM)៖

*«រូបថត វីដេអូ សារសំឡេង ឬការថតសំឡេងផ្សេងទៀត ឬសម្ភារៈតំណាងពិត ឬឌីជីថលណាផ្សេងទៀតដែលបង្កឱ្យមានការរំលោភបំពានផ្លូវភេទកុមារ ឬផ្នែកផ្លូវភេទរបស់កុមារ ដើម្បីគោលបំណងផ្លូវភេទជាចម្បង»* ។

## ករណីសិក្សា ក

អ្នកទទួលបានការហៅទូរស័ព្ទពីអ្នកគ្រប់គ្រងហាងកុំព្យូទ័រមួយ។ ពួកគេបានទទួលកុំព្យូទ័រយួរដៃមួយ ដែលត្រូវការជួសជុលពីអតិថិជនជនជាតិខ្មែរម្នាក់។ ពេលបើកកុំព្យូទ័រនោះ ជាងជួសជុលកុំព្យូទ័របានរកឃើញតំណភ្ជាប់ទៅនឹងរូបភាពជាង ១០០០រូបភាព នៃកុមារដែលត្រូវបានរំលោភបំពានផ្លូវភេទ រួមទាំងរូបភាពដែលមើលទៅដូចកុមារកម្ពុជា។ រូបភាព និងវីដេអូមួយចំនួន ហាក់ដូចជាទើបត្រូវបានគេផលិតឡើងក្នុងប៉ុន្មានសប្តាហ៍កន្លងមកនេះ។

ជាងជួសជុលកុំព្យូទ័រក៏បានរកឃើញឯកសារដែលគាត់ជឿថា ជាកំណត់ត្រារបស់អតិថិជនទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជាដែលបានទិញរូបភាពទាំងនេះកំណត់ត្រានេះបង្ហាញពីឈ្មោះនិងព័ត៌មានទំនាក់ទំនងលម្អិតរបស់អតិថិជនអ្វីដែលពួកគេបានទិញនិងចំនួនប្រាក់ដែលពួកគេបានបង់រួចរាល់ហើយ។អ្នក ដែលកំពុងនិយាយតាមទូរស័ព្ទនោះ ក៏បានពន្យល់ទៀតថា អតិថិជននឹងត្រឡប់មកហាងគាត់វិញ ដើម្បីយកកុំព្យូទ័រយួរដៃរបស់គាត់វិញរយៈពេលពីរថ្ងៃទៀត។

## ករណីសិក្សា ខ

អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាមួយ ទាក់ទងមកកាន់ការិយាល័យរបស់អ្នក ពួកគេកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនគរបាលក្រៅប្រទេសទាក់ទងនឹងរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) ដែលបានរកឃើញនៅលើកុំព្យូទ័រយួរដៃរបស់ជនបរទេសម្នាក់ដែលរស់ក្នុងប្រទេសនោះ។នៅក្នុងការស៊ើបអង្កេតនាពេលថ្មីៗនេះរូបភាពរាប់ពាន់សន្លឹកត្រូវបានរកឃើញនៅលើកុំព្យូទ័រនៅផ្ទះរបស់គាត់ ហើយគាត់ត្រូវបានចោទប្រកាន់និងផ្តន្ទាទោសពីបទឧក្រិដ្ឋមួយចំនួន។រូបភាពខ្លះបានមកពីពេលដែលជនល្មើសនោះបានមកលេងប្រទេសកម្ពុជាកាលពីប៉ុន្មានឆ្នាំមុននេះ អំឡុងឆ្នាំ២០១៥។ ក្មេងៗដែលមានវត្តមាននៅក្នុងរូបថតទាំងនោះឥឡូវនេះទំនងបានក្លាយជាមនុស្សពេញវ័យហើយ។រូបភាពជាច្រើនរបស់ពួកគេត្រូវបានបង្ហោះចូលទៅក្នុងគេហទំព័រងងឹត (Dark Web)។ ឥឡូវនេះ គេបានយករូបភាពទាំងនេះចេញពីគេហ-ទំព័រនោះហើយ ប៉ុន្តែអាចនៅមានគេបង្ហោះនៅកន្លែងផ្សេងទៀត។

ជនល្មើសចូលចិត្តរក្សាកំណត់ត្រាលម្អិត អំពីកុមារទាំងអស់ដែលគាត់បានធ្វើបាប និងបានផ្តល់បញ្ជីឈ្មោះកុមារកម្ពុជាមួយចំនួនដល់នគរបាលក្រៅប្រទេស និងអង្គការក្រៅរដ្ឋាភិបាលកម្ពុជា (បច្ចុប្បន្នពួកគេមនុស្សពេញវ័យ) ដែលត្រូវបានគេរំលោភបំពាន/កេងប្រវ័ញ្ច និងទីតាំងដែលការរំលោភបំពាននេះបានកើតឡើង។ ប្រហែលជាគ្មាននរណាម្នាក់ក្នុងចំណោមជនរងគ្រោះទាំងនេះ ដឹងថាការរំលោភបំពានរបស់ពួកគេត្រូវបានគេបង្ហោះតាមប្រព័ន្ធអនឡាញ ហើយពួកគេប្រហែលជាមិនដែលរាយការណ៍អំពីបញ្ហានៃការរំលោភបំពានរបស់ពួកគេ ឬទទួលបានការគាំទ្រសម្រាប់បទពិសោធន៍ ដែលពួកគេបានឆ្លងកាត់ទេ។

អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា បានផ្តល់ព័ត៌មានថា ពួកគេបានរកឃើញទីតាំងរបស់ស្ត្រីម្នាក់ (បច្ចុប្បន្ននេះមានអាយុ២៣ឆ្នាំ) ដែលកំពុងរស់នៅជាមួយប្តី និងកូនតូចៗពីរនាក់ទៀត។

## ករណីសិក្សា គ

## ការចែកចាយ CSAM (ក្រុម Facebook សាលា)

អ្នកគ្រូម្នាក់បង្រៀននៅវិទ្យាល័យមួយក្នុងតំបន់បានទាក់ទងមកអ្នកបន្ទាប់ពីទទួលបានការណែនាំពីអង្គការរដ្ឋាភិបាលក្នុងស្រុកមួយ។ ពេលថ្មីៗកន្លងមកនេះ គាត់ទទួលបានការបណ្តុះបណ្តាល ស្តីអំពីការយល់ដឹងពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) ពីអង្គការមិនមែនរដ្ឋាភិបាលនោះ ហើយវគ្គបណ្តុះបណ្តាល បានលើកកម្ពស់ការយល់ដឹងអំពីការរំលោភបំពានតាមប្រព័ន្ធអនឡាញ។ គាត់បានពន្យល់ថាកាលពីម្សិលមិញនេះមានសិស្សម្នាក់បានប្រាប់គាត់ថាពួកគេបានឃើញរូបថតអាក្រាតរបស់សិស្សម្នាក់ដែលរៀននៅក្នុងថ្នាក់ជាមួយពួកគេគាត់ទើបអាយុ១៣ឆ្នាំហើយត្រូវបានគេបានចែកចាយរូបភាពនោះ និងចែកចាយបន្តនៅក្នុងគ្រុបហ្វេសប៊ុកសាលា។ គេមិនបានដឹងច្បាស់ថា តើអ្នកណាបានបង្ហោះរូបនោះក្នុងគ្រុបទេ អ្នកបង្ហោះរូបនោះបានចូលក្នុងក្រុមហ្វេកប៊ុកសាលា ប៉ុន្តែដូចជាបានប្រើគណនីក្លែងក្លាយ។ (អង្គការមិនមែនរដ្ឋាភិបាលបានធ្វើការស្រាវជ្រាវ ហើយមើលទៅហាក់ដូចជាគណនីក្លែងក្លាយ)។ ឥឡូវនេះ រូបភាពទាំងនេះត្រូវបានគេចែកចាយនៅខាងក្រៅក្រុមហ្វេកប៊ុកសាលា ហើយក៏បានចែកចាយបន្តទៀតនៅលើបណ្តាញសង្គមផ្សេងទៀតផងដែរ។

គ្រូបាននិយាយជាមួយសិស្សដែលពាក់ព័ន្ធ ប៉ុន្តែគាត់ហាក់ដូចជាមិនបានដឹងអ្វីទាំងអស់អំពីរូបភាពដែលត្រូវបានគេចែកចាយនោះទេ។សិស្សម្នាក់នោះមានអារម្មណ៍តក់ស្លុតនិងទុក្ខព្រួយយ៉ាងខ្លាំងហើយក្រោយមកបានពន្យល់ប្រាប់ថា នាងបានមានទំនាក់ទំនងមិត្តភាពតាមប្រព័ន្ធអនឡាញ រយៈពេលពីរបីខែមកហើយជាមួយនឹងបុរសម្នាក់ដែលបានប្រាប់នាងថា គាត់មានអាយុ២០ឆ្នាំ និងបានរស់នៅក្នុងទីក្រុងជាមួយគ្នា ប៉ុន្តែនាងមិនដែលបានឃើញមុខរបស់គាត់ទេ។ មិត្តភាពរបស់ពួកគេបានអភិវឌ្ឍអស់រយៈពេលជាច្រើនខែទៅជាមានទំនាក់ទំនងដ៏ស្និទ្ធស្នាល។នាងបានពន្យល់ថាបុរសនោះចិត្តល្អនិងយកចិត្តទុកដាក់នឹងនាងខ្លាំងណាស់ ដោយនិយាយថាគាត់ស្រឡាញ់នាង ចង់រៀបការជាមួយនាងពេលនាងពេញវ័យ។ ទីបំផុតនាងត្រូវបានបុរសនោះបញ្ចុះបញ្ចូលឱ្យថត និងចែកចាយរូបភាពអាក្រាតរបស់នាង។ នាងក៏បានពន្យល់ប្រាប់គ្រូថា នាងក៏បានថតវីដេអូបង្ហាញពីរាងកាយរបស់នាងផងដែរ ប៉ុន្តែវីដេអូនេះមិនទាន់បានចែកចាយដល់ក្រុមនៅឡើយទេ។

ក្មេងស្រីម្នាក់នេះមានទុក្ខព្រួយជាខ្លាំង ដោយសារមិត្តភក្តិនៅសាលាទាំងអស់គ្នា និងបងស្រីរបស់នាងអាយុ ២០ឆ្នាំ) បានឃើញរូបភាពនាង។ នាងបាននិយាយអំពីការធ្វើអត្តឃាត ដោយសារនាងមិនអាចរស់នៅជាមួយភាពអាម៉ាស់នៃអ្វីដែលបានកើតឡើងទេ ហើយនាងមានអារម្មណ៍ភ័យខ្លាចយ៉ាងខ្លាំងថាវីដេអូនេះអាចនឹងត្រូវបានគេចែករំលែកផងដែរ។

នាងសុខចិត្តទៅជួបនគរបាល ប៉ុន្តែលុះត្រាតែនាងអាចនិយាយជាមួយនគរបាលស្រី ព្រោះថានាងខ្មាស់អៀនខ្លាំងណាស់ មិនអាចនិយាយជាមួយនគរបាលប្រុសបានទេ នាងមិនចង់ឱ្យឪពុកម្តាយនាងដឹងអំពីរឿងនេះទេ ព្រោះនាងមានអារម្មណ៍ថាពួកគេនឹងអាម៉ាស់ និងស្តីបន្ទោសឱ្យនាងជាខ្លាំង។ កាលពីមុននាងត្រូវបានម្តាយធ្វើបាបលើរាងកាយ ពេលដែលម្តាយនាងមិនពេញចិត្តនឹងនាង។ នាងក៏មានអារម្មណ៍ថានាងត្រូវទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើង ដោយសារនាងបានព្រមផ្ញើរូបភាព និងវីដេអូទៅឱ្យបុរសម្នាក់នោះ ហើយក៏បារម្ភថានគរបាលនឹងស្តីបន្ទោសឱ្យនាងដែរ។



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

## ករណីសិក្សា ឃ ការជួញដូររូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទកុមារ (CSAM) យ៉ាងសកម្ម

មន្ត្រីជាន់ខ្ពស់ម្នាក់ បានប្រាប់អ្នកយ៉ាងសង្ខេបពីស្ថានភាពមួយទាក់ទងនឹងការជួញដូរ CSAM ហើយគាត់ចង់ឱ្យអ្នករៀបចំផែនការអន្តរាគមន៍ក្នុងករណីនេះ។ ព័ត៌មានលម្អិតពីករណីនេះមានដូចខាងក្រោម៖

នគរបាលបានទទួលព័ត៌មានសម្ងាត់និងបានកំណត់អត្តសញ្ញាណនិងចាប់ខ្លួនជនល្មើសម្នាក់ដែលរស់នៅក្នុងប្រទេសកម្ពុជា ដែលបានបង្កើតក្រុមតេលេក្រាមជាច្រើនលក់រូបភាព និងវីដេអូ CSAM។ រូបភាព និងវីដេអូទាំងនេះ បង្ហាញពីកុមារមកពីទូទាំងពិភពលោក ហើយអាយុរបស់កុមារទាំងនោះហាក់ដូចជាចាប់ពីទារករហូតដល់ក្មេងជំទង់។

ភស្តុតាងបានបង្ហាញថា ជនល្មើសមានក្រុមអ្នកទិញនៅប្រទេសកម្ពុជា និងនៅទូទាំងអាស៊ីអាគ្នេយ៍ និងប្រទេសដទៃទៀត។ មានបញ្ជីតម្លៃលម្អិត គណនីធនាគារក្នុងប្រទេសកម្ពុជា មានរាប់ពាន់ដុល្លារ និងបញ្ជីទំនាក់ទំនងមួយចំនួន (អ៊ីម៉ែល) ដែលគេជឿថាជារបស់អតិថិជន។

ក្នុងការសម្ភាសបឋម ជនសង្ស័យបានសារភាពថា គាត់បានចែកចាយ CSAM ប៉ុន្តែបាននិយាយដោយការពារខ្លួនថា មានមនុស្សជាច្រើនទៀតដែលគាត់ស្គាល់កំពុងធ្វើដូចគាត់ដែរ ហើយរូបភាពទាំងនេះត្រូវបានថត «យូរមកហើយ» ហើយគាត់មិនបានប្រព្រឹត្តបទឧក្រិដ្ឋទេ។ គាត់បាននិយាយថា គាត់មិនបានធ្វើបាបអ្នកណាទេ គ្រាន់តែឆ្លើយតបទៅនឹងអ្វីដែលមនុស្សចង់បានតែប៉ុណ្ណោះ។

## ករណីសិក្សា ង

បុគ្គលិកជាអ្នកវិភាគប្រព័ន្ធអ៊ីនធឺណិតហតឡាញនៅកម្ពុជា (Internet Hotline Cambodia) បានទាក់ទងអ្នក ក្រោយទទួលបានការរាយការណ៍ពីនារីវ័យក្មេងម្នាក់ ដែលស្នើសុំឱ្យលុបវីដេអូមិនសមរម្យមួយចំនួន ដែលត្រូវបានគេបង្ហោះក្នុងគេហទំព័រពាណិជ្ជកម្មអាសអាភាស។ ព័ត៌មានដែលអ្នកទទួលបានមានដូចខាងក្រោម៖

របាយការណ៍នេះទទួលបានពីក្មេងស្រីម្នាក់អាយុ១៧ឆ្នាំ រស់នៅខេត្តសៀមរាប។ នាងបានរាយការណ៍ថា នាង និងអតីតមិត្តប្រុស (មិត្តប្រុសតាមអនឡាញ) បានបង្កើតវីដេអូជាស៊េរីតាមអនឡាញ ដែលពួកគេសម្រេចកាមដោយខ្លួនឯងជាមួយគ្នា។ ក្នុងវីដេអូទាំងអស់នោះ បានបង្ហាញមុខរបស់នាងយ៉ាងច្បាស់ ប៉ុន្តែមិត្តប្រុសរបស់នាងបាន ប្រើកម្មវិធីដើម្បីបិទមុខរបស់ខ្លួន។ នាងបានពន្យល់ថា នាងមិនបានដឹងថាគាត់កំពុងថតសកម្មភាពផ្លូវភេទនោះទេ។ ទំនាក់ទំនងរបស់ពួកគេ បានបញ្ចប់កាលពីប្រាំមួយខែមុននេះ។

កាលពីសប្តាហ៍មុននេះ មិត្តភក្តិម្នាក់របស់នាងបានប្រាប់នាងថា គាត់បានឃើញវីដេអូនេះនៅលើគេហទំព័រពាណិជ្ជកម្មអាសអាភាស។ (គេហទំព័រនេះបង្កើតឡើងនៅប្រទេសហូឡង់)។ ក្មេងស្រីម្នាក់នេះពិបាកចិត្តខ្លាំងណាស់ ព្រោះអតីតមិត្តប្រុសរបស់នាងបានសន្យាថានឹងលុបវីដេអូទាំងនេះចោល។ នាងបានព្យាយាមទាក់ទងទៅគាត់ ប៉ុន្តែគាត់មិនបានឆ្លើយតបនឹងសាររបស់នាងទេ។ នាងបានបន្តប្រាប់ថា បុរសនោះបានប្រាប់នាងថា គាត់រស់នៅខេត្តបាត់ដំបង ប៉ុន្តែនាងមិនដឹងថានេះជាការពិត ឬយ៉ាងណាទេ ហើយនាងក៏មិនស្គាល់ឈ្មោះពិតរបស់បុរសនេះដែរ។ក្មេងស្រីម្នាក់នេះមានព័ត៌មានតិចតួចបំផុតអំពីបុរសម្នាក់បន្ទាប់ពីនាងបានលុបចោលប្រវត្តិ នៃការសន្ទនារបស់ពួកគេទាំងពីរនាក់នេះមក។


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

អង្គការដែលពាក់ព័ន្ធបានណែនាំក្មេងស្រីនេះឱ្យដាក់ពាក្យបណ្ដឹងជាផ្លូវការទៅនគរបាល ប៉ុន្តែនៅពេលនេះ នាងបាននិយាយថា នាងមិនចង់ធ្វើដូច្នេះទេ។ នាងរស់នៅជាមួយម្ដាយ និងប្អូនតូចៗរបស់នាង ហើយមិនចង់បង្កបញ្ហាអ្វីដល់ម្ដាយនាងទេ។នាងក៏ភ័យខ្លាចថាម្ដាយរបស់នាងនឹងខឹងនាង ហើយមនុស្សផ្សេងទៀតនឹងដឹងរឿងអាថ៌កំបាំងដ៏អាម៉ាស់របស់នាងផងដែរ។

## ការផ្សាយផ្ទាល់អំពីការរំលោភបំពានផ្លូវភេទកុមារ៖

*«ការរំលោភបំពានផ្លូវភេទកុមារ ដែលត្រូវបានប្រព្រឹត្ត និងមើលក្នុងពេលដំណាលគ្នាក្នុងពេលវេលាជាក់ស្ដែងតាមរយៈឧបករណ៍ទំនាក់ទំនង កម្មវិធីប្រជុំ ឬឡាយតាមអនឡាញ និង/ឬកម្មវិធីជជែកកម្សាន្តដទៃទៀត។ ក្នុងករណីភាគច្រើនជនល្មើសបានស្នើសុំការរំលោភបំពានជាថ្នូរនឹងការបង់ប្រាក់ឬអត្ថប្រយោជន៍ជាសម្ភារៈផ្សេងទៀតដែលជនល្មើសមានទីតាំងនៅកន្លែងផ្សេងពីកុមារ និងអ្នកសម្របសម្រួលនៃការរំលោភបំពាននេះ»។*

ករណីសិក្សា **ក** ការផ្សាយផ្ទាល់ (បន្តផ្ទាល់)

មន្ត្រីជាន់ខ្ពស់ម្នាក់ បានសង្ខេបប្រាប់អ្នកពីករណីមួយពាក់ព័ន្ធនឹងកុមារត្រូវបានគេរំលោភបំពាន ហើយការរំលោភបំពាននេះ ត្រូវបានគេផ្សាយលើប្រព័ន្ធអនឡាញទៅមនុស្សនៅបរទេស។ មានភស្តុតាងជាក់លាក់ថា ក្មេងប្រុស និងក្មេងស្រីទាំងនេះមានអាយុក្រោម១២ឆ្នាំ ដែលត្រូវបានគេបញ្ជាឱ្យរំលោភបំពាន។

អ្នកមានព័ត៌មានលម្អិតនៃទីតាំងនៃការរំលោភបំពាននេះត្រូវបានផ្សាយ និងកំពុងធ្វើការជាមួយមន្ត្រី និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធ្វើផែនការក្នុងប្រតិបត្តិការសង្គ្រោះកុមារ និងចាប់ខ្លួនជនសង្ស័យ កុមារទាំងនោះ ទំនងជាមានការប៉ះទង្គិចយ៉ាងខ្លាំង ដោយសារការរំលោភបំពាន ដែលពួកគេបានជួបប្រទះ ហើយក៏មានការប្រថុយប្រថានដែរ ក្នុងការធ្វើឱ្យពួកគេកាន់តែប៉ះទង្គិចថែមទៀត ដោយសារតែការប្រតិបត្តិការនេះ។

ករណីសិក្សា **ខ** ការផ្សាយផ្ទាល់នៃវីដេអូមួយ ដែលគេបានថតទុកពីការផ្សាយបន្តផ្ទាល់

អ្នកទទួលបានព័ត៌មានទាក់ទងនឹងក្រុមតេលេក្រាមមួយ ដែលវីដេអូរបស់កុមារត្រូវបានគេរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ និងត្រូវបានបង្ហោះផ្សាយយ៉ាងទៀងទាត់ និងចែករំលែកតាមប្រព័ន្ធអនឡាញ។ ការរុករកដំបូងនៃការផ្សាយបន្តផ្ទាល់នេះ ហាក់ដូចជាបង្ហាញកុមារមកពីជុំវិញពិភពលោក រួមទាំងកុមារមួយចំនួនដែលជាជនជាតិអាស៊ីនិងអាចជាជនជាតិខ្មែរផងដែរ។ក្រុមនេះមានសមាជិកជាង៤០០០នាក់ (មានសមាជិកខ្មែរមួយចំនួន និងបរទេសជាច្រើននាក់)។វាមិនតែងតែច្បាស់លាស់ទេ ប៉ុន្តែ «ការផ្សាយផ្ទាល់» មួយចំនួនហាក់ដូចជាវីដេអូដែលត្រូវបានគេថតកាលពីពេលមុន ហើយត្រូវបានគេចាក់ផ្សាយ។

# ការលួងលោមកុមារតាមប្រព័ន្ធអនឡាញក្នុងគោលបំណងផ្លូវភេទ៖

*«ការភ្ជាប់ទំនាក់ទំនងកុមារជាមួយប្រព័ន្ធបច្ចេកវិទ្យា ដោយមានចេតនាបំពានផ្លូវភេទ ឬកេងប្រវ័ញ្ចលើកុមារ»* ។

ករណីសិក្សា **ក**

អ្នកទទួលបានព័ត៌មានថា គ្រូបង្រៀនអាយុ ៣៥ឆ្នាំម្នាក់ នៅសាលារៀនអន្តរជាតិមួយ បានទាក់ទងជាមួយអតីតសិស្សរបស់គាត់មួយចំនួន និងបានផ្ញើសារមិនសមរម្យ និងរូបភាពទាក់ទងផ្លូវភេទរបស់គាត់ទៅដល់ពួកគេ។

ព័ត៌មាននេះបានមកពីមិត្តរួមការងារនិងមិត្តនៅផ្ទះជាមួយគ្រូបង្រៀននោះដែលត្រូវបានរាយការណ៍ពីអតីតសិស្សម្នាក់របស់គាត់។ អតីតសិស្សម្នាក់នោះបានប្រាប់នាងថា មានមិត្តភក្តិផ្សេងទៀតបានរៀបរាប់រឿងរ៉ាវស្រដៀងគ្នា ទាក់ទងនឹងគ្រូប្រុសម្នាក់នេះហើយពួកគេខ្លះបានចែករំលែករូបថតស្និទ្ធស្នាលជាមួយគ្រូប្រុសម្នាក់នោះ។ (មិត្តរួមការងាររបស់គ្រូប្រុសនោះ (ដែលជាគ្រូស្រី) ក៏បានឃើញសារ និងរូប ភាពខ្លះដែរ)។

គ្រូស្រីបាននិយាយជាឯកជនជាមួយក្មេងស្រីមួយចំនួន។ ក្មេងស្រីដែលពាក់ព័ន្ធទាំងអស់មានអាយុ ១២-១៤ឆ្នាំ។ ជនល្មើសបានផ្ញើសារប្រាប់ពួកគេថាគាត់ស្រឡាញ់ពួកគេ ហើយនិយាយថាគាត់កំពុងរង់ចាំពួកគេពេញវ័យ ដើម្បីគាត់អាចរួមភេទជាមួយពួកគេ ហើយថែមទាំងផ្ញើរូបថតអាក្រាតកាយ និងប្រដាប់ភេទរបស់គាត់ផងដែរ។ រហូតមកដល់ពេលនេះ គ្មានក្មេងស្រីណាម្នាក់សុខចិត្តដាក់ពាក្យបណ្តឹងជាផ្លូវការទៅសាលា ឬអាជ្ញាធរឡើយ។ ពួកគេមានអារម្មណ៍ខ្មាស់អៀន និងទទួលខុសត្រូវមួយផ្នែកចំពោះអ្វីដែលបានកើតឡើង ហើយក្មេងស្រីមួយចំនួនជឿថាគ្រូប្រុស នោះពិតជាស្រឡាញ់ពួកគេពិតមែន។


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

គ្រូនោះកំពុងបន្តបម្រើការងារបង្រៀននៅសាលានោះនៅឡើយទេ ហើយបង្រៀនក្មេងៗថ្នាក់ទី៦-៧។

មិត្តភក្តិគ្រូប្រុសនេះ/សហសេវិកម្នាក់នេះបាននិយាយជាមួយប្រធានគ្រូនៅសាលា... ហើយបង្ហាញពីកង្វល់របស់នាង ប៉ុន្តែសាលាមិនទាន់មានចំណាត់ការអ្វីនៅឡើយទេ។ ប្រធានគ្រូបានណែនាំថា វាជារឿង សំខាន់ក្នុងការការពារកេរ្តិ៍ឈ្មោះរបស់សាលា និងជឿថាក្មេងស្រីទាំងនោះប្រហែលជាកំពុងប្រឌិតរឿង ទាំងនេះឡើងទេ ប៉ុន្តែគាត់នឹង«តាមដានស្ថានភាព»នេះ។ រហូតដល់ពេលនេះ សហសេវិកម្នាក់នេះមិន ទាន់ដាក់ពាក្យដណ្តឹងជាផ្លូវការនៅឡើយទេ ព្រោះនាងមានការព្រួយបារម្ភអំពីការងារ និងសុវត្ថិភាពផ្ទាល់ខ្លួនរបស់នាង ប្រសិនបើជនល្មើសបានដឹង។

មិនទាន់មានរបាយការណ៍ ឬពាក្យបណ្តឹងជាផ្លូវការនៅឡើយទេ ប៉ុន្តែនេះជាឧទាហរណ៍ជាក់ស្តែងថាកុមារកំពុងស្ថិតក្នុងហានិភ័យ។

## ករណីសិក្សា ២ ការផ្សាយផ្ទាល់ (បន្តផ្ទាល់)

ម្តាយរបស់ក្មេងប្រុសអាយុ១៤ឆ្នាំម្នាក់បានទាក់ទងមកអ្នក។ គាត់មានការព្រួយបារម្ភយ៉ាងខ្លាំងអំពីឥរិយាបថថ្មីៗរបស់កូនប្រុសគាត់ ដោយសារគាត់មានភាពស្ងប់ស្ងាត់ប្លែក និងដកខ្លួនចេញ ហើយចំណាយពេលច្រើននៅតែក្នុងបន្ទប់ជាមួយកុំព្យូទ័រយួរដៃរបស់គាត់ គាត់មិនសូវចាប់អារម្មណ៍ជាមួយមិត្តភក្តិ និងក្រុមគ្រួសារ ហើយពិន្ទុនៅសាលារបស់គាត់ក៏មិនសូវល្អប៉ុន្មានដែរខែចុងក្រោយនេះ។ ជាធម្មតាគាត់ជាសិស្សទទួលបាននិទ្ទេស A ។

ថ្ងៃមួយ ឪពុកចុងរបស់ក្មេងប្រុសនេះបានចូលមើលទូរស័ព្ទកូនប្រុសគាត់ ពេលគាត់កំពុងដេកលក់ហើយបានរកឃើញថា កូនប្រុសគាត់បានទាក់ទងជាមួយស្ត្រីខ្មែរពេញវ័យម្នាក់ [ដែលរស់នៅក្នុងទីក្រុងមួយផ្សេងទៀត] អស់រយៈពេលជាច្រើនខែ។ វាពិបាកក្នុងការដឹងពីអាយុពិតប្រាកដរបស់ស្ត្រីម្នាក់នេះតាមរយៈរូបថតរបស់នាង ប៉ុន្តែនាងមើលទៅទំនងជាមានអាយុចន្លោះពី៣០ទៅ៤០ឆ្នាំ។

ស្ត្រីម្នាក់នេះបានផ្ញើសារមកកូនប្រុសគាត់ ហើយសារខ្លះទាក់ទងនឹងការរួមភេទ។ នាងក៏បានផ្ញើរូបថតអាក្រាតរបស់នាងមកឱ្យគាត់ ហើយសុំគាត់ឱ្យធ្វើដូចគ្នា ហើយគាត់ក៏បានធ្វើដូច្នេះដែរ។ ស្ត្រីម្នាក់នោះបានប្រាប់ថា នាងស្រឡាញ់ក្មេងប្រុសនោះ ហើយមានគម្រោងនឹងមកស្រុកកំណើតក្នុងពេលឆាប់ៗនេះដើម្បីពួកគេអាចជួបគ្នា និងរួមភេទជាមួយគ្នា។

ម្តាយរបស់ក្មេងប្រុសនេះមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះអ្វីដែលគាត់បានរកឃើញ ហើយស្ថានភាពនេះកាន់តែស្មុគស្មាញ ដោយសារប្តីរបស់គាត់ដែលជាឪពុកចុងរបស់ក្មេងប្រុស បានប្រាប់គាត់ថា កុំឱ្យធ្វើអ្វីទាំងអស់។ គាត់ជឿថា នេះជារឿងធម្មតាទេដែលក្មេងប្រុសចាប់អារម្មណ៍នឹងមនុស្សស្រី ហើយគិតថាជាការល្អកូនប្រុសគាត់អាចរួមរ័ក្សជាមួយមនុស្សស្រី ព្រោះគាត់អាចរៀនពីរបៀបក្លាយជា «បុរសពិត»។ គាត់បាននិយាយថាក្មេងប្រុសមាន«សំណាង»ហើយ និងគិតថានឹងកូនប្រុសនេះនឹងមានសុខភាពល្អ។

របាយការណ៍បញ្ឈប់គ្រោះថ្នាក់ក៏និយាយរឿងហេតុជាក់ស្តែងផ្សេងៗទៀត ដែលរួមចំណែកដល់ការយល់ដឹងអំពីបរិបទ និងបរិស្ថានវប្បធម៌សង្គមដែលអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA) កើតឡើងផងដែរ។

# ការចែករំលែកខ្លឹមសារផ្លូវភេទ ដែលបង្កើតដោយខ្លួនឯងពាក់ព័ន្ធនឹងកុមារ

*ការនេះអាចនាំទៅដល់ ឬជាផ្នែកមួយនៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារលើប្រព័ន្ធអនឡាញ (OCSEA) ទោះបីជាខ្លឹមសារនេះត្រូវបានផលិតដំបូង និងចែករំលែកដោយស្ម័គ្រចិត្តរវាងមិត្តភក្តិក៏ដោយ ក៏អាចត្រូវបាន បញ្ជូនបន្តដោយគ្មានការអនុញ្ញាត ឬទទួលបានតាមរយៈការបោកប្រាស់ ឬការបង្ខិតបង្ខំ។*

## ករណីសិក្សា ក

ឪពុកម្តាយរបស់ក្មេងស្រីអាយុ១៧ឆ្នាំម្នាក់ បានមកជួបអ្នក។ ពួកគេបានរកឃើញថាកូនស្រីរបស់ពួកគេមានមិត្តប្រុសម្នាក់ (អាយុ១៧ឆ្នាំដូចគ្នា) ហើយពួកគេបានផ្លាស់ប្តូររូបថត និងសារបែបផ្លូវភេទរយៈពេលជាច្រើនខែមកហើយ។ មិនមានភស្តុតាងណាដែលបង្ហាញថាមានការគំរាមការលួងលោមឬការបង្ខិតបង្ខំណាមួយពីយុវជនណាម្នាក់ដែលពាក់ព័ន្ធក្នុងរឿងនេះទេ។ មើលទៅហាក់ដូចជាយុវជនទាំងពីរនាក់នេះបានយល់ព្រមចែករំលែករូបភាពទាំងនេះ។ ប៉ុន្តែឪពុកម្តាយរបស់ក្មេងស្រីមិនសប្បាយចិត្ត។ ពួកគាត់ខឹងកូនស្រីដែលបានប្រព្រឹត្តទង្វើបែបនេះ និងបារម្ភអំពីកេរ្តិ៍ឈ្មោះគ្រួសារ។ ពួកគាត់ចង់ឱ្យអ្នកចាប់ខ្លួន និងអនុវត្តន៍ច្បាប់ ដោយចាប់ក្មេងប្រុសនោះមកផ្តន្ទាទោស។

## ករណីសិក្សា ខ

ក្មេងស្រីអាយុ១៥ឆ្នាំម្នាក់ និងមិត្តប្រុសអាយុ១៧ឆ្នាំរបស់នាង មានទំនាក់ទំនងជិតស្និទ្ធ និងយកចិត្តទុកដាក់ចំពោះគ្នាអស់រយៈពេលជាងមួយឆ្នាំមកហើយ។ ពេលខ្លះពួកគេចែករំលែកសារបែបផ្លូវភេទ និងរូបថតតាមកម្មវិធី WhatsApp ហើយតែងតែយកចិត្តទុកដាក់មិនឱ្យនរណាម្នាក់ឃើញសារ និងការសន្ទនារបស់ពួកគេទេ។

ថ្ងៃមួយ មិត្តភក្តិរបស់ក្មេងប្រុសនោះបានប្រើទូរស័ព្ទគាត់ ហើយដោយមានគោលបំណងចង់លេងសើចក៏សម្រេចចិត្ត បង្ហោះរូបថតពួកគេតាមប្រព័ន្ធអនឡាញ។ មិនយូរប៉ុន្មាន រូបភាពនេះត្រូវបានគេចែករំលែកហើយចែករំលែកបន្តទៀតដោយអ្នកលែងបណ្តាញសង្គមជាច្រើនហើយយុវជនទាំងពីរនាក់នោះ



ឧបត្ថម្ភដោយ End Violence Against Children unicef for every child

បានសម្រេចចិត្តចាកចេញពីសាលា ដោយសារ ពួកគេត្រូវបានគេសើចចំអក និងធ្វើបាប។ ក្មេងប្រុសខឹងខ្លាំងណាស់ ចង់សងសឹកនឹងមិត្តភក្តិខ្លួន ហើយនារីរងគ្រោះ បានប្រាប់មិត្តភក្តិរបស់នាងថា នាងមានអារម្មណ៍ថា កេរ្តិ៍ឈ្មោះ និងជីវិតរបស់នាង ត្រូវបានគេបំផ្លាញ ហើយមានអារម្មណ៍ថាចង់បញ្ចប់ជីវិតនាង។ យុវជនទាំងពីរបានមកប៉ុស្តិ៍នគរបាល ជាមួយបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលមួយ។

## ការគំរាមកំហែងខាងផ្លូវភេទលើកុមារ

*សំដៅលើការប្រើប្រាស់ការគំរាមកេប្រយោជន៍ ឬការគំរាមកំហែង ដើម្បីស្នើសុំរូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទ ឬ អត្ថប្រយោជន៍ផ្សេងទៀត (ឧ៖ ប្រាក់) ពីកុមារ ដែលជារឿយៗដោយប្រើប្រាស់រូបភាពផ្លូវភេទរបស់កុមារដែលទទួលបានពីមុន ។*

### ករណីសិក្សា ក

ធែ ជាក្មេងប្រុសអាយុ១៥ឆ្នាំម្នាក់ រស់នៅជាមួយជីដូន ខណៈពេលដែលម្តាយរបស់គាត់ធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ។ ឪពុករបស់គាត់បានធ្វើអត្តឃាតកាលពីប៉ុន្មានឆ្នាំមុននេះ។ គាត់មានបងប្អូនប្រុសស្រីផ្សេងទៀតប៉ុន្តែពួកគេរស់នៅជាមួយសាច់ញាតិដទៃទៀតនៅខេត្តផ្សេង។ចាប់តាំងពីឪពុករបស់គាត់បានទទួលមរណភាពមក ធែបានក្លាយជាក្មេងប្រុសម្នាក់ដែលមានភាពអៀនខ្មាស់ និងមានមិត្តភក្តិតិចតួចណាស់ហើយគាត់តែងតែត្រូវបានគេធ្វើបាបនៅសាលាព្រោះគាត់ជាក្មេងប្រុសដែលស្លូតបូតហើយគាត់ក៏ត្រូវបានគេសើចចំអកឌឺដងឱ្យផងដែរ។

ក្មេងខ្លះនិយាយលេងសើចថាធែជាខ្ទើយ(ស្រឡាញ់ភេទដូចគ្នា)ហើយខ្លះទៀតនិយាយអាក្រក់អំពីឪពុកគាត់ដោយ និយាយថា ឪពុកធែបានសម្លាប់ខ្លួនព្រោះគាត់មិនស្រឡាញ់ធែទៀតទេ។ ធែស្រឡាញ់ជីដូនគាត់ខ្លាំងណាស់ ហើយ មានទំនាក់ទំនងជិតស្និទ្ធជាមួយគាត់ ប៉ុន្តែធែ មិនដែលប្រាប់គាត់អំពីបញ្ហារបស់ខ្លួននៅសាលា ឬថាខ្លួនមានអារម្មណ៍ឯកោទេ។ ជីដូនរបស់ ធែ មានវ័យចំណាស់ ហើយមានបញ្ហាសុខភាពមួយចំនួនទៀត ដូច្នេះធែមិនចង់ធ្វើឱ្យជីដូនមានការព្រួយបារម្ភឡើយ។ ពេលខ្លះគាត់មានអារម្មណ៍ក្រៀមក្រំ ហើយបានប្រើកាំបិតអារដៃខ្លួនឯង ការធ្វើបែបនេះធ្វើឱ្យគាត់បន្ធូរភាពតានតឹងបានខ្លះ។

ចាប់តាំងពីការរាតត្បាតជំងឺកូវីដ១៩ គាត់គ្មានជម្រើសអ្វីផ្សេង ក្រៅពីការសិក្សាតាមប្រព័ន្ធអនឡាញទេ គាត់ចូលចិត្ត ចំណាយពេលនៅតែម្នាក់ឯងពេលនៅផ្ទះ នៅក្នុងបន្ទប់របស់គាត់ជាមួយកុំព្យូទ័រយួរដៃរបស់គាត់។ គាត់លេងហ្គេមច្រើន ហើយប្រើកម្មវិធីផ្ញើសារ និងគេហទំព័របង្កើតមិត្តភក្តិជាច្រើនទៀត។ គាត់មានអារម្មណ៍ថាវាងាយស្រួលជួបមនុស្សតាមប្រព័ន្ធអនឡាញជាងក្នុងនៅជីវិតពិតហើយជារឿយៗគាត់ចែករំលែកបញ្ហារបស់គាត់ជាមួយមនុស្ស ដែលគាត់បានជួបនៅក្នុងការជជែកគ្នាតាមប្រព័ន្ធអនឡាញ។ គាត់មានអារម្មណ៍ថាវាងាយស្រួល និងមានសុវត្ថិភាពជាងមុន ក្នុងការជឿទុកចិត្តមនុស្សតាមប្រព័ន្ធអនឡាញ។

មនុស្សម្នាក់ដែលគាត់បានជួបតាមប្រព័ន្ធអនឡាញដែលគាត់ជឿថាស្រីខ្មែរបាននិយាយប្រាប់គាត់ថា នាងមានអាយុ២១ឆ្នាំ។ ពួកគេចែករំលែករឿងរ៉ាវជាច្រើនតាមរយៈសារ ហើយបានផ្ញើសារឱ្យគ្នាទៅវិញទៅមកអំពីបញ្ហារបស់ពួកគេ។ យូរៗទៅ គាត់មានអារម្មណ៍ថាគាត់អាចទុកចិត្តនាងបាន ហើយទំនាក់ ទំនងរបស់ពួកគេក៏កាន់តែជិតស្និទ្ធជាងមុន។ គាត់មិនដែលឃើញមុខនាងតាមប្រព័ន្ធអនឡាញទេ ប៉ុន្តែនាងបានចែករំលែករូបថត ដែលនាងនិយាយថាជារូបរបស់នាង។ នាងសន្យាថាថ្ងៃណាមួយនឹងជួបតាមវីដេអូខល (video messenger) ហើយបានពន្យល់ថា នាងក៏ដូចជាគាត់ដែរនាងក៏អៀនដែរ។

បន្តិចម្តងៗ ពួកគេចាប់ផ្តើមនិយាយអំពីរឿងស្និទ្ធស្នាលកាន់តែច្រើនជាងមុន ហើយនាងបានចែករំលែករូបថតនាង រួមទាំងរូបថតអាក្រាតរបស់នាងផងដែរ។ នាងបានសុំរូបថតគាត់ ហើយដោយសារនាងធ្វើឱ្យគាត់មានអារម្មណ៍ពិសេស» គាត់ក៏យល់ព្រម។ គាត់ជឿជាក់លើនាងខ្លាំង ដូច្នេះហើយពេលដែលនាងសុំឱ្យគាត់ធ្វើវីដេអូខល អំពីការសម្រេចកាមដោយខ្លួនឯង គាត់ក៏យល់ព្រម។ រឿងនេះកើតឡើងពីរទៅបីដង ហើយគាត់មានអារម្មណ៍ល្អចំពោះទំនាក់ទំនងនេះ ហើយសង្ឃឹមថានឹងបានជួបនាងនាពេលអនាគត។

ថ្ងៃមួយ គាត់ទទួលបានការទាក់ទងដោយបុគ្គលម្នាក់ដែលគាត់មិនស្គាល់ ដែលនិយាយថា ពួកគេមានវីដេអូ និងរូបថតរបស់គាត់ ហើយគេនឹងចែករំលែកវាយ៉ាងទូលំទូលាយតាមប្រព័ន្ធអនឡាញ និងជាមួយមនុស្សគ្រប់គ្នានៅសាលារបស់គាត់ លុះត្រាតែគាត់បង់ប្រាក់ ២០០ដុល្លារ ឱ្យពួកគេ។ គាត់បានព្យាយាមទាក់ទងទៅស្រីដែលគាត់បានផ្ញើរូបថត និងវីដេអូទៅ ប៉ុន្តែគណនីរបស់នាងត្រូវបានគេបិទហើយ គាត់ពិបាកចិត្តជាខ្លាំងអំពីរឿងសម្ងាត់មួយនេះ ហើយមានអារម្មណ៍ខ្មាស់គេ ដែលគាត់ត្រូវបានគេបោកប្រាស់ ប៉ុន្តែភ័យខ្លាចមនុស្សដឹងពីរឿងរបស់គាត់។ គាត់មានអារម្មណ៍ចង់ធ្វើអត្តឃាត ហើយបានទាក់ទងទៅអង្គការមិនមែនរដ្ឋាភិបាលមួយដើម្បីសុំជំនួយ ហើយគាត់ក៏យល់ព្រមមកជួបអ្នកដែលជាមន្ត្រីនគរបាលដើម្បីពន្យល់ពីរឿងរ៉ាវរបស់គាត់។

## ករណីសិក្សា ២

គ្រីស្នា ជាក្មេងស្រីអាយុ១៦ឆ្នាំម្នាក់ ដែលរស់នៅជាមួយឪពុកម្តាយនាង។ ឪពុកម្តាយរបស់នាងមិនសូវយកចិត្តទុកដាក់ នឹងនាងប៉ុន្មានទេ ព្រោះពួកគេរវល់ធ្វើការច្រើនម៉ោង ដូច្នេះតាំងពីអាយុ១២ឆ្នាំមក នាងបានចំណាយពេលច្រើននៅផ្ទះតែម្នាក់ឯងនៅពេលល្ងាច។ នាងបានចំណាយពេលច្រើនតាមប្រព័ន្ធអនឡាញ តាមរយៈការផ្ញើសារទៅមិត្តភ័ក្តិ ការជជែកលេងក្នុងគ្រុបឆាត និងជួបមនុស្សដទៃទៀត។

នាងបានជួបនឹងយុវជនម្នាក់ដែលនិយាយថាគាត់រស់នៅប្រទេសបារាំង ហើយមានអាយុ២៣ឆ្នាំ។ពួកគេបានប្រាស្រ័យទាក់ទងគ្នាជាភាសាអង់គ្លេសតាមរយៈសារ និងតាមរយៈវីដេអូខលផងដែរ។ គាត់បង្ហាញចិត្តល្អចំពោះនាង ហើយធ្វើឱ្យនាងមានអារម្មណ៍ល្អចំពោះខ្លួនឯង ហើយបាននិយាយថានាងជាស្រីស្អាតម្នាក់។ ពួកគេបានយល់ព្រមធ្វើជាមិត្តស្រីមិត្តប្រុសតាមប្រព័ន្ធអនឡាញ ហើយគាត់បានសន្យាថាថ្ងៃណាមួយគាត់នឹងមកប្រទេសកម្ពុជាដើម្បីជួបនាង។ យូរៗទៅពួកគេនិយាយអំពីរឿងស្និទ្ធស្នាលរួមទាំងរឿងផ្លូវភេទផងដែរ ហើយពួកគេចូលអនឡាញ និងបង្ហាញរាងកាយ និងសម្រេចកាមដោយខ្លួនឯង

ជាមួយគ្នា។ ពួកគេយល់ស្របថាពួកគេមិនគួរថតវីដេអូទុកពេលពួកគេជួបគ្នាតាមអនឡាញទេ។ គ្រីស្នាមានអារម្មណ៍មិនសូវស្រួលក្នុងការធ្វើបែបនេះទេ ប៉ុន្តែបានយល់ព្រមព្រោះគាត់ធ្វើឱ្យនាងមាន អារម្មណ៍ពិសេស ហើយគាត់ប្រាប់នាងថាគាត់ស្រឡាញ់នាង ហើយថាគាត់ចង់រស់នៅជាមួយនាង។ យ៉ាងណាមិញ ថ្ងៃមួយគាត់បានសុំនាងឱ្យដោះសម្លៀកបំពាក់ចេញ ហើយនាងមិនសប្បាយចិត្តនឹងរឿងនេះទេនាងបានបដិសេធ។ គាត់ខឹងនឹងនាងខ្លាំង ហើយគំរាមផ្ញើរូបថតស្និទ្ធស្នាលរបស់នាងទៅមិត្តភក្តិ និង សមាជិកគ្រួសាររបស់នាងតាមហ្វេកប៊ុក ហើយថែមទាំងបង្ហោះវីដេអូរបស់នាង នៅលើគេហទំព័រអាសអាភាសទៀតផង។ នាងបានបដិសេធគាត់ មានអារម្មណ៍ ខឹងខ្លាំងបានបិទការហៅតាមទូរស័ព្ទ ហើយបានប្លុកគាត់ចោល។ នាងខឹងខ្លាំងណាស់ ហើយមានអារម្មណ៍ភ័យខ្លាច តែមិនជឿថាគាត់នឹងធ្វើបែបនេះទេ ។

នៅថ្ងៃបន្ទាប់ នាងបានទទួលបានសារពីមិត្តភក្តិនៅសាលារបស់នាង ដោយនិយាយថាពួកគេទទួលបានរូបថតអាក្រាត របស់នាង ហើយបន្ទាប់មកបងប្រុសរបស់នាងបានទូរស័ព្ទរកនាង។ គាត់ខឹងនាងយ៉ាងខ្លាំង ហើយស្រែកដាក់នាង ដោយសារគាត់ក៏បានទទួលរូបភាពអាក្រាតរបស់នាង ហើយចង់ដឹងថា មានរឿងអ្វីកើតឡើង គាត់បានស្តីបន្ទោសឱ្យនាងថានាងជា«ស្រីអាក្រក់»។

## ករណីសិក្សា គ

ធីតាមានអាយុ១៥ឆ្នាំ ក្រោយពីរៀននៅសាលាហើយ នាងត្រលប់ទៅផ្ទះវិញ ហើយចំណាយពេលច្រើនតែម្នាក់ឯងតាម ប្រព័ន្ធអនឡាញ។ នាងបានជួបក្មេងស្រីម្នាក់ឈ្មោះ សុជាតិ អាយុ១៦ឆ្នាំ តាមរយៈហ្វេសប៊ុក។ ពួកគេបានមានទំនាក់ ទំនងស្និទ្ធស្នាលជាមួយគ្នា ជួបគ្នារាល់ថ្ងៃតាមអនឡាញ។ ពួកគេនិយាយគ្នាអំពីជីវិតក្តីសុបិន និងបញ្ហារបស់ពួកគេ ហើយបានបង្កើនការមានទំនុកចិត្តលើគ្នាទៅវិញទៅមក។

ថ្ងៃមួយ ពេលកំពុងផ្ញើសារដោះដូរគ្នា សុជាតិបានសុំឱ្យធីតាចែករំលែករូបថតប្លែកៗ។ សុជាតិសុំឱ្យធីតាផ្ញើរូបថតអត់ ពាក់អាវ ហើយធីតាបានផ្ញើរូបថតអត់ពាក់អាវឱ្យទៅសុជាតិ។ ពេលនោះ ធីតាបានសម្រេចចិត្តថានឹងមិនផ្ញើរូបថតបែបនេះទៀតទេហើយពួកគេនៅតែជាមិត្តភក្តិនឹងគ្នាដដែល។ថ្ងៃមួយពួកគេបានជួបគ្នាជាលើកដំបូង ដើម្បីញ៉ាំកាហ្វេនៅ ហាងកាហ្វេមួយក្នុងតំបន់ ហើយពួកគេមានទំនាក់ទំនងល្អជាមួយគ្នា។ ធីតាពិតជារីករាយជាមួយពេលវេលាដែលនាងមានជាមួយសុជាតិខ្លាំងណាស់ ហើយពួកគេបានដោះដូរគ្រឿងអលង្ការឱ្យគ្នាទៅវិញទៅមក ជាសញ្ញានៃចំណងមិត្តភាព។ ធីតាគិតថា សុជាតិ ជាមនុស្សបើកចំហ និងស្មោះត្រង់ខ្លាំងណាស់ ហើយក្នុងន័យខ្លះទៀត ធីតាបានចាប់ផ្តើមមានអារម្មណ៍«ចាប់ចិត្តស្រឡាញ់» សុជាតិ។ នាងមិនសូវយល់ពីអារម្មណ៍របស់នាងប៉ុន្មានទេ ប៉ុន្តែនាងមានអារម្មណ៍ទាក់ទាញចំពោះសុជាតិ។ យូរៗទៅ ពួកគេកាន់តែស្និទ្ធស្នាលជាងមុន ហើយធីតាក៏យល់ព្រមផ្ញើរូបថតនិងវីដេអូខ្លីៗអំពីរាងកាយអាក្រាតរបស់នាង។

ថ្ងៃមួយ ធីតា បានទទួលសំណើអ៊ីនស្រ្តាក្រាម ពីជនមិនស្គាល់មុខម្នាក់ ហើយនាងបានទទួលយកសំណើនោះ។ម្នាក់នោះបានផ្ញើរូបថតដែលនាងធ្លាប់ចែករំលែកជាមួយសុជាតិហើយបានទាមទាររូបថត


ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

បន្ថែមទៀត។ ប្រសិនបើនាងមិនយល់ព្រមទេ បុគ្គលនោះបាននិយាយថា ពួកគេនឹងចែករំលែករូបថត និងវីដេអូរបស់នាងយ៉ាងទូលំទូលាយនៅលើ Facebook Instagram និងបណ្តាញសង្គមផ្សេងទៀត។

នាងភ័យខ្លាចជាខ្លាំង ដូច្នេះនាងបានផ្ញើរូបភាពបន្ថែមទៀត ហើយបន្ទាប់មកបានប្លុកគណនីអ៊ីនស្តាក្រាមនោះចោល។ នាងបានទាក់ទងទៅសុជាតិ ហើយសុជាតិបានប្រាប់នាងថា គណនីរបស់នាងត្រូវបានគេលួចចូលហើយពួកគេបានលួចរូបថតទាំងនោះ។ធីតាមិនប្រាកដថានាងអាចទុកចិត្តសុជាតិបានឬមិនបានទេ ហើយក៏មិនដឹងប្រាកដថាសុជាតិនិយាយការពិតឬមិនពិតដែរ ទើបនាងសម្រេចចិត្តបញ្ចប់មិត្តភាព ហើយបានប្លុកគណនីរបស់សុជាតិចោល។ ចាប់តាំង ពីពេលនោះមក ធីតាបានទទួលសារពីគណនីមិនស្គាល់ និងគំរាមចែករំលែករូបថតរបស់នាង លុះត្រាតែនាងចែក រំលែករូបថតបន្ថែមទៀត។

នាងបានទាក់ទងទៅអង្គការមិនមែនរដ្ឋាភិបាលមួយដើម្បីសុំជំនួយ បន្ទាប់ពីបានឃើញខ្សែភាពយន្តព័ត៌មានតាមប្រព័ន្ធអនឡាញនិយាយអំពីសុវត្ថិភាពតាមប្រព័ន្ធអនឡាញ។នាងចង់ឱ្យបញ្ហានេះទៅឆ្ងាយ ប៉ុន្តែមិនដឹងថាត្រូវធ្វើយ៉ាងណាទេ។

# ការបៀតបៀនផ្លូវភេទកុមារ៖

*យោងតាមការស្ទង់មតិគ្រួសារនៅក្នុងការសិក្សាស្តីអំពីការបញ្ឈប់គ្រោះថ្នាក់ស្ទើរតែ១៦%នៃកុមារដែលប្រើប្រាស់អ៊ីនធឺណិតក្នុងប្រទេសកម្ពុជា នៅក្នុងឆ្នាំមុននេះ បានទទួលនូវមតិ (comments) បែបផ្លូវភេទអំពីពួកគេ ដែលធ្វើឱ្យពួក គេមានអារម្មណ៍មិនស្រណុកចិត្ត ដែលក្នុងនោះរួមមាន៖ រឿងកំប្លែង រឿងផ្សេងៗ ឬមតិអំពីរាងកាយកុមារ រូបរាង ឬ សកម្មភាពផ្លូវភេទ។ កុមារភាគច្រើនទទួលរងផលអវិជ្ជមានពីការទាំងនេះ ហើយជាទូទៅមានអារម្មណ៍ខ្មាស់អៀន ធុញថប់ តប់ប្រមល់ ឬខឹង ដែលទទួលបានការប្រព្រឹត្តបែបនេះមកកាន់ពួកគេ។*

## ករណីសិក្សា ក

ក្មេងស្រីម្នាក់មានអាយុ ១៤ឆ្នាំ បានទទួលសំណេរបង្ហោះមួយ នៅលើទំព័រហ្វេសប៊ុករបស់នាងពីមិត្តភក្តិ Facebook ម្នាក់ដែលនិយាយពាក្យអាក្រក់ៗ ពីរូបរាងកាយរបស់នាង។ មិត្តភក្តិ និងក្រុមគ្រួសាររបស់នាងទាំងអស់គ្នាសុទ្ធតែអាចមើលឃើញសារទាំងនេះដែរ។ សារទាំងនេះបានបញ្ចេញមតិអំពីការអភិវឌ្ឍផ្លូវភេទ និងទំហំសុដន់របស់នាង ហើយប្រាប់នាងថា នាងមើលទៅដូចជាស្រីពេស្យា ដែលមើលទៅទំនងជានឹងមានក្លិនដូចធ្លាប់បានរួមភេទច្រើនដងជាមួយបុរសវ័យចំណាស់ៗ។

ក្មេងស្រីម្នាក់នេះមានអារម្មណ៍អាក់អន់ចិត្ត និងពិបាកចិត្តជាខ្លាំងដោយសារពាក្យ**សំដី**ដ៏អាក្រក់បែបនេះ ហើយជាពិសេស ពេលដែលមនុស្សជាច្រើនទៀតក៏បង្ហោះរូបសញ្ញាអារម្មណ៍សើចក្អាកក្អាយ និងមតិសើចចំអកផ្សេងទៀតផងដែរ។

### ករណីសិក្សា ៦

ក្មេងប្រុសអាយុ១៥ឆ្នាំម្នាក់ បានទាក់ទងការិយាល័យអ្នក បន្ទាប់ពីទទួលបានសារ និងសារនៅលើបណ្តាញសង្គម ដែលចោទប្រកាន់ថាគាត់ជាមនុស្សស្រឡាញ់ភេទដូចគ្នា។ បុគ្គល ឬអ្នកដែលបានផ្ញើសារនោះ បានយករូបថតគាត់ចេញពីគណនីហ្វេកប៊ុកគាត់ហើយបានកាត់តក្បាលរបស់គាត់ដាក់លើរូបភាពបុរសវ័យក្មេងកំពុងរួមភេទ។ គាត់មានមិត្តភក្តិ Facebook ជាច្រើន ហើយមិនដឹងពីរបៀបកំណត់ឯកជនភាពរបស់គាត់ទេ ដូច្នេះរូបភាពនេះត្រូវបានគេចែករំលែក ហើយចែករំលែកបន្តទៀតជាច្រើនដង។

គាត់ពិតជាអាក់អន់ចិត្ត និងពិបាកចិត្តណាស់ ដោយសារការបង្ហោះរូបនេះ និងពាក្យសម្ដីអាក្រក់ៗ ហើយជាពិសេស ក៏មានមហាជនជាច្រើនទៀតបានបង្ហោះរូបសញ្ញាអារម្មណ៍សើចក្អាកក្អាយ និងបញ្ចេញមតិយោបល់លេងសើចផ្សេងទៀតផងដែរ។

# ការជួបប្រទះដែលកុមារមិនចង់ជួប ចំពោះមាតិកាផ្លូវភេទតាមប្រព័ន្ធអនឡាញ

*វាអាចបង្កើតឬបើកដំណើរការនៃការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) នៅក្នុងករណីមួយចំនួន។ ឧទាហរណ៍៖ ជនល្មើសអាចបង្ហាញកុមារដោយចេតនាអំពីខ្លឹមសារផ្លូវភេទ ដែលជាផ្នែកមួយនៃការលួងលោមពួកគេ ដើម្បីលួងពួកគេឱ្យធ្វើសកម្មភាពផ្លូវភេទ។*

### ករណីសិក្សា ៧

ក្មេងស្រីម្នាក់មានអាយុ ១៤ឆ្នាំ បានទទួលរូបភាពបែបផ្លូវភេទ និងការផលិតរូបភាពអាសអាភាសលក្ខណៈពាណិជ្ជកម្មពីសិស្សប្រុសអាយុច្រើនជាងគាត់នៅសាលារៀនរបស់គាត់។ ពួកគេជាមិត្តភក្តិតាម Facebook ហើយបើទោះបីជានាង បានប្លុកគាត់ជាច្រើនដងហើយក៏ដោយ ក៏គាត់នៅតែរករបៀបផ្សេងៗដោយបង្កើតអត្តសញ្ញាណថ្មី និងបន្តផ្ញើសម្ភារៈផ្លូវ ភេទមកឱ្យនាង។ កាលណានាងកាន់តែប្លុកគាត់ កាលនោះនាងកាន់តែទទួលបានសារកាន់តែច្រើនជាងមុនពីគាត់។ នៅសារចុងក្រោយ អ្នកដែលបានផ្ញើសារមកឱ្យនាង បានប្រាប់នាងថា គាត់ចង់ធ្វើចំពោះនាងដូចអ្វីដែលមនុស្សនៅក្នុងខ្សែភាពយន្តនោះកំពុងធ្វើ។

### ករណីសិក្សា ខ

យុវជនម្នាក់អាយុ ១៧ឆ្នាំ បានមកជួបអ្នកនៅការិយាល័យរបស់អ្នក ជាមួយមិត្តភក្តិម្នាក់របស់គាត់។ គាត់ខ្មាស់អៀនយ៉ាងខ្លាំង ហើយក៏មានអារម្មណ៍តានតឹង និងតូចចិត្តផងដែរ ប៉ុន្តែដោយសារមានជំនួយពីមិត្តភក្តិរបស់គាត់ គាត់បានយល់ ព្រមមកជួបអ្នក។ គាត់បានពន្យល់ថា គាត់បានក្លាយជាមិត្តតាមអនឡាញជាមួយបុរសជនជាតិខ្មែរអាយុច្រើនជាងគាត់ (យ៉ាងហោចណាស់បុរសនោះមានអាយុប្រហែល ៣០ឆ្នាំ ទោះបីគាត់មិនច្បាស់ក៏ដោយ)។ បុរសម្នាក់នោះឈ្មោះ សុជា វត្ត បានផ្ញើសម្ភារៈអាសអាភាសរបស់បុរសរួមរក្សជាមួយបុរស និងខ្សែភាពយន្តបុរសសម្រេចកាមដោយខ្លួនឯងដល់គាត់ សម្ភារៈខ្លះត្រូវបានផលិតឡើងជាលក្ខណៈពាណិជ្ជកម្ម ហើយខ្លះទៀតហាក់ដូចជាផលិតឡើងដោយខ្លួនឯង ទោះបីគាត់មិនច្បាស់ពីការនេះក៏ដោយ។

បន្ទាប់ពីការពិភាក្សាបន្ថែមមក មិត្តរបស់ក្មេងប្រុសនោះបានពន្យល់ថា គាត់(ក្មេងប្រុសនោះ) ចាប់អារម្មណ៍នឹងបុរសនោះ ហើយគិតថា គាត់ប្រហែលជាស្រឡាញ់ភេទដូចគ្នាហើយមើលទៅ ដូច្នេះគាត់កាន់តែមានអារម្មណ៍ខ្មាស់អៀនក្នុងការរាយការណ៍ពីអ្វីដែលបានកើតឡើង។ គាត់មានអារម្មណ៍ថា គាត់ជាអ្នកត្រូវទទួលខុសត្រូវចំពោះអ្វី ដែលបានកើតឡើង ប៉ុន្តែមានអារម្មណ៍តានតឹងចិត្ត និងតូចចិត្តកាន់តែខ្លាំងឡើង។ បុរសដែលផ្ញើខ្សែភាពយន្តនោះប្រាប់គាត់ថា ភាពយន្តនោះ គឺដើម្បីជួយគាត់ឱ្យដឹងថា តើបុរសស្រឡាញ់ភេទដូចគ្នាមានលក្ខណៈបែបណា បុរសរូបនោះក៏បានសុំឱ្យក្មេងប្រុសនោះ ផ្ញើរូបភាព និងថតវីដេអូអាក្រាតរបស់គាត់ផងដែរ ប៉ុន្តែរហូតមកដល់ពេលនេះគាត់បានបដិសេធមិនធ្វើដូច្នេះទេ។

## កុមារ LGBTQI៖

### ករណីសិក្សា ក

អង្គការមិនមែនរដ្ឋាភិបាលមួយបានទាក់ទងមកអ្នក បន្ទាប់ពីក្មេងប្រុសអាយុ ១៦ឆ្នាំម្នាក់ បានទាក់ទងមកពួកគេ បន្ទាប់ពីឧប្បត្តិហេតុមួយកាលពីសប្តាហ៍មុន។ ក្មេងប្រុសម្នាក់នេះ មិនចង់បញ្ចេញឈ្មោះគាត់ឱ្យគេស្គាល់ទេនៅពេលនេះ។ គាត់បានពន្យល់ថា គាត់បានចូលរួមពិធីជប់លៀងមួយ ជាមួយមិត្តភក្តិនៅមហាវិទ្យាល័យ គាត់ស្រវឹងខ្លាំងណាស់ ហើយក៏សន្លប់បាត់ទៅ។ ពេលដឹងខ្លួនឡើងវិញនៅថ្ងៃបន្ទាប់គាត់បានត្រឡប់ទៅផ្ទះវិញ ហើយបានដេកច្រើនម៉ោង ព្រោះគាត់ឈឺក្បាលខ្លាំង។

ក្រោយមកនៅថ្ងៃដដែលនោះ គាត់បានទទួលសារពីមិត្តម្នាក់របស់គាត់ ដែលបង្ហាញការព្រួយបារម្ភអំពីវីដេអូរួមភេទរបស់គាត់ជាមួយបុរសពេញវ័យពីរនាក់ទៀត ដែលត្រូវបានគេបង្ហោះលើប្រព័ន្ធអនឡាញ។ មិត្តភក្តិម្នាក់នោះបានសន្មតថាក្មេងប្រុសនោះបានបង្ហោះវីដេអូនោះដោយខ្លួនឯងប៉ុន្តែគាត់មិនបានធ្វើដូច្នេះទេហើយគាត់មានអារម្មណ៍តក់ស្លុតនិងរំខានយ៉ាងខ្លាំងដោយសារអ្វីដែលគាត់បានឃើញវីដេអូនេះបានកើតឡើងក្នុងពិធីជប់លៀង ប៉ុន្តែក្មេងប្រុសម្នាក់នោះមិនបាននឹកចាំពីអ្វីទាំងអស់ ដែលបានកើតឡើងទេ។

ចាប់តាំងពីពេលនោះមក ក្មេងប្រុសម្នាក់នោះបានទទួលសារជាច្រើនបង្ហាញ ពីការស្អប់ខ្ពើមគាត់នៅលើគណនី Facebook និងInstagram របស់គាត់ ដូច្នេះហើយគាត់ក៏បិទគណនីទាំងពីរនោះចោលទៅ។ ហាក់ដូចជាវីដេអូនោះ ត្រូវបានគេចែករំលែកយ៉ាងទូលំទូលាយនៅលើបណ្តាញសង្គម។

តាំងពីពេលនោះមក គាត់មិនបានចាកចេញពីផ្ទះទេ ហើយឈប់ចូលរៀននៅមហាវិទ្យាល័យទៀត គាត់ក៏ព្យាយាមធ្វើអត្តឃាត (ចងក) ដែរ។ ឪពុកម្តាយគាត់បានដឹងពីរឿងនេះ ហើយពួកគាត់មានទុក្ខព្រួយយ៉ាងខ្លាំង។ ពេលនេះក្មេងប្រុសនេះ បានលាតត្រដាងប្រាប់ឪពុកម្តាយរបស់គាត់ថា គាត់ជាអ្នកស្រឡាញ់មនុស្សភេទដូចគ្នា ហើយពួកគេក៏ខកចិត្តចំពោះរឿងនេះដែរ ប៉ុន្តែពួកគេនៅតែគាំទ្រគាត់។

អង្គការមិនមែនរដ្ឋាភិបាល បានពន្យល់ប្រាប់ក្មេងប្រុសនោះថា អ្វីដែលបានកើតឡើង គឺជាការរំលោភបំពានដោយគ្មានការយល់ព្រមពីគាត់ ហើយអ្វីដែលបានកើតឡើងក្រោយពីពេលនោះ (ការចែករំលែកខ្សែវីដេអូ និងរូបភាព) គឺជាបទល្មើសឧក្រិដ្ឋផងដែរ។ ពួកគេបានសំណូមពរឱ្យក្មេងប្រុសនោះ គួររាយការណ៍ពីរឿងរ៉ាវដែលបានកើតឡើងទៅអាជ្ញាធរ ប៉ុន្តែនៅពេលនេះ គាត់មិនទាន់ព្រមធ្វើដូច្នេះនៅឡើយទេ។ គាត់បាននិយាយប្រាប់បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលថា គាត់ធ្លាប់ប្រាប់គេថា គាត់ជាមនុស្សស្រឡាញ់ភេទដូចគ្នា ហើយទទួលបានបទពិសោធន៍ នៃការរើសអើងជាច្រើន។ គាត់ជឿថាប្រសិនបើគាត់រាយការណ៍ គាត់ក៏នឹងទទួលបានការរើសអើងពីនគរបាល ហើយត្រូវបានគេស្តីបន្ទោសដោយសារអ្វី ដែលបានកើតឡើង។

## ករណីសិក្សា ២

អ្នកត្រូវទៅមន្ទីរពេទ្យខេត្តនៅក្នុងស្រុក បន្ទាប់ពីទទួលបានទូរស័ព្ទពីវេជ្ជបណ្ឌិត ដែលកំពុងព្យាបាលអ្នកជំងឺម្នាក់ បន្ទាប់ពីទទួលរងការវាយប្រហារផ្លូវភេទដោយប្រើហិង្សា ពេលអ្នកទៅដល់មន្ទីរពេទ្យ អ្នកបានជួបវេជ្ជបណ្ឌិត ដែលបានពន្យល់អ្នកអំពីស្ថានភាពរបស់អ្នកជំងឺ គាត់បាននិយាយថា អ្នកជំងឺគឺជាបុរសវ័យក្មេងអាយុ ១៧ឆ្នាំ គាត់ជា «អ្នកកែភេទ» ដូច្នេះគេកំណត់អត្តសញ្ញាណគាត់ថាជាក្មេងស្រី។

វេជ្ជបណ្ឌិតនោះបានពន្យល់ទៀតថា គាត់បានដឹងព័ត៌មានលម្អិត នៃការវាយប្រហារនេះនៅមានកម្រិតនៅឡើយ ដោយសារគាត់ផ្តោតលើការព្យាបាលរបួសដែលអ្នកជំងឺមាន។ គាត់បានពន្យល់ថា ការរងរបួសនេះបង្ហាញថា ជននោះត្រូវបានគេវាយនឹងដំបង និងឧបករណ៍ទាល (មិនមានចុងស្រួច) ហើយមានស្នាមមុត និងជាំពេញខ្លួន។ របួសក៏បានបង្ហាញថា អ្នកជំងឺត្រូវបានគេរំលោភតាមរន្ធគូថយ៉ាងធ្ងន់ធ្ងរ ដោយសារមានដាច់រយាស់រន្ធគូថ ហើយមានរបួសនៅខាងក្នុង។ បុគ្គលកែភេទនេះបានមកដល់មន្ទីរពេទ្យជាមួយមិត្តភក្តិគាត់។ ពេលជួបជាមួយពួកគេ ពួកគេបានពន្យល់ថា អ្នកជំងឺចូលចិត្តឱ្យគេហៅឈ្មោះខ្លួនថា «ស្រីពេជ្រ» ហើយចូលចិត្តទៅជប់លៀង និងច្រៀងរកលុយតាមក្រុមភ្លេងដោយតែងខ្លួនជាមនុស្សស្រី។ ស្រីពេជ្រ មានសំលេងពិរោះ ហើយល្បីខ្លាំងណាស់។ មិត្តភក្តិគាត់បានពន្យល់ថា គាត់មិនប្រាកដ ១០០% ពីព័ត៌មានលម្អិតដែលបានកើតឡើងទេ ប៉ុន្តែក្រោយពីចប់ពិធីជប់លៀងកាលពីយប់ថ្ងៃសៅរ៍ ស្រីពេជ្រ ត្រូវបានគេលួងលោមឱ្យទៅផឹកស៊ីជាមួយក្រុមបុរសក្នុងភូមិមួយក្រុម។ ប៉ុន្តែអ្វីដែលគាត់រំពឹងថាជាការផឹកស៊ីដ៏សប្បាយរីករាយបានក្លាយជាសុបិនអាក្រក់ទៅវិញ។ ក្រុមបុរសនោះមានគ្នាយ៉ាងហោចណាស់ ១២នាក់ បានវាយដំលើ

លើរាងកាយនាងដោះសំលៀកបំពាក់សម្លៀងនៅលើឆាករបស់នាងចេញហើយដាក់វេនគ្នាចាប់រំលោភនាង ។បុរសទាំងនោះស្រវឹងស្រាជោកជាំហើយប្រើហិង្សាលើនាងយ៉ាងខ្លាំងរួចក៏បានចាប់រំលោភនាងដោយប្រើដបភេសជ្ជៈផងដែរ។

មិត្តភក្តិនាងបានពន្យល់ប្រាប់ទៀតថា ចាប់តាំងពីព្រឹត្តិការណ៍នោះមក វីដេអូនៃព្រឹត្តិការណ៍នេះ ត្រូវបានគេចែករំលែកនៅលើបណ្តាញសង្គមផ្សេងៗ ជាច្រើន ហើយនាងក៏ប្រើកម្មវិធីទាំងនេះផងដែរ។ នៅពេលនេះជនរងគ្រោះមានអាការៈឈឺខ្លាំងហើយគ្រូពេទ្យបានប្រើថ្នាំស្ងប់អារម្មណ៍ដល់គាត់ប៉ុន្តែគាត់អាចនិយាយបាន។ កន្លងមកនារីរងគ្រោះធ្លាប់មានទំនាក់ទំនងជាមួយមន្ត្រីនគរបាល ដែលរើសអើងនាងថាស្លៀកពាក់ដូចស្រី។ ដូច្នេះហើយនាងមានទំនុកចិត្តតិចតួចលើនគរបាល ហើយមិនប្រាកដថា នាងនឹងអាចនិយាយជាមួយពួកគេបានទេ។

## កុមារដែលមានពិការភាព៖

**ករណីសិក្សា ក**

ឪពុកម្តាយក្មេងស្រីអាយុ ១៤ឆ្នាំម្នាក់ បានទាក់ទងទៅភ្នាក់ងារនគរបាល។ កូនស្រីរបស់គាត់ (ឈ្មោះបុប្ផា) បានចែករំលែករូបភាពផ្លូវភេទ ដែលផលិតដោយខ្លួនឯងជាមួយក្មេងប្រុសអាយុច្រើនជាងនាង (គេជឿថាអាយុប្រហែល ១៥ ឬ១៦ឆ្នាំ)។ នាងជឿថាក្មេងប្រុងនោះជា «មិត្តប្រុសតាមអនឡាញ» របស់នាង ហើយនាងនិយាយថា នាងស្រឡាញ់គាត់។ យ៉ាងណាមិញ បងស្រីរបស់ក្មេងស្រីនេះ (អាយុ១៧ឆ្នាំ) បានពន្យល់ប្រាប់ឪពុកម្តាយថា រូបភាពដែលប្អូនស្រីរបស់នាងផ្ញើឱ្យក្មេងប្រុសនោះ ពេលនេះត្រូវបានគេចែករំលែកយ៉ាងទូលំទូលាយនៅលើបណ្តាញសង្គម។

ឪពុកម្តាយរបស់នាងបានពន្យល់ថា កូនស្រីរបស់ពួកគេមានពិការភាព និងមាន «ជំងឺពិការខួរក្បាល»។ ជំងឺនេះអាចប៉ះពាល់ដល់មនុស្ស១នាក់ក្នុងចំណោម៥០០នាក់។រោគសញ្ញាអាចមានលក្ខណៈខុសប្លែកគ្នាហើយអាចរួមបញ្ចូល៖ ចលនារាងកាយ ការគ្រប់គ្រងសាច់ដុំ ការសម្របសម្រួលសាច់ដុំ សភាពនៃសាច់ដុំរ៉េផ្លិចសណ្ឋាន និងតុល្យភាព។ មនុស្សមួយចំនួនទៀតដែលមានជំងឺពិការខួរក្បាល ក៏អាចមានពិការភ្នែក ការរៀន ការស្តាប់ ការនិយាយ ជំងឺឆ្កួតជ្រូក និង/ឬពិការភាពបញ្ញាផងដែរ។

ទោះជាយ៉ាងណាក៏ដោយ ពួកគេបានពន្យល់ទៀតថា កូនស្រីរបស់ពួកគេមិនមានពិការភាពបញ្ញា ឬពិបាករៀននោះទេ ទោះបីជានាងប្រើឧបករណ៍ជំនួយការស្តាប់ក៏ដោយ... ហើយការនិយាយរបស់នាងពេលខ្លះអាចពិបាកយល់សម្រាប់ មនុស្សដែលមិនស្គាល់នាង។ នាងចូលរៀននៅសាលាអង្គការមួយ ហើយរៀនថ្នាក់ទី៦ និងមានបុគ្គលិកជំនួយដល់ការរៀនសូត្ររបស់នាង។

ឪពុកម្តាយខឹងខ្លាំងណាស់ ចង់រកក្មេងប្រុសនោះមកចាក់សោឱ្យជាប់។ កំហឹងរបស់ពួកគេកាន់តែខ្លាំងជាងមុនពេល ដែលពួកគេទៅប៉ុស្តិ៍នគរបាលមូលដ្ឋាន ហើយត្រូវបានគេប្រាប់ថា វាគ្មានប្រយោជន៍អីទេក្នុងការ

ប៉ឹងផ្តល់ជនពិការ ដោយសារពួកគេមិនអាចធ្វើជាសាក្សីដ៏គួរឱ្យទុកចិត្តបានទេ ហើយពួកគេមិនយល់ពីអ្វីដែលបានកើតឡើងចំពោះពួកគេទេ។

## ករណីសិក្សា ២

ប្រធានគ្រូនៅមជ្ឈមណ្ឌលលំនៅឋានសម្រាប់កុមារពិការមួយ បានទាក់ទងមកអ្នក ដោយសារតែក្មេងប្រុសម្នាក់អាយុប្រហែល១៥ឆ្នាំឈ្មោះឆៃដែលស្ថិតក្រោមការមើលថែរបស់ពួកគេ។ក្មេងប្រុសនេះមានបញ្ហាមួយដែលគេហៅថា «Autism Spectrum Disorder (មានអូទីស្ស៊ីម)» (ASD)។

រោគសញ្ញាមួយចំនួននៃ ASD អាចរួមបញ្ចូល៖ ការប្រាស្រ័យទាក់ទង និងអន្តរកម្មសង្គម (ការយល់ដឹងពីមនុស្សដទៃនិង/ឬធ្វើឱ្យមនុស្សដទៃទៀតយល់ពីពួកគេ)មានឥរិយាបថដែលអាចមើលទៅខុសប្លែកពីអ្នកដទៃ (ឧ៖ ការនិយាយតាមពាក្យសំដី ឬកាយវិការរបស់មនុស្សដែលនៅជុំវិញពួកគេ) និងការយល់ដឹងទាក់ទងនឹងញ្ញាណ (ឧ៖ ការមើល ឃើញ ការស្តាប់ ការប៉ះ រសជាតិ ក្លិន តុល្យភាព និងការយល់ដឹងពីរាងកាយ)។ ដោយមានជំនួយ និងការគាំទ្រត្រឹមត្រូវ ហើយនៅក្នុងបរិយាកាសមួយប្រកបដោយសុវត្ថិភាព កុមារទាំងនេះទទួលបានជំនួយដើម្បីអាចរស់នៅក្នុងជីវិត ប្រកបដោយភាពវិជ្ជមានបាន។

ឆៃ ជាក្មេងប្រុសស្ងប់ស្ងាត់ម្នាក់ គាត់ចូលចិត្តចំណាយពេលតែម្នាក់ឯង គាត់យល់ថាការប្រាស្រ័យទាក់ទងក្នុងស្ថានភាពសង្គមពិបាកខ្លាំងសម្រាប់គាត់ ដូច្នេះហើយគាត់ចំណាយពេលច្រើនតាមប្រព័ន្ធអនឡាញ ដោយប្រើទូរស័ព្ទ ឬថេប្លេតរបស់គាត់។ គាត់ជាក្មេងឆ្លាត គាត់ចូលចិត្តការរៀនសូត្រ និងការលេង «ហ្គេម» ផងដែរ។ គាត់គឺជាសមាជិកនៃសហគមន៍ហ្គេមអនឡាញជាច្រើន។ គាត់ចាត់ទុកថាមនុស្សជាច្រើនដែលគាត់បានជួបតាមប្រព័ន្ធអនឡាញជាមិត្តរបស់គាត់ ព្រោះគាត់មិនចាំបាច់ជួបមុខពួកគេទេ(ដែលវាពិបាកសម្រាប់គាត់)។ ភាគច្រើនជីវិតរបស់គាត់រស់នៅតាមរយៈទំនាក់ទំនងតាមប្រព័ន្ធអនឡាញ។

ថ្មីៗនេះប្រធានគ្រូបានដឹងថាបុរសម្នាក់ដែលគាត់បានជួបតាមអនឡាញ(មិនស្គាល់ឈ្មោះទេ)បានផ្ញើសារបែបផ្លូវភេទ រូបថតរួមភេទ និងវីដេអូរួមភេទដល់ឆៃ។ ជននោះក៏បានសុំឱ្យឆៃធ្វើដូចគ្នាដែរ។ ប្រធានគ្រូបានឆ្លើយតបដោយដកយកឧបករណ៍អេឡិកត្រូនិកទាំងអស់របស់ឆៃហើយហាមគាត់មិនឱ្យប្រើប្រព័ន្ធអនឡាញទេ។ តាំងពីពេលនោះមក ឆៃបានបដិសេធមិនព្រមចេញពីបន្ទប់របស់គាត់ទេ ហើយអារដៃខ្លួនឯងដោយប្រើអំបែងកែវ។

# ឧបសម្ព័ន្ធ “គ”៖

# ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ និងមាត្រាច្បាប់ពាក់ព័ន្ធនៅប្រទេសកម្ពុជា


ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

# ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) និងមាត្រាច្បាប់ពាក់ព័ន្ធនៅប្រទេសកម្ពុជា

ឯកសារនេះមានទម្រង់ជាតារាង និងផ្តល់នូវខ្លឹមសារសង្ខេបនៃមាត្រាច្បាប់នៅកម្ពុជា ដែលពាក់ព័ន្ធខ្លះៗទៅនឹងអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA)នៅពេលរៀបរៀង(ខែឧសភាឆ្នាំ២០២៣)។ច្បាប់នៅក្នុងប្រទេសកម្ពុជាដែលពាក់ព័ន្ធខ្លាំងបំផុតទៅនឹងអំពើកេងប្រវ័ញ្ចផ្លូវភេទជាទូទៅហើយមានរួមបញ្ចូលនូវធាតុបទល្មើសទាក់ទងនឹងអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) គឺមានច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨ និងក្នុងឆ្នាំ២០០៩ ក៏ដាក់ទោសបទល្មើសមួយចំនួនទាក់ទងនឹង OCSEA ដែរ។

សូមចំណាំថា មាត្រាច្បាប់ថ្មីៗនៅក្នុងសេចក្តីព្រាងច្បាប់បទល្មើសបច្ចេកវិទ្យាព័ត៌មាន ដែលកំពុងត្រូវបានរៀបចំឡើង ដែលអាចនឹងបំពេញបន្ថែមលើការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ។ នេះនឹងរួមបញ្ចូល ការគំរាមកំហែងខាងផ្លូវភេទ ការលួងលោមតាមអ៊ីនធឺណិត និងការផ្សាយបន្តផ្ទាល់ការរំលោភបំពានផ្លូវភេទលើកុមារជាដើម។ ក៏មានក្នុងមាត្រាខ្លះនៃក្រមព្រហ្មទណ្ឌផងដែរ ដើម្បីដាក់ទោសឧក្រិដ្ឋកម្មនៃការរំលោភបំពានផ្លូវភេទដែលមិនពាក់ព័ន្ធលើរូបរាងកាយ។ នៅពេលដែលការកែប្រែទាំងនោះត្រូវបានធ្វើឡើង មានឆ្លុះបញ្ចាំងនៅក្នុងឯកសារនេះដែរ។

| ឥរិយាបថពាក់ព័ន្ធនឹង OCSEA | តើមានមាត្រាច្បាប់នៅកម្ពុជាចែងដូចម្តេច? | កំណត់សម្គាល់បន្ថែម |
|---|---|---|
| » ការលួងលោមកុមារតាមប្រព័ន្ធអនឡាញ | តាមន័យបច្ចេកទេស នេះមិនទាន់ត្រូវបានដាក់ទោសទណ្ឌទេ។ ទោះបីជាក្រមព្រហ្មទណ្ឌមិនមានចែងពីការលួងលោមកុមារតាមប្រព័ន្ធអនឡាញ សម្រាប់គោលបំណងផ្លូវភេទ (ការលួងលោមតាមប្រព័ន្ធអនឡាញ) ថាជាបទល្មើសក៏ដោយក្តី ក៏ច្បាប់នេះដាក់ទោសលើ «អំពើរបស់នីតិជនដែលរៀបចំការជួបជុំ ដែលរួមមានការបង្ហាញកេរភេទ ឬមានទំនាក់ទំនងផ្លូវភេទ ដោយមានអនីតិជនបានមើល ឬចូលរួមផងនោះ» តាមមាត្រា ៣៤៦។ | ទោះបីជាមានការដាក់ទោសទណ្ឌលើលទ្ធផលដែលអាចកើតមានចេញពីដំណើរការលួងលោម (ឧ.ការចូលរួមក្នុងសកម្មភាពផ្លូវភេទក្នុងអំឡុងពេលជួបដោយផ្ទាល់) មាត្រាច្បាប់បច្ចុប្បន្នមិនបានដាក់ទោសទណ្ឌលើដំណើរការកសាងទំនុកចិត្តរវាងជនល្មើស និងកុមារ ក៏ដូចជាស្ថានភាពដែលការរំលោភបំពានផ្លូវភេទកើតឡើងតាមអ៊ីនធឺណិត។(ឧទាហរណ៍ប្រសិនបើកុមារ |

## ការផលិត ការកាន់កាប់ ឬការចែកចាយរូបភាព-សម្ភារៈរំលោភបំពាន ផ្លូវភេទកុមារ (CSAM)៖

នៅក្នុងបរិបទកម្ពុជា ការកាន់កាប់មិនមែនជាបទឧក្រិដ្ឋ។ ប៉ុន្តែ ការផលិត និងការចែកចាយ គឺជាបទល្មើស យោងតាមច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**មាត្រា ៣៩៖ រូបភាព និងសម្ភារៈអាសអាភាស**

ជនណាចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬ បង្ហាញ នៅទីសាធារណៈនូវរូបភាព និងសម្ភារអាសអាភាស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ថ្ងៃទៅ១ខែ និងពិន័យជាប្រាក់ពី ១០០ .០០០រៀល ទៅ ២០០.០០០រៀល។

ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬនាំចេញនូវរូបភាព និងសម្ភារៈអាសអាភាសក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសខាងលើ ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី១ ខាងលើ។

ជនណាផលិតរូបភាព និងសម្ភារៈអាសអាភាសក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទ ល្មើសណាមួយដែលមានចែងក្នុងកថាខណ្ឌទី១ និងទី ២ នៃមាត្រានេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ឆ្នាំ ដល់១ឆ្នាំ និងពិន័យជាប្រាក់ពី២០០.០០០ ទៅ ២.០០០.០០០ លានរៀល។

នៅក្នុងបរិបទកម្ពុជា ការកាន់កាប់មិនមែនជាបទល្មើសទេ។ ប៉ុន្តែការផលិត និងការចែកចាយ គឺជាបទល្មើស។

ត្រូវបានស្នើសុំឱ្យផ្ញើខ្លឹមសារផ្លូវភេទទៅកាន់ជនល្មើសតាមរយៈវេទិកាអនឡាញ)។ **ច្បាប់នាពេលអនាគត៖** ច្បាប់ប្រឆាំងបទ និងច្បាប់កិច្ចការពារកុមារត្រូវបានគេរំពឹងថានឹងដាក់ទោសទណ្ឌលើការលួងលោមកុមារសម្រាប់គោលបំណងផ្លូវភេទ (ជារឿយៗហៅថា «ការអូសទាញ» នៅក្នុងច្បាប់) រួមទាំងតាមរយៈអ៊ីនធឺណិត និងបច្ចេកវិទ្យាឌីជីថល ឬប្រព័ន្ធទំនាក់ទំនងផ្សេងទៀត ដើម្បីជួយសម្រួលដល់ការកេងប្រវ័ញ្ចផ្លូវភេទតាមអ៊ីនធឺណិត ឬក្រៅអ៊ីនធឺណិត។ សម្រាប់ការលួងលោមកុមារ ក្នុងគោលបំណងផ្លូវភេទ សេចក្តីព្រាងច្បាប់ ពិនិត្យកែតម្រូវ តាមឈ្មោះ ច្បាប់ ២០២២ «ការលួងលោម» ដូចដែលបានកំណត់នៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការការពារកុមារ សំដៅតាមអ៊ីនធឺណិត ឬក្រៅបណ្តាញអ៊ីនធឺណិត ការរាប់អានកុមារ ឬសមាជិកផ្សេងទៀតនៃគ្រួសាររបស់កុមារនិងការកសាងទំនុកចិត្តរបស់ពួកគេ ដោយចេតនា កេងប្រវ័ញ្ចកុមារ និងបង្កគ្រោះថ្នាក់ដល់ពួកគេ។ ក្រោយពីច្បាប់នេះត្រូវបានអនុម័ត នឹងមានការហាមប្រាមបុគ្គលមិនឱ្យប្រាស្រ័យទាក់ទងគ្នាតាមរយៈមធ្យោបាយអេឡិកត្រូនិកដើម្បី (ក) បោក បញ្ឆោត បង្ខំ ឬដាក់សម្ពាធលើកុមារឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទឬ (ខ) បង្កើតទំនាក់ទំនងសម្រាប់គោលបំណងបែបនេះឡើយ។

ច្បាប់ដែលអាចមាននាពេលអនាគត៖ សេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារកុមារដែលទាក់ទងនឹង**រូបភាព-សម្ភារៈរំ**លោភបំពានផ្លូវភេទលើកុមារ (CSAM) ឆ្នាំ ២០២២ បានកំណត់និយមន័យ CSAM ថា «ការតំណាងណាមួយ ទោះជាដោយមធ្យោបាយណាក៏ដោយរបស់កុមារដែលចូលរួមក្នុងសកម្មភាពផ្លូវភេទជាក់ស្តែង ឬប្រដូច ឬការតំណាងឱ្យផ្នែកផ្លូវភេទរបស់កុមារសម្រាប់គោលដៅផ្លូវភេទជាចម្បង រួមទាំងការផ្សាយបន្តផ្ទាល់»

| | | |
|---|---|---|
| **ការផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទកុមារ** | តាមន័យបច្ចេកទេស នេះមិនទាន់ត្រូវបានដាក់ទោស ទណ្ឌទេ។ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចផ្លូវភេទ ក៏ដូចជាក្រមព្រហ្មទណ្ឌមិនដាក់ទោសទណ្ឌលើការគំរាមកំហែងខាងផ្លូវភេទលើកុមារតាមអ៊ីនធឺណិត និងការផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទលើកុមារទេ។ | ច្បាប់នាពេលអនាគត៖<br>សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន<br>ការតំណាងណាក៏ដោយ តាមមធ្យោបាយណាក៏ដោយរបស់កុមារដែលចូលរួមក្នុងសកម្មភាពផ្លូវភេទជាក់ស្តែង ឬប្រដូច ឬតំណាងឱ្យផ្នែកផ្លូវភេទរបស់កុមារ សម្រាប់គោលបំណងផ្លូវភេទជាចម្បង រួមទាំងការផ្សាយបន្តផ្ទាល់។ |
| **ការចែករំលែកខ្លឹមសារពាក់ព័ន្ធនិងភេទ ឬរូបភាពអាសអាភាសរបស់ពួកគេ ដែលបង្កើតដោយខ្លួនឯងពាក់ព័ន្ធនឹងកុមារ។** | មិនមែនជាបទឧក្រិដ្ឋសម្រាប់យុវជនពីរនាក់ក្នុងការ ចែករំលែករវាងខ្លួនគេទេ ប៉ុន្តែក្លាយជាបទឧក្រិដ្ឋ ប្រសិនបើអ្នកណាម្នាក់ប្រើវាដើម្បីជំរិតទារ ឬគំរាមកំហែង ឬបៀតបៀន។ ក្រមព្រហ្មទណ្ឌមាត្រា ៣០២ (ការបំពានឯកជនភាព ការចែកចាយពីរូបភាពរបស់បុគ្គលម្នាក់ដែលត្រូវបានថតទុក)ក៏អាចត្រូវបានកាត់ទោសយោងទៅ តាមការចែកចាយ រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទ CSAM (សូមមើលខាងលើ) ឬការបៀត បៀនផ្លូវភេទ។ (សូមមើលខាងក្រោម) | រូបភាព-សម្ភារៈរំលោភបំពានផ្លូវភេទរបស់កុមារ «ដែលបង្កើតដោយខ្លួនឯង»គឺជាបញ្ហាដែលកំពុងកើនឡើងសម្រាប់សុវត្ថិភាពរបស់កុមារនៅលើអ៊ីនធឺណិត។វាគឺជាពេលដែលកុមារនិងយុវវ័យថតរូប និងវីដេអូដោយប្រើស្មាតហ្វូន ឬកាមេរ៉ាកុំព្យូទ័រ ហើយបន្ទាប់មកចែករំលែកវានៅលើវេទិកាអនឡាញ។ខណៈពេលដែលវាអាច ជាទម្រង់ នៃការបញ្ចេញមតិសម្រាប់កុមារមួយចំនួនវាក៏មានភ្ជាប់មកជាមួយនូវហានិភ័យជាច្រើន នៃការកេងប្រវ័ញ្ច និងរំលោភ បំពានលើប្រព័ន្ធអនឡាញ។<br><br>កុមារអាចត្រូវបានលួងលោម បោកបញ្ឆោត ឬជំរិតបង្ខំឱ្យផលិតនិងចែកចាយរូបភាពឬវីដេអូផ្លូវភេទរបស់ពួកគេជារឿយៗដោយនរណាម្នាក់នៅលើអ៊ីនធឺណិត។ រូបភាពអាចនឹងត្រូវបានប្រើប្រាស់ដើម្បីបង្ខិតបង្ខំ ឬគំរាមកេប្រយោជន៍ពីកុមារបន្ថែមទៀត ហើយអាចត្រូវបានប្រើប្រាស់ខុស ឬ ផ្សព្វផ្សាយដោយគ្មានការយល់ព្រម។នៅឆ្នាំ២០២២មូលនិធិឃ្លាំមើលតាមប្រព័ន្ធអ៊ីនធឺណិតបានរកឃើញមាន ១៩៩-៣៦៣ ទំព័រដែលមាន**រូបភាព-សម្ភារៈ**រំលោភបំពានផ្លូវភេទរបស់កុមារ «បង្កើតដោយខ្លួនឯង» ដោយកើនឡើង ៩ភាគរយពីឆ្នាំ២០២១។ |

| | | |
|---|---|---|
| ការគំរាមកំហែងខាង ផ្លូវភេទលើកុមារ | **ក្រមព្រហ្មទណ្ឌ ផ្នែកទី៣៖ មាត្រា ២៣១ ៖បទគំរាម កំហែង មាត្រា ២៣២៖ បទគំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ។**<br>ពេលខ្លះ ព្រះរាជអាជ្ញាអាចប្រើមាត្រា៣៧២ ទាក់ទងនឹងការគម្រាមកំហែងហែកកេរ្តិ៍។ | ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចផ្លូវភេទ និងក្រមព្រហ្មទណ្ឌដាក់ទោសទណ្ឌលើការជំរិតទារផ្លូវភេទតាមប្រព័ន្ធអនឡាញ និងការផ្សាយបន្តផ្ទាល់នៃការរំលោភបំពានផ្លូវភេទលើកុមារនៅពេលនេះដែរ។ |
| ការបៀតបៀនផ្លូវភេទលើកុមារ | **ក្រមព្រហ្មទណ្ឌ ផ្នែកទី២ មាត្រា ២៤៦**<br>គ្រប់អំពើប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិន ស្ម័គ្រផងតែ ឬបង្ខំបុគ្គលដទៃឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួន ឬទៅលើតតិយបុគ្គលក្នុងគោលបំណងធ្វើឱ្យរំជួល ឬកែរាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស គឺជាអំពើប្រទូស្តកេរខ្មាស់។<br>អំពើប្រទូស្តកេរខ្មាស់ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារពី១ឆ្នាំទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២,០០០,០០០(ពីរលាន) រៀលទៅ ៦,០០០,០០០ (ប្រាំមួយលាន) រៀល។ | ក្រមព្រហ្មទណ្ឌមានបទប្បញ្ញត្តិ ដែលកំណត់ឧក្រិដ្ឋកម្មលើការបៀតបៀនផ្លូវភេទ ទោះបីជាមិនដាក់លាក់ថានៅ**តាមប្រព័ន្ធអនឡាញ ឬប្រឆាំងនឹងកុមារក៏ដោយ។**<br>បទល្មើសនេះ (ដាក់ពន្ធនាគារពីប្រាំមួយថ្ងៃទៅបីខែនិងពិន័យជាប្រាក់ពី ១០,០០០រៀល ទៅ ៥០០,០០០រៀល ស្មើនឹងចន្លោះពី ២,៥០ ទៅ ១២៥ ដុល្លារអាមេរិក) មិនឆ្លុះ បញ្ចាំងពីលក្ខណៈធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ជាពិសេសនៅពេលប្រព្រឹត្តលើកុមារ។ |
| ការប៉ះពាល់ ឬការបៀតបៀនផ្លូវភេទលើកុមារ | នេះអាស្រ័យលើចេតនានៃគោលបំណងនៃការចែករំលែក តម្រូវឱ្យបញ្ជាក់ថា សម្រាប់គោលបំណងផ្លូវភេទ។ (ឧ.ប្រើដើម្បីលួង ឬលួងលោមកុមារឬយុវជន) ក្រមព្រហ្មទណ្ឌៈគ្មានឯកសារយោងនៅក្នុងក្រមព្រហ្មទណ្ឌចែងថា (មាត្រា៤៖ ពុំមានបទល្មើសប្រសិនបើគ្មានចេតនាប្រព្រឹត្ត។) ប៉ុន្តែក្នុងករណីដែលច្បាប់ចែងទុកមុន បទល្មើសមួយ អាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ។ | ច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ៖ មាត្រា៤១ - រូបភាព និងសម្ភារៈអាសអាភាសកុមារ<br>ជនណាចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬ បង្ហាញនៅទីសាធារណៈនូវរូបភាព និងសម្ភារៈអាសអាភាសកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំដល់៥(ប្រាំ)ឆ្នាំនិងពិន័យជាប្រាក់ពី ៤,០០០,០០០(បួនលាន)រៀល ដល់ ១០,០០០,០០០ (ដប់លាន) រៀល។<br>ជនណាកាន់កាប់ដឹកជញ្ជូន នាំចូលឬនាំចេញនូវរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ ក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើស ដូចមានចែងនៅក្នុងកថា ខណ្ឌទី១ ខាងលើត្រូវផ្តន្ទាទោសដូចគ្នា។ |

| | | |
|---|---|---|
| | | ជនណាផលិតរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ដល់ ១០ (ដប់) ឆ្នាំ។ ជនណាផលិតរូបភាព-សម្ភារៈអាសអាភាសកុមារក្នុងគោលដៅយកទៅប្រើនៅក្នុងការប្រព្រឹត្តបទល្មើសណាមួយដូចមានចែងនៅក្នុងកថាខណ្ឌទី១ និងទី២ ខាងលើត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ដល់ ២០ (ម្ភៃ) ឆ្នាំ។ |

## កំណត់សម្គាល់ពិសេស៖

- ផែនការសកម្មភាពជាតិ ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងការរំលោភបំពានតាមប្រព័ន្ធអនឡាញ និងផែនការអនុវត្ត យុទ្ធសាស្ត្រការពារកុមារកម្ពុជាឆ្នាំ ២០២២ - ២០២៦ (កំពុងអភិវឌ្ឍន៍) ក៏មានឯកសារយោងទៅលើតួនាទីនៃការអនុវត្តច្បាប់ផងដែរ។
- លើសពីនេះ សេចក្តីព្រាងច្បាប់ស្តីពីការការពារកុមារ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ និង សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មតាមបច្ចេកវិទ្យា រួមជាមួយនឹងក្រមព្រហ្មទណ្ឌកម្ពុជា ផ្តល់នូវឧបករណ៍នីតិប្បញ្ញត្តិជាតិសំខាន់ៗ។
- នៅពេលដែលសេចក្តីព្រាងច្បាប់ត្រូវបានឱ្យសច្ចានុម័ត និងដាក់ឱ្យដំណើរការនូវឯកសារបណ្តុះបណ្តាលនឹងត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំងពីការអភិវឌ្ឍទាំងនោះ។
- នៅថ្នាក់មូលដ្ឋាន ផែនការសកម្មភាពក្នុងតំបន់អាស៊ានសម្រាប់ការការពារកុមារទាំងអស់ពីការកេងប្រវ័ញ្ច និងរំលោភបំពានតាមប្រព័ន្ធអនឡាញ រៀបរាប់លម្អិតយ៉ាងច្បាស់អំពីតួនាទីរបស់អ្នកពាក់ព័ន្ធទាំងអស់ រួមទាំងនគរបាល និងក្របខ័ណ្ឌការពារកុមារតាមប្រព័ន្ធអនឡាញរបស់ ITU/ASEAN ។

# ឧបសម្ព័ន្ធ “ឃ”៖

# សេចក្តីសង្ខេប អនុសញ្ញាស្តីពីសិទ្ធិកុមារ (UNHCR)

អនុសញ្ញាស្តីពីសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ គឺជាកិច្ចព្រមព្រៀងដ៏សំខាន់របស់ប្រទេសជាហត្ថលេខីដែលបានសន្យាការពារសិទ្ធិរបស់កុមារ។

អនុសញ្ញារៀបរាប់ពីនរណាជាកុមារ សិទ្ធិដែលពួកគេទទួលបាន និងការទទួលខុសត្រូវនៃរាជរដ្ឋាភិបាល។ សិទ្ធិទាំងអស់ គឺពាក់ព័ន្ធគ្នា មានសារៈសំខាន់ដូចគ្នា ហើយមិនអាចយកចេញពីកុមារបាននោះទេ។

អនុសញ្ញាស្តីពីសិទ្ធិកុមារ៖ ឯកសារសម្រាប់កុមារធ្វើការស្វែងយល់

១. និយមន័យកុមារ៖ កុមារសំដៅលើជនទាំងឡាយដែលមានអាយុក្រោម ១៨ឆ្នាំ។

២. គ្មានការរើសអើង៖ កុមារគ្រប់គ្នាសុទ្ធតែមានសិទ្ធិទាំងនេះ មិនថាពួកគេជានរណា ពួកគេរស់នៅទីណា ពួកគេនិយាយភាសាអ្វី ពួកគេកាន់សាសនាមួយណា ពួកគេគិតអំពីអ្វី ពួកគេមានរូបរាងបែបណា មិនថាពួកគេជាក្មេងប្រុស ឬក្មេងស្រី មានពិការភាព ឬគ្មានពិការភាព មានជីវភាពក្រីក្រ ឬធូរធារ និងមិនថាឪពុកម្តាយ ឬគ្រួសាររបស់ពួកគេជា នរណា ឬថាតើឪពុកម្តាយ ឬគ្រួសាររបស់ពួកគេជឿលើអ្វី ឬធ្វើអ្វីឡើយ។ មិនគួរមានកុមារណាម្នាក់ គួរត្រូវបានគេប្រតិបត្តិដាក់ដោយមិនត្រឹមត្រូវនោះឡើយ ទោះជាដោយសារ មូលហេតុអ្វីក៏ដោយ។

៣. ឧត្តមប្រយោជន៍កុមារ៖ នៅពេលដែលមនុស្សពេញវ័យធ្វើសេចក្តីសម្រេចចិត្ត ពួកគេគួរគិតថាតើការសម្រេចចិត្តរបស់ពួកគេនឹងបង្កផលប៉ះពាល់អ្វីខ្លះដល់កុមារ។ មនុស្សពេញវ័យគ្រប់រូប គួរធ្វើអ្វីៗ ដើម្បីឧត្តមប្រយោជន៍របស់កុមារ។ រាជរដ្ឋាភិបាលគួរធានាឱ្យកុមារទទួលបានការការពារ និងការថែទាំពីឪពុកម្តាយរបស់ពួកគេ ឬពីអ្នកផ្សេងទៀត នៅពេលដែលចាំបាច់។ រាជរដ្ឋាភិបាលគួរធានាថា មនុស្ស និងកន្លែងដែលទទួលខុសត្រូវមើលថែទាំកុមារ ពិតជាកំពុងផ្តល់ ការថែទាំដល់កុមារបានល្អ។

៤. ការបង្កើតសិទ្ធិពិតប្រាកដ៖រាជរដ្ឋាភិបាលត្រូវធ្វើអ្វីៗគ្រប់បែបយ៉ាងដែលអាចធ្វើបានដើម្បីធានាថាកុមារគ្រប់រូបនៅ ក្នុងប្រទេសរបស់ពួកគេ អាចទទួលបានសិទ្ធិទាំងអស់ ដូចមានចែងនៅក្នុងអនុសញ្ញានេះ។

៥. ការណែនាំស្របតាមវ័យរបស់កុមារ៖ រាជរដ្ឋាភិបាលគួរផ្តល់ឱកាសឱ្យគ្រួសារ និងសហគមន៍ផ្តល់ការណែនាំដល់កូនៗរបស់ពួកគេដើម្បីឱ្យនៅពេលដែលពួកគេធំឡើងពួកគេរៀនប្រើប្រាស់សិទ្ធិរបស់ពួកគេបានល្អបំផុត។ នៅពេលដែលកុមារកាន់តែចម្រើនវ័យ ពួកគេត្រូវការការណែនាំកាន់តែតិច។

៦. ជីវិត ការរស់រានមានជីវិត និងការអភិវឌ្ឍ៖ កុមារគ្រប់រូបមានសិទ្ធិរស់រាន។ រាជរដ្ឋាភិបាលត្រូវធានាថាកុមាររស់រាន និងអភិវឌ្ឍបានល្អបំផុត។

៧. ឈ្មោះ និងសញ្ជាតិ៖ ត្រូវមានការចុះសំបុត្រកំណើតឱ្យកុមារ នៅពេលដែលពួកគេកើតមក និងទទួលបានឈ្មោះ ដែលមានការទទួលស្គាល់ជាផ្លូវការពីរាជរដ្ឋាភិបាល។ កុមារត្រូវមានសញ្ជាតិ (ជាពលរដ្ឋរបស់ប្រទេសណាមួយ)។

៨. អត្តសញ្ញាណ៖ កុមារមានសិទ្ធិមានអត្តសញ្ញាណផ្ទាល់ខ្លួន ជាឯកសារផ្លូវការដែលកំណត់ថាតើពួកគេជានរណា ដោយក្នុងនោះមានឈ្មោះ សញ្ជាតិ និងទំនាក់ទំនងគ្រួសាររបស់ពួកគេ។ ពុំគួរមាននរណាម្នាក់ដកហូតសិទ្ធិនេះពីពួកគេឡើយ ប៉ុន្តែប្រសិនបើមានការដកហូតសិទ្ធិបែបនេះ រាជរដ្ឋាភិបាលត្រូវជួយឱ្យកុមារទទួលបានអត្តសញ្ញាណពួកគេមកវិញឱ្យបានឆាប់រហ័ស។



ឧបត្ថម្ភដោយ End Violence Against Children unicef for every child

៩. ការរស់នៅជួបជុំគ្រួសារ៖ គេមិនគួរបំបែកកុមារចេញពីឪពុកម្តាយរបស់ពួកគេឡើយ លើកលែងតែក្នុងករណីដែលកុមារពុំបានទទួលបានការថែទាំឱ្យបានត្រឹមត្រូវ ឧទាហរណ៍ ប្រសិនបើឪពុកម្តាយធ្វើឱ្យពួកគេទទួលរងការឈឺចាប់ ឬមិនបានថែទាំកុមារជាដើម។ កុមារដែលឪពុកម្តាយមិនរស់ជាមួយគ្នាគួរបន្តទំនាក់ទំនងជាមួយនឹងឪពុកម្តាយទាំង ២ លើកលែងតែការធ្វើបែបនេះអាចបង្កគ្រោះថ្នាក់ដល់កុមារនោះ។

១០. ទំនាក់ទំនងជាមួយឪពុកម្តាយឆ្លងប្រទេស៖ ប្រសិនបើកុមាររស់នៅក្នុងប្រទេសផ្សេងពីឪពុកម្តាយរបស់ពួកគេ រាជរដ្ឋាភិបាលត្រូវផ្តល់ឱកាសឱ្យកុមារ និងឪពុកម្តាយធ្វើដំណើរ ដើម្បីឱ្យពួកគេអាចបន្តទំនាក់ទំនង និងបាននៅជុំគ្នា។

១១. ការការពារពីការចាប់ជំរិត៖ រាជរដ្ឋាភិបាលត្រូវចាត់វិធានការ ដើម្បីកុំឱ្យមានការយកកុមារចេញទៅក្រៅប្រទេស នៅពេលដែលការធ្វើបែបនេះជាទង្វើផ្ទុយនឹងច្បាប់ ឧទាហរណ៍ត្រូវបានចាប់ជំរិតដោយនរណាម្នាក់ ឬត្រូវបានរក្សាទុកនៅក្រៅប្រទេសដោយឪពុក ឬម្តាយ នៅពេលដែលម្តាយ ឬឪពុកម្ខាងទៀតមិនយល់ស្រប។

១២. គោរពទស្សនៈ៖ កុមារមានសិទ្ធិបង្ហាញពីការយល់ឃើញរបស់ពួកគេដោយសេរីអំពីបញ្ហានានាដែលបង្កផលប៉ះពាល់ដល់ពួកគេ។ មនុស្សពេញវ័យគួរស្តាប់ដោយយកចិត្តទុកដាក់ចំពោះមតិយោបល់របស់កុមារ។

១៣. ការចែករំលែកគំនិតដោយសេរី៖ កុមារមានសិទ្ធិចែករំលែកដោយសេរីជាមួយនឹងអ្នកដទៃទៀតអំពីអ្វីដែលពួកគេបានរៀនគិត និងអារម្មណ៍របស់ពួកគេ តាមរយៈការនិយាយ ការគូររូប ការសរសេរ ឬតាមរបៀបផ្សេងទៀត ដរាបណាវាមិនបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។

១៤. សេរីភាពនៃជំនឿ និងសាសនា៖ កុមារអាចជ្រើសរើសគំនិត ការយល់ឃើញ និងសាសនារបស់ពួកគេ ប៉ុន្តែការធ្វើបែបនេះមិនគួររារាំងមិនឱ្យអ្នកដទៃទៀត ក្នុងការប្រើប្រាស់សិទ្ធិរបស់ពួកគេឡើយ។ ឪពុកម្តាយអាចផ្តល់ការណែនាំដល់កូន ដើម្បីឱ្យនៅពេលដែលពួកគេធំឡើង ពួកគេរៀនប្រើប្រាស់សិទ្ធិនេះឱ្យបានត្រឹមត្រូវ។

១៥. ការបង្កើត ឬចូលរួមក្រុម៖ កុមារអាចចូលរួម ឬបង្កើតក្រុម ឬអង្គការ ហើយពួកគេអាចជួបប្រជុំជាមួយនឹងអ្នកដទៃទៀត ដរាបណាការធ្វើបែបនេះមិនបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។

១៦. ការការពារឯកជនភាព៖ កុមារគ្រប់រូបមានសិទ្ធិទទួលបានឯកជនភាព។ ច្បាប់ត្រូវការពារឯកជនភាពគ្រួសារ គេហដ្ឋាន ការទំនាក់ទំនង និងកេរ្តិ៍ឈ្មោះ (កិត្តិសព្ទ) របស់កុមារពីការវាយប្រហារនានា។

១៧. សិទ្ធិទទួលបានព័ត៌មាន៖ កុមារមានសិទ្ធិទទួលបានព័ត៌មានពីអ៊ីនធឺណិត វិទ្យុ ទូរទស្សន៍ សារព័ត៌មាន សៀវភៅ និងប្រភពផ្សេងទៀត។ មនុស្សពេញវ័យគួរធានាថា ព័ត៌មានដែលកុមារទទួលបានមិនបង្កគ្រោះថ្នាក់ដល់ពួកគេឡើយ។ រាជរដ្ឋាភិបាលគួរលើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយ ធ្វើការផ្សព្វផ្សាយព័ត៌មានពីប្រភពផ្សេងៗឱ្យបានច្រើន ជាភាសាដែលកុមារគ្រប់រូបអាចយល់បាន។

១៨. ទំនួលខុសត្រូវរបស់ឪពុកម្តាយ៖ ឪពុកម្តាយគឺជាមនុស្សសំខាន់ជាងគេ ដែលទទួលខុសត្រូវក្នុងការចិញ្ចឹមបីបាច់កុមារ។ នៅពេលដែលកុមារមិនមានឪពុកម្តាយ មនុស្សពេញវ័យម្នាក់ទៀត ត្រូវបំពេញការទទួលខុសត្រូវហើយ ដែលគេហៅថា "អាណាព្យាបាល"។ ឪពុកម្តាយ និងអាណាព្យាបាល ជានិច្ចកាលគួរធ្វើអ្វី ដើម្បីឧត្តមប្រយោជន៍របស់កុមារនោះ។ រាជរដ្ឋាភិបាលគួរជួយដល់ឪពុកម្តាយ និងអាណាព្យាបាលទាំងនោះ។ នៅពេលដែលកុមារម្នាក់មានទាំងឪពុកទាំងម្តាយ ពួកគេទាំងពីរនាក់គួរជាអ្នកទទួលខុសត្រូវលើការចិញ្ចឹមបីបាច់កុមារនេះ។

១៩. ការការពារពីអំពើហិង្សា៖ រាជរដ្ឋាភិបាលត្រូវការពារកុមារពីអំពើហិង្សា ការរំលោភបំពាន និងការមិនអើពើពីអ្នកដែល ត្រូវមើលថែទាំពួកគេ។

២០. កុមារកំព្រា៖ កុមារគ្រប់រូបដែលមិនអាចទទួលបានការថែទាំពីគ្រួសាររបស់ខ្លួន មានសិទ្ធិទទួលបានការថែទាំឱ្យ បានសមស្របពីមនុស្សដែលគោរពសាសនាវប្បធម៌ ភាសារបស់កុមារ និងទិដ្ឋភាពផ្សេងទៀតនៅក្នុងជីវិតរបស់ពួកគេ។

២១. កុមារដែលគេយកទៅចិញ្ចឹម៖ នៅពេលដែលកុមារត្រូវបានគេយកទៅចិញ្ចឹម ចំណុចសំខាន់ជាងគេ គឺត្រូវធ្វើអ្វី ដើម្បីឧត្តមប្រយោជន៍របស់កុមារ។ ប្រសិនបើកុមារម្នាក់មិនអាចទទួលបានការថែទាំឱ្យបានសមស្របនៅក្នុងប្រទេសរបស់ខ្លួន ឧទាហរណ៍ តាមរយៈការរស់នៅជាមួយនឹងគ្រួសារមួយទៀត នោះកុមារនេះអាចត្រូវបានគេយកទៅចិញ្ចឹម នៅក្នុងប្រទេសមួយផ្សេងទៀត។

២២. កុមារជនភៀសខ្លួន៖កុមារដែលចាកចេញពីប្រទេសកំណើតទៅប្រទេសមួយទៀតក្នុងនាមជាជនភៀសខ្លួន (ដោយសារតែពួកគេមិនមានសុវត្ថិភាពក្នុងការបន្តស្នាក់នៅក្នុងប្រទេសរបស់ខ្លួន)គួរទទួលបានជំនួយ និងការការពារ និងមានសិទ្ធិដូចកុមារដែលកើតនៅក្នុងប្រទេសនោះដែរ។

២៣. កុមារពិការ៖កុមារដែលមានពិការភាពគ្រប់រូបគួរទទួលបានជីវិតល្អបំផុតដែលអាចមាននៅក្នុងសង្គម។ រដ្ឋាភិបាល គួរលុបបំបាត់រាល់ឧបសគ្គទាំងអស់ដែលកុមារមានពិការភាពជួបប្រទះ ដើម្បីឱ្យពួកគេមានភាពម្ចាស់ការដោយខ្លួនឯង និងចូលរួមឱ្យបានសកម្មនៅក្នុងសហគមន៍។

២៤. សុខភាព ទឹកស្អាត អាហារ បរិស្ថាន៖ កុមារមានសិទ្ធិទទួលបានសេវាថែទាំសុខភាពល្អបំផុតតាមដែលអាចធ្វើទៅបាន ទឹកស្អាតសម្រាប់ផឹក អាហារដែលទ្រទ្រង់សុខភាព និងបរិយាកាសរស់នៅស្អាតប្រកបដោយសុវត្ថិភាព។ មនុស្សពេញវ័យនិងកុមារគ្រប់រូប គួរទទួលបានព័ត៌មានអំពីការរក្សាសុវត្ថិភាព និងសុខភាពរបស់ពួកគេឱ្យនៅមាំមួន។

២៥. ការពិនិត្យឡើងវិញនូវស្ថានភាពរស់នៅរបស់កុមារ៖ កុមារគ្រប់រូបដែលត្រូវបានយកទៅដាក់នៅកន្លែងផ្សេងក្រៅតែពីផ្ទះរបស់ពួកគេ ដើម្បីទទួលបានការថែទាំ ការការពារ ឬសេវាសុខភាព គួរមានការពិនិត្យស្ថានភាពរស់នៅរបស់ពួកគេឱ្យបានជាទៀងទាត់ ដើម្បីពិនិត្យថាតើអ្វីៗ ដំណើរការទៅបានល្អដែរឬទេ និងថាតើកន្លែងនោះនៅតែជាកន្លែង ដែលល្អបំផុតសម្រាប់កុមារដែរឬទេ។

២៦. ជំនួយផ្នែកសង្គម និងសេដ្ឋកិច្ច៖រាជរដ្ឋាភិបាលគួរផ្តល់ថវិកា ឬការឧបត្ថម្ភដទៃទៀត ដើម្បីជួយកុមារមកពីគ្រួសារក្រីក្រ។

២៧. អាហារ សម្លៀកបំពាក់ លំនៅស្ថានសុវត្ថិភាព៖កុមារមានសិទ្ធិទទួលបានអាហារ សម្លៀកបំពាក់ និងកន្លែងរស់នៅដែលមានសុវត្ថិភាព ដើម្បីឱ្យពួកគេអាចអភិវឌ្ឍបានល្អបំផុត។ រាជរដ្ឋាភិបាលគួរជួយដល់គ្រួសារ និងកុមារដែលពុំមានលទ្ធភាពទទួលបានសេវាទាំងនេះ។



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

២៨. **សិទ្ធិទទួលបានការអប់រំ៖** កុមារគ្រប់រូបមានសិទ្ធិទទួលបានការអប់រំ។ ការអប់រំបឋមសិក្សាគួរផ្តល់ដោយឥតគិតថ្លៃ ការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា គួរមានសម្រាប់កុមារគ្រប់រូប។ គួរមានការលើកទឹកចិត្តកុមារទៅសាលារៀន ដើម្បីរៀនបានខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន។ ការដាក់វិន័យនៅក្នុងសាលារៀនគួរគោរពសិទ្ធិរបស់កុមារ ហើយមិនត្រូវមានការប្រើប្រាស់អំពើហិង្សាជាដាច់ខាត។

២៩. **គោលបំណងនៃការអប់រំ៖** ការអប់រំរបស់កុមារ គួរជួយឱ្យពួកគេអភិវឌ្ឍបុគ្គលិកលក្ខណៈ ទេពកោសល្យ និងសមត្ថភាពរបស់ពួកគេឱ្យបានពេញលេញ។ ការអប់រំ គួរបង្រៀនពួកគេឱ្យយល់ពីសិទ្ធិរបស់ខ្លួន និងគោរពសិទ្ធិ វប្បធម៌ និងភាពខុសប្លែកគ្នារបស់អ្នកដទៃ។ ការអប់រំ គួរជួយឱ្យកុមាររស់នៅប្រកបដោយសុខសន្តិភាព និងការការពារ។

៣០. **វប្បធម៌ ភាសា និងសាសនារបស់ជនជាតិដើមភាគតិច៖** កុមារមានសិទ្ធិប្រើប្រាស់ភាសា វប្បធម៌ និងសាសនារបស់ខ្លួន សូម្បីតែភាសា វប្បធម៌ សាសនាទាំងនេះមិនមែនជារបស់មនុស្សភាគច្រើននៅក្នុងប្រទេសដែលពួកគេរស់នៅក៏ដោយ។

៣១. **សម្រាក កម្សាន្ត វប្បធម៌ សិល្បៈ៖** កុមារគ្រប់រូបមានសិទ្ធិសម្រាកលំហែកាយ លេងកម្សាន្ត និងចូលរួមក្នុងសកម្មភាពវប្បធម៌ និងកម្សាន្តនានា។

៣២. **ការការពារពីការងារគ្រោះថ្នាក់៖** កុមារមានសិទ្ធិទទួលបានការការពារពីការធ្វើការប្រកបដោយគ្រោះថ្នាក់ ឬដែលបង្កផលប៉ះពាល់ដល់ការអប់រំ សុខភាព ឬការអភិវឌ្ឍរបស់ពួកគេ។ ប្រសិនបើកុមារធ្វើការ ពួកគេមានសិទ្ធិទទួលបាន សុវត្ថិភាព និងទទួលបានប្រាក់កម្រៃត្រឹមត្រូវ។

៣៣. **ការការពារពីគ្រឿងញៀនអន្តរាយ៖** រាជរដ្ឋាភិបាលត្រូវការពារកុមារពីការប្រើប្រាស់ ផលិត ទុក ឬលក់គ្រឿងញៀន ដែលបង្កគ្រោះថ្នាក់។

៣៤. **ការការពារពីការរំលោភបំពានផ្លូវភេទ៖** រាជរដ្ឋាភិបាលគួរការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ ត្រូវបានគេធ្វើអាជីវកម្មនិងរំលោភបំពានផ្លូវភេទដូចជា៖ ការប្រព្រឹត្តដោយមនុស្សដែលបង្ខំកុមារឱ្យរួមភេទដើម្បីទទួលបានប្រាក់កម្រៃ ឬថតរូបភាពយន្តអាសអាភាសរបស់កុមារជាដើម។

៣៥. **ការការពារពីការជួញដូរ៖** រាជរដ្ឋាភិបាលត្រូវធានាថា កុមារមិនត្រូវបានគេចាប់ជំរិត ឬលក់ ឬនាំទៅកាន់ប្រទេស ឬកន្លែងផ្សេងទៀត ដើម្បីកេងប្រវ័ញ្ច (ធ្វើអាជីវកម្មលើ) នោះឡើយ។

៣៦. **ការការពារពីការកេងប្រវ័ញ្ច ៖** កុមារមានសិទ្ធិទទួលបានការការពារ ពីការកេងប្រវ័ញ្ចគ្រប់ប្រភេទដទៃទៀត បើទោះជាការកេងប្រវ័ញ្ចទាំងនេះ មិនត្រូវបានលើកឡើងឱ្យបានជាក់លាក់នៅក្នុងអនុសញ្ញានេះក៏ដោយ។

៣៧. **កុមារជាប់ក្នុងមន្ទីរឃុំឃាំង៖** កុមារដែលត្រូវបានចោទថាបានបំពានច្បាប់ មិនគួរត្រូវបានគេប្រហារជីវិត ធ្វើទារុណកម្ម ធ្វើបាបឃោរឃៅ ដាក់ពន្ធនាគារជារៀងរហូត ឬដាក់ពន្ធនាគារជាមួយនឹងមនុស្សពេញវ័យនោះឡើយ។ ពន្ធនាគារគួរជាជម្រើសចុងក្រោយ និងគួរដាក់តែក្នុងរយៈពេលខ្លីបំផុត។ កុមារដែលជាប់ពន្ធនាគារ គួរទទួលបាន ជំនួយផ្លូវច្បាប់ និងអាចបន្តទំនាក់ទំនងជាមួយនឹងគ្រួសាររបស់ពួកគេ។

៣៨. **ការការពារក្នុងសង្គ្រាម៖** កុមារមានសិទ្ធិទទួលបានការការពារក្នុងពេលមានសង្គ្រាម ពុំគួរមានកុមារអាយុក្រោម ១៥ឆ្នាំ អាចចូលបម្រើការក្នុងកងទ័ព ឬចូលរួមនៅក្នុងការធ្វើសង្គ្រាមនោះឡើយ។

៣៩. **ការព្យាបាល និងការស្ដារឡើងវិញ៖** កុមារមានសិទ្ធិទទួលបានជំនួយ ប្រសិនបើពួកគេទទួលរងការឈឺចាប់ ត្រូវបានគេទុកចោល ទទួលបានការធ្វើបាប ឬទទួលរងផលប៉ះពាល់ដោយសារសង្គ្រាម ដើម្បីឱ្យពួកគេអាចទទួលបាននូវ សុខភាព សេចក្ដីថ្លៃថ្នូរមកវិញ។

៤០. **កុមារដែលប្រឈមមុខនឹងច្បាប់៖** កុមារដែលត្រូវបានចោទប្រកាន់ថាបានបំពានច្បាប់មានសិទ្ធិទទួលបានជំនួយផ្លូវច្បាប់ និងការប្រតិបត្តិប្រកបដោយយុត្តិធម៌។ គួរមានដំណោះស្រាយឱ្យបានច្រើនដើម្បីជួយឱ្យកុមារទាំងនេះក្លាយជាសមាជិកល្អនៃសហគមន៍របស់ពួកគេ។ ពន្ធនាគារគួរតែជា ជម្រើសចុងក្រោយបំផុត។

៤១. **ច្បាប់ល្អសម្រាប់កុមារអនុវត្ត៖** ប្រសិនបើច្បាប់របស់ប្រទេសណាមួយការពារសិទ្ធិកុមារបានល្អប្រសើរជាងអនុសញ្ញានេះ គេគួរប្រើប្រាស់ច្បាប់ទាំងនោះ។

៤២. **មនុស្សគ្រប់គ្នាត្រូវយល់ដឹងពីសិទ្ធិកុមារ៖** រាជរដ្ឋាភិបាលគួរអប់រំផ្សព្វផ្សាយឱ្យបានសកម្មដល់កុមារ និងមនុស្សពេញវ័យ អំពីអនុសញ្ញានេះ ដើម្បីឱ្យគ្រប់គ្នាដឹងពីសិទ្ធិរបស់កុមារ។

៤៣. **ដល់ 54. របៀបអនុវត្តន៍អនុសញ្ញានេះ៖** មាត្រាទាំងនេះពន្យល់ថាតើរាជរដ្ឋាភិបាលអង្គការសហប្រជាជាតិព្រមទាំងគណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ និងអង្គការ យូនីសេហ្វ ព្រមទាំងអង្គការស្ថាប័នដទៃទៀតត្រូវធ្វើការងាររួមគ្នាដោយរបៀបណាដើម្បីធានាឱ្យកុមារគ្រប់រូបទទួលបានសិទ្ធិទាំងអស់របស់ពួកគេ។

## ឧបសម្ព័ន្ធ “ឃ១” ៖

# សិទ្ធិកុមារក្នុង ពិភពឌីជីថល

## សេចក្ដីសង្ខេប និងសន្លឹកកិច្ចការ



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

# សិទ្ធិកុមារក្នុងពិភពឌីជីថល

## — សេចក្តីសង្ខេប និង សន្លឹកកិច្ចការ

មុនពេលយើងស្វែងយល់ពីបញ្ហាសិទ្ធិកុមារក្នុងពិភពឌីជីថល-នេះជាសារតៃខ្លះៗ អំពីសិទ្ធិកុមារ និងអនុសញ្ញាអង្គការ សហប្រជាជាតិស្តីពីសិទ្ធិកុមារ UNCRC៖

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (UNCRC) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៨៩ ហើយត្រូវបានចុះហត្ថលេខាដោយភាគីចំនួន ១៨៩ប្រទេស រួមទាំងប្រទេសកម្ពុជាផងដែរ។ មេដឹកនាំពិភពលោក បានរួមគ្នាធ្វើកិច្ចព្រមព្រៀងជាប្រវត្តិសាស្ត្រនេះ ដោយធ្វើការសន្យាដល់កុមារគ្រប់រូបថាពួកគេនឹងធ្វើអ្វីគ្រប់យ៉ាងដែលពួកគេអាចធ្វើបានដើម្បីការពារ និងបំពេញសិទ្ធិរបស់កុមារ។
- សិទ្ធិទាំងនេះអនុវត្តចំពោះកុមារទាំងអស់ ហើយរដ្ឋភាគីត្រូវបានរំពឹងថានឹងធានាថា មានការចាត់វិធានការវិជ្ជមានដើម្បីការពារសិទ្ធិទាំងនេះ។
- CRC បានកំណត់នូវសិទ្ធិជាក់លាក់ចំនួន ៣២ ដែលកុមារមានសិទ្ធិ និងដែលត្រូវបានធានាចំពោះពួកគេ។ អ្នកអាចអានសិទ្ធិទាំង ៣២ នៅក្នុងឯកសារសង្ខេបនេះ៖ (សូមចំណាំថាមាត្រាសរុបមាន ៥៤ នៅក្នុង CRC)។ សិទ្ធិសំខាន់ៗមួយចំនួនដែលទាក់ទងនឹងអ្នកក្នុងនាមជាមន្ត្រីនគរបាលមានរៀបរាប់ដូចខាងក្រោម។
- នៅកន្លែងដែលមានប្រអប់អត្ថបទ អ្នកអាចធ្វើកំណត់ចំណាំបន្ថែមទាក់ទងនឹងរឿងនេះសម្រាប់មន្ត្រីនគរបាល (នេះមានន័យថាយើងត្រូវធ្វើយ៉ាងណាដើម្បីប្រាកដថាសិទ្ធិរបស់កុមារត្រូវបានគោរព)៖

**មាត្រា ១ (និយមន័យ កុមារ)៖** មនុស្សគ្រប់រូបដែលមានអាយុក្រោម ១៨ឆ្នាំមានសិទ្ធិទាំងអស់នៅក្នុងអនុសញ្ញា។

**មាត្រា ២ (គ្មានការរើសអើង)៖** អនុសញ្ញានេះអនុវត្តចំពោះកុមារគ្រប់រូបដោយមិនមានការរើសអើង មិនថាជាជនជាតិ ភេទ សាសនា ភាសាមួយណា សមត្ថភាព ឬស្ថានភាពផ្សេងទៀត មិនថាអ្វីពួកគេគិត ឬនិយាយអ្វីក៏ដោយ ឬប្រវត្តិគ្រួសាររបស់ពួកគេយ៉ាងណាក៏ដោយ។

*ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖*

**មាត្រា ៣ (ឧត្តមប្រយោជន៍កុមារ)៖** ឧត្តមប្រយោជន៍របស់កុមារត្រូវតែជាអាទិភាពចម្បងក្នុងការសម្រេចចិត្តនិងសកម្មភាពទាំងអស់ដែលប៉ះពាល់ដល់កុមារ។

*ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖*



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

**មាត្រា ១២ (ការគោរពទស្សនៈរបស់កុមារ)៖** កុមារគ្រប់រូបមានសិទ្ធិបញ្ចេញទស្សនៈ អារម្មណ៍ និងបំណងប្រាថ្នារបស់ខ្លួនក្នុងគ្រប់បញ្ហាដែលប៉ះពាល់ដល់ពួកគេ ហើយត្រូវយកទស្សនៈរបស់ពួកគេមកពិចារណា និងយកចិត្តទុកដាក់ខ្លាំង។ សិទ្ធិនេះត្រូវបានអនុវត្តគ្រប់ពេលវេលា ឧទាហរណ៍ក្នុងអំឡុងពេលដំណើរការអន្តោប្រវេសន៍ ការសម្រេចចិត្តលើលំនៅស្ថាន ឬជីវិតរស់នៅប្រចាំថ្ងៃរបស់កុមារ។

*ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖*

**មាត្រា ១៣ (ការចែករំលែកគំនិតដោយសេរី)៖** កុមារគ្រប់រូបត្រូវមានសេរីភាពក្នុងការបញ្ចេញមតិយោបល់ និងអាច ទទួលបានព័ត៌មានគ្រប់ប្រភេទ ដរាបណាវាស្ថិតនៅក្នុងច្បាប់។

*ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖*

**មាត្រា ១៦ (សិទ្ធិឯកជនភាព)៖** កុមារគ្រប់រូបមានសិទ្ធិឯកជនភាព។ ច្បាប់គួរតែការពារជីវិតឯកជន គ្រួសារ និងការរស់នៅរបស់កុមាររួមទាំងការការពារកុមារពីការវាយប្រហារ ដោយខុសច្បាប់ដែលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់ពួកគេ។

*ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖*

**មាត្រា ១៩ (ការការពារពីអំពើហិង្សា ការរំលោភបំពាន និងការធ្វេសប្រហែស)៖** រាជរដ្ឋាភិបាលត្រូវធ្វើអស់ពីសមត្ថភាព ដើម្បីធានាថាកុមារត្រូវបានការពារពីអំពើហិង្សា និងការរំលោភបំពានគ្រប់ទម្រង់ ការព្រងើយកន្តើយ និងការធ្វើបាបពីឪពុកម្តាយរបស់ពួកគេ ឬអ្នកផ្សេងទៀតដែលមើលថែពួកគេ។

*ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖*


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

**មាត្រា ២៣ (កុមារពិការ)៖** កុមារពិការមានសិទ្ធិរស់នៅក្នុងជីវិតពេញលេញ និងសមរម្យប្រកបដោយសេចក្តីថ្លៃថ្នូរ និងឯករាជ្យភាពនិងចូលរួមយ៉ាងសកម្មក្នុងសហគមន៍តាមដែលអាចធ្វើទៅបាន។រាជរដ្ឋាភិបាលត្រូវតែធ្វើឱ្យអស់ពីសមត្ថភាពដើម្បីជួយគាំទ្រដល់កុមារពិការ និងគ្រួសាររបស់ពួកគេ។

> ***ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖***

**មាត្រា ៣៤ (ការកេងប្រវ័ញ្ចផ្លូវភេទ)** រាជរដ្ឋាភិបាលត្រូវតែការពារកុមារពីគ្រប់ទម្រង់នៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទទាំងអស់។

> ***ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖***

**មាត្រា ៣៥ (ការចាប់ពង្រត់ ការលក់ និងការជួញដូរ)** រាជរដ្ឋាភិបាលត្រូវការពារកុមារពីការចាប់ពង្រត់ លក់ ឬផ្លាស់ទី ដោយខុសច្បាប់ទៅកន្លែងផ្សេងក្នុង ឬក្រៅប្រទេសក្នុងគោលបំណងកេងប្រវ័ញ្ច។

> ***ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖***

**មាត្រា ៣៩ (ការព្យាបាល និងការស្តារឡើងវិញពីការប៉ះទង្គិច)៖** កុមារដែលបានជួបប្រទះការធ្វេសប្រហែស ការរំលោភបំពាន ការកេងប្រវ័ញ្ច ការធ្វើទារុណកម្ម ឬជាជនរងគ្រោះនៃសង្គ្រាម ត្រូវតែទទួលបានការគាំទ្រពិសេសដើម្បីជួយពួកគេឱ្យស្តាសុខភាព សេចក្តីថ្លៃថ្នូរ ការគោរពខ្លួនឯង និងជីវិតសង្គមរបស់ពួកគេឡើងវិញ។

> ***ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖***

**មាត្រា ៤១ (ការគោរពបទដ្ឋានជាតិខ្ពស់ជាង)៖** ប្រសិនបើប្រទេសមួយមានច្បាប់ និងបទដ្ឋានដែលលើសពីអនុសញ្ញាបច្ចុប្បន្ន ប្រទេសនោះត្រូវតែគោរពតាមច្បាប់ទាំងនេះ។

> *ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖*

**មាត្រា ៤២ (ចំណេះដឹងអំពីសិទ្ធិ)៖** រាជរដ្ឋាភិបាលត្រូវតែធ្វើការយ៉ាងសកម្មដើម្បីធ្វើឱ្យប្រាកដថាកុមារ និងមនុស្សពេញវ័យបានដឹងអំពីអនុសញ្ញានេះ។

> *ដើម្បីរក្សាសិទ្ធិកុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖*

**កំណត់ចំណាំចុងក្រោយ៖** អនុសញ្ញានេះមានមាត្រាសរុបចំនួន ៥៤មាត្រា។ មាត្រា ៤៣-៥៤ និយាយអំពីរបៀបដែលមនុស្សពេញវ័យនិងរាជរដ្ឋាភិបាលត្រូវធ្វើការរួមគ្នាដើម្បីប្រាកដថាកុមារទាំងអស់អាចទទួលបានសិទ្ធិទាំងអស់របស់ពួកគេ។

# តើសិទ្ធិកុមារត្រូវបានអនុវត្តយ៉ាងដូចម្តេចនៅក្នុងពិភពឌីជីថល?

- សុវត្ថិភាព និងសុខុមាលភាពរបស់កុមារតាមប្រព័ន្ធអនឡាញមិនអាចបំបែកចេញពីសិទ្ធិទូលំទូលាយដែលកុមារមាននោះទេ។ **សិទ្ធិកុមារគឺដូចគ្នានៅតាមប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ។**
- មូលដ្ឋានសុវត្ថិភាពរបស់កុមារ គឺជាសិទ្ធិដែលកុមារទាំងអស់មាន ដូចមានចែងក្នុង CRC ដើម្បីការពារគ្រោះថ្នាក់គ្រប់ទម្រង់ទាំងអស់ **(មាត្រា ១៩)** និងពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទគ្រប់ទម្រង់ពីការចាប់ពង្រត់ ដើម្បីយកទៅលក់ ឬការជួញដូរ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត (មាត្រា ៣៤-៣៥)
- ដូច្នេះវាមិនអាចទៅរួចទេ ក្នុងការនិយាយអំពីការការពារកុមារពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ (OCSEA) និងគ្រប់ទម្រង់នៃអំពើហិង្សាដែលសម្របសម្រួលដោយបច្ចេកវិទ្យា ដោយគ្មានការនិយាយអំពីសិទ្ធិរបស់កុមារ។

- ការប្រើប្រាស់អ៊ីនធឺណិត និងបច្ចេកវិទ្យានៅក្នុងជីវិតរបស់កុមារកាន់តែសំខាន់ឡើងៗ និងឱកាសដែលវាផ្តល់ឱ្យ (ការពិភាក្សាក្នុងមេរៀនទី១នៃវគ្គបណ្តុះបណ្តាលនេះ) មានន័យថាខណៈពេលដែលធានាថាកុមារត្រូវបានការពារតាមប្រព័ន្ធអនឡាញ ឱកាសពេញលេញដែលពិភពឌីជីថលបង្ហាញដល់កុមារ មិនត្រូវបានកំណត់ ឬ ដកចេញពីពួកគេនោះទេ។
- ជាឧទាហរណ៍ សិទ្ធិទទួលបានសុវត្ថិភាពលើប្រព័ន្ធអនឡាញ មិនគួរប៉ះពាល់លើសិទ្ធិទទួលការអប់រំ ព័ត៌មាន ឬការថែទាំសុខភាពនោះទេ ជាឧទាហរណ៍ កុមារទាំងអស់អាចចូលប្រើប្រាស់ប្រព័ន្ធអនឡាញបាន ហើយ ពឹងផ្អែកលើវា។
- ដូចគ្នាដែរការស្រាវជ្រាវពីជុំវិញពិភពលោកបានបង្ហាញថានៅពេលដែលកុមារមិនមានសុវត្ថិភាពតាមប្រព័ន្ធអនឡាញ នោះពួកគេមិនអាចដឹងច្បាស់អំពីអត្ថប្រយោជន៍ដែលមានសម្រាប់ពួកគេតាមរយៈអ៊ីនធឺណិត និងបច្ចេកវិទ្យានោះទេ។

## ការអភិវឌ្ឍសំខាន់ៗ

- នៅខែមករា ឆ្នាំ២០២១ CRC បានអនុម័តនូវអ្វីដែលហៅថា **មតិទូទៅ២៥ (GC.25)** ដោយកត់សម្គាល់ថា **សិទ្ធិរបស់កុមារទាំងអស់អនុវត្តស្មើៗគ្នាទាំងនៅក្នុងប្រព័ន្ធអនឡាញ** និងក្រៅប្រព័ន្ធអនឡាញ។
- អ្វីដែលសំខាន់នោះគឺ មតិទូទៅក៏ផ្តល់ការណែនាំអំពីរបៀបដែលសិទ្ធិរបស់កុមារនៅក្នុងពិភពឌីជីថលអាចត្រូវបានបំពេញ។
- តម្រូវការក្នុងការធ្វើឱ្យមានតុល្យភាពនៃសិទ្ធិទទួលបានសុវត្ថិភាពនិងការការពារតាមប្រព័ន្ធអនឡាញជាមួយនឹងឱកាសដែលត្រូវបានបង្ហាញ និងបង្ហាញនៅក្នុងការបកស្រាយនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ
- **GC.25** ក៏ផ្តល់នូវ**គោលការណ៍អន្តរវិស័យ** ដែលជាចំណុចសំខាន់ក្នុងការសម្រេចបាននូវសិទ្ធិរបស់កុមារនៅក្នុងបរិយាកាសឌីជីថល ដែលមានដូចជា៖
- **គោលការណ៍មិនរើសអើង**

*ដើម្បីរក្សាសិទ្ធិមិនរើសអើងកុមារ នេះមានន័យថាក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖*

## គោលការណ៍ដើម្បីលើកកម្ពស់ឧត្តមប្រយោជន៍របស់កុមារ

ដើម្បីរក្សា និងលើកកម្ពស់ឧត្តមប្រយោជន៍របស់កុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖

## សិទ្ធិរស់រានមានជីវិត និងការអភិវឌ្ឍ

ដើម្បីរក្សាសិទ្ធិមិនរើសអើងកុមារ នេះមានន័យថាក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖

## ការគោរពចំពោះទស្សនៈរបស់កុមារ

ដើម្បីរក្សា និងលើកកម្ពស់ឧត្តមប្រយោជន៍របស់កុមារនោះមានន័យថា ក្នុងនាមជាមន្ត្រីនគរបាលយើងគួរ៖


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

# ឧបសម្ព័ន្ធ “ង”៖

# គោលការណ៍នៃ ការអនុវត្តបែបកុមារមេត្រី

## សេចក្តីសង្ខេប និងសន្លឹកកិច្ចការ



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

# គោលការណ៍នៃការអនុវត្តបែបកុមារមេត្រី

## — *សេចក្តីសង្ខេប និងសន្លឹកកិច្ចការ*

សន្លឹកកិច្ចការសង្ខេបនេះ ត្រូវបានរៀបចំឡើងដើម្បីជាការរំលឹកអំពីគោលការណ៍សំខាន់ៗនៃការអនុវត្តបែបកុមារមេត្រី ដើម្បីធ្វើការជាមួយជនរងគ្រោះ និងអ្នករស់រានមានជីវិតពីការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានលើកុមារ។ វាមិនជំនួសការបណ្តុះបណ្តាលជំនាញលើប្រធានបទនេះទេ ដោយសារតែការបណ្តុះបណ្តាលនោះលម្អិតជាងនេះ។

ប្រអប់អត្ថបទដែលបានផ្តល់នៅក្រោមផ្នែកនីមួយៗគឺសម្រាប់មន្ត្រីនគរបាលដើម្បីធ្វើកំណត់ចំណាំបន្ថែមលើប្រធានបទនីមួយៗ ដើម្បីជួយឱ្យចងចាំនូវអ្វីដែលពួកគេអាចធ្វើបានក្នុងតួនាទីរបស់ពួកគេ នៅពេលធ្វើការជាមួយកុមារ សាក្សី និងគ្រួសារ/អាណាព្យាបាល។ ប្រអប់ក៏អាចត្រូវបានប្រើដើម្បីសរសេរសំណួរនៅក្នុងការបណ្តុះបណ្តាលផងដែរ។

## ១. ការលើកកម្ពស់សិទ្ធិកុមារ - វិធីសាស្ត្រផ្អែកលើសិទ្ធិ៖

- **កុមារគ្រប់រូប គួរតែត្រូវបានផ្តល់ការថែទាំ និងការព្យាបាលប្រកបដោយគុណភាពដូចគ្នា** ដោយ មិនគិតពីពូជសាសន៍ សាសនា ភេទ ស្ថានភាពគ្រួសារ ឬស្ថានភាពរបស់អ្នកមើលថែទាំ ប្រវត្តិវប្បធម៌ ស្ថានភាព ហិរញ្ញវត្ថុ ឬសមត្ថភាពពិសេស ឬពិការភាពនោះទេ។
- ជនរងគ្រោះមានសិទ្ធិទទួលបាន**ការការពារ ពិគ្រោះយោបល់ និងជូនដំណឹង**អំពីសកម្មភាពទាំងអស់ដែលត្រូវបានអនុវត្តជំនួសពួកគេ។
- កុមារមានសិទ្ធិ**ចូលរួមក្នុងការសម្រេចចិត្ត**ដែលមានផលប៉ះពាល់ក្នុងជីវិតរបស់ពួកគេ។
- ព័ត៌មានអំពីបទពិសោធន៍នៃការរំលោភបំពានរបស់កុមារគួរតែត្រូវបានប្រមូល ប្រើប្រាស់ ចែករំលែក និងរក្សាទុកក្នុងលក្ខណៈ**សម្ងាត់**។
- ឧត្តមប្រយោជន៍របស់កុមារ៖ គួរតែជាការ**ពិចារណាចម្បង**នៅក្នុងការសម្រេចចិត្តណាមួយដែលកុមារនឹងរងផលប៉ះពាល់។ ( នគរបាល ព្រះរាជអាជ្ញា និងចៅក្រម ផ្តល់អាទិភាពដល់ផលប្រយោជន៍របស់កុមារ។ )

**ដើម្បីធានាថាគោលការណ៍កុមារមេត្រីត្រូវបានអនុវត្តក្នុងនាមជាមន្ត្រីនគរបាល យើងគួរ៖**

---

1. ព័ត៌មានដែលបានបញ្ចូលនៅក្នុងសន្លឹកកិច្ចការនេះគឺផ្អែកលើ «គោលការណ៍ណែនាំការអនុវត្តការដឹកនាំដោយយកកុមារជាកណ្តាល» (សម្រាប់ការសម្ភាស និងគាំទ្រកុមាររងគ្រោះដោយឧក្រិដ្ឋកម្មផ្លូវភេទ) ដែលផលិតដោយអង្គការសកម្មភាពដើម្បី កុមារ ជាអង្គការមិនមែនរដ្ឋាភិបាល ក្នុងឆ្នាំ២០២១។ គោលការណ៍ណែនាំ/ វិធីសាស្ត្រគឺផ្អែកលើគោលការណ៍អនុវត្តដែលមាន ចែងនៅក្នុងគោលការណ៍ណែនាំរបស់ UNHCR ស្តីពីការឆ្លើយតប និងការការពារអំពើហិង្សាផ្លូវភេទ និង យុត្តិធម៌សម្រាប់កុមារ និងការអនុវត្តប្រកបដោយជោគជ័យរបស់កម្ពុជារបស់អង្គការ UNICEF ដែលត្រូវបានបង្កើតឡើងនៅក្នុងដោយពិគ្រោះ យោបល់ជាមួយកងកម្លាំងនគរបាលជាតិកម្ពុជា ក្នុងបរិបទនៃកម្ពុជាស្របតាមស្តង់ដារអន្តរជាតិ។

- កុមារមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងការសម្រេចចិត្តដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។
- នៅក្នុងការស៊ើបអង្កេតរបស់នគរបាល នេះរួមបញ្ចូលទាំងការជូនដំណឹងដល់កុមារអំពីជំហាន និងគោលបំណងនៃការសម្ភាស និងផ្តល់ឱកាសឱ្យកុមារចូលរួមក្នុងការសម្រេចចិត្តថា អ្នកណានឹងមានវត្តមាន របៀបសម្ភាសអាចសម្របខ្លួនបានប្រសើរជាងមុនទៅនឹងតម្រូវការរបស់គាត់ និងអ្វីដែលនឹងកើតឡើងបន្ទាប់ពីបទសម្ភាស។

*ដើម្បីធានាថាគោលការណ៍កុមារមេត្រីត្រូវបានអនុវត្ត នេះមានន័យថាក្នុងនាមជាមន្ត្រីនគរបាល យើងគួរ៖*

## ២. ការអនុវត្តនីតិវិធីកុមារមេត្រី - វិធីសាស្រ្តផ្តោតលើកុមារជាចំណុចកណ្តាល៖

- រាល់សកម្មភាពដែលធ្វើឡើងដោយមន្ត្រីនគរបាលគួរតែធានាថាជនរងគ្រោះ ជាពិសេសកុមារ គឺជាអាទិភាពក្នុងការសម្រេចចិត្ត និងសកម្មភាពទាំងអស់។
- គ្រប់ករណីដែលពាក់ព័ន្ធនឹងជនរងគ្រោះជាកុមារ ឬសាក្សី មិនថាវិធានការ និងការការពារគួរតែត្រូវបាន អនុវត្ត ដើម្បីការពារពួកគេចផុតពីគ្រោះថ្នាក់នានា ឬ ជនរងគ្រោះបន្ទាប់បន្សំ ដែលអាចកើតឡើងក្នុងពេលចូលរួមក្នុងដំណើរការយុត្តិធម៌។
- ជាឧទាហរណ៍ជនរងគ្រោះគឺ (១).មិនត្រូវបានចាត់ទុកជាជនល្មើស (២).មិនត្រូវឱ្យពួកគេមានអារម្មណ៍ទទួលខុសត្រូវ ឬស្តីបន្ទោសចំពោះការរំលោភបំពាន ឬកេងប្រវ័ញ្ចផ្ទាល់ខ្លួនរបស់ពួកគេតាមមធ្យោបាយណាមួយ(៣).មិនត្រូវបានធ្វើពួកគេរងគ្រោះឡើងវិញឬការមាក់ងាយរិះគន់វិនិច្ឆ័យចំអក ឬការរើសអើងតាមមធ្យោបាយណាមួយ (៤).សិទ្ធទទួលបានកាគាំទ្រផ្នែកសង្គម និងច្បាប់។

*ដើម្បីធានាថាគោលការណ៍កុមារមេត្រីត្រូវបានអនុវត្តក្នុងនាមជាមន្ត្រីនគរបាល យើងគួរ៖*

## ៣. កិច្ចសហការក្នុងភាពជាដៃគូដើម្បីធានាបាននូវវិធីសាស្ត្រពហុវិស័យប្រកបដោយប្រសិទ្ធភាព៖

- ភ្នាក់ងារ និងអ្នកជំនាញទាំងអស់ រួមទាំងនគរបាលមានទំនួលខុសត្រូវក្នុងការធ្វើការរួមគ្នាប្រកបដោយប្រសិទ្ធភាព និងដោយការគោរព ដោយការទទួលខុសត្រូវទៅវិញទៅមក និងការទទួលខុសត្រូវរួមគ្នា។
- ការគ្រប់គ្រងករណីរំលោភបំពានលើកុមារគួរមានអ្នកពាក់ព័ន្ធចូលរួម។ ពួកគេគួរតែធ្វើការជាក្រុមប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ការការពារសមស្រប សេវាផ្លូវច្បាប់ និងសង្គមដល់កុមាររងគ្រោះដោយការរំលោភបំពាន និងការកេងប្រវ័ញ្ច។
- ការងារនេះគួររួមបញ្ចូល៖ មន្ត្រីអនុវត្តច្បាប់ និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) ដែលមានទំនួលខុសត្រូវ និងតួនាទីផ្សេងៗគ្នា។
- នេះរាប់បញ្ចូលទាំងមន្ត្រីនគរបាល និងអ្នកជំនាញផ្នែកយុត្តិធម៌ព្រហ្មទណ្ឌផ្សេងទៀតដូចជា ព្រះរាជ-អាជ្ញា ចៅក្រម មេធាវី។
- អ្នកជំនាញផ្នែកសុខភាព និងសុខុមាលភាពសង្គម រួមទាំងបុគ្គលិកសង្គមកិច្ច គ្រូពេទ្យ អ្នកជំនាញសុខភាពផ្លូវចិត្ត រួមទាំងទីប្រឹក្សា មន្ត្រីរដ្ឋាភិបាលមូលដ្ឋាន។ល។ ធ្វើការជាក្រុមរួមគ្នា ដើម្បីគាំទ្រដល់កុមារដែលជាជនរងគ្រោះ និងលើកកម្ពស់អត្ថប្រយោជន៍របស់ពួកគេ។
- ភ្នាក់ងារអនុវត្តច្បាប់ត្រូវសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធទាំងនេះ ដើម្បីបង្កើតទំនាក់ទំនងវិជ្ជមាន

*ដើម្បីធានាថាគោលការណ៍កុមារមេត្រីត្រូវបានអនុវត្តក្នុងនាមជាមន្ត្រីនគរបាល យើងគួរ៖*

## ៤. វិធីសាស្ត្រដែលផ្តោតលើការគិតគូរពីយេនឌ័រ៖

- យើងគួរទទួលស្គាល់ និងទទួលយកថាមនុស្សទាំងអស់ ទាំងកុមារី កុមារា ស្ត្រី និងបុរស និងមនុស្សដែលមានអត្តសញ្ញាណចម្រុះ គឺជាជនងាយរងគ្រោះ ហើយអាចក្លាយជាជនរងគ្រោះនៃការរំលោភបំពាន និងការកេងប្រវ័ញ្ច។
- យើងមិនគួរវិនិច្ឆ័យ រិះគន់ ស្តីបន្ទោស ចំអក ឬរើសអើងលើជនរងគ្រោះ ដោយផ្អែកលើបទពិសោធន៍របស់ពួកគេ អត្តសញ្ញាណយេនឌ័រ ឬជំនឿផ្ទាល់ខ្លួនអំពីលក្ខណៈរបស់ភេទស្រី និងប្រុស។

- **ឧទាហរណ៍៖** ការស្តីបន្ទោសក្មេងស្រីចំពោះសម្លៀកបំពាក់ដែលពួកគេស្លៀក។ ការស្តីបន្ទោសក្មេងប្រុសដោយសារតែគាត់មិនអាចប្រឆាំងនឹងអ្នករំលោភបំពាន។ ការស្តីបន្ទោសអ្នកស្រលាញ់ភេទដូចគ្នា ឬអ្នកកែភេទ ពីព្រោះយើងគិតថាពួកគេខុសគេ។
- យើងគួរតែយល់ថា បុគ្គលនៃភេទណាមួយ ឬអត្តសញ្ញាណណាមួយក៏ដោយ រួមទាំងបុគ្គល ដាក់ក្នុងសន្ទានុក្រមអាចជា និងជាជនរងគ្រោះនៃការរំលោភបំពាន និងការកេងប្រវ័ញ្ច ហើយមិនគួររើសអើងពួកគេតាមរបៀបណាមួយនោះឡើយ។
- យើងគួរតែទទួលស្គាល់ថា ការយល់ឃើញបទពិសោធន៍ និងតម្រូវការរបស់ស្ត្រី និងក្មេងស្រី បុរស និងក្មេងប្រុស និងបុគ្គល LGBTQ អាចមានលក្ខណៈស្រដៀងគ្នា ប៉ុន្តែក៏អាចមានភាពខុសប្លែកគ្នាដែរ ហើយពួកគេទាំងអស់គ្នាមានសិទ្ធិស្មើគ្នា ។
- ការផ្តល់សេវា ដោយមានការគិតគូរអំពីយេនឌ័រដល់កុមារ និងយុវជនដែលត្រូវបានកេងប្រវ័ញ្ច និងរំលោភបំពាន រួមមានវិធីសាស្ត្រផ្អែកលើសិទ្ធិ។ នេះមានន័យថាយើងគួរតែឆ្លើយតបទៅនឹងតម្រូវការជាក់លាក់របស់ជនរង គ្រោះគ្រប់ពេលវេលា និងគ្រប់ដំណាក់កាលនៃដំណើរការ ការប្រព្រឹត្តចំពោះពួកគេដោយការគោរព និងលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់ពួកគេ។
- មន្ត្រីអនុវត្តច្បាប់ គួរតែដោះស្រាយភាពលំអៀងយេនឌ័រ ដែលខ្លួនមានចំពោះជនរងគ្រោះជាកុមារ ហើយកែសម្រួលចំពោះតម្រូវការរបស់បុគ្គលទាំងអស់។

*ដើម្បីធានាថាគោលការណ៍កុមារមេត្រីត្រូវបានអនុវត្តក្នុងនាមជាមន្ត្រីនគរបាល យើងគួរ៖*

## ៥. ការសម្ភាស៖ ការផ្តល់អាទិភាពដល់សុខុមាលភាព និងប្រយោជន៍របស់កុមារ

- ប្រសិនបើកុមាររងគ្រោះមិនសប្បាយចិត្តខ្លាំងក្នុងការផ្តល់សេចក្តីរាយការណ៍ភ្លាមៗ សូមពន្យារពេលការសម្ភាសរហូតដល់កុមារត្រៀមខ្លួនរួចរាល់។
- សូមសម្របសម្រួលជាមួយឪពុកម្តាយ ឬអាណាព្យាបាលរបស់កុមារ និងបុគ្គលិកសង្គមកិច្ច ឬអ្នកមានវិជ្ជាជីវៈផ្សេងទៀត ដើម្បីសម្រេចនូវឱកាសណាមួយឱ្យបានលឿនបំផុតសម្រាប់ការសម្ភាសកុមារប្រកបដោយសុវត្ថិភាព។
- មានភាពហ្មត់ចត់ក្នុងការសម្ភាស ដើម្បីជៀសវាងការសម្ភាសច្រើនដង និងមានសម្រាកឱ្យបានច្រើនកំឡុងពេលសម្ភាសន៍តាមតម្រូវការរបស់កុមារ។

*ដើម្បីធានាថាគោលការណ៍កុមារមេត្រីត្រូវបានអនុវត្តក្នុងនាមជាមន្រ្តីនគរបាលយើងគួរ៖*

## ៦. ការបង្កើតឲ្យមានបរិយាកាសកុមារមេត្រី៖

- ការសម្ភាសជាមួយកុមារគួរតែធ្វើឡើងក្នុងកន្លែងឯកជន ប្រកបដោយផាសុកភាព ដែលមិនមានការរំខាន (ឧទាហរណ៍៖ សំឡេងទូរស័ព្ទរោទិ៍ មនុស្សចេញចូល) និងមានសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្តសម្រាប់កុមារ និងសមាជិកគ្រួសារ។
- ការសម្ភាសជាមួយជនរងគ្រោះជាកុមារនិងសាក្សីមិនគួរធ្វើឡើងនៅក្នុងការិយាល័យដ៏មមាញឹកដែលមនុស្សអាចមើលឃើញកុមារ និងស្តាប់ឮនូវអ្វីដែលពួកគេកំពុងនិយាយនោះទេ។
- ប្រដាប់ប្រដារក្មេងលេង និងហ្គេមមានប្រយោជន៍ក្នុងការរក្សាកុមារឱ្យនៅជាប់ខណៈពេលដែលពួកគេកំពុងរង់ចាំ គួរយកវាចេញក្នុងពេលសម្ភាសន៍ ដើម្បីកុំឱ្យកុមារមានការរំខាន។
- ប្រសិនបើមិនមានកន្លែងកុមារមេត្រីនៅក្នុងប៉ុស្តិ៍នគរបាលទេ សូមស្នើសុំការប្រើប្រាស់កន្លែងកុមារមេត្រីរបស់ភាគីពាក់ព័ន្ធផ្សេងទៀត (ដូចជាកន្លែងបុគ្គលិកសង្គម ឬអង្គការមិនមែនរដ្ឋាភិបាល)។
- មន្រ្តីនគរបាលមិនគួរពាក់ឯកសណ្ឋាន ដោយសារតែវាអាចធ្វើឱ្យកុមារមានការភ័យខ្លាច។
- មន្រ្តីនគរបាលគួរតែអង្គុយក្បែរកុមារ ជាជាងអង្គុយទល់មុខ ដើម្បីចៀសវាងការប្រឈមមុខ។

*ដើម្បីធានាថាគោលការណ៍កុមារមេត្រីត្រូវបានអនុវត្តក្នុងនាមជាមន្រ្តីនគរបាល យើងគួរ៖*

## ៧. វត្តមានអ្នកគាំទ្រកុមារ៖

- ឪពុកម្តាយ អាណាព្យាបាលឬសាច់ញាតិរបស់កុមារចាំបាច់ត្រូវមានវត្តមានសម្រាប់ការសម្ភាស វត្តមានរបស់ពួកគេអាចជួយឱ្យកុមារមានទំនុកចិត្ត និងផាសុកភាព។
- សូមសួរថាតើកុមារចង់ឱ្យនរណាម្នាក់មានវត្តមានដែរឬទេ ប្រសិនបើកុមារស្នើសុំ ហើយវាជាឧត្តមប្រយោជន៍របស់កុមារ គួរតែមាន ឪពុកម្តាយ អាណាព្យាបាល សាច់ញាតិ ឬមនុស្សពេញវ័យម្នាក់អាចអង្គុយ ធ្វើជាអ្នកអង្កេតនៅក្នុងការសម្ភាស។

- ប្រសិនបើឪពុកម្តាយ ឬអាណាព្យាបាលមានវត្តមាន សូមចាំថាត្រូវផ្តោតការសម្ភាសលើកុមារ ដែលជនរងគ្រោះ និង/ឬសាក្សី មិនមែនផ្តោតលើឪពុកម្តាយ ឬអាណាព្យាបាលនោះទេ។
- អ្នកចូលរួម ដូចជាឪពុកម្តាយ អាណាព្យាបាល ឬអ្នកពាក់ព័ន្ធ មិនត្រូវឆ្លើយជំនួស កុមារឡើយ ។ ឪពុកម្តាយឬអ្នកជំនួយផ្សេងទៀតមិនគួរមានវត្តមានទេប្រសិនបើនគរបាលមានការព្រួយបារម្ភថាគាត់អាចព្យាយាមមានឥទ្ធិពលលើភស្តុតាងរបស់កុមារ។

## ៨. វត្តមានមន្ត្រីសង្គមកិច្ចៈ

- ការសម្ភាសគួរតែធ្វើឡើងដោយមានការចូលរួមមន្ត្រីសង្គមកិច្ច ដើម្បីកាត់បន្ថយការប៉ះទង្គិចរបស់កុមារពីការសម្ភាសច្រើនដង និងផ្តល់ការគាំទ្រដល់កុមារតាមតម្រូវការ។ (នេះអាចជាបុគ្គលិក សង្គមមកពីអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្នើសុំយោបល់ពីព្រះរាជអាជ្ញា)។

*ដើម្បីធានាថាគោលការណ៍កុមារមេត្រីត្រូវបានអនុវត្តក្នុងនាមជាមន្ត្រីនគរបាល យើងគួរៈ*

## ៩. កុមារមានពិការភាពៈ

- ប្រសិនបើកុមារមានពិការភាពដែលប៉ះពាល់ដល់សមត្ថភាពក្នុងការប្រាស្រ័យទាក់ទងរបស់គាត់ ចាំបាច់ក្នុងការរៀបចំឱ្យមានអ្នកជំនាញមានវត្តមាន (ឧ. អ្នកបកប្រែភាសាកាយវិការ អ្នកចិត្តសាស្ត្រ។ល។)
- សូមកុំសន្មតថាកុមារពិការមិនត្រូវបានគេកេងប្រវ័ញ្ច ឬរំលោភបំពាន ឬថាពួកគេធ្វើជាសាក្សីដែលមិនគួរឱ្យទុកចិត្ត។ សូមចងចាំថា កុមារទាំងអស់មានសិទ្ធិទទួលការជឿ និងប្រព្រឹត្តដោយស្មើភាពគ្នា

*ដើម្បីធានាថាគោលការណ៍កុមារមេត្រីត្រូវបានអនុវត្តក្នុងនាមជាមន្ត្រីនគរបាល យើងគួរៈ*

## ១០. មន្ត្រីនគរបាលដែលធ្វើបទសម្ភាសៈ

- ការសម្ភាសកុមារគួរគិត ពីយេនឌ័រ។ ការផ្ដល់ជម្រើសឱ្យពួកគេ ក៏អាចមានប្រយោជន៍ក្នុងការកសាងទំនុកចិត្ត និងជួយពួកគេឱ្យមានអារម្មណ៍ថាមានសុវត្ថិភាពផងដែរ។
- ជាធម្មតា ក្មេងស្រីអាចចូលចិត្តឱ្យស្ត្រីសម្ភាសន៍។ ក្មេងប្រុសអាចចូលចិត្តបុរស ឬស្ត្រី អាស្រ័យលើស្ថានភាព និងអត្តសញ្ញាណពិតប្រាកដរបស់អ្នករំលោភបំពាន (ប្រុស ឬស្រី)។
- ក្នុងករណីមានការរំលោភបំពានផ្លូវភេទ ជាការប្រសើរជនរងគ្រោះជាកុមារី ការសម្ភាសគួធ្វើឡើងដោយមន្ត្រីនគរបាលជាស្ត្រី។ ប្រសិនបើមិនមានទេ មន្ត្រីសុខុមាលភាពសង្គម ដែលចូលរួមសម្ភាសគួរតែជាស្ត្រី ដើម្បីធានាថាក្មេងស្រីមិនត្រូវបានសម្ភាសន៍នៅចំពោះមុខបុរសពីរនាក់។

***ដើម្បីធានាថាគោលការណ៍កុមារមេត្រីត្រូវបានអនុវត្តក្នុងនាមជានគរបាលយុត្តិធម៌ យើងគួរ៖***

## ១១. ការផ្ដាច់ទំនាក់ទំនងរវាងកុមាររងគ្រោះ និងជនសង្ស័យ

- មិនថាស្ថិតក្រោមកាលៈទេសៈណាក៏ដោយ កុមារមិនគួរមានវត្តមាននៅក្នុងបន្ទប់តែមួយជនសង្ស័យនោះទេ។ ជនសង្ស័យមិនគួរមានឱកាសបដិសេធសាច់រឿងរបស់ កុមារ ឬសេចក្ដីរាយការណ៍ នៅក្នុងបន្ទប់តែមួយ ឬនៅកន្លែងកើតហេតុនៃឧក្រិដ្ឋកម្មឡើយ។
- មន្ត្រីនគរបាលមិនត្រូវដាក់កុមាររងគ្រោះ នៅជាមួយជនសង្ស័យឡើយ ។(ឧ.នេះក៏មានន័យថា ពួកគេមិនគួរធ្វើដំណើរក្នុងយានជំនិះដូចគ្នាទៅកាន់ប៉ុស្ដិ៍នគរបាល)។
- ការសម្ភាសមិនគួរធ្វើឡើងនៅចំពោះមុខជនសង្ស័យ ឬមនុស្សពេញវ័យផ្សេងទៀតដែលមិនពាក់ព័ន្ធឡើយ ។ប្រសិនបើកុមារត្រូវតែកំណត់អត្តសញ្ញាណជនសង្ស័យជាផ្លូវការនេះគួរតែធ្វើឡើងតាមរយៈរូបថតមួយសន្លឹក ឬតាមរយៈកញ្ចក់ពីខាងក្រៅប្រសិនបើអាចធ្វើបាននៅប៉ុស្ដិ៍នគរបាល ជាជាងនៅចំពោះមុខដោយផ្ទាល់។

## ១២. ការប្រើភាសាស្របតាមអាយុ និងកម្រិតនៃការអភិវឌ្ឍរបស់កុមារ៖

- មុនពេលសម្ភាសន៍ មន្ត្រីនគរបាលគួរយកចិត្តទុកដាក់ លើកម្រិត ការយល់ដឹង ការអភិវឌ្ឍន៍ និងភាសារបស់កុមារ


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

- មន្ត្រីនគរបាលមិនគួរបង្ខំឱ្យមានការលាតត្រដាងឬបន្តការសម្ភាសនៅពេលដែលកុមារឈឺចាប់ខ្លាំង ព្រោះវាអាចនឹងធ្វើឱ្យកុមារប៉ះទង្គិចផ្លូវចិត្ត។
- ក្នុងពេលសម្ភាសកុមារដែលប៉ះទង្គិចធ្ងន់ធ្ងរ គួរទទួលបានការកសាងទំនុកចិត្តលើកទឹកចិត្ត ហើយចៀសវាងការសម្ភាសច្រើនដង។ ស្វែងយល់បន្ថែមអំពីការប្រាស្រ័យទាក់ទងជាមួយកុមារដែលមានអាយុ និងដំណាក់កាល ផ្សេងៗ គ្នា។

*ដើម្បីធានាថាគោលការណ៍កុមារមេត្រីត្រូវបានអនុវត្តក្នុងនាមជាមន្ត្រីនគរបាល គួរ៖*

## *** ដំណាក់កាលទាំង៥ នៃការសម្ភាស

១. **សេចក្តីផ្តើម/ការបង្កើតគោលការណ៍៖** សូមណែនាំខ្លួនអ្នកដល់កុមារ។ ណែនាំមនុស្សផ្សេងទៀត និងតួនាទីរបស់ពួកគេ ពន្យល់ពីអ្វីដែលអ្នកកំពុងធ្វើនៅទីនេះ និងអ្វីដែលនឹងកើតឡើងនៅក្នុងការសម្ភាស។

២. **ការកសាងទំនាក់ទំនង និងទំនុកចិត្ត៖** ចាប់ផ្តើមសួរសំណួរទាក់ទងនឹងជីវិតរបស់កុមារ ឧ. «តើប្អូនរៀននៅឯណា?» ដើម្បីធ្វើឱ្យពួកគេមានផាសុកភាព និងយល់ពីរបៀបទំនាក់ទំនង និងកម្រិតនៃការយល់ដឹងរបស់ពួកគេ។

៣. **ការទទួលបានព័ត៌មានដែលពាក់ព័ន្ធ - ការរំលឹកឡើងវិញដោយសេរី៖** អនុញ្ញាតឱ្យកុមារនិយាយអំពីព្រឹត្តិការណ៍នៅក្នុងពាក្យពេចន៍របស់ពួកគេផ្ទាល់។

៤. **ការទទួលបានព័ត៌មានពាក់ព័ន្ធ - ការសាកសួរ៖** សូមពន្យល់ថា ឥឡូវនេះអ្នកនឹងសួរកុមារនូវសំណួរមួយចំនួន និងការផ្លាស់ពីសំណួរបើកចំហទៅសំណួរជាក់លាក់បន្ថែមទៀត។

៥. **ការបិទ៖** ទោះជាការសម្ភាសមានប្រយោជន៍ប៉ុណ្ណាក៏ដោយ ត្រូវប្រាកដថាការបញ្ចប់ការសម្ភាសមានភាពវិជ្ជមាន។ សរសើរកុមារសម្រាប់ការមកសម្ភាសន៍ (មិនមែនសម្រាប់អ្វីដែលពួកគេបាននិយាយនោះ) ឆ្លើយនូវសំណួរផ្សេងៗដែលពួកគេមាន និងពន្យល់ពីអ្វីដែលនឹងកើតឡើងបន្ទាប់។

# ឧបសម្ព័ន្ធ “ច” ៖

# ការស៊ើបអង្កេតអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារដែលស្របតាមគោលការណ៍ច្បាប់

## — សេចក្ដីសង្ខេប

# ការស៊ើបអង្កេតអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារស្របតាមគោលការណ៍ច្បាប់

## សេចក្តីសង្ខេប

**ចំណុចរៀនសូត្រសំខាន់ៗ៖** ដោយសារបទល្មើសនៃអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ( OCSEA ) មួយចំនួនអាចកើតឡើងតាមប្រព័ន្ធអនឡាញទាំងស្រុង ភារកិច្ចរបស់មន្ត្រីនគរបាលអាចប្រែប្រួលយោងទៅតាមករណីនីមួយៗ។ ក្នុងករណី ខ្លះនៃបទឧក្រិដ្ឋកើតឡើងតាមប្រព័ន្ធអនឡាញ និងផ្នែកខ្លះទៀតកើតឡើងក្រៅប្រព័ន្ធអនឡាញ អាចមានភារកិច្ចផ្សេងៗដែលអ្នកត្រូវយកចិត្តទុកដាក់ខ្ពស់។

**ចំណុចរៀនសូត្រសំខាន់ៗ៖** សូមចាំថា ការលើកកម្ពស់សិទ្ធិកុមារ ឧត្តមប្រយោជន៍កុមារ និងការអនុវត្តបែបកុមារមេត្រីគឺ ជាតួនាទីដ៏សំខាន់មួយសម្រាប់មន្ត្រីនគរបាលទាំងអស់ ក្នុងគ្រប់ភារកិច្ចទាំងអស់ដែលអ្នកត្រូវធ្វើ។ អ្នកគួរតែពិចារណាគ្រប់ពេលវេលាអំពីរបៀបដែលអ្នកគួរធ្វើសកម្មភាព និងគួរប្រព្រឹត្តចំពោះកុមារស្របតាមតម្រូវការទាំងនេះ។

## ១. ការទទួលពាក្យបណ្តឹង៖

**ភារកិច្ចសម្រាប់នគរបាលយុត្តិធម៌៖**

- ជួបជាមួយអ្នកដាក់ពាក្យបណ្តឹង និងអាណាព្យាបាល/គ្រួសារ (ឬបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដំបូង ឬមនុស្សផ្សេងទៀត)។
- ទទួលយកសេចក្តីរាយការណ៍ដំបូងដំបូងពីដើមបណ្តឹង កុមាររងគ្រោះ និងសាក្សី ឬអ្នករាយការណ៍ព័ត៌មាន។
- ប្រសិនបើករណីទាំងនេះជា «បទល្មើសជាក់ស្តែង» នគរបាលអាចចាប់ខ្លួនជនសង្ស័យភ្លាមៗ ប៉ុន្តែប្រសិនបើមិនមែនជាបទល្មើសជាក់ស្តែងទេ នគរបាលនឹងស្នើសុំការស៊ើបអង្កេតស្រាវជ្រាវពីព្រះរាជអាជ្ញា។

**សូមចាំថា ត្រូវអនុវត្តភារកិច្ចទាំងនេះដោយយោងតាមការណែនាំអំពីការអនុវត្តកុមារមេត្រី។ សូមមើលឯកសារស្តីអំពីសិទ្ធិកុមារជាឯកសារយោង។**


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

## ២. ដំណាក់កាលស៊ើបអង្កេតបឋម៖

**ភារកិច្ចសម្រាប់នគរបាលយុត្តិធម៌៖**

- រៀបចំរបាយការណ៍ ព័ត៌មានសង្ខេបអង្គហេតុ ដើម្បីស្នើសុំទៅថ្នាក់ដឹកនាំរបស់ខ្លួន និងព្រះរាជអាជ្ញាដើម្បីធ្វើការស៊ើបអង្កេតបឋម។
- ការកំណត់អត្តសញ្ញាណជនរងគ្រោះ (ការសសម្ភាស ជនរងគ្រោះ ការសម្ភាសសាក្សី យោងទៅតាមការណែនាំស្តី អំពីការអនុវត្តកុមារមេត្រី)។
- ការពិនិត្យសុខភាព (ប្រសិនបើចាំបាច់-ករណីខ្លះប្រហែលជាមិនចាំបាច់ទេ ហើយបទល្មើស OCSEA ខ្លះក៏មិនចាំបាច់ដែរ)។
- ការប្រមូលភស្តុតាងរូបវន្តដំបូង (ប្រសិនបើពាក់ព័ន្ធ-ប្រហែលជាមិនចាំបាច់ទេ ក្នុងករណីដែលកើតឡើងតាមប្រព័ន្ធអនឡាញទាំងស្រុង)។
- ការប្រមូលលើកដំបូងនៃការរឹបអូសនិងការរក្សាទុកប្រកបដោយសុវត្ថិភាព/ការរក្សាទុកភស្តុតាងឌីជីថល/ ឧបករណ៍ (ការធ្វើបែបនេះតម្រូវឱ្យមាន ការបណ្តុះបណ្តាលអ្នកឯកទេសបច្ចេកទេស/ឌីជីថលបន្ថែមទៀត - មិនទាន់ធ្វើចប់សព្វគ្រប់នៅឡើយទេ)។
- ការកំណត់អត្តសញ្ញាណជនសង្ស័យ (ឈ្មោះ ភេទ ថ្ងៃ ខែ ឆ្នាំកំណើត សញ្ញាតិ មុខរបរ អាសយដ្ឋាន...។ល។)
- ប្រសិនបើ និងពេលប្រមូលបានភស្តុតាងគ្រប់គ្រាន់។

**សូមចាំថា ត្រូវអនុវត្តភារកិច្ចទាំងនេះដោយយោងតាមការណែនាំអំពីការអនុវត្តកុមារមេត្រី។ សូមមើលឯកសារស្តីអំពីសិទ្ធិកុមារជាឯកសារយោង។**

## ៣. ដំណាក់កាលស្តាប់ចម្លើយ/ប្រមូលភស្តុតាង

**ភារកិច្ចនគរបាលយុត្តិធម៌៖** (សូមកត់ចំណាំ៖ ការបណ្តុះបណ្តាលជាក់លាក់ និងការផ្តោតទៅលើការកំណត់អត្តសញ្ញាណការរឹបអូសនិងការរក្សាទុកឧបករណ៍ឌីជីថលនិងភស្តុតាងត្រូវបានគ្រោងទុករួចហើយ ទោះបីមិនទាន់បានកើតឡើង នៅឡើយក៏ដោយ)។

- ការស្តាប់ចម្លើយជនសង្ស័យដោយផ្អែកលើបទល្មើសព្រហ្មទណ្ឌ ធ្វើឱ្យស្របតាមនីតិវិធីច្បាប់។
- កំណត់រកកន្លែងកើតហេតុ (ក្នុងករណី OCSEA ខ្លះ «កន្លែងកើតហេតុ» អាចមានទាំងនៅក្នុងប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ)។

- ការស្វែងរកកន្លែងកើតហេតុឌីជីថលលើកដំបូង (មានតែក្នុងករណីតាមប្រព័ន្ធអនឡាញតែប៉ុណ្ណោះ អាចជាឧបករណ៍អេឡិកត្រូនិក និងឌីជីថល កម្មវិធី វេទិកា (Cloud) ឧបករណ៍ផ្ទុកឯកសារ គណនីអ៊ីម៉ែលជាដើម... ដូច្នេះអាចទាមទារការបណ្តុះបណ្តាល និងជំនាញបន្ថែម រួមទាំងកិច្ចសហប្រតិបត្តិការជាមួយអង្គភាពជំនាញ ពាក់ព័ន្ធផងដែរ។)
- រាយការណ៍ទៅថ្នាក់ដឹកនាំ ឬព្រះរាជអាជ្ញា ដើម្បីសុំគោលការណ៍ចង្អុលបង្ហាញ ឬដឹកនាំបន្ថែម។

**សូមចាំថា ត្រូវអនុវត្តភារកិច្ចទាំងនេះដោយយោងតាមការណែនាំអំពីការអនុវត្តកុមារមេត្រី។ សូមមើលឯកសារស្តីអំពីសិទ្ធិកុមារជាឯកសារយោង។**

## ៤. ការរៀបចំរបាយការណ៍

### ភារកិច្ចនគរបាលយុត្តិធម៌៖

- សរសេររបាយការណ៍សរុបសំណុំរឿងនិងរៀបចំកញ្ចប់ភស្តុតាងតាមនីតិវិធីច្បាប់ដើម្បីបញ្ជូនទៅថ្នាក់ដឹកនាំពិនិត្យ ផ្ទៀងផ្ទាត់មុនសម្រេចបញ្ជូនទៅតុលាការ។
- ភ្ជាប់ឯកសារគាំទ្រទាំងអស់ (ពាក្យបណ្តឹងរបស់ដើមបណ្តឹង សេចក្តីថ្លែងការណ៍របស់ជនរងគ្រោះ សាក្សី និងជនសង្ស័យ កំណត់ហេតុឃាត់ខ្លួន ......។ល។)
វិញ្ញាបនប័ត្រវេជ្ជសាស្ត្រ (ប្រសិនបើមាន)
- ភស្តុតាងគាំទ្រផ្សេងទៀត ភស្តុតាងឌីជីថល (ត្រូវទាមទារការបណ្តុះបណ្តាលបន្ថែមស្តីអំពីរបៀបកំណត់អត្តសញ្ញាណ ការរក្សាទុកប្រកបដោយសុវត្ថិភាព និងការរក្សាទុកភស្តុតាងឌីជីថល)។
- បញ្ជូនភស្តុតាង និងសំណុំរឿង និងភស្តុតាងទៅព្រះរាជអាជ្ញាទាំងអស់។

## ៥. ដំណាក់កាលព្រះរាជអាជ្ញា

### ភារកិច្ចព្រះរាជអាជ្ញា៖

- ពិនិត្យមើលរបាយការណ៍អំពីដំណើររឿង សេចក្តីថ្លែងការណ៍ និងភស្តុតាងគាំទ្រទាំងអស់ (ភស្តុតាងជាក់ស្តែង និងឌីជីថល)
- សម្ភាសន៍កុមាររងគ្រោះ សម្ភាសន៍ ឬមិនសម្ភាសន៍ អាស្រ័យលើព្រះរាជអាជ្ញា)
- ស្តាប់ចម្លើយជនសង្ស័យ
- ចោទប្រកាន់ និងបញ្ជូនទៅចៅក្រមស៊ើបសួរ

## ៦. ដំណាក់កាលចៅក្រមស៊ើបសួរ

### ភារកិច្ចចៅក្រមស៊ើបសួរ៖

- ពិនិត្យ និងផ្ទៀងផ្ទាត់ សំណុំរឿង និងភស្តុតាង
- ស្តាប់ចម្លើយជនសង្ស័យ
- អាចសម្ភាសន៍ជនរងគ្រោះ/សាក្សី
- ប្រសិនបើចៅក្រមស៊ើបសួរជឿថា មានភស្តុតាងគ្រប់គ្រាន់ដើម្បីកាត់ទោសជនជាប់ចោទនឹងចេញដីកាឃុំខ្លួន ជនត្រូវចោទនឹងត្រូវបញ្ជូនទៅតុលាការដើម្បីកាត់ទោស (ឃុំខ្លួនបណ្តោះអាសន្ន)។

## ៧. សវនាការ៖

### ភារកិច្ចនគរបាលយុត្តិធម៌៖

- ចូលរួមសវនាការ ដើម្បីបំភ្លឺនៅដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលបើកសវនាការ
- ត្រៀមឆ្លើយសំណួរ ដែលសួរដេញដោយមេធាវីការពារជនជាប់ចោទ
- អាចតម្រូវឱ្យឆ្លើយសំណួរបន្ថែមដែលសួរដោយចៅក្រម

# ឧបសម្ព័ន្ធ “ឆ” ៖

## សម្រង់ខ្លឹមសារនៃសេចក្តីរាយការណ៍

### បទពិសោធន៍របស់កុមារ និងគ្រួសារក្នុងការស្វែងរក និងទទួលបានជំនួយពីមន្ត្រីនគរបាល



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

# សម្រង់ខ្លឹមសារនៃសេចក្តីរាយការណ៍ — បទពិសោធន៍របស់កុមារ និងគ្រួសារក្នុងការស្វែករក និងទទួលបានជំនួយពីនគរបាល

## សារៈប្រយោជន៍នៃការឆ្លើយតបបែបវិជ្ជមាន

- “គាត់ជួយខ្ញុំឱ្យនិយាយ... នៅពេលគាត់សម្ភាសន៍ខ្ញុំ គាត់ក៏លើកទឹកចិត្តខ្ញុំដែរ....ហើយខ្ញុំអាចនិយាយបានដោយមិនភ័យខ្លាច...ខ្ញុំនិយាយអ្វីគ្រប់យ៉ាងដែលខ្ញុំដឹង....គាត់និយាយត្រង់ៗ ចំៗ ចំណុច ...គាត់មិននិយាយពាក្យបច្ចេកទេសទេ គាត់ប្រើតែពាក្យថា ខ្ញុំដឹង (យល់)...គាត់ធាប់យល់ គាត់ប្រើភាសាដែលខ្ញុំប្រើរាល់ថ្ងៃ។”

- “វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការមាន "ការលើកទឹកចិត្ត គាំទ្រ និងយល់ចិត្ត” ពីនគរបាល (ប៉ូលិស) និងអ្នកដែលមានការពាក់ព័ន្ធ ..... គឺជួយឱ្យ មានការជឿជាក់ និងទំនុកចិត្តនៅក្នុងដំណើរការនេះ ហើយក៏ជួយ សម្រាលការថប់បារម្ភរបស់យើងផងដែរ។”

- “វាមានប្រយោជន៍ខ្លាំងណាស់ នៅពេលដែលនគរបាលណែនាំយើងដល់បុគ្គលិកផ្តល់សេវាគាំទ្រ ពីអង្គការមិនមែនរដ្ឋាភិបាល ឬមេធាវី។ វាជួយយើងឱ្យយល់កាន់តែច្បាស់ និងមានទំនុកចិត្តក្នុងដំណើរការ។” ការជួបជាមួយប៉ូលិស សូម្បីតែជនរងគ្រោះអាចជាការពិបាកខ្លាំង

- “នគរបាលនិយាយថា៖ ពួកគេនៅតែបន្តនិយាយ ហើយប្រាស្រ័យទាក់ទងជាមួយយើង ព្រោះពួកគេមិនទាន់ចាប់បានជនសង្ស័យទេ ដូច្នេះយើងត្រូវបន្តទាក់ទងជាមួយពួកគេ បញ្ជូនភស្តុតាង និងឯកសារទៅពួកគេ...ដើម្បីធ្វើឱ្យវាស៊ើបអង្កេត។ របៀបដែលពួកគេនិយាយគឺស្ងប់ស្ងាត់ ធ្វើឱ្យខ្ញុំទុកចិត្តនិងជួយខ្ញុំឱ្យមានភាពក្លាហាន ហ៊ាននិយាយអំពីអ្វីដែលពិតជាបានកើតឡើងចំពោះខ្ញុំ។”

- “វាពិតជាមានប្រយោជន៍ខ្លាំងណាស់ក្នុងការទំនាក់ទំនង និងធ្វើបច្ចុប្បន្នភាពជាប្រចាំអំពីករណីនេះ ហើយនៅពេលដែលនគរបាល និងអ្នកផ្សេងទៀតប្រើភាសាចំៗ និងងាយយល់។”

- “ពួកគាត់ (នគរបាល) រាក់ទាក់ និងសហការល្អជាមួយយើង...នគរបាលបានពន្យល់ពីសិទ្ធិរបស់ឪពុក និងសិទ្ធិរបស់កុមារ...ក្នុងដំណើរការនីតិវិធី របស់នគរបាលមានការប្រុងប្រយ័ត្ន សម្ងាត់ និងមានសុវត្ថិភាព។”

ការជួបជាមួយនគរបាលសូម្បីតែកុមាររងគ្រោះក៏អាចមានការភ័យខ្លាចនៅពេលដែលលឺថា ត្រូវជួបនគរបាល ហើយវាជាដំណើរការមួយដែលស្មុគស្មាញ ដូច្នេះយើងសូមកោតសរសើរ ចំពោះការគាំទ្ររបស់ពួកគេចំពោះបញ្ហានេះ។ វាជួយ យើងឱ្យសហការគ្នាកាន់តែល្អ។"

» " ដើម្បីធ្វើឱ្យវាកាន់តែងាយស្រួល សូមកុំបំភ័យពួកគេ [កុមារ] នៅពេលពួកគេនិយាយ។នៅពេលកុមារសួរសំណួរសូមឆ្លើយឬប្រសិនបើពួកគេ | ឆ្ងល់អំពីអ្វីមួយ សូមអនុញ្ញាតឱ្យពួកគេសួរសំណួរ ឱ្យបានច្រើន ហ៊ាននិយាយ... ប្រាប់ពួកគេអំពីរឿង ដែលនឹងកើតឡើង។វានឹងធ្វើឱ្យកាន់តែងាយស្រួល ព្រោះវាកាន់តែមានភាពស្និទ្ធស្នាល។ សូមឱ្យពួកគេគិតអំពីការទទួលស្វាគមន៍ មិនធ្វើឱ្យកុមារ ភ័យខ្លាចនោះទេ គឺបែបនោះ!"

» " ខ្ញុំមានសារមួយដល់នគរបាល គឺត្រូវយកចិត្តទុកដាក់ចាត់ទុកកុមារដូចជាកូនរបស់ខ្លួន ដូច្នេះសូមរកយុត្តិធម៌ឱ្យពួកគេ។

» " សម្រាប់នគរបាល ពួកគេគួរតែរកកន្លែងស្ងាត់បំផុត ដែលអាចសួរនិងឆ្លើយ ដើម្បីកុំឱ្យ កុមារទាំងនោះមានការភ័យខ្លាច។ ដោយសារតែកុមារខ្លះអាម៉ាស់ ភ័យខ្លាច ហើយនិយាយមិនចេញ។ ដូច្នេះគេគួររកកន្លែងស្ងាត់ ដើម្បីងាយស្រួលក្នុងការម្តាស។"

» " ខ្ញុំគិតថានគរបាលគួរតែធ្វើអ្វីដែលពួកគេអាចធ្វើបាន ដើម្បីលើកទឹកចិត្តកុមារកុំឱ្យភ័យខ្លាចនៅពេលពួកគេពន្យល់ពីអ្វីមួយ...ហើយញញឹម...ធ្វើអ្វីគ្រប់ យ៉ាងដើម្បីជួយធ្វើឱ្យការភ័យខ្លាចបាត់ទៅវិញ។"

» " ខ្ញុំសង្ឃឹមថាពួកគេអាចផ្លាស់ប្តូរឥរិយាបថ និង របៀបដែលសួរសំនួរ... ហើយនៅពេលដែលពួក គេសួរសំណួរ ពួកគេគួរតែសួរម្តងមួយៗ មិនលឿនពេកហើយសួរឱ្យបានច្បាស់ ដើម្បីកុំឱ្យច្រលំនូវអ្វីដែល ពួកគេកំពុងសួរ។"

» "ដំបូងឡើយ ពេលខ្ញុំជួបគេដំបូង ខ្ញុំមានអារម្មណ៍ ភ័យខ្លាច។ ខ្ញុំនិយាយទាំងអាក់អួល បន្ទាប់មកជាលើកទី២ មានអង្គការមិនមែនរដ្ឋាភិបាលជួយលើកទឹកចិត្តឱ្យខ្ញុំនិយាយ។ ខ្ញុំនិយាយដូចខ្លាច ខ្ញុំនិយាយលឿនមិនចាំអ្វីៗនោះទេ ខ្ញុំត្រដិតឈប់ ហើយចាប់ផ្តើមភ្លេចអ្វីៗទាំងអស់។ ពួកគេបានពន្យល់យ៉ាងច្បាស់ ហើយលើកទឹកចិត្តខ្ញុំឱ្យមានភាពក្លាហានក្នុងការនិយាយ...ហើយខ្ញុំក៏មានទំនុកចិត្តក្នុងការនិយាយ។ ខ្ញុំអាចក្លាហានបានដោយសារតែពួកគេនៅពីក្រោយខ្ញុំ។"

# ការឆ្លើយតបបែបអវិជ្ជមានដែលមិនគួរឱ្យកើតមាន

- “ប្រសិនបើមានរឿងបែបនេះកើតឡើងម្តងទៀត ចំពោះអ្នកផ្សេងទៀត នគរបាលគួរតែរក្សាការសម្ងាត់....ពួកគេមិនគួរបើកចំហអ្វីគ្រប់យ៉ាង ដើម្បីឱ្យអ្នកដទៃដឹងនោះទេ។ ព្រោះនៅក្នុងបន្ទប់ដែលគាត់សួរយើងវាមិនគ្រាន់តែមានគាត់ និងជនរងគ្រោះទេ គឺមានមនុស្សជាច្រើននាក់ទៀតនៅទីនោះដែរ។”

- “ ខ្ញុំពិបាកនិយាយ ពេលជួបប៉ូលិសប្រុសៗ ។ ពួកគេជាប្រុស ហើយខ្ញុំជាក្មេងស្រី ហើយវាធ្វើឱ្យខ្ញុំពិបាក ប្រាប់គាត់ ហើយឆ្លើយសំណួរផ្សេងៗ។”

- “នៅពេលខ្ញុំនិយាយ ខ្ញុំខ្លាចពួកគេខ្លះគិតដល់វាហើយសើច ធ្វើឱ្យខ្ញុំមានអារម្មណ៍អាម៉ាស ភ័យខ្លាច ... ខ្ញុំភ័យ... វាធ្វើឱ្យខ្ញុំគិត នៅពេលដែលពួកគេសួរហើយខ្ញុំឆ្លើយ។ខ្ញុំឆ្លើយតែនៅពេលដែលពួកគេស្រែកខ្ញុំនិយាយមិនចេញទេ វាធ្វើឱ្យខ្ញុំគាំង ហើយមិនដឹងថាត្រូវធ្វើអ្វី។”

- “ ពេលខ្លះនគរបាលមានទឹកមុខ មើលទៅគួរឱ្យភ័យខ្លាច ”

- “ ពាក្យមានន័យជ្រៅ ហើយវាពិបាកយល់ និងគិត មិនងាយស្រួលទេ ខ្ញុំត្រូវគិតយូរ ហើយខ្ញុំពិបាក ឆ្លើយណាស់។”

- “ ខ្ញុំចង់និយាយជាមួយបងស្រីនគរបាល ដោយសារនិយាយជាមួយស្រីៗដូចគ្នា ខ្ញុំមិនសូវខ្មាស់។”(កុមារ)

- “ ខ្ញុំចាំថាខ្ញុំខ្លាចកូនស្រីរបស់ខ្ញុំខ្មាស់គេ ដោយសារ តែការនិយាយសាច់រឿងបែបនោះជាមួយប្រុសៗ គឺ ធ្វើឱ្យអាម៉ាស់តែម្តង។” (ម្តាយរបស់កុមារ)

- “ខ្ញុំចង់ឱ្យបន្ទប់ដែលប្រើសម្រាប់ការសម្ភាសគួរតែមានអ្នកដែលចាំបាច់ដែលត្រូវធ្វើការសម្ភាសនៅទីនោះបានហើយ...មានអ្នកសម្ភាសតែម្នាក់ គឺវាគ្រប់គ្រាន់ហើយ។ សូមកុំធ្វើដូចគេធ្វើជាមួយយើងមានមនុស្សច្រើននៅទីនោះ មានច្រើនណាស់ មិនមែនត្រឹមតែពីរបីនាក់នោះទេ។”

» “នៅពេលខ្ញុំត្រូវបានសម្ភាសន៍ ហើយនគរបាលបាន បង្ហាញរូបថតមកខ្ញុំ មន្ត្រីផ្សេងទៀតនៅក្នុងបន្ទប់កំពុងស្តាប់ ហើយសើចចំអកដាក់ខ្ញុំ។ ខ្ញុំគ្រាន់តែចង់ឱ្យពួកគេឈប់សើច ហើយឈប់រើសអើងខ្ញុំ។”

» “វាហាក់ដូចជាពួកគេកំពុងតែបន្ទោសខ្ញុំ។ នគរបាល បាននិយាយថា វាយឺតពេលហើយ ហេតុអ្វីបានជាខ្ញុំមិននៅផ្ទះ? បានពន្យល់ពួកគេពីអ្វីដែលបាន កើតឡើង។ បន្ទាប់មកពួកគេនិយាយថា ហេតុអ្វីបានជាខ្ញុំដើរចេញក្រៅនៅពេលយប់?» ពួកគេហាក់ដូចជាចង់បន្ទោសខ្ញុំ សម្រាប់អ្វីដែលបានកើតឡើង។”

» “ពួកគេបានស្តីបន្ទោសខ្ញុំចំពោះស្ថានភាពរបស់ខ្ញុំ ដោយនិយាយថាមកពីខ្ញុំចង់បានវា (ដោយប្រើកម្ម វិធីអនឡាញ) ហើយពួកគេសួរថា ហេតុអ្វីបានជាខ្ញុំទៅរាយការណ៍ទៅវិញ។”

# ឧបសម្ព័ន្ធ "ឆ១"៖ ករណីសិក្សា

## បទពិសោធន៍វិជ្ជមានរបស់កុមារកម្ពុជា នៃការស្វែងរកជំនួយពីនគរបាល

ករណីសិក្សានេះដកស្រង់ចេញពីការស្រាវជ្រាវ Disrupting Harm Cambodia (2022) ដោយផ្អែកលើបទពិសោធន៍របស់ក្មេងស្រីខ្មែរម្នាក់ ដែលជាជនរងគ្រោះនៃOCSEA។

ករណីនេះត្រូវបានបង្ហាញសម្រាប់អ្នកចូលរួមដើម្បីកំណត់នូវការឆ្លើយតបបែបវិជ្ជមាន និងមានប្រយោជន៍របស់មន្ត្រីនគរបាល និងដើម្បីបង្ហាញពីការ "អនុវត្តន៍ល្អ" នៃការគោរពសិទ្ធិ និងឧត្តមប្រយោជន៍កុមារ និងការអនុវត្តតាមនីតិវិធីកុមារមេត្រីដែលអាចផ្តល់អត្ថប្រយោជន៍ដល់អ្នកពាក់ព័ន្ធនិងនាំឱ្យទទួលបានលទ្ធផលជោគជ័យករណីសិក្សាស្រីលីន។

ករណីសិក្សា **ស្រី លីន**

ស្រីលីន (មិនមែនឈ្មោះពិត) ជាជនរងគ្រោះនៃអំពើ OCSEA ដែលត្រូវបានសម្ភាសន៍ជាផ្នែកមួយនៃការស្រាវជ្រាវ Disrupting Harm Cambodia នៅកម្ពុជា។ ឪពុករបស់នាងក៏ត្រូវបានសម្ភាសន៍ដោយនគរបាល និងផ្តល់គុណតម្លៃសម្រាប់គាត់។ យើងអាចរៀនបានច្រើនពីបទពិសោធន៍វិជ្ជមាន ការយល់ដឹងការអនុវត្តល្អៗ។

សរុបមកទាំងកូនស្រី និងឪពុក បានពិពណ៌នាអំពីករណីមួយដែលត្រូវបានដោះស្រាយយ៉ាងល្អ ដោយអាជ្ញាធរដែលបង្ហាញពីវិជ្ជាជីវៈ និង "ការអនុវត្តល្អៗ" ក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។

**ការរាយការណ៍៖**

- ឪពុកបានទៅជួបមន្ត្រីនគរបាល និងបានរៀបរាប់ថា មានការលើកទឹកចិត្តយ៉ាងខ្លាំងចំពោះការឆ្លើយរបស់ពួកគេ ដែលគាត់បានពិពណ៌នាថា ងាយស្រួល និងរក្សាការសម្ងាត់។
- គាត់និយាយថា ៖នគរបាលបានស្វាគមន៍ និងរាក់ទាក់ មានការសហការណ៍ល្អ នគរបាលបានពន្យល់ពីតួនាទី និងសិទ្ធិរបស់ឪពុកជាដើមបណ្តឹង និងសិទ្ធិកុមារជាជនរងគ្រោះ ហើយនីតិវិធីរបស់នគរបាលមានការប្រុងប្រយ័ត្នខ្ពស់ និងមានសុវត្ថិភាព។
- គាត់និយាយថា នគរបាលបានស្វាគមន៍ និងរាក់ទាក់ មានការសហការណ៍ល្អ នគរបាលបានពន្យល់ពីតួនាទី និងសិទ្ធិរបស់ឪពុកជាដើមបណ្តឹង និងសិទ្ធិកុមារជាជនរងគ្រោះ និងនីតិវិធីរបស់នគរបាលមានការប្រុងប្រយ័ត្នខ្ពស់ និងមានសុវត្ថិភាព។

## ការរក្សាព័ត៌មានសម្ងាត់ និងអនុវត្តតាមនីតិវិធីកុមារមេត្រី៖

- ប៉ុស្តិ៍នគរបាលដែលពួកគេដាក់ពាក្យបណ្ដឹង កុមារ និងឪពុក ត្រូវបានសម្ភាសន៍នៅក្នុងបន្ទប់ស្ងាត់ និងសម្ងាត់ ដោយមិនមានការរំខានអ្វីឡើយ។
- កុមារត្រូវបានប្រព្រឹត្តដោយសប្បុរស និងដោយការគោរពគ្រប់ពេលវេលា។
- មន្ត្រីនគរបាលបានប្រើភាសាសមរម្យ និងងាយយល់សម្រាប់កុមារយល់។
- មន្ត្រីនគរបាលបានផ្ដល់ព័ត៌មានត្រឹមត្រូវអំពីច្បាប់ និងដំណើរការច្បាប់
- មន្ត្រីនគរបាលបានផ្ដល់ព័ត៌មានពេញលេញអំពីសិទ្ធិរបស់ជនរងគ្រោះនិងសិទ្ធិរបស់អាណាព្យាបាល
- ឪពុកបានចូលរួមការសម្ភាសរបស់កូនស្រីគាត់ ជាមួយនឹងមន្ត្រីនគរបាល ដែលអាចឱ្យគាត់មានលទ្ធភាពផ្ដល់ការគាំទ្រ និងលើកទឹកចិត្តដល់កូនគាត់។
- មន្ត្រីនគរបាលបានឆ្លើយតបទៅនឹងសំណួររបស់ពួកគាត់។
- មន្ត្រីនគរបាលបានផ្ដល់ព័ត៌មានពេញលេញទាក់ទងទៅនឹងកញ្ចប់សេវាកម្មដែលអាចស្វែងរកពីស្ថាប័នផ្សេង ( ឧ. មេធាវី អ្នកប្រឹក្សាយោបល់ និងបុគ្គលិកសង្គមកិច្ចជាដើម...។ )
- មន្ត្រីនគរបាលបានធ្វើការទំនាក់ទំនងជាប្រចាំជាមួយឪពុកដើម្បីផ្ដល់ព័ត៌មានបច្ចុប្បន្នភាពនិងដំណើរនៃករណី។

## ជួបប្រជុំជាមួយមេធាវី និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល៖

- លោកស្រីមេធាវី ពីអង្គការមិនមែនរដ្ឋាភិបាល មានការគាំទ្រ លើកទឹកចិត្ត និងងាយស្រួលសម្រាប់នាងជាក្មេងស្រីជជែកពិភាក្សា ដោយសារតែជាស្រីដូចគ្នា។
- កុមារក៏មានសិទ្ធិទទួលបានសេវាគាំទ្រ បុគ្គលិកសង្គមកិច្ច/អ្នកប្រឹក្សាយោបល់ ដែលគាំទ្រ និងតស៊ូមតិសម្រាប់នាងក្នុងការបន្តចូលរួមនីតិវិធី។

## ជួបជាមួយចៅក្រមស៊ើបសួរ៖

- ស្រី លីន បានរៀបរាប់ថា "នៅពេលខ្ញុំជួបចៅក្រមស៊ើបសួរ គ្មានអ្វីត្រូវពន្យល់ទៀតទេ ព្រោះគាត់មានឯកសាររបស់ខ្ញុំរួចហើយ ដូច្នេះគាត់មានសំណួរដែលគាត់សួរ ហើយអានអ្វីដែលជនសង្ស័យនិយាយ ហើយគាត់សួរសំណួរដើម្បីបញ្ជាក់ថាតើវាយ៉ាងម៉េច។ តើជាការពិតឬមិនមែនជាការពិត។ ពេលនោះមិនមានអ្វីពិបាកទេ ហើយក៏មិនសូវមានមនុស្សច្រើនដែរ ពេលដែលយើងជួបនោះមានតែខាងគាត់ និងយើង»។

## នីតិវិធីក្នុងពេលសវនាការ៖

- «តុលាការដែលមិនអនុញ្ញាតឱ្យពួកគេចូលមើលសវនាការទេ សម្រាប់ខ្លួនខ្ញុំផ្ទាល់ មានបន្ទប់មួយនៅខាងក្រៅ និងអាចអង្គុយរង់ចាំស្ដាប់។ នៅពេលដែលពួកគេត្រូវការសេចក្ដីថ្លែងការណ៍របស់ខ្ញុំ ខ្ញុំបានចូលទៅ ហើយពួកគេបានដាក់អេក្រង់នៅពីមុខខ្ញុំ ដើម្បីកុំឱ្យនរណាម្នាក់ឃើញមុខរបស់ខ្ញុំ។ ដូច្នេះវាពិតជាងាយស្រួលសម្រាប់ខ្ញុំ"។

**ជោគជ័យក្នុងសំណុំរឿង៖**

- ជនសង្ស័យត្រូវបានចោទប្រកាន់តាមមាត្រា៤១"រូបភាពអាសអាភាសកុមារ"នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា២៣២ "ការគំរាមកំហែងដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ" នៃក្រមព្រហ្មទណ្ឌ។
- ជនសង្ស័យត្រូវបានតុលាការផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេលបីឆ្នាំ។
- ស្រីលីនបានទទួលបានសេវាគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលផ្នែកផ្លូវច្បាប់ ប្រឹក្សាយោបល់ផ្លូវចិត្ត និងការគាំទ្រជាបន្តបន្ទាប់ពីឪពុកម្ដាយរបស់នាង។
- ពួកគេបានយល់ព្រមចូលរួមក្នុងការស្រាវជ្រាវ ពីព្រោះពួកគេចង់ឱ្យមនុស្សផ្សេងទៀតស្វែងយល់អំពីបទពិសោធន៍របស់ពួកគេ ដើម្បីជួយនគរបាល និងអ្នកផ្ដល់សេវាផ្សេងទៀតថា តើវាមានសារៈសំខាន់យ៉ាងណាក្នុងការគាំទ្រកុមារ។

# សំណួរសម្រាប់ពិភាក្សាជាមួយសិក្ខាកាម

តើអ្វីជាចំណុចសំខាន់ និងចំណុចដែលអាចរៀនសូត្របានពីករណីសិក្សាខាងលើនេះ ដែលនឹងអនុវត្តក្នុងការងារប្រចាំថ្ងៃរបស់អ្នក។

សូមចែករំលែកបទពិសោធន៍របស់អ្នក នូវអ្វីដែលអ្នកគិតថា ធ្លាប់ជួប និងអនុវត្តន៍ប្រហាក់ប្រហែលករណីសិក្សាខាងលើ និងចំណុចវិជ្ជមានក្នុងការគាំទ្រកុមារ គ្រួសារ ដែលរងផលប៉ះពាល់ដោយអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ។

# ឧបសម្ព័ន្ធ “ឆ២”៖ តម្រូវការកុមារពីអ្នកអនុវត្តច្បាប់

ឯកសារនេះ សង្ខេបនូវសារៈសំខាន់ៗជាច្រើនពីកុមារ និងយុវជនដែលរងផលប៉ះពាល់ពីអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទទាំងក្នុងនិងក្រៅប្រព័ន្ធអនឡាញ (CSEA&OCSEA) នៅពេលដែលពួកគេត្រូវបានគេសាកសួរអំពីអ្វីដែលពួកគេត្រូវការពីមន្ត្រីនគរបាល មន្ត្រីផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ អ្នកផ្តល់សេវា និងអ្នកគាំទ្រផ្សេងៗ។ ប្រសិនបើយើងប្តេជ្ញាចិត្តយ៉ាងពិតប្រាកដ ក្នុងការគាំពារសិទ្ធិរបស់កុមារ និងឆ្លើយតបតាមបែបកុមារមេត្រី យើងអាចចាប់ផ្តើមដោយសិក្សាពាក្យសម្តី និងគំនិតរបស់ពួកគេ និងគិតអំពីរបៀបដែលយើងអាចអនុវត្តនៅក្នុងការងារប្រចាំថ្ងៃរបស់យើង។ ប្រសិនបើយើងអាចបញ្ចូលគំនិតទាំងនេះ និងធ្វើឱ្យវាជាផ្នែកប្រចាំថ្ងៃ និងទូទៅនៃការអនុវត្តរបស់យើង វាមានអត្ថប្រយោជន៍ជាច្រើន៖

- កុមារនឹងមានអារម្មណ៍ថា មានសុវត្ថិភាព និងទុកចិត្តអ្នកកាន់តែច្រើន ហើយមានទំនុកចិត្តកាន់តែច្រើន និងអាចសហការយ៉ាងជិតស្និទ្ធជាមួយអ្នក។
- វានឹងធ្វើឱ្យដំណើរការកាន់តែរលូន និងបង្កើនលទ្ធភាពដែលជាលទ្ធផលជោគជ័យសម្រាប់អ្នកក្នុងនាមជាមន្ត្រីនគរបាល។
- របៀបដែលអ្នក និងមនុស្សផ្សេងទៀតមានឥរិយាបថ អាចមានឥទ្ធិពលវិជ្ជមានលើរបៀបដែលពួកគេព្យាបាលពីបទពិសោធន៍នៃការរងគ្រោះរបស់ពួកគេ

## តើកុមារ និងយុវជននិយាយថា ពួកគេត្រូវការអ្វីខ្លះពីអ្នកអនុវត្តច្បាប់ អ្នកផ្តល់សេវា គ្រួសារ និងអ្នកគាំទ្រផ្សេងទៀតដើម្បីចូលរួម?

- ស្តាប់ខ្ញុំ
- ជឿខ្ញុំ
- ទទួលយកខ្ញុំ
- មិនវិនិច្ឆ័យ ឬបន្ទោស
- ជម្រើសភេទស្រី-ប្រុស ដើម្បីសម្ភាសន៍ខ្ញុំ
- មានសំឡេងផ្សេងៗដែលប៉ះពាល់ដល់ខ្ញុំ
- ជួយនៅពេលជួបបញ្ហា
- មនុស្សទន់ភ្លន់ និងអត់ធ្មត់ដែលផ្តល់ជំនួយដល់ខ្ញុំ
- មានសុវត្ថិភាព ផ្តល់ក្តីស្រលាញ់
- ព័ត៌មានត្រឹមត្រូវអំពីសេវា និងសុវត្ថិភាពអ៊ីនធឺណិត
- ទទួលបានការការពារ
- មានជម្រើស និងផ្តល់អំណាច
- ទទួលបានការលើកទឹកចិត្ត
- ទំនាក់ទំនងដែលគួរឱ្យទុកចិត្ត
- យល់ចិត្ត
- រក្សាការសម្ងាត់
- ទីកន្លែងឯកជន និងស្ងៀមស្ងាត់ សម្រាប់កិច្ចសម្ភាស
- គោរពសិទ្ធិរបស់ខ្ញុំ


ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

# ឧបសម្ព័ន្ធ “ជ” ៖

## ករណីសិក្សា

– សំនួរសម្រាប់ការងារជាក្រុម

# ករណីសិក្សា–សំនួរសម្រាប់ការងារជាក្រុម

## គោលការណ៍ណែនាំ និងសំនួរសម្រាប់ករណីសិក្សា៖

ដោយផ្អែកលើព័ត៌មាន ដែលបានរួមបញ្ចូលនៅក្នុងករណីសិក្សា សូមពិចារណា និងឆ្លើយតបសំនួរនីមួយៗខាងក្រោមក្នុងក្រុមរបស់អ្នក។

សូមអានករណីសិក្សាជាមួយគ្នា មុនពេលឆ្លើយសំនួរណាមួយនៅលើសន្លឹកនេះ។ អានសំនួរនីមួយៗ មុនពេលអ្នកចាប់ផ្ដើមឆ្លើយ ដូច្នេះអ្នកយល់ច្បាស់ពីកិច្ចការមុនពេលអ្នកចាប់ផ្ដើម។

អ្នកត្រូវធ្វើការជាក្រុមដើម្បីឆ្លើយតបទៅនឹងសំនួរនីមួយៗ។ អ្នកត្រូវរៀបចំផែនការដើម្បីធ្វើឱ្យប្រាកដថា កុមារនៅក្នុងករណីសិក្សា ត្រូវបានឆ្លើយតបយ៉ាងសមរម្យ យោងទៅតាមព័ត៌មានលម្អិតនៃករណីសិក្សានីមួយៗ។

អ្នកនឹងត្រូវប្រាកដថា អ្នកធ្វើផែនការអនុលោមតាមគោលការណ៍កុមារមេត្រី និងគោរពសិទ្ធិកុមារ។ សូមប្រើសន្លឹកកិច្ចការ ដើម្បីជួយអ្នកណែនាំការពិភាក្សារបស់អ្នក ហើយរៀបចំចម្លើយ និងបទបង្ហាញរបស់អ្នកទៅកាន់ក្រុមធំ។ (អ្នកអាចប្រើក្រដាសផ្ទាំងធំ (Flip Chart) ដើម្បីរៀបចំធ្វើបទបង្ហាញ)។[1]

សូមចាំថា មានជំហានជាច្រើនក្នុងការស៊ើបអង្កេត និងកិច្ចការផ្សេងៗជាច្រើនដែលត្រូវធ្វើ ដើម្បីទទួលបានជោគជ័យនៅក្នុងករណីសិក្សានេះ។

១. **កំណត់ថាតើមានសមាសធាតុតាមប្រព័ន្ធអនឡាញតែប៉ុណ្ណោះចំពោះឧក្រិដ្ឋកម្មនេះ ឬមានទាំងក្នុងប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ។** សូមសរសេរសកម្មភាព ឥរិយាបថ ឬសមាសធាតុនៃបទល្មើសនីមួយៗទាំងតាមប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ។ សូមសរសេរចម្លើយរបស់អ្នកនៅក្នុងប្រអប់ខាងក្រោម)

| សមាសធាតុតាមប្រព័ន្ធអនឡាញ | សមាសធាតុក្រៅប្រព័ន្ធអនឡាញ (ប្រសិនបើមាន) |
| --- | --- |
| | |

1. ប្រសិនបើអ្នកមានធនធានគ្រប់គ្រាន់ ហើយអ្នកចូលរួមមានសមត្ថភាពដើម្បីធ្វើដូច្នេះ អ្នកអាចប្រើសន្លឹកកិច្ចការនេះ ឬបង្កើត ផ្ទាំងស្លាយទទេសម្រាប់អ្នកចូលរួមប្រើប្រាស់ និងបង្កើតបទបង្ហាញមួយ។



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

## ២. បើយោងតាមច្បាប់ប្រទេសកម្ពុជាបច្ចុប្បន្ន តើមានមាត្រាច្បាប់ណាខ្លះដែលអាចយកមកប្រើប្រាស់បាន ពាក់ព័ន្ធក្នុងករណីនេះ ?

សូមចាំថា ត្រូវគិតអំពីច្បាប់ពាក់ព័ន្ធទាំងអស់ទាំងក្នុងប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញ។ សម្រាប់សកម្មភាពទាំងនៅលើអ៊ីនធឺណិត និងក្រៅអ៊ីនធឺណិត។ (សូមសរសេរចម្លើយរបស់អ្នកនៅក្នុងប្រអប់ខាងក្រោម)

ប្រសិនបើចាំបាច់ សូមបើកឯកសារ OCSEA និងច្បាប់ ដើម្បីជួយអ្នកឆ្លើយសំនួរ។

| មាត្រាច្បាប់ទាក់ទងនឹងប្រព័ន្ធអនឡាញ៖ | មាត្រាច្បាប់ទាក់ទងក្រៅប្រព័ន្ធអនឡាញ |
| --- | --- |
| | |

## ៣. តើអ្នកមានកង្វល់អ្វីខ្លះទាក់ទងនឹងករណីនេះ ?

មានព័ត៌មាន និងតម្រុយនៅក្នុងករណីសិក្សានីមួយៗដែលទាក់ទងនឹងកង្វល់នានាសម្រាប់កុមារដែលពាក់ព័ន្ធ ដូច្នេះសូមអានករណីសិក្សាដោយយកចិត្តទុកដាក់។

(កង្វល់នានាអាចទាក់ទងនឹងសុវត្ថិភាព ឬសុខភាពរបស់កុមារ របៀបដែលអ្នកដទៃទៀតប្រព្រឹត្តចំពោះកុមារ ការភ័យខ្លាចនគរបាល ហានិភ័យទាក់ទងនឹងជនល្មើស ការរើសអើងដែលពួកគេអាចជួបប្រទះ ពិការភាពណាមួយ ឬតម្រូវការពិសេសដែលកុមារអាចមាន តម្រូវការសម្រាប់មន្ត្រីស្រី/ប្រុសជាអ្នកសម្ភាស ឬបញ្ហាផ្សេងទៀត)។

ដោយផ្អែកលើគំនិតរបស់អ្នក តើអ្នកគួរធ្វើអ្វីដើម្បីឆ្លើយតបឱ្យបានត្រឹមត្រូវ ដើម្បីដោះស្រាយកង្វល់របស់អ្នក? (សូមកត់ត្រាចម្លើយរបស់អ្នកដោយប្រើប្រអប់ខាងក្រោម)

| កង្វល់ | ការឆ្លើយតបដែលសមរម្យ |
| --- | --- |
| | |



ឧបត្ថម្ភដោយ End Violence Against Children unicef for every child

## ៤. នីតិវិធីកុមារមេត្រី និងសិទ្ធិកុមារ៖

ផ្អែកលើព័ត៌មាននៅក្នុងករណីសិក្សា តើអ្នកត្រូវធ្វើ ឬជាក់អ្វីខ្លះ ដើម្បីធានាថាសិទ្ធិរបស់កុមារត្រូវបានគោរព និងការពារ ហើយនីតិវិធីកុមារមេត្រីអ្វីខ្លះ ដែលត្រូវអនុវត្ត?
(ប្រសិនបើអ្នកត្រូវការជំនួយដើម្បីរំលឹក សម្រាប់ការងារក្រុមរបស់អ្នក សូមប្រើឯកសារស្តីពី សិទ្ធិកុមារ

| សិទ្ធិកុមារ | នីតិវិធីកុមារមេត្រី |
| --- | --- |
| | |

## ៥. ការធ្វើផែនការ៖

ដោយផ្អែកលើព័ត៌មាននៅក្នុងករណីសិក្សា សូមពណ៌នាអំពីផែនការរបស់អ្នកក្នុងការជួបជាមួយកុមារ និងអាណាព្យាបាលរបស់ពួកគេ ដើម្បីធ្វើសេចក្តីថ្លែងការណ៍ ដោយធានាថា កុមារត្រូវបានប្រព្រឹត្តដោយគិតគូរពីអារម្មណ៍របស់ពួកគេ និងដោយការគោរព យោងតាមគោលការណ៍ណែនាំបែបកុមារមេត្រី។ (ការទទួលពាក្យបណ្តឹង ការស៊ើបអង្កេតបឋម ការប្រមូលភស្តុតាងដំបូង)

សូមផ្តល់ព័ត៌មានលម្អិតអំពីរបៀបដែលអ្នកនឹងអនុវត្ត តើនរណាខ្លះ និងអង្គភាពណាខ្លះ ដែលអ្នកនឹងបញ្ចូលក្នុងផែនការរបស់អ្នក។ (សូមមើលឯកសារ8A៖ ជំហាននៃការស៊ើបអង្កេត) ប្រសិនបើអ្នកត្រូវការរំលឹកអំពីជំហាន។

| ចំណុចសកម្មភាព | តើអ្នកណាខ្លះត្រូវចូលរួម? |
| --- | --- |
| | |



ឧបត្ថម្ភដោយ
End Violence Against Children
unicef for every child

## ៦. ការប្រមូល និងធានាភស្តុតាង៖

យោងតាមករណីសិក្សា ច្បាប់ និងលក្ខណៈនៃឧក្រិដ្ឋកម្ម ឧបករណ៍អេឡិកត្រូនិក និងកម្មវិធីដែលប្រើ សូមពណ៌នាអំពីប្រភពភស្តុតាងដែលអាចមាន។

*សូមចំណាំថា តម្រូវឱ្យមានការបណ្ដុះបណ្ដាលបន្ថែមទាក់ទងនឹងការប្រមូល និងការរក្សាភស្តុតាងឌីជីថល ដែលបច្ចុប្បន្ននេះកំពុងស្ថិតក្រោមការពង្រាង)។

| ប្រភពភស្តុតាងឌីជីថល និងអនឡាញ | ប្រភពភស្តុតាងក្រៅប្រព័ន្ធអនឡាញ |
|---|---|
| ទូរស័ព្ទរបស់ជនរងគ្រោះរូបថតនិងរូបភាពឌីជីថល សារ និងការសន្ទនាតាមឆាត(Messenger ) | កំណត់ហេតុរបស់ជនរងគ្រោះ ព័ត៌មានរបស់អ្នករាយការណ៍ដំបូង(គ្រូ) ការបំភ្លឺរបស់សាក្សី ប្រសិនបើមានសមាសជាតុក្រៅបណ្ដាញអនឡាញ (ទល់មុខគ្នា) នៃឧក្រិដ្ឋកម្ម៖ ភស្តុតាងរូបវន្ត ប្រសិនបើឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងបទល្មើសផ្លូវភេទក្រៅប្រព័ន្ធអនឡាញ។ របាយការណ៍វេជ្ជសាស្ត្រប្រសិនបើ ឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងការចោទប្រកាន់លើការរំលោភបំពានផ្លូវភេទ ការបំពាន ឬរំលោភសេពសន្ថវៈ រូបថតនៃការរងរបួសលើរាងកាយ |

## ៧. ការស្ដាប់ចម្លើយ/ការសម្ភាសជនសង្ស័យ និងការប្រមូលភស្តុតាងបន្ថែម៖

ដោយសន្មតថាមានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញថាឧក្រិដ្ឋកម្មបានកើតឡើង អ្នកត្រូវបានតម្រូវឱ្យសម្ភាសន៍ជនល្មើសដើម្បីទទួលបាននូវភស្តុតាងឌីជីថលនិងរូបវន្តណាមួយនៅកន្លែងនោះសូមពណ៌នាអំពីផែនការរបស់អ្នក ដើម្បីសម្រេចកិច្ចការនេះនៅក្នុងប្រអប់ខាងក្រោម។

| ចំណុចសកម្មភាព | តើអ្នកណាខ្លះត្រូវចូលរួម? |
|---|---|
| | |


ឧបត្ថម្ភដោយ End Violence Against Children unicef for every child

## ៨. សកម្មភាពបន្ថែម៖

ដោយសន្មតថាអ្វីៗដំណើរការទៅតាមផែនការ ហើយអ្នកប្រមូលសេចក្ដីថ្លែងការណ៍ និងភស្តុតាងបាន សូមសង្ខេបជំហានបន្ទាប់ដោយសង្ខេប យោងទៅតាមជំហាននៃការស៊ើបអង្កេត។ (នេះអាចរួមបញ្ចូលការរៀបចំរបាយការណ៍ កញ្ចប់ភស្តុតាង។ល។)

សូមចំណាំថា ក្នុងករណីខ្លះ វាក៏អាចរួមបញ្ចូលការបញ្ជូនសំណុំរឿងទៅកាន់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យាផងដែរ ប្រសិនបើអ្នកត្រូវការការពិនិត្យកោសល្យវិច្ច័យកម្រិតខ្ពស់បន្ថែមទៀតនៃឧបករណ៍ឌីជីថល ឬជំនួយផ្សេងទៀត។ សូមសង្ខេបនូវអ្វីដែលអ្នកនឹងធ្វើ និងដំណើរការដែលអ្នកនឹងអនុវត្តតាម។

| ចំណុចសកម្មភាព | តើអ្នកណាខ្លះត្រូវចូលរួម? |
|---|---|
| | |

# ឧបសម្ព័ន្ធ "ឈ" ៖

# ការដោះស្រាយបញ្ហាប្រឈមទូទៅ

## *នៅក្នុងករណី OCSEA សម្រាប់កុមារ និងគ្រួសារ*



ឧបត្ថម្ភដោយ

# ការដោះស្រាយបញ្ហាប្រឈមទូទៅនៅក្នុងករណី (OCSEA) សម្រាប់កុមារ និងគ្រួសារ

១. កុមារនិយាយថា ពួកគេមិនមានបំណងចង់ផ្តល់ចំលើយដល់នគរបាល ដោយសារតែការភ័យខ្លាចជនល្មើស និង/ឬជនល្មើសគឺជាមនុស្សដែលពួកគេស្គាល់ច្បាស់។ ពួកគេព្រួយបារម្ភអំពីអ្វីដែលនឹងកើតឡើង។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

២. កុមារមិនយល់អ្វីដែលបានកើតឡើងចំពោះពួកគេ គឺជាការខុសនោះទេ៖

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

៣. កុមាររងគ្រោះគិតថា ត្រូវបានគេស្តីបន្ទោសឱ្យពួកគេ ចំពោះអ្វីដែលបានកើតឡើង។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

៤. កុមារមើលទៅភ័យខ្លាចខ្លាំងណាស់ នៅពេលដែលអ្នកជួបពួកគេ។ អាណាព្យាបាល និង/ឬបុគ្គលិកសុខុមាលភាពកុមារពន្យល់ថា កុមារភ័យខ្លាចនគរបាលខ្លាំងណាស់។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

៥. កុមារដែលជាជនរងគ្រោះនៃ OCSEA ប៉ុន្តែពួកគេគិតថាពួកគេបានចូលរួមប្រព្រឹត្តបទឧក្រិដ្ឋ ហើយមានការភ័យខ្លាចយ៉ាងខ្លាំងថា ពួកគេនឹងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ហើយអាចជាប់ពន្ធនាគារ។ ដូច្នេះគេមិនព្រមនិយាយ ជាមួយអ្នកទេ។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

៦. កុមារមានអារម្មណ៍អាម៉ាស់ខ្លាំង ហើយយំសោក។ ពួកគេមិនចង់និយាយជាមួយនរណាម្នាក់អំពីអ្វីដែលបានកើតឡើងចំពោះពួកគេទេ។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

៧. កុមារអាយុ១៦ឆ្នាំម្នាក់ គឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្ម ហើយមានការខូចនិងខឹងសម្បារយ៉ាងខ្លាំងចំពោះអ្វីដែលបានកើតឡើងប៉ុន្តែពួកគេមិនចង់ឱ្យឪពុកម្តាយរបស់ខ្លួនដឹងអំពីរឿងនេះទេ ដូច្នេះពួកគេមិនចង់ធ្វើការរាយការណ៍ជាផ្លូវការទៅអង្គភាពណាទេ។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

៨. ក្មេងពិបាកនិយាយរឿងផ្លូវភេទជាមួយនគរបាលប្រុស ព្រោះជនល្មើសក៏ជាប្រុសដែរ។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

៩. កុមារពិបាកនិយាយរឿងពាក់ព័ន្ធផ្លូវភេទណាស់។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

១០. កុមារមានការភ័យខ្លាចយ៉ាងខ្លាំង-ពួកគេនិយាយត្រដិតរកពាក្យនិយាយមិនចេញ។ (នេះក៏អាចបង្ហាញពីពិការភាពដែលអាចកើតមានដែរទេ ? )

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

១១. ឪពុកម្តាយ និង/ឬកុមារមិនយល់ពីច្បាប់ ឬដំណើរការច្បាប់ទេ។ ពួកគេទំនងជាមិនសហការទេ លុះត្រាតែពួកគេអាចយល់កាន់តែច្បាស់។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

១២. អ្នកសង្កេតឃើញសហសេវិកម្នាក់រើសអើងដល់យុវជន ហើយបន្ទោសពួកគេចំពោះអ្វីដែលបានកើតឡើង ដោយសារតែពួកគេជា LGBTQI។ ពួកគេប្រាប់យុវជនថា ប្រសិនបើពួកគេ «ធម្មតា» ដូចគេឯង នោះពួកគេមិនជួបរឿងបែបនេះទេ។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

១៣. អ្នកសង្កេតឃើញសហការីរបស់អ្នក ... ម្នាក់រើសអើងលើជនរងគ្រោះជាកុមារ ហើយបន្ទោសពួកគេចំពោះអ្វីដែលបានកើតឡើង។ ពួកគេប្រាប់កុមារថា ប្រសិនបើពួកគេមិនបានចំណាយពេលច្រើននៅលើទូរស័ព្ទទេ រឿងនេះនឹងមិនកើតឡើងនោះទេ។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

១៤. អ្នកសង្កេតឃើញឪពុកម្តាយរបស់កុមារ ហើយពួកគេខឹងខ្លាំងណាស់ចំពោះពួកគេដែលបានធ្វើបាបកុមារ ហើយបន្ទោសកុមារសម្រាប់អ្វីដែលបានកើតឡើង។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

១៥. កុមារឃ្លាន និង/ឬមានតម្រូវការមូលដ្ឋាន និង/ឬតម្រូវការផ្នែកវេជ្ជសាស្ត្រដែលត្រូវការការយកចិត្តទុកដាក់។ អ្នកចង់ធ្វើការសម្ភាស ដើម្បីអ្នកអាចទៅផ្ទះបាន។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

១៦. កុមារនឿយហត់ ប៉ះទង្គិច និងប៉ះពាល់ផ្លូវចិត្ត ពួកគេគេងមិនលក់ ហើយពួកគេមិនអាចផ្តង់អារម្មណ៍និយាយបាន។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?

១៧. កុមារមានពិការភាពខាងសតិបញ្ញា/ការអភិវឌ្ឍ ហើយពិបាកទំនាក់ទំនងបានច្បាស់។ តើអ្នកគួរឆ្លើយតបបែបណា?

- **តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?**
- **តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?**

១៨. កុមារមានបញ្ហាការស្តាប់ហើយមិនអាចយល់ពីអ្វីដែលអ្នកកំពុងនិយាយឬទំនាក់ទំនង។

- **តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?**
- **តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?**

១៩. អ្នកផ្សេងទៀត(ឪពុកម្តាយ មិត្តភក្តិ) បានប្រាប់កុមារថា អ្វីដែលបានកើតឡើងមិនធ្ងន់ធ្ងរទេ ហើយពួកគេមិនគួរខ្វះខ្វាយពេលរាយការណ៍ទៅដោយសារនគរបាលពុករលួយ និងមិនចាប់អារម្មណ៍ជួយអ្នកទេ។

- **តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?**
- **តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?**

២០. កុមាររស់នៅតាមដងផ្លូវ ហើយហិតកាវ និងកំពុង «បែកថ្នាំ» នៅពេលអ្នកជួបគាត់។

- **តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?**
- **តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?**

២១. កុមារហាក់ដូចជាមានបញ្ហាសុខភាពផ្លូវចិត្តមួយចំនួន ហើយមានការភ័ន្តច្រឡំខ្លាំង ហើយមើលទៅហាក់ដូចជាខ្លាចអ្នកខ្លាំងណាស់។

- **តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?**
- **តើអ្នកគួរធ្វើអ្វី ហើយនិយាយអ្វី?**

២២. កុមារមានអាយុ ១៥ឆ្នាំ ហើយប្រាប់អ្នកថា ពួកគេបានយល់ព្រមចំពោះការកេងប្រវ័ញ្ចនេះ ដែលត្រូវបានរៀបចំដោយភាគីទីបីតាមរយៈកម្មវិធីទូរស័ព្ទ WhatsApp។

- **តើបញ្ហាផ្លូវច្បាប់ និងបញ្ហាអ្វីខ្លះក្នុងករណីនេះដែលត្រូវពិចារណា? តើអ្នកគួរឆ្លើយតបបែបណា?**

២៣. បុគ្គលិកសង្គមកិច្ចដែលនៅជាមួយយុវជនប្រាប់អ្នកថា យុវជននោះកំណត់អត្តសញ្ញាណថាជា LGBTQI ហើយពួកគេបានជួបប្រទះការរើសអើងជាច្រើនពីមនុស្សក្នុងសហគមន៍ពីមុនមក រួមទាំងមន្ត្រីនគរបាល។ ពួកគេ រំពឹងថា ដូចគ្នានឹងកើតឡើងជាមួយ AHTJP ដូច្នេះពួកគេមិនមានអារម្មណ៍ជឿជាក់ក្នុងការធ្វើសេចក្តីបំភ្លឺទេ។

» **តើអ្នកគួរធ្វើអ្វី និងនិយាយអ្វី ដើម្បីធានាថាពួកគេអាចប្រើសិទ្ធិរបស់ពួកគេ?**

២៤. អ្នកផ្សេងទៀត (ឪពុកម្តាយ មិត្តភក្តិ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ឬនគរបាល) បានប្រាប់កុមារថា អ្វីដែលបានកើតឡើងគឺមិនធ្ងន់ធ្ងរទេ ព្រោះវាគ្រាន់តែនៅក្នុងប្រព័ន្ធអនឡាញហើយដូចជាមិនមានការប៉ះពាល់អ្វីឡើយ។ ពួកគេប្រាប់បុគ្គលនោះថា ពួកគេមិនគួរខ្វះខ្វាយពេលវេលារាយការណ៍អំពីឧក្រិដ្ឋកម្មនោះទេ។

» **តើបញ្ហាផ្លូវច្បាប់ និងបញ្ហាអ្វីខ្លះក្នុងករណីនេះដែលត្រូវពិចារណា? តើអ្នកគួរឆ្លើយតបបែបណា?**

# បញ្ហាប្រឈមរបស់មន្ត្រីនគរបាល និងនីតិវិធី

២៥. អ្នកចង់ធ្វើការសម្ភាស តែមិនអាចរកបានបុគ្គលិកសង្គមកិច្ច ឬអាណាព្យាបាលណាចូលរួមបាន ត្រូវចាំរហូតដល់ពេលក្រោយ។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី?

២៦. សហការីរបស់អ្នកដែលគ្រោងនឹងធ្វើបទសម្ភាស ហើយមិនសូវមានជំនាញ «កុមារមេត្រី»។ អ្នកព្រួយបារម្ភថា ពួកគេនឹងមិនធ្វើការបានល្អ។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី?

២៧. សហសេវិករបស់អ្នកដែលនឹងធ្វើបទសម្ភាសអស់កម្លាំង និងតានតឹងខ្លាំង។ អ្នកមានការព្រួយបារម្ភថា ពួកគេមិនមែនជាមនុស្សដែលល្អក្នុងការធ្វើបទសម្ភាសបឋមជាមួយកុមារនោះទេ។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី?

២៨. សហសេវិករបស់អ្នកបានទាញយករូបភាពមួយចំនួននៃ OCSEA ដាក់ក្នុងទូរស័ព្ទផ្ទាល់ខ្លួនរបស់គាត់ ហើយចែករំលែកនៅក្នុងក្រុម Telegram។

- តើស្ថានភាពនេះមានបញ្ហាអ្វី?
- តើអ្នកគួរធ្វើអ្វី?

២៩. ឯកសណ្ឋាននគរបាល ធ្វើឱ្យកុមារមានអារម្មណ៍មិនស្រួល និងភ័យខ្លាច។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី?

៣០. ក្មេងពិបាកនិយាយជាមួយមន្ត្រីប្រុស។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី?

៣១. បន្ទប់ដែលអ្នកចង់ធ្វើការសម្ភាស គឺមិនឯកជនទេ ហើយកុមារអាចត្រូវបានគេមើលឃើញ អ្នកដទៃផ្សេងទៀតអាចស្តាប់ឮ។

- **តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?**
- **តើអ្នកគួរធ្វើអ្វី?**

៣២. សហការីរបស់អ្នកដែលនឹងធ្វើបទសម្ភាស គឺអស់កម្លាំង និងតានតឹងខ្លាំង។

- **តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?**
- **តើអ្នកគួរធ្វើអ្វី?**

៣៣. មន្ត្រីផ្សេងទៀតដើរកាត់បន្ទប់ដែលអ្នកកំពុងសម្ភាសន៍កុមារ ហើយពេលខ្លះពួកគេចូលមកស្តាប់។ អ្នកសង្កេតឃើញថា គាត់មិនមានផាសុកភាព និងខ្មាសអៀន។

- **តើស្ថានភាពនេះមានបញ្ហាអ្វី?**
- **តើអ្នកគួរធ្វើអ្វី?**

៣៤. អ្នកកំពុងពិភាក្សាករណីមួយជាមួយក្មេងប្រុសដែលត្រូវបានគេរំលោភបំពាន។ សហសេវិកពីរនាក់បានស្តាប់ឮអំពីការសន្ទនា ហើយសើចចំអកដាក់កុមារនោះ និងនិយាយចំអន់ផ្សេងៗ។

- **តើស្ថានភាពនេះមានបញ្ហាអ្វី?**
- **តើអ្នកគួរធ្វើអ្វី?**

៣៥. អ្នកឮសហសេវិកនិយាយអំពីករណី OCSEA និងកុមារដែលគាត់នឹងសម្ភាសន៍។ គាត់និយាយថា វាមិនធ្ងន់ធ្ងរទេ ព្រោះជាក្មេងប្រុសម្នាក់ដែលស្រលាញ់ភេទដូចគ្នា ហើយគាត់ប្រហែលជាចង់ឱ្យវាកើតឡើងអញ្ចឹងដែរ។

- **តើស្ថានភាពនេះមានបញ្ហាអ្វី?**
- **តើអ្នកគួរធ្វើអ្វី?**

៣៦. អ្នកឮសហសេវិកនិយាយអំពីករណី OCSEA និងកុមារដែលគាត់នឹងសម្ភាសន៍។ គាត់និយាយថា វាមិនធ្ងន់ធ្ងរទេ ព្រោះជនរងគ្រោះជាក្មេងប្រុស ហើយជនល្មើសជាស្ត្រី។ ពួកគេនិយាយថា ក្មេងប្រុសនេះ «សំណាង» ដែលគាត់អាចទទួលបានបទពិសោធនេះ ហើយសើច។

- **តើស្ថានភាពនេះមានបញ្ហាអ្វី?**
- **តើអ្នកគួរធ្វើអ្វី?**

៣៧. អ្នកឮសហសេវិកនិយាយជាមួយឪពុកម្តាយរបស់កុមារទាក់ទងនឹងករណី OCSEA ហើយពួកគេប្រាប់ឪពុកម្តាយថា "ហេតុផលតែមួយគត់ដែលអ្នកនៅទីនេះគឺដោយសារតែអង្គការឱ្យមកប៉ុណ្ណោះ!"

- **តើស្ថានភាពនេះមានបញ្ហាអ្វី?**
- **តើអ្នកគួរធ្វើអ្វី?**

៣៨. កុមារ និងអាណាព្យាបាលរបស់គាត់ កំពុងរង់ចាំទទួលការសម្ភាស។ សហការីរបស់អ្នកបានសុំឱ្យអ្នកធ្វើអ្វីមួយសម្រាប់ពួកគេ។ ការធ្វើកិច្ចការនោះមានន័យថា កុមារអាចត្រូវរង់ចាំពីរម៉ោងទៀត។

- **តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?**
- **តើអ្នកគួរធ្វើអ្វី?**

៣៩. កុមារដែលអ្នកត្រូវសម្ភាសមានពិការភាពផ្នែកបញ្ញា និងការលំបាកក្នុងការទំនាក់ទំនង។

- **តើអ្នកមានកង្វល់អ្វីខ្លះ ហើយតើអ្នកគួរបន្តដោយរបៀបណា?**

៤០. កុមារដែលត្រូវបានរំលោភបំពានតាមប្រព័ន្ធអនឡាញ ថ្លង់ ហើយត្រូវការអ្នកបកប្រែភាសាសញ្ញា ដើម្បីទំនាក់ទំនងបានច្បាស់។

- **តើអ្នកមានកង្វល់អ្វីខ្លះ ហើយតើអ្នកគួរបន្តដោយរបៀបណា?**

៤១. ការសម្ងាត់នៃសម្ភារៈ និងភស្តុតាងទាំងអស់ (ដាក់ស្តែង និងឌីជីថល) គឺមានសារៈសំខាន់ខ្លាំងណាស់។

- **តើអ្នកធានាថាទិន្នន័យ សម្ភារៈ និងភស្តុតាងទាំងអស់មានសុវត្ថិភាព និង សម្ងាត់បានដោយរបៀបណា?**

៤២. ដាក់ស្តែងនៅក្នុងករណី OCSEA នគរបាលត្រូវរាយការណ៍ទៅថ្នាក់គ្រប់គ្រងពីមួយទៅមួយទៀត និងអាចផ្ញើរូបអាសអាភាសកុមារ ឬតំណភ្ជាប់នៃរូបភាពទាំងនេះ។

- **តើអ្នកជៀសវាងការចែកចាយរូបភាពអាសអាភាសកុមារដោយរបៀបណា**
- **តើអ្នកគ្រប់គ្រងភស្តុតាងឌីជីថលដោយរបៀបណា?**

# បញ្ហាប្រឈមទាក់ទងនឹងបទល្មើសជាក់លាក់ ច្បាប់ និង/ឬបញ្ហាបច្ចេកវិទ្យាឌីជីថល

៤៣. ជនរងគ្រោះមិនស្គាល់អត្តសញ្ញាណជនសង្ស័យទេព្រោះគាត់ប្រើអត្តសញ្ញាណ និងគណនីហ្វេសប៊ុកក្លែងក្លាយ។ កុមារពិបាកចិត្តខ្លាំងណាស់។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយទៅកុមារបែបណា?

៤៤. ជនល្មើសបានប្រព្រឹត្តបទល្មើសយ៉ាងធ្ងន់ធ្ងរលើកុមារ ហើយភស្តុតាងទាំងអស់បានបង្ហាញថា ពួកគេអាចនឹងរស់នៅក្រៅប្រទេសកម្ពុជា។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី ហើយនិយាយទៅកុមារបែបណា?
- តើអ្នកគួរចាត់វិធានការអ្វីទៀត?

៤៥. កុមារ និងឪពុកម្ដាយរបស់ពួកគេ ប្ដឹងអំពីអាកប្បកិរិយាតាមប្រព័ន្ធអនឡាញ ដែលតាមលក្ខណៈបច្ចេកទេសគឺមិនទាន់ជាឧក្រិដ្ឋកម្មនៅក្នុងប្រទេសកម្ពុជា។ កុមារពិបាកចិត្តណាស់ ដោយគ្រាន់តែប្រាប់គេថាគ្មានអ្វីដែលអ្នក អាចធ្វើបានទេ ព្រោះវាមិនខុសច្បាប់ ហើយក៏គ្មានប្រយោជន៍ដែរ។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី និងនិយាយទៅកាន់កុមារ និងឪពុកម្ដាយអ្វីខ្លះ?
- តើព័ត៌មានបន្ថែមអ្វីខ្លះដែលអ្នកអាចផ្ដល់ឱ្យពួកគេ ដែលអាចមានប្រយោជន៍?

៤៦. អ្នកជួបករណីដែលឪពុកម្ដាយចង់ប្ដឹង ប៉ុន្តែកូន ឬយុវជនមិនព្រម។ (ខ. កុមារបានចែកចាយរូបភាពអាក្រាតជាមួយមិត្តប្រុស មិត្តស្រីរបស់ពួកគេ ដោយការយល់ព្រម។តាមបច្ចេកទេសមិនមានឧក្រិដ្ឋកម្មណាមួយត្រូវបានប្រព្រឹត្តទេ។ ឪពុកម្ដាយខឹងខ្លាំងណាស់។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកគួរធ្វើអ្វី និងនិយាយទៅកាន់ឪពុកម្ដាយ (ក) និង ទៅយុវជន (ខ) ហើយអ្នកត្រូវចាំថារក្សាសិទ្ធិរបស់ពួកគេ?

៤៧. អ្នកកំពុងធ្វើការលើករណីដែលអ្នកសង្ស័យថា មានរូបភាព CSAM នៅក្នុងឧបករណ៍អេឡិកត្រូនិក ប៉ុន្តែអ្នកមិនមានជំនាញបច្ចេកទេសឌីជីថល ដើម្បីស្វែងរកបានទេ។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើអ្នកត្រូវការធ្វើអ្វី?
- ចូរពន្យល់ពីជំហានដែលអ្នកត្រូវធ្វើតាម

៤៨. ក្រឡេកមើលអង្គហេតុនៃករណីនេះ បទល្មើសហាក់ដូចជាបានប្រព្រឹត្ត ប៉ុន្តែយុវជននោះមានអាយុលើស ១៨ឆ្នាំ។

- តើបញ្ហាសំខាន់អ្វីខ្លះដែលអ្នកត្រូវពិចារណា?
- តើការពិតអ្វីខ្លះដែលអ្នកត្រូវយកមកពិចារណា?
- តើអ្នកគួរធ្វើអ្វី?

កំណត់ត្រាផ្សេងៗ

**អគ្គស្នងការដ្ឋាននគរបាលជាតិ**
មហាវិថី ព្រះនរោត្តម,សង្កាត់ ទន្លេបាសាក់, ខណ្ឌ ចំការមន, រាជធានី ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
អ៊ីម៉ែល: info@police.gov.kh
គេហទំព័រ: www.police.gov.kh

APLE

unicef for every child

End Violence Against Children